ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

# ផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា

# Agricultural Extension Strategic Action Plan and Implemenation Guidelines for Policy on Agricultural Extension in Cambodia

**រៀបចំដោយ៖** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ផ្តល់មូលនិធិដោយ៖** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)

ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៨

IFAD
Investing in rural people

# អក្សរកាត់

| | | |
|---|---|---|
| AEA | : | ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម |
| AEAC | : | គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ |
| AES | : | អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម |
| AIH | : | មជ្ឈមណ្ឌលព័ត៌មានកសិកម្ម |
| AERSC | : | អនុគណៈកម្មាធិការនិយ័តកម្មការផ្សព្វផ្សាយកសិកម្ម |
| ASPIRE | : | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| CAC | : | គណៈកម្មាធិការកសិកម្មឃុំ |
| CARDI | : | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា |
| CEW | : | ភ្នាក់ងារផ្សព្វផ្សាយឃុំ |
| DAE | : | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| DATST | : | ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក |
| GDA | : | អគ្គនាយកដ្ឋានកសិកម្ម |
| HRD | : | ការអភិវឌ្ឍធនធានមនុស្ស |
| ICT | : | ព័ត៌មានវិទ្យា |
| MAFF | : | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| PAEC | : | គោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា |
| PNCA | : | សាលាជាតិកសិកម្មព្រែកលៀប |
| TWGAW | : | ក្រុមការងារបច្ចេកទេសទទួលបន្ទុកកសិកម្ម និងទឹក |
| KNSA | : | សាលាជាតិកសិកម្មកំពង់ចាម |
| NATSC | : | អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម |
| NGO | : | អង្គការមិនមែនរដ្ឋាភិបាល |
| PAEWG | : | ក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត |
| PDAFF | : | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត |
| RGC | : | រាជរដ្ឋាភិបាលកម្ពុជា |
| RUA | : | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| VEW | : | ភ្នាក់ងារផ្សព្វផ្សាយភូមិ |

# មាតិកា

Contents

**មាតិកា** ... III
**អារម្ភកថា** ... 1
**សេចក្តីថ្លែងអំណរគុណ** ... 9
**របាយការណ៍សង្ខេប** ... 11
**ផ្នែកទី ១៖ ផែនការសកម្មភាពជាយុទ្ធសាស្រ្តសម្រាប់ការផ្សព្វផ្សាយកសិកម្ម** ... 24
គោលនយោបាយផ្សព្វផ្សាយកសិកម្ម៖ ចក្ខុវិស័យ បេសកម្ម និងគោលដៅ ... 26
គោលបំណង ... 26
ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ (SWOT) របស់ការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា ... 27
ក្របខ័ណ្ឌការងារផែនការសកម្មភាពយុទ្ធសាស្រ្តផ្សព្វផ្សាយកសិកម្ម ... 33
ផែនការសកម្មភាពយុទ្ធសាស្រ្តសម្រាប់ការអនុវត្ត PAEC ... 36
១. ការរៀបចំស្ថាប័ន និងក្របខ័ណ្ឌការងារផ្នែកច្បាប់ ... 39
២. ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម ... 45
៣. ការតភ្ជាប់ការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា ... 54
៤. ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម ... 57
៥. ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ... 62
ការផ្តល់ហិរញ្ញវត្ថុដល់សេវាផ្សព្វផ្សាយកសិកម្ម ... 68
ការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ ... 69
សន្និដ្ឋាន ... 74
ឯកសារពិគ្រោះ ... 75
**ផ្នែកទី ២. គោលការណ៍ណែនាំសម្រាប់ ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា** ... 76
សេចក្តីផ្តើម និងសារតា ... 76
ការរៀបចំការងារផ្នែកស្ថាប័ន ក្របខ័ណ្ឌការងារផ្នែកច្បាប់ ... 77

គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ ........ 79
អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC) ........ 82
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) ........ 86
ក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត ........ 86
ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក ........ 89
មជ្ឈមណ្ឌលកសិកម្មឃុំ ........ 90
ការជ្រើសរើស និងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ........ 92
តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ........ 93
ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម ........ 95
តម្រូវការបណ្តុះបណ្តាលបុគ្គលិក ........ 97
វិធីសាស្ត្រក្នុងការបណ្តុះបណ្តាល ........ 98
នីតិវិធីសម្រាប់ការដាក់ពាក្យសុំ និងការជ្រើសរើស ........ 99
វិទ្យាស្ថានបណ្តុះបណ្តាល (សាកលវិទ្យាល័យ/មហាវិទ្យាល័យ/មជ្ឈមណ្ឌលបណ្តុះបណ្តាល) ........ 100
ប្រព័ន្ធការវាយតម្លៃ និងដាក់ពិន្ទុ ........ 101
ផ្នែកការហាត់ការ និងអនុវត្តន៍ជាក់ស្តែង ........ 102
ការវាយតម្លៃពីភាគីពាក់ព័ន្ធ ........ 102
ម៉ូឌុលបណ្តុះបណ្តាល ........ 102
ផែនការការអភិវឌ្ឍសមត្ថភាពសម្រាប់នាយកដ្ឋាន/ភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ 104
ការតភ្ជាប់ការស្រាវជ្រាវ ការអប់រំ និងការផ្សព្វផ្សាយពីកសិកម្ម សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា ........ 106
ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម ........ 108
ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ........ 113
យុទ្ធសាស្ត្រដើម្បីពង្រឹងការផ្សព្វផ្សាយកសិកម្ម ........ 116
ការផ្តល់ហិរញ្ញវត្ថុសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម ........ 116
ការតាមដាន វាយតម្លៃ និងការរៀនសូត្រ ........ 117
ឯកសារពិគ្រោះ ........ 124
ឧបសម្ព័ន្ធ ក៖ រចនាសម្ព័ន្ធស្ថាប័ននៃអង្គភាពផ្សេងៗរបស់សេវាផ្សព្វផ្សាយកសិកម្ម ........ 127
ឧបសម្ព័ន្ធ ខ៖ ការពិពណ៌នាវគ្គសិក្សាសម្រាប់ការបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្ម (ដែលត្រូវបានស្នើឡើង)131
ម៉ូឌុលទី ១៖ មូលដ្ឋានគ្រឹះនៃការអប់រំកសិកម្ម ........ 132

ម៉ូឌុល ១.១៖ ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ........ 132
ម៉ូឌុល ១.២៖ វិធីសាស្ត្រ និងបច្ចេកទេសដែលមានការចូលរួម ........ 134
ម៉ូឌុល ១.៣៖ ផលិតកម្មដំណាំនៅតាមវាល ........ 136
ម៉ូឌុល ១.៤៖ ផលិតកម្មដំណាំសាកវប្បកម្ម ........ 138
ម៉ូឌុល ១.៥៖ វារីវប្បកម្ម ........ 141
ម៉ូឌុល ១.៦៖ ផលិតកម្មសត្វ ........ 143
ម៉ូឌុល ១.៧៖ ផលិតកម្មដំណាំចម្ការ ........ 145
ម៉ូឌុល ១.៨៖ ព្រៃឈើ ........ 147
ម៉ូឌុល ១.៩៖ សុខភាពសត្វ ........ 148
ម៉ូឌុលទី ២៖ ម៉ូឌុលកម្រិតខ្ពស់ស្តីពីការផ្សព្វផ្សាយកសិកម្ម ........ 150
ម៉ូឌុល ២.១៖ សង្គមវិទ្យាជនបទ ........ 150
ម៉ូឌុល២.២៖ ការប្រាស្រ័យទាក់ទងផ្នែកកសិកម្ម ........ 152
ម៉ូឌុល ២.៣៖ ការកៀងគរផ្នែកសង្គម ........ 154
ម៉ូឌុល ២.៤៖ ការអភិវឌ្ឍសហគមន៍ ........ 156
ម៉ូឌុល ២.៦៖ ការងារជាក្រុម និង ការអភិវឌ្ឍជាក្រុម ........ 159
ម៉ូឌុល ២.៧៖ យេនឌ័រ និង ការអភិវឌ្ឍ ........ 161
ម៉ូឌុល ២.៨៖ ធ្វើការជាមួយសហគមន៍ជនបទ ........ 162
ម៉ូឌុល ២.៩៖ ការធ្វើទីផ្សារកសិកម្ម និងសហគមន៍ ........ 163
ម៉ូឌុលទី ៣៖ ការគ្រប់គ្រង ផ្តោតលើវគ្គបណ្តុះបណ្តាលសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម ........ 165
ម៉ូឌុល៣.១៖ ការអភិវឌ្ឍកម្មវិធីផ្សព្វផ្សាយកសិកម្ម ........ 165
ម៉ូឌុល ៣.២៖ ការអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្ម ........ 167
ម៉ូឌុល ៣.៣៖ ការតាមដាន និងវាយតម្លៃកម្មវិធី ........ 169
ម៉ូឌុល ៣.៤៖ការគ្រប់គ្រងភាពជាអ្នកដឹកនាំ ........ 171
ម៉ូឌុល ៣.៥៖ វិធីសាស្ត្រស្រាវជ្រាវ ........ 173
ម៉ូឌុល ៣.៦៖ ការគ្រប់គ្រងកសិធុរកិច្ចកសិកម្ម ........ 175
ម៉ូឌុល ៣.៧៖ ទីផ្សារ និងការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់ ........ 178
ម៉ូឌុលទី ៤៖ ម៉ូឌុលស្តីពី បច្ចេកទេសកសិកម្ម ........ 181
ម៉ូឌុល ៤.១៖ ផលិតកម្មដំណាំស្រូវ ........ 181

ម៉ូឌុល ៤.២ ៖ ផលិតកម្មគ្រាប់ពូជ ....183
ម៉ូឌុល ៤.៣ ៖ វិធានការចម្រុះការពារដំណាំ ....185
ម៉ូឌុល ៤.៤៖ ផលិតកម្មការចិញ្ចឹមជ្រូក ....188
ម៉ូឌុល ៤.៥៖ ផលិតកម្មទឹកដោះ និងសាច់គោ ....190
ម៉ូឌុល ៤.៦៖ ផលិតកម្មបក្សី ....193
ម៉ូឌុល ៤.៧៖ កសិ-រុក្ខកម្ម ....195
ឧបសម្ព័ន្ធ គ-១៖ ការពិនិត្យតាមដានសេវាផ្សព្វផ្សាយកសិកម្ម (គំរូសូចនាករ).... 197
ឧបសម្ព័ន្ធ គ-២៖ ការពិនិត្យតាមដានសេវាផ្សព្វផ្សាយកសិកម្ម .... 206
ឧបសម្ព័ន្ធ ឃ៖ ការសិក្សាទិន្នន័យដើមគ្រា និងការស្ទាបស្ទង់មតិវាយតម្លៃសេចក្តីត្រូវការ .... 224
ឧបសម្ព័ន្ធ ង៖ គំរូឧបករណ៍វាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិដ្ឋាន.... 245
ឧបសម្ព័ន្ធ ច-១៖ ការស្ទង់មតិព័ត៌មានដើមគ្រាអំពីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម .... 273
ឧបសម្ព័ន្ធ ច-២៖ សន្និធិអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម .... 275

## បញ្ជីរាយនាមតារាង

តារាងទី១.សេចក្តីសង្ខេបលើអនុសាសន៍នៃផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម...14
តារាងទី២. ថវិកាប៉ាន់ប្រមាណសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា.....23
តារាងទី៣. សង្ខេបអំពីគំហើញ SWOT....30
តារាងទី៤៖ ខ្លឹមសារសង្ខេបនៃការរៀបចំផ្នែកស្ថាប័នសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធនានាក្នុងការអនុវត្ត PAEC....40
តារាងទី ៥៖ ថវិកាសម្រាប់អនុវត្តសមាសធាតុផ្នែកការរៀបចំស្ថាប័ន និងក្របខ័ណ្ឌការងារស្ថាប័ន....45
តារាងទី ៦៖ ផែនការរយៈពេលប្រាំឆ្នាំសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ចំនួនមនុស្ស)...52
តារាងទី ៧៖ ផែនការថវិកាសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ដុល្លារអាមេរិក)....53
តារាងទី ៨៖ ថវិកាប៉ាន់ប្រមាណសម្រាប់ការតភ្ជាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្មសម្រាប់អភិវឌ្ឍបច្ចេកវិទ្យា (ដុល្លារអាមេរិក)....57
តារាងទី ៩. ថវិកាប៉ាន់ប្រមាណសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម (ដុល្លារអាមេរិក)....61
តារាងទី ១០. ថវិកាប៉ាន់ប្រមាណសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម (ដុល្លារអាមេរិក)....67
តារាងទី ១១. ការចំណាយសម្រាប់ការអនុវត្ត PAEC សម្រាប់រយៈពេល ៥ ឆ្នាំ....68

តារាងទី ១២. សង្ខេបអនុសាសន៍សម្រាប់ផែនការសកម្មភាពយុទ្ធសាស្រ្ត……………………………………..71
តារាងទី ១៣. ការរៀបចំផ្នែកស្ថាប័នសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងការអនុវត្ត PAEC……………81
តារាងទី ១៤. ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលត្រូវការសម្រាប់ប្រទេសកម្ពុជា…………………………………..97
តារាងទី ១៥. ប្រព័ន្ធដាក់ពិន្ទុសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម…………………………..101
តារាងទី ១៦. ម៉ូឌុលបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម……………………………………..103
តារាងទី ១៧. ការបណ្តុះបណ្តាលពេលកំពុងបំពេញការងារសម្រាប់នាយកដ្ឋាន/ទីភ្នាក់ងារនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ……………………………………………………………………………105
តារាងទី ១៨.ឧទាហរណ៍អំពីសូចនាករតាមដានសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម………………………………118
តារាងទី ១៩.បញ្ជីសូចនាករវាយតម្លៃផលប៉ះពាល់ដែលត្រូវបានស្នើឡើង……………………………………..120

## បញ្ជីរាយនាមរូបភាព

រូបភាពទី ១៖ រចនាសម្ព័ន្ធការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា. ........................................................ 33
រូបភាពទី ២៖ ក្របខ័ណ្ឌការងារយុទ្ធសាស្រ្តដើម្បីពង្រឹងការផ្សព្វផ្សាយកសិកម្ម ........................................... 34
រូបភាពទី ៣៖ ក្របខ័ណ្ឌការងារផែនការសកម្មភាពយុទ្ធសាស្រ្តសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម. ................. 38
រូបភាពទី ៤៖ ប្រភេទ និងកម្រិតភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា......................................... 47
រូបភាពទី ៥៖ គោលវិធីបែបម៉ូឌុលក្នុងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម................................ 49
រូបភាពទី ៦. ក្រាហ្វិកលំហូរការងារសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម...................................... 62
រូបភាពទី ៧. រចនាសម្ព័ន្ធរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (ដែលត្រូវបានស្នើឡើង). ............................ 88
រូបភាពទី ៨. ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដើរតួនាទីជាស្ពានភ្ជាប់រវាងសហគមន៍ជាមួយការស្រាវជ្រាវផ្នែកកសិកម្ម អង្គការបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្ម. ........................................................................................ 130
រូបភាពទី ៩. ក្រាហ្វិកលំហូរការងារសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម។ (កែសម្រួលចេញពី ទីប្រឹក្សាផ្នែកគ្រប់គ្រងចំណេះដឹង និង ព័ត៌មានវិទ្យា n.d.) ................................................................................ 132
រូបភាពទី ១០. រចនាសម្ព័ន្ធការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយកសិកម្ម. ................................ 138

# អារម្ភកថា

កសិកម្ម គឺជាវិស័យឈានមុខគេមួយសម្រាប់កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ ការអភិវឌ្ឍកសិកម្ម គឺមានសារៈសំខាន់ណាស់សម្រាប់សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ។ ដូច្នោះហើយរាជរដ្ឋាភិបាលកម្ពុជា (RGC) មានផែនការបន្តការវិនិយោគដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករខ្នាតតូចក៏ដូចជាកសិករខ្នាតធំផងដែរ។ ប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយ គឺមានដែនកំណត់ ដោយខ្វះនូវក្រមខ័ណ្ឌស្ថាប័ន និងនីតិបញ្ញត្តិសម្រាប់គាំទ្រ និងការសម្របសម្រួលនៃប្រតិបត្តិការសេវាផ្សព្វផ្សាយ ធនធានមនុស្សមានកំណត់ ការតភ្ជាប់រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអប់រំ កសិករ និងទីផ្សារនៅមានកម្រិត ហើយ សេវាផ្សព្វផ្សាយដាច់ដោយឡែកពីគ្នា ឬមានការសហការគ្នាមិនបានល្អនៅក្នុងចំណោម វិស័យសាធារណៈ និងវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជានាឆ្នាំ២០១៥ គឺគាំទ្រការផ្តល់សេវាកម្មតាមបែបពហុភាគីនិយម (Pluralism) ដូចជាការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងការផ្តល់សេវាផ្សព្វផ្សាយដល់កសិករ យន្តការទាំងនេះ ជាការគាំទ្រ សម្របសម្រួល និងផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្រប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការអ្នកផលិត និងតម្រូវការទីផ្សារ។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) បានរៀបចំ " **ឯកសារ ផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**" នេះឡើង ដោយបានរៀបចំ ការប្រជុំជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម គណៈកម្មាធិការពិគ្រោះយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម (AEAC) អនុគណៈកម្មាធិការបច្ចេកទេស (NATSC) អនុក្រុមការងារផ្សព្វផ្សាយកសិកម្ម និងទឹក និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម អ្នកឯកទេស និងអ្នកពាក់ព័ន្ធមកពីស្ថាប័ន និងអង្គភាពផ្សព្វផ្សាយកសិកម្ម អង្គភាពជំនាញបច្ចេកទេសនានា មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង ២៥រាជធានី ខេត្ត/ក្រុង វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមដាក់ចេញនូវ " **ឯកសារ ផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**" ដែលជាឯកសារគ្រឹះសម្រាប់មន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកទេសកសិកម្មថ្មីៗ វិធីសាស្ត្រ ការផ្លាស់ប្តូរនូវបទពិសោធន៍ ការចែករំលែកចំណេះដឹង និងនាំមកនូវកំណើនផលិតកម្មកសិកម្ម ជម្រុញឲ្យមានស្ថិរភាពសេដ្ឋកិច្ចគ្រួសារកសិករ សម្រួលដល់កសិករក្នុងការ

សម្របខ្លួនតាមស្ថានភាពវិវត្តនៃសាកលភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម បន្សាំនិងការប្រែប្រួលអាកាសធាតុ រួមចំណែកក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្មនៅលើទីផ្សារប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ទី ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី...............ខែ.............ឆ្នាំ២០១៨

**អគ្គនាយកដ្ឋានកសិកម្ម**

# សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធានាសន្តិសុខស្បៀង និងអាហាររូបត្ថម្ភរបស់ប្រជាជនកម្ពុជា។ ការផ្សព្វផ្សាយកសិកម្ម គឺជាមុខងារចំបងមួយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)ដែលមានគោលដៅកាត់បន្ថយភាពក្រីក្រ និងបង្កើនផលិតភាពកសិកម្មតាមរយៈការធ្វើទំនើបកម្ម និងពាណិជ្ជូបនីយកម្មវិស័យកសិកម្មក្នុងប្រទេសកម្ពុជា។ ដើម្បីឈានទៅសម្រេចគោលដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសឱ្យប្រើប្រាស់នូវគោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា (PAEC)ក្នុងឆ្នាំ២០១៥។គោលនយោបាយនេះចែងអំពីយុទ្ធសាស្ត្រនិងផែនការសកម្មភាពដើម្បីពង្រឹងសេវាផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា។

គោលនយោបាយផ្សព្វផ្សាយកសិកម្មថ្មីនេះ តស៊ូមតិឱ្យមានការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈវិមជ្ឈការនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដោយផ្តល់សេវាផ្សព្វផ្សាយកសិកម្មផ្អែកលើភាពចាំបាច់ និងសេចក្តីត្រូវការក្នុងមូលដ្ឋាន និងការចូលរួមពីភាគីពាក់ព័ន្ធនានានៅក្នុងការធ្វើផែនការ និងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ គោលនយោបាយថ្មីនេះ ដាក់ឱ្យមានយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាច្រើន ប៉ុន្តែមិនមានគោលការណ៍ណែនាំជាក់លាក់លម្អិតនោះទេ។ ដៃគូអភិវឌ្ឍនិងអ្នកអនុវត្តន៍ទាំងអស់ត្រូវការគោលការណ៍ណែនាំជាក់លាក់អំពីថាតើគណៈកម្មាធិការធ្វើការសម្រេចចិត្តបែបការចូលរួមនានាត្រូវបំពេញមុខងារយ៉ាងណា និងធ្វើយ៉ាងណាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួលកិច្ចសហការនិងភាពជាដៃគូរវាងអ្នកផ្តល់សេវានានា។ ឯកសាររបស់យើងនាពេលនេះគឺជាកិច្ចឆ្លើយតបជាមួយសេចក្តីត្រូវការនេះ។

ឯកសារនេះត្រូវបានផលិតឡើងដោយមានការគាំទ្រយ៉ាងខ្លាំងក្លា ពីអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE)។ លោកបណ្ឌិត ម៉ាក់ សឿន ដែលជាប្រធានកម្មវិធីស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម និងលោកបណ្ឌិត ម៉ៅ មិនា ដែលជាប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានផ្តល់ធាតុចូលនិងមតិយោបល់ស្តីពីយុទ្ធសាស្ត្រផែនការសកម្មភាព ជាក់លាក់ និង បានចង្អុលបង្ហាញផ្លូវស្តីពីការអនុវត្តគោលនយោបាយនេះ។ ផែនការសកម្មភាព និងគោលការណ៍ណែនាំការអនុវត្តនេះត្រូវបានចែកជូនទៅដល់សមាជិកគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មជាតិ (NATSC) ក្រុមការងារបច្ចេកទេសទទួលបន្ទុកកសិកម្ម និងទឹក (TWGAW) និងសមាជិករបស់ក្រុមការងារជំនួយផ្នែកការបណ្តុះបណ្តាលនិងបច្ចេកទេសរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ សមាជិកគណៈកម្មាធិការនិងក្រុមការងារនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានផ្តល់មតិនិងយោបល់គ្រលប់លើសេចក្តីព្រាងផែនការសកម្មភាពជាយុទ្ធសាស្ត្រនិងគោលការណ៍ណែនាំការអនុវត្ត PAEC ហើយធាតុចូលទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារនេះ។

សូមថ្លែងអំណរគុណជាពិសេសចំពោះលោកបណ្ឌិត Norman Welsh ជាទីប្រឹក្សាកម្មវិធី ASPIRE ដែលបានចែករំលែកគំហើញពីការវិភាគ SWOT លើបញ្ហាការអភិវឌ្ឍធនធានមនុស្ស និងយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សសម្រាប់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ ក្រុមការងារកម្មវិធី ASPIRE ដែលរួមមាន លោកស្រី យឹម សំណាង លោក ចាយ គង់គ្រុយ លោកស្រី សាង ស៊ីឡេង លោក ខៀន សុវណ្ណារា លោក ហេង ប៊ុន្នី និង លោក

សាយ  តុម  បានជួយផ្តល់ឯកសារដែលមានបច្ចុប្បន្នទាក់ទងជាមួយព័ត៌មាននៅក្នុងឯកសារនេះយ៉ាងទាន់ពេលវេលា។

ខ្ញុំសូមថ្លែងអំណរគុណចំពោះមតិ និងយោបល់គ្រឡប់ទាំងអស់ដែលបានមកពីបុគ្គលនិងគណៈកម្មាធិការដូចបានរាយនាមខាងលើ។ រាល់កំហុស និងភាពខ្វះចន្លោះទាំងឡាយដែលអាចមាននៅក្នុងឯកសារនេះ គឺជាកំហុស និងភាពខ្វះចន្លោះរបស់រូបខ្ញុំផ្ទាល់។

សាស្ត្រាចារ្យ Murari Suvedi
ទីប្រឹក្សាកម្មវិធី ASPIRE

# របាយការណ៍សង្ខេប

កសិកម្ម គឺជាវិស័យឈានមុខគេមួយសម្រាប់កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ ការអភិវឌ្ឍកសិកម្ម គឺមានសារៈសំខាន់ណាស់សម្រាប់សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ។ ដូច្នោះហើយរាជរដ្ឋាភិបាលកម្ពុជា (RGC) មានផែនការបន្តការវិនិយោគដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករខ្នាតតូចក៏ដូចជាកសិករខ្នាតធំផងដែរ។ ប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយ គឺមានដែនកំណត់ ដោយខ្វះនូវក្រមខ័ណ្ឌស្ថាប័ន និងនីតិបញ្ញត្តិសម្រាប់គាំទ្រ និងការសម្របសម្រួលនៃប្រតិបត្តិការសេវាផ្សព្វផ្សាយ ធនធានមនុស្សមានកំណត់ការតភ្ជាប់រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអប់រំ កសិករ និងទីផ្សារនៅមានកម្រិត ហើយសេវាផ្សព្វផ្សាយដាច់ដោយឡែកពីគ្នា ឬមានការសហការគ្នាមិនបានល្អនៅក្នុងចំណោម វិស័យសាធារណៈ និងវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ។ ស្ថានភាពនេះតម្រូវឱ្យមានគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាហើយនៅឆ្នាំ ២០១៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (MAFF) បានបង្កើតនិងផ្សព្វផ្សាយគោលនយោបាយនេះ។

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា (PAEC) បានបើកផ្លូវឱ្យកាន់តែមានប្រសើរ និងការផ្តល់សេវាផ្សព្វផ្សាយកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ដោយចាប់យកការផ្សព្វផ្សាយកសិកម្មតាមតម្រូវការអ្នកប្រើប្រាស់ ដោយមានការចូលរួម និងដោយការផ្តល់សេវាផ្សព្វផ្សាយតាមបែបពហុនិយម ហើយមានការសម្របសម្រួល ហើយបទបញ្ញត្តិកាន់តែប្រសើរឡើងនៃសេវាកម្មដែលផ្តល់ដោយអ្នកផ្តល់សេវាកម្មផ្សេងៗ។

របាយការណ៍នេះមានពីរផ្នែក គឺផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។

ឯកសារនេះរៀបរាប់ពីវិធីដោះស្រាយបញ្ហាដែលប្រឈមនឹងសេវាផ្សព្វផ្សាយនាពេលបច្ចុប្បន្ន។ **ទីមួយ** វាស្របតាមចក្ខុវិស័យនៃផែនការមេរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទឆ្នាំ២០៣០។ **ទីពីរ** វាត្រូវបានបង្កើតឡើងដើម្បីបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃគោលនយោបាយផ្សព្វផ្សាយកសិកម្ម។

ផែនការសកម្មភាពនេះរៀបរាប់ពីយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហាប្រឈមមុខនានា។ ការផ្សព្វផ្សាយកសិកម្មមានមុខងារចំនួនប្រាំ ឬផ្នែកសំខាន់ៗនៃសេវាផ្សព្វផ្សាយដូចជា ក្របខ័ណ្ឌ ស្ថាប័ននិងនីតិបញ្ញត្តិ ការអភិវឌ្ឍធនធានមនុស្ស ការតភ្ជាប់ការស្រាវជ្រាវផ្សព្វផ្សាយនិងការអប់រំ សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយនិងការផ្តល់សេវាផ្សព្វផ្សាយ។ វាមានបង្ហាញពីគោលដៅ គោលបំណង លទ្ធផលចុងក្រោយ យុទ្ធសាស្ត្រសកម្មភាពជាក់លាក់ និងថវិកាសម្រាប់សមាសភាគសំខាន់ៗនីមួយៗ។

ផ្នែកទីមួយនៃរបាយការណ៍បង្ហាញពីផែនការសកម្មភាពជាយុទ្ធសាស្ត្រ ដោយតម្រឹមគោលដៅនៃការផ្សព្វផ្សាយកសិកម្មទៅនឹងផែនការមេរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០៣០ ។ ការវិភាគពីចំណុចខ្លាំង ភាពទន់ខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) នៃប្រព័ន្ធផ្សព្វផ្សាយត្រូវបានធ្វើឡើងតាម

រយៈការពិនិត្យឡើងវិញនូវរបាយការណ៍ផ្ទៃក្នុង ករណីសិក្សានានា ការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយបុគ្គលិកផ្នែកផ្សព្វផ្សាយ។

**នៅផ្នែកនៃចំណុចខ្លាំង** គឺក្រសួងកសិកម្មបានអនុម័តគោលនយោបាយផ្សព្វផ្សាយកសិកម្មដែលបច្ចុប្បន្នកំពុងត្រូវបានអនុវត្តន៍មានកម្លាំងពលកម្ម ដែលមានស្រាប់មានការគាំទ្រថវិកាហើយមានសម្ភារៈបណ្តុះបណ្តាលមួយចំនួនអាចរកបាន។ ទំនាក់ទំនងរវាងអគ្គនាយកដ្ឋានកសិកម្ម (GDA) នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) និងអ្នកបង្កើតបច្ចេកវិទ្យាថ្មី ជាអាទិ៍ភ្នាក់ងារស្រាវជ្រាវ ដូចជាវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) គឺជាកម្លាំងមួយ ប៉ុន្តែ កង្វះខាតនៃយន្តការសម្រាប់បម្លែងលទ្ធផលស្រាវជ្រាវទៅជាសារសម្រាប់កសិករ គឺជាចំណុចខ្សោយមួយ។ ចំណុចខ្លាំងផ្សេងទៀត រួមមានព័ត៌មានវិទ្យា (ICTs) និងការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នៅក្នុងខេត្តជាច្រើន។ រដ្ឋាភិបាល ឬប្រព័ន្ធ ផ្សព្វផ្សាយសាធារណៈបានគ្របដណ្តប់ទូទាំងថ្នាក់ស្រុក។ នៅតាមបណ្តាខេត្តមួយចំនួនមានវត្តមានភ្នាក់ងារផ្សព្វផ្សាយឃុំ (CEWs) និងភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWs) នៅតាមស្រុកមួយចំនួនបាននាំកសិករឱ្យខិតទៅជិតទៅរកការផ្សព្វផ្សាយ។

**ទាក់ទងនឹងភាពទន់ខ្សោយ** គឺមានការថយចុះបន្តិចបន្តួចនៃចំនួនបុគ្គលិកផ្សព្វផ្សាយសាធារណៈសមាមាត្រនៃបុគ្គលិកផ្សព្វផ្សាយធៀបកសិករ គឺខ្ពស់ អ្នកធ្វើការងារផ្សព្វផ្សាយមិនមានវត្តមាននៅក្នុងបណ្តាស្រុកជាច្រើន បុគ្គលិកធ្វើការងារផ្សព្វផ្សាយត្រូវបានបណ្តុះបណ្តាលតិចតួច ហើយពួកគេខ្វះចំណេះដឹងបច្ចេកទេស ជាមូលដ្ឋាន និងជំនាញលើដំណើរការនៃការផ្សព្វផ្សាយ។ ថវិកាមិនគ្រប់គ្រាន់ ការគាំទ្រស្ថាប័ននៅទន់ខ្សោយ និងលក្ខខណ្ឌការងារមិនល្អសម្រាប់បុគ្គលិកកម្រិតថ្នាក់ដែលធ្វើការនៅទីវាលត្រូវបានគេលើកឡើងជាញឹកញាប់នូវឧបសគ្គរារាំងដែលប្រឈមនឹងសេវាផ្សព្វផ្សាយ។

**នៅផ្នែកឱកាស** សេវាផ្សព្វផ្សាយអាចងាយស្រួលដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងនីតិវិធីថ្មីរបស់សមាគមន៍នៃបណ្តាប្រទេសជាសមាជិកនៅអាស៊ីអាគ្នេយ៍ដើម្បីបង្កើនការផ្តល់ជូនរបស់ខ្លួន។ ប្រទេសកម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិជ្ជា និងនវានុវត្តន៍ថ្មីៗក្នុងវិស័យកសិកម្ម ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពអ្នកជំនាញការតាមរយៈភាពជាដៃគូរវាងរដ្ឋាភិបាលទ្វេភាគី និងដៃគូអភិវឌ្ឍន៍។ នៅលើឆាកជាតិ ការផ្សព្វផ្សាយអាចទាញយកប្រយោជន៍ពីវត្តមាននៃការផ្សព្វផ្សាយវិស័យឯកជនរួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការកសិករសម្រាប់ការផ្តល់សេវាកាន់តែមានប្រសិទ្ធភាពដល់កសិករ។ ការផ្សព្វផ្សាយ វិស័យ ឯកជនមានសមត្ថភាពក្នុងការបត់បែន និងកំណត់គោលដៅសេវាកម្មរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយគុណវុឌ្ឍិរបស់បុគ្គលិកផ្នែកផ្សព្វផ្សាយវិស័យឯកជន មានកម្រិតទាបជាងភ្នាក់ងារផ្សព្វផ្សាយរបស់រដ្ឋាភិបាល។ ចំណុចខ្សោយសំខាន់ គឺនិរន្តរភាព ដែលអង្គការមិនមែនរដ្ឋាភិបាលមានភាពឃើតយ៉ាវជាអាទិ៍ គម្រោងដែលឧបត្ថម្ភដោយម្ចាស់ជំនួយអាចនឹងត្រូវអនុវត្តក្នុងរយៈពេលកំណត់ ហើយបុគ្គលិកផ្សព្វផ្សាយអាចផ្លាស់ទីលំនៅបន្ទាប់ពីការបញ្ចប់គម្រោង។

ផែនការសកម្មភាពកំណត់នូវសមាសភាគសំខាន់ៗចំនួនប្រាំយ៉ាង អភិក្រមនៃការផ្សព្វផ្សាយកសិកម្មតាមតម្រូវការអ្នកប្រើប្រាស់ ដោយមានការចូលរួម និងការផ្សព្វផ្សាយតាមបែបពហុនិយម ហើយនិងពិពណ៌នាអំពី

គោលដៅ គោលបំណង លទ្ធផលចុងក្រោយ និងផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយកសិកម្ម។

**សមាសភាគទីមួយស្តីពី** ការរៀបចំស្ថាប័ន និងក្របខ័ណ្ឌច្បាប់ដែលពិពណ៌នាពីយន្តការសម្រាប់វិមជ្ឈការតម្រូវការទីផ្សារឈរលើតម្រូវការមូលដ្ឋាន និងការផ្តល់សេវាផ្សព្វផ្សាយបែបពហុនិយម។ ក្រោមគោលនយោបាយថ្មី ការរៀបចំផែនការ និងការអនុវត្តកម្មវិធីផ្សព្វផ្សាយជាក់លាក់ និងសកម្មភាពនានានឹងជាការទទួលខុសត្រូវរបស់ការិយាល័យថ្នាក់ខេត្ត និងស្រុកដែលមានធាតុចូលពីគណៈកម្មាធិការភាគីពាក់ព័ន្ធ។

**សមាសភាគទីពីរ** ពិពណ៌នាអំពីសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយ។ វាបង្ហាញពីយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍបុគ្គលិកផ្សព្វផ្សាយកសិកម្មដែលបានបណ្តុះបណ្តាលយ៉ាងល្អដើម្បីបំពេញតម្រូវការរបស់កសិករ និងអ្នកពាក់ព័ន្ធវិស័យកសិកម្មនៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ។

**សមាសភាគទីបី** ផ្តោតលើការបង្កើនទំនាក់ទំនងតភ្ជាប់រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការអប់រំដើម្បីអភិវឌ្ឍន៍និងផ្សព្វផ្សាយព័ត៌មាននិងបច្ចេកវិទ្យាដែលផ្អែកលើការស្រាវជ្រាវដើម្បីលើកកំពស់ផលិតកម្មកសិកម្ម និងការអភិរក្សធនធានធម្មជាតិ។ការភ្ជាប់ទំនាក់ទំនងនេះនឹងត្រូវបានពង្រឹងតាមរយៈការដឹកនាំពីគណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) លើការសម្របសម្រួលនៃនាយកដ្ឋានជំនាញនានានៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍និងវិស័យឯកជន។

**សមាសភាគទីបួន** គឺការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនឹងសម្របសម្រួលការអភិវឌ្ឍព័ត៌មានដែលមានលក្ខណៈទាក់ទាញ ងាយស្រួលប្រើ ឈរលើលទ្ធផលពីការស្រាវជ្រាវ និងឯកសារសម្រាប់ការបណ្តុះបណ្តាល។ វានឹងបង្កើតមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម (Extension Hub) និងគេហទំព័រផ្សព្វផ្សាយកសិកម្ម (Extension Web Portal) ដែលចែកចាយព័ត៌មានគួរឱ្យជឿជាក់។

**សមាសភាគទីប្រាំ** ពិពណ៌នាអំពីអភិក្រមបែបវិមជ្ឈការ និងបែបពហុនិយមចំពោះការផ្តល់សេសេវាផ្សព្វផ្សាយដល់កសិករ និងភាគីពាក់ព័ន្ធដើម្បីបង្កើនផលិតភាពកសិកម្ម ការធ្វើពិពិធភាពកម្ម និងការធ្វើពាណិជ្ជូបនីយកម្មកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ សេវាផ្សព្វផ្សាយ និងសកម្មភាពនានានឹងត្រូវបានចុះកិច្ចសន្យាជារបៀបកិច្ចសន្យាជួលអ្នកក្រៅទៅអ្នកផ្តល់សេវានៅក្នុងស្រុក ឬតំបន់ ដូចជាភ្នាក់ងារផ្សព្វផ្សាយឃុំ (CEWs) និងភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWS) អង្គការមិនមែន រដ្ឋាភិបាល និងអង្គការកសិករ។ វិធីសាស្ត្រផ្សព្វផ្សាយនឹងរួមបញ្ចូលទាំងការផ្តល់ដំបូន្មានផ្ទាល់ខ្លួន និងការប្រឹក្សាយោបល់ តាមរយៈការទស្សនកិច្ចតាមកសិដ្ឋាន និងតាមផ្ទះ ការបង្ហាញវិធីសាស្ត្រ និងលទ្ធផលកិច្ចប្រជុំក្រុម និងដំណើរទស្សនកិច្ចសិក្សា សាលារៀនស្រែកសិករ សកម្មភាពជាក្រុម ដូចជាការធ្វើទីផ្សារតាមរយៈសហការ និងការប្រើប្រាស់សម្ភារៈប្រព័ន្ធព័ត៌មានវិទ្យា (ICT) ។ កម្មវិធី និងសកម្មភាពផ្សព្វផ្សាយនឹងបញ្ជាក់ពីការប្រើប្រាស់ការសិក្សារៀនសូត្រពីកសិករទៅកសិករ។

**តារាងទី១.សេចក្តីសង្ខេបលើអនុសាសន៍នៃផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម**

| យុទ្ធសាស្ត្រ | សកម្មភាពនានាដែលបានផ្តល់អនុសាសន៍ |
|---|---|
| **យុទ្ធសាស្ត្រទី១. ក្របខ័ណ្ឌស្ថាប័ន/ច្បាប់ប្រសើរជាងមុន** | |
| ភាពជាអ្នកដឹកនាំសម្រាប់ការផ្សព្វផ្សាយ | ១.០.នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនឹងផ្តល់ការសម្របសម្រួលថ្នាក់ជាតិលើព័ត៌មាន ការបណ្តុះបណ្តាលលើវិស័យដែលប្រទាក់ក្រឡាគ្នាដូចជា ការប្រែប្រួលអាកាសធាតុ សមាហរណកម្មយេនឌ័រនៅក្នុងកម្មវិធីផ្សព្វផ្សាយ បណ្តុះបណ្តាលយុវជនលើសហគ្រិនភាព និងការអប់រំយុវជនឱ្យធ្វើកសិកម្មជាមុខរបរ។ |
| ការចូលរួមពីអ្នកពាក់ព័ន្ធ | ១.១.បង្កើត និងធានាឱ្យមានប្រសិទ្ធភាពលើមុខងាររបស់គណៈកម្មាធិការផ្សព្វផ្សាយកសិកម្មពីនាក់ពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិៈ<br>• គណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC)<br>• អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC),<br>• ក្រុមការងារផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត (PAEWG),<br>• ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST),<br>• គណៈកម្មាធិការកសិកម្មឃុំ (CAC) |
| វិមជ្ឈការសេវាផ្សព្វផ្សាយ | ១.២.ធ្វើវិមជ្ឈការប្រតិបត្តិការសេវាផ្សព្វផ្សាយ(ឧ.ទាការធ្វើផែនការតាមកម្មវិធី ការអនុវត្ត ការវាយតម្លៃ និងការធ្វើរបាយការណ៍) នៅថ្នាក់ខេត្ត និងស្រុក)។<br>១.៣.បង្កើតគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការវិមជ្ឈការនិងការគ្រប់គ្រងសេវាផ្សព្វផ្សាយនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។<br>១.៤.បង្កើតគោលការណែនាំគ្រប់គ្រងបុគ្គលិកដោយរួមបញ្ចូលការពិពណ៌នាលើការងារ គុណវុឌ្ឍអប្បបរិមា ការជ្រើសរើសបុគ្គលិកថ្មី ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍គោលនយោបាយមុខរបរនានា។<br>១.៥.បណ្តុះបណ្តាលសមាជិកគណៈកម្មាធិការអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកលើវិធីសាស្ត្រនៃការចូលរួមការឈរលើតម្រូវការនិងសេវាផ្សព្វផ្សាយតាមតម្រូវការទីផ្សារ។<br>១.៦.បង្កើតគោលការណ៍ណែនាំនិងនីតិវិធីសម្រាប់ផ្តល់មូលនិធិលើការផ្តល់ប្រព័ន្ធសេវាផ្សព្វផ្សាយតាមបែបពហុនិយមតាមរយៈភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងឯកជន (PPP)។ |
| ភាពជាដៃគូរវាងស្ថាប័នរដ្ឋ | ១.៧.សហការជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយរបស់ដៃគូអភិវឌ្ឍ |

| | |
|---|---|
| និងវិស័យឯកជន | អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជនក្នុងការផ្សព្វផ្សាយ។<br>១.៨.ទទួលយកនូវ គោលនយោបាយ និងនីតិវិធីដូចគ្នា(Uniform)សម្រាប់ផ្តល់សេវាផ្សព្វផ្សាយ។ |
| សេវាផ្សព្វផ្សាយតាមបែបពហុនិយម | ១.៩ ផ្តួចផ្តើមធ្វើកិច្ចសន្យាលើសេវាសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយជាក់លាក់ណាមួយ។<br>១ ១០.ធ្វើពាណិជ្ជកម្មនិង ឬធ្វើឯកជនភាវូបនីយកម្មលើសេវាផ្សព្វផ្សាយ / |
| ការតាមដាន និងវាយតម្លៃ | ១.១១ អនុវត្តប្រព័ន្ធនៃការតាមដាន និងវាយតម្លៃឱ្យមត់ចត់សម្រាប់ការផ្សព្វផ្សាយ។ |
| **យុទ្ធសាស្ត្រទី២. ការអភិវឌ្ឍធនធានមនុស្ស** | |
| បណ្តុះបណ្តាលអ្នកផ្សព្វផ្សាយកសិកម្ម | ២.១. ទទួលយកនូវប្រព័ន្ធបណ្តុះបណ្តាលតាមតាមវិធីសាស្ត្រជាម៉ូឌុល (មេរៀនជាកញ្ចប់ផ្តែកលើជំនាញជាក់លាក់)សម្រាប់វិជ្ជាជីវៈជាអ្នកផ្សព្វផ្សាយកសិកម្ម។<br>• ភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWs)៖ កសិករឆ្នើម ឬកសិករឈានមុខគេនៅក្នុងភូមិទទួលការបណ្តុះបណ្តាលជំនាញផ្សព្វផ្សាយពី២ទៅ៤សប្តាហ៍<br>• ភ្នាក់ងារផ្សព្វផ្សាយឃុំ(CEWs)៖ បញ្ចប់វិទ្យាល័យ និងកសិករឆ្នើម ឬកសិករឈានមុខគេទទួលការបណ្តុះបណ្តាលជំនាញផ្សព្វផ្សាយពី២ទៅ៤ខែ<br>• ទីប្រឹក្សាផ្សព្វផ្សាយ(AEAs)៖និស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យបច្ចេកទេសរយៈពេល២ឆ្នាំទទួលបានវគ្គបណ្តុះបណ្តាលជំនាញផ្សព្វផ្សាយពី៣ទៅ៦ខែ<br>• អ្នកឯកទេសផ្សព្វផ្សាយ(AESs)៖និស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យកសិកម្ម ព្រៃឈើ ឬជលផលរយៈពេល៤ឆ្នាំទទួលបានវគ្គបណ្តុះបណ្តាលជំនាញផ្សព្វផ្សាយពី៦ទៅ៩ខែ<br>• VEW/CEW អាចឈានដល់កម្រិត AES បានដោយបន្ថែមនូវការអប់រំ និងបណ្តុះបណ្តាល។ |
| គ្រឹះស្ថានបណ្តុះបណ្តាល | ២.២.ពង្រឹងសមត្ថភាពនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្នុងការផ្តល់វគ្គបណ្តុះបណ្តាលក្នុងពេលកំពង់អនុវត្តការងារសម្រាប់អ្នកបម្រើការងារជាអ្នកផ្សព្វផ្សាយ។<br>២.៣.ពង្រឹងមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្សព្វផ្សាយនិងធ្វើបង្ហាញបន្ថែមចំនួន៣ទៀត។ |
| | ២.៤. ប្រើប្រាស់ភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជនសម្រាប់ការ |

| | |
|---|---|
| | បណ្តុះបណ្តាល VEWs និងCEWs នៅថ្នាក់ក្រោមជាតិ។<br>២.៥.ពង្រឹង សាលាជាតិកសិកម្មព្រែកលៀប(PNCA) សាលាជាតិកសិកម្ម កំពង់ចាម (KNSA) និងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មដែលមានតាមតំបន់។ ភូមិសាស្ត្រប្រទេសកម្ពុជាសម្រាប់ការបណ្តុះបណ្តាល AEAs។<br>២.៦. សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) និងPNCA ផ្តល់ការបណ្តុះបណ្តាល AESs ហើយ RUA ផ្តល់ការបណ្តុះបណ្តាលកម្រិតមហាវិទ្យាល័យនៅក្នុងប្រទេស។ |
| ការបណ្តុះបណ្តាលជំនាញផ្សព្វផ្សាយក្នុងពេលកំពង់បម្រើការងារ | ២.៧.កសាងសមត្ថភាពថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោល (TOT) |
| | ២.៨ អនុវត្តផែនការនៃការអភិវឌ្ឍធនធានមនុស្សសម្រាប់នាយកដ្ឋាននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភ្នាក់ងារនានាដោយរួមបញ្ចូល RUA, PNCA និងKNSA។ |
| | ២.៩.បង្កើនជំនាញផ្សព្វផ្សាយដល់អ្នកធ្វើការងារផ្សព្វផ្សាយដែលមានស្រាប់តាមរយៈការបណ្តុះបណ្តាលក្នុងពេលកំពង់បម្រើការងារ។ |
| | ២.១០.ពង្រឹងការបណ្តុះបណ្តាលក្នុងពេលកំពង់បម្រើការងារ និងថ្នាក់មហាវិទ្យាល័យ (បរិញ្ញាប័ត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត)សម្រាប់អ្នកធ្វើការងារផ្សព្វផ្សាយនៅក្នុង និងក្រៅប្រទេស។ |
| ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានបណ្តុះបណ្តាល | ២.១១.បង្កើត និងអនុវត្តការចុះបញ្ជី និងប្រព័ន្ធទទួលស្គាល់គុណភាពអប់រំសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលការផ្សព្វផ្សាយ និងអ្នកផ្តល់សេវាផ្សព្វផ្សាយនានា (ឧ.ទា NGOs, CBOs, FOs)។ |
| **យុទ្ធសាស្ត្រទី៣. ការតភ្ជាប់ការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការអប់រំសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា** | |
| អន្តរទំនាក់ទំនងក្នុងចំណោមការស្រាវជ្រាវ ការផ្សព្វផ្សាយនិងការអប់រំ | ៣.១.ពង្រឹងការតភ្ជាប់ ការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអប់រំជាមួយ វិស័យឯកជនតាមរយៈការជួបប្រជុំជាប្រចាំ សិក្ខាសាលានានា និងចូលរួមគ្នាក្នុងការបោះពុម្ពផ្សេងៗ។ |
| | ៣.២.ពង្រឹងភាពជាដៃគូរ អគ្គនាយកដ្ឋានកសិកម្ម (GDA), នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE), និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ស្រាវជ្រាវកសិកម្មនៅកម្ពុជា (CARDI) ដើម្បីអភិវឌ្ឍន៍ ធ្វើតេស្តនៅទីវាល និងចែកចាយលទ្ធផលនៃការស្រាវជ្រាវទៅដល់អ្នកដែលចង់ប្រើប្រាស់ចុងក្រោយ ឬទៅកសិករ។ |
| | ៣.៣.រៀបចំការស្រាវជ្រាវថ្នាក់ជាតិ និងវេទិកាផ្សព្វផ្សាយ (ឬសន្និសីទ)ដើម្បីចែករំលែកការស្រាវជ្រាវថ្មីៗ និងការអភិវឌ្ឍនៅក្នុងវិស័យកសិកម្ម ព្រៃឈើ និងជលផល។ |

| | |
|---|---|
| ការអភិវឌ្ឍបច្ចេកវិទ្យា | ៣.៤.ពង្រឹង CARDI ដើម្បីបង្កើតបច្ចេកវិទ្យាដែលធន់ជាមួយនឹងការប្រែប្រួលអាកាសធាតុសមស្របសម្រាប់លក្ខខណ្ឌនានាក្នុងតំបន់។ |
| | ៣.៥.បង្កើតនិងជម្រុញបច្ចេកវិទ្យានានាដែលទាក់ទងនឹងយ៉េនឌ័រស្រួចស្រាវ និងបង្កើត និងអនុវត្តការអភិវឌ្ឍកុមារ និងការងាររបស់យុវជន។ |
| | ៣.៦.ធ្វើដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងមជ្ឈមណ្ឌលក្រុមប្រឹក្សាយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR Centers) ដើម្បីអភិវឌ្ឍន៍/កែតម្រូវបច្ចេកវិទ្យាសមស្របសម្រាប់ ស្ថានភាពនានានៅក្នុងតំបន់។ |
| **យុទ្ធសាស្ត្រទី៤. ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយ** | |
| ចូលរួមគ្នាក្នុងការបោះពុម្ពផ្សេងៗ | ៤.១.បង្កើតអនុគណៈកម្មាធិការលើការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយនានាជាមួយនឹងការទទួលខុសត្រូវពី CARDI, DAE, RUA, និងនាយកដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។ |
| | ៤.២.បង្កើតប្រព័ន្ធនៃការធានាគុណភាពសម្ភារៈផ្សព្វផ្សាយដែលជឿទុកចិត្តបាន ឧបករណ៍ និងធនធាននានា ជាអាទិ៍ ព្រឹត្តិបត្រព័ត៌មាន ផ្ទាំងរូបភាព ខ្សែវីដេអូ គេហទំព័រ។ ល។ ដែលផ្អែកលើតម្រូវការ និងអាទិភាពរបស់កសិករ។ |
| ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយ | ៤.៣.បង្កើតទូរទស្សន៍ និងធ្វើការផ្សាយតាមវិទ្យុសាធារណៈ និងផ្ញើសារ ទៅអ្នកពាក់ព័ន្ធតាមតំបន់គោលដៅជាក់លាក់។ |
| | ៤.៤.អភិវឌ្ឍន៍ធនធានផ្សព្វផ្សាយនានាដើម្បីតភ្ជាប់ទៅក្នុងមជ្ឈមណ្ឌលអ្នកចូលរួមផ្តល់ ចែករំលែកព័ត៌មានកសិកម្ម និង/ឬគេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្មដែលនឹងត្រូវបានចែកចាយដោយអ្នកផ្តល់សេវាផ្សព្វផ្សាយទាំងអស់។ |
| មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មថ្មី | ៤.៥.ពង្រឹងមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករ និងមជ្ឈមណ្ឌលធ្វើបង្ហាញបច្ចេកវិទ្យាទាំងឡាយរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ហើយបង្កើតមជ្ឈមណ្ឌលថ្មីលើតំបន់កសិកម្មខ្ពង់រាប តំបន់ឆ្នេរ និងតំបន់ទន្លេសាប។ |
| **យុទ្ធសាស្ត្រទី៥. ការផ្តល់សេវាផ្សព្វផ្សាយ** | |
| សេវាផ្សព្វផ្សាយតាមបែបពហុនិយម | ៥.១.នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) នឹងទទួលខុសត្រូវសម្រាប់ការធ្វើផែនការ និងផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ |
| | ៥.២ ប្រទេសកម្ពុជានឹងទទួលយកនូវអភិក្រមនៃការផ្តល់សេវាផ្សព្វផ្សាយតាមបែបពហុនិយម។ ដៃគូអភិវឌ្ឍន៍នានា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងវិស័យឯកជន នឹងផ្តល់សេវាផ្សព្វផ្សាយនៅថ្នាក់ក្រោម ជាតិ។ |
| | ៥.៣.ពង្រឹងឱកាសការសិក្សារៀនសូត្រពីកសិករទៅកសិករដោយប្រើ |

| | |
|---|---|
| | ប្រាស់ថវិកាផ្តួចផ្តើមដើម្បីជម្រុញការអនុវត្តកសិកម្មល្អ។ |
| ការពង្រឹងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | ៥.៤.បង្កើតកម្មវិធីផ្សព្វផ្សាយថ្មីៗដែលដឹកនាំដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដែលសំដៅទៅរកប្រធានបទដែលប្រទាក់ក្រឡាគ្នាដូចជា ការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រ និងការទាក់ទាញយុវជនឱ្យធ្វើកសិកម្ម។ |
| | ៥.៥.បង្កើតមជ្ឈមណ្ឌលអ្នកចូលរួមផ្តល់ ចែករំលែកព័ត៌មានកសិកម្ម និង/ឬគេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្មនៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដែលជាប្រព័ន្ធនៃការគ្រប់គ្រងចំណេះដឹងបែបអេឡិចត្រូនិក។ |

ក្រោមផែនការសកម្មភាពជាយុទ្ធសាស្ត្រនេះ កម្ពុជានឹងទទួលស្គាល់ការចូលរួមចំណែករបស់ស្ត្រីក្នុងវិស័យកសិកម្មនិងជីវភាពរស់នៅ ហើយផែនការនេះនឹងគាំទ្រដល់ការជ្រើសរើសនិងបណ្តុះបណ្តាលស្ត្រីដូចជា VEWs, CEWs, AEAs និងAESs។ គួរកត់សម្គាល់ថា VEWs និងCEWs នឹងដើរតួជាអ្នកបម្រើក្នុងតំបន់ និងសហគ្រិនកសិកម្ម។ ការិយាល័យកសិកម្មស្រុក អង្គការមិនមែន រដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ និង អង្គភាពឯកជនអាចចុះកិច្ចសន្យាសេវាការងារក្រោមទម្រង់ជាកិច្ចសន្យាជួលអ្នកក្រៅជាមួយពួកគេ។

ផ្នែកទី២ នៃរបាយការណ៍នេះផ្តោតលើគោលការណ៍ណែនាំសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE)នឹងបន្តផ្តល់នូវភាពជាអ្នកដឹកនាំដល់ថ្នាក់ជាតិសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនឹងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងការគាំទ្រផ្នែកបច្ចេកទេសដល់អ្នកជំនាញក្នុងពេលកំពុងអនុវត្តន៍ការងារក្នុងការដោះស្រាយបញ្ហាដែលប្រទាក់ក្រឡាគ្នាដូចជា ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រទៅក្នុងរាល់ការផ្តល់ការផ្សព្វផ្សាយទាំងអស់ ការអភិវឌ្ឍសេវាកម្មកុមារ និងការផ្តល់សិទ្ធិអំណាចដល់យុវជនសម្រាប់ជម្រុញកំណើនកសិកម្ម និងការអភិវឌ្ឍ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងធ្វើជាម្ចាស់រក្សានៃមជ្ឈមណ្ឌលអ្នកចូលរួមផ្តល់ ចែករំលែកព័ត៌មានកសិកម្ម សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/អគ្គនាយកដ្ឋានកសិកម្ម។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មក៏នឹងធ្វើជាម្ចាស់រក្សា គេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្ម សម្រាប់ការផ្សព្វផ្សាយព័ត៌មានទាន់ពេលវេលា និងមានប្រសិទ្ធភាពដល់មន្ត្រីថ្នាក់ខេត្ត និងថ្នាក់ស្រុក កសិករអាជីវកម្មខ្នាតធំ ប្រតិបត្តិករកសិ-ធុរកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល អង្គការកសិករ អង្គការសហគមន៍មូលដ្ឋាន ដែលបណ្តុះបណ្តាល VEWs និង CEWs និងគ្រប់គ្រងសកម្មភាពផ្សព្វផ្សាយនៅទីវាល ឬនៅថ្នាក់មូលដ្ឋាន។

សេវាផ្សព្វផ្សាយកសិកម្មដល់កសិករ និងប្រតិបត្តិករកសិ-ធុរកិច្ចនឹងត្រូវបានធ្វើវិមជ្ឈការនៅថ្នាក់ក្រោមជាតិ។ ការិយាល័យកសិកម្មស្រុក (DAO) នឹងក្លាយជាតួអង្គបង្គោលសម្រាប់ការរៀបចំផែនការ និងការអនុវត្តសេវាតាមតម្រូវការមូលដ្ឋាន និងទីផ្សារ តាមរយៈភាពជាដៃគូរវាងរដ្ឋ និង ឯកជន។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងខេត្តនីមួយៗនឹងសម្របសម្រួលកម្មវិធី និងសកម្មភាពផ្សព្វផ្សាយ គ្រប់គ្រងមូលនិធិពីរាជរដ្ឋាភិបា

លកម្ពុជា និង ជួយសម្រួលដល់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដើម្បីផ្តល់សេវាផ្សព្វផ្សាយនៅកម្រិតស្រុក ឃុំ ភូមិ។

គណៈកម្មាធិការអ្នកពាក់ព័ន្ធនៅតាមខេត្ត ស្រុក និងថ្នាក់ជាតិនឹងដើរតួនាទីស្នូលនៅក្នុងការកសាងផែនការ និងការផ្តល់សេវាផ្សព្វផ្សាយ។ គណៈកម្មាធិការទាំងអស់នឹងតំណាងឱ្យអង្គការ និងក្រុមអតិថិជនជាច្រើន។ MAFF/កម្មវិធីASPIRE នឹងរៀបចំព្រឹត្តិការណ៍បណ្តុះបណ្តាល និងសិក្ខាសាលាដើម្បីផ្តល់សិទ្ធិអំណាចដល់សមាជិកគណៈកម្មាធិការភាគីពាក់ព័ន្ធ។

ការិយាល័យកសិកម្មស្រុកនឹងអនុវត្តកម្មវិធីផ្សព្វផ្សាយដោយធ្វើការសម្របសម្រួលការផ្តល់សេវាកម្មជាមួយភ្នាក់ងារវិស័យសាធារណៈ និងឯកជនដើម្បីផ្តល់ព័ត៌មាន និងសេវាកម្មឱ្យទាន់ពេលវេលាដោយមិនជាន់គ្នា។

គណៈកម្មាធិការប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្មថ្នាក់ជតិ(AEAC)នឹងត្រូវដំណើរការនៅថ្នាក់ជាតិ។ AEAC នឹងត្រូវបានធ្វើជាប្រធានដោយ រដ្ឋលេខាធិការ ហើយនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់គោលការណ៍ណែនាំគោលនយោបាយ និងក្របខ័ណ្ឌសម្របសម្រួលសម្រាប់រៀបចំផែនការ ការអនុវត្តនិងវាយតម្លៃសេវាផ្សព្វផ្សាយកសិកម្ម។ AEAC នឹងធានាថាគោលនយោបាយផ្សព្វផ្សាយ និងកម្មវិធីរបស់ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ត្រូវបានតម្រូវទៅនឹងតម្រូវការរបស់កសិករហើយនឹងបំពេញតាមតម្រូវការទីផ្សារ។ AEAC នឹងផ្តល់នូវទិសដៅច្បាស់លាស់ស្តីពីអាទិភាពជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្មដល់អ្នកផ្តល់មូលនិធិ/ម្ចាស់ជំនួយ និងអ្នកផ្តល់សេវាវិស័យឯកជនដែលតម្រូវឱ្យផ្អែកលើតម្រូវការរបស់កសិករ កសិ-ធុរកិច្ច និងទីផ្សារ។ ហើយវានឹងធានាថាគោលនយោបាយអភិវឌ្ឍន៍កសិកម្មមានសង្គតភាពក្នុងផែនការមេកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០៣០ និងគោលនយោបាយពាក់ព័ន្ធនានាថ្នាក់ជាតិ ថ្នាក់ខេត្តស្រុក និងឃុំ។

អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មជាតិ (NATSC) នឹងត្រូវបានបង្កើតឡើង និងរៀបចំជាផ្លូវការហើយដឹកនាំដោយ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ NATSC នឹងផ្តល់នូវគោលការណ៍ណែនាំ និងគោលនយោបាយគាំទ្រសម្រាប់សេវាផ្សព្វផ្សាយកសិកម្មចាំបាច់។ NATSC ក៏នឹងធានានូវភាពបច្ចេកទេសត្រឹមត្រូវនៃបច្ចេកវិទ្យាកសិកម្ម និងនវានុវត្តន៍ ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយរបស់ពួកគេដល់អ្នកប្រើប្រាស់ចុងក្រោយ ។

ក្រោមការណែនាំពី AEAC, NATSC នឹងបង្កើតនូវគោលការណ៍និងនីតិវិធីជាក់ស្តែងសម្រាប់ដំណើរការប្រតិបត្តិការ និងការគ្រប់គ្រងការផ្សព្វផ្សាយកសិកម្មដោយរលូន។ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា សេវាផ្សព្វផ្សាយមួយចំនួននឹងទៅជាកម្មសិទ្ធឯកជន ឬជាជំនួញ បើសិនជាសហគ្រាសនោះមានការយកចិត្តទុកដាក់លើទីផ្សារ ពាណិជ្ជកម្មក្នុងធម្មជាតិ និងមានការប្រកួតប្រជែងគ្រប់គ្រាន់ដើម្បីបង្កើតនូវតម្រូវការសេវាផ្សព្វផ្សាយក្នុងការរកផលចំណេញ។ ឧទាហរណ៍ ការបង្កើនពូជនិងចែកចាយពូជអាចត្រូវបានចុះកិច្ចសន្យាជាមួយវិស័យឯកជនលើមូលដ្ឋានប្រកួតប្រជែងមួយ។ ដូចគ្នានេះដែរការលក់ជី ថ្នាំសម្លាប់សត្វល្អិត និងសម្ភារៈកសិកម្មអាចត្រូវបានគ្រប់គ្រងដោយវិស័យឯកជន។ សេវាផ្សព្វផ្សាយ និងក្រុមអតិថិជននឹងត្រូវបានចាត់ថ្នាក់ដើម្បីកំណត់ថាសេវាកម្មណាមួយនឹងនៅតែឥតគិតថ្លៃ។ សម្រាប់សេវាកម្មផ្សេងទៀត

NATSC នឹងចេញនូវគោលការណ៍ណែនាំដែលអតិថិជន ឬក្រុមអតិថិជននឹងបន្តទទួលបានសេវាផ្សព្វផ្សាយឥតគិតថ្លៃ។

NATSC ក៏នឹងធានាបាននូវភាពរលូននៃទំនាក់ទំនងការងារក្នុងចំណោមការស្រាវជ្រាវកសិកម្ម ការផ្សព្វផ្សាយ ការអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាល។ អនុគណៈកម្មការនេះនឹងផ្តល់នូវគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការទំនាក់ទំនងរវាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងធ្វើផែនស្រាវជ្រាវផ្អែកលើតម្រូវការរបស់កសិករ និងសកម្មភាពផ្សព្វផ្សាយរួមគ្នា។ អនុគណៈកម្មការនឹងសម្របសម្រួលការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយ ការបោះពុម្ពផ្សាយ និងព័ត៌មានដែលឈរលើព័ត៌មានវិទ្យា។ ចំណេះដឹង និងព័ត៌មានដែលផ្អែកលើមូលដ្ឋាននៃការស្រាវជ្រាវនឹងត្រូវបានចែករំលែក តាមរយៈ សម្ភារៈផ្សព្វផ្សាយ និងតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម និង/ឬគេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្ម។

NATSC ក៏នឹងបង្កើតយន្តការដើម្បីធានាគុណភាពនៃសេវាផ្សព្វផ្សាយ។ គណៈកម្មាធិការនេះនឹងចាប់ផ្តើមចុះបញ្ជីនិងផ្តល់អាជ្ញាប័ណ្ណដល់អ្នកផ្តល់សេវាផ្សព្វផ្សាយ និងជួយដល់ក្រសួងកសិកម្មដើម្បីគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាផ្សព្វផ្សាយផ្នែកឯកជន។ វាក៏នឹងបង្កើតនូវប្រព័ន្ធទទួលស្គាល់គុណភាពអប់រំដើម្បីទទួលបាននូវគុណភាពខ្ពស់ក្នុងការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលជាច្រើន។ ការទទួលស្គាល់គុណភាពអប់រំ នឹងពិចារណាលើលក្ខណៈវិនិច្ឆ័យរួមទាំងសមត្ថភាពរបស់មហាវិទ្យាល័យ ភាពរឹងមាំនៃកម្មវិធីសិក្សា ការបង្រៀន/ការរៀន និងការវាយតម្លៃការបណ្តុះបណ្តាល។

AEAC និង NATSC ក៏នឹងបង្កើតគោលការណ៍ណែនាំស្តីពីការវាយតម្លៃបុគ្គលិកផ្សព្វផ្សាយសម្រាប់ ការដំឡើងតួនាទី ការផ្ទេរ ឬការបញ្ចប់ និងដាក់ឱ្យមាននូវវិមជ្ឈការក្របខ័ណ្ឌនៃការត្រួតពិនិត្យ និងវាយតម្លៃ។

នៅថ្នាក់ខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត (PAEWG) ដែលនឹងជួយក្នុងការសម្របសម្រួលប្រតិបត្តិការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយដែលត្រូវតាមមូលដ្ឋាន និងដែលបំពេញតម្រូវការទីផ្សារផងដែរ។ PAEWG ក៏នឹងជួយសម្របសម្រួលកម្មវិធី និងសេវាកម្មដែលបានផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ហើយដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

ការិយាល័យកសិកម្មស្រុក (DAO) នឹងក្លាយជាអង្គភាពចម្បងដែលទទួលខុសត្រូវក្នុងការរៀបចំ និងផ្តល់សេវាផ្សព្វផ្សាយ។ DAO នឹងធ្វើការក្រោមការដឹកនាំរបស់ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST) ដើម្បីសម្របសម្រួលសេវាផ្សព្វផ្សាយទាំងអស់នៅក្នុងស្រុក។ ជាមួយនឹងដំបូន្មានពីក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក ការិយាល័យកសិកម្មស្រុក នឹងកំណត់បានថាតើសេវាផ្សព្វផ្សាយណាដែលបានជាកម្មសិទ្ធរបស់ឯកជន ហើយនឹងជម្រុញឱ្យវិស័យឯកជនចូលរួមផ្តល់សេវាផ្សព្វផ្សាយនៅថ្នាក់ឃុំ និងថ្នាក់ស្រុក។

មជ្ឈមណ្ឌលកសិកម្មឃុំ ប្រតិបត្តិការនៅកម្រិតមូលដ្ឋាន។ គណៈកម្មាធិការកសិកម្មឃុំ (CAC) នឹងត្រូវបង្កើតឡើងនៅក្នុងឃុំនីមួយៗដើម្បីសម្របសម្រួល និងដឹកនាំសកម្មភាពរបស់មជ្ឈមណ្ឌលកសិកម្មឃុំ។ CAC

នឹងធានាថាសេវាកម្មផ្សព្វផ្សាយនឹងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កសិករក្នុងតំបន់និងបំពេញតាមតម្រូវការទីផ្សារ។

ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយនឹងក្លាយជាអាទិភាពមួយ។ វិធីសាស្ត្រជា ម៉ូឌុលក្នុងការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយនឹងត្រូវអនុវត្តដើម្បីបង្ហាត់បង្រៀន VEWs, CEWs AEAs និង AESs។ NATSC នឹងបង្កើត និងពង្រឹងប្រព័ន្ធទទួលស្គាល់គុណភាពអប់រំដើម្បីគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីរក្សាស្តង់ដារគុណភាពនៃគ្រប់កម្រិតនៃកម្មវិធីបណ្តុះបណ្តាលលើការផ្សព្វផ្សាយ។

មានតម្រូវការជាបន្ទាន់សម្រាប់ការបណ្តុះបណ្តាលដល់បុគ្គលិកផ្សព្វផ្សាយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងគាំទ្រដល់ការពង្រឹងសមត្ថភាពបណ្តុះបណ្តាលអ្នកជំនាញផ្សព្វផ្សាយនៅ RUA PNCA និង KNSA ។ គ្រឹះស្ថានអប់រំកសិកម្មទាំងនេះនឹងត្រូវការពង្រឹងដល់មហាវិទ្យាល័យរបស់ខ្លួន នូវកម្មវិធីបណ្តុះបណ្តាល ការអនុវត្តជាក់ស្តែង និងសម្ភារៈសម្រាប់បង្រៀន។ ផែនការអភិវឌ្ឍធនធានមនុស្សដ៏ទូលំទូលាយរួមទាំងតម្រូវការកសាងសមត្ថភាពរបស់ RUA, PNCA និង KNSA ត្រូវបានបញ្ចូលនៅក្នុងគោលការណ៍ណែនាំអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងសហការជាមួយនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់អ្នកផ្សព្វផ្សាយ ពេលកំពុងអនុវត្តន៍បម្រើសេវា ឬកំពុងអនុវត្តការងារ **"បណ្តុះបណ្តាលរំលឹកមេរៀនឡើងវិញ"** ។ ការបណ្តុះបណ្តាលទាំងនេះនឹងជួយលើកកម្ពស់ចំណេះដឹងផ្នែកបច្ចេកទេស និង ដុះខាត់សមត្ថភាពជំនាញនៃបុគ្គលិកផ្សព្វផ្សាយ។ ជាមួយនឹងការផ្តល់ដំបូន្មានពី NATSC និង នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្រុមអ្នកស្រាវជ្រាវរបស់ CARDI និងអ្នកឯកទេសផ្សព្វផ្សាយនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងត្រូវបានប្រើដើម្បីអភិវឌ្ឍន៍ឯកសារផ្សព្វផ្សាយដែលអាចជឿទុកចិត្តនិងមានប្រយោជន៍ដែលសមស្របសម្រាប់ផ្សព្វផ្សាយជាឯកសារបោះពុម្ព និង/ឬអេឡិចត្រូនិក។ រាល់ការបោះពុម្ពផ្សាយ និងព័ត៌មានអំពីប្រព័ន្ធផ្សព្វផ្សាយនឹងត្រូវបានពិនិត្យឡើងវិញដោយ NATSC មុនពេលពួកគេផ្សព្វផ្សាយតាមរយៈ មជ្ឈមណ្ឌលអ្នកចូលរួមផ្តល់ ចែករំលែកព័ត៌មានកសិកម្ម និង/ឬគេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្ម ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនឹងធ្វើជាមជ្ឈមណ្ឌលអ្នកចូលរួមផ្តល់ ចែករំលែកព័ត៌មានកសិកម្ម និង/ឬគេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្មដើម្បីផ្តល់នូវមធ្យោបាយប្រកបដោយភាពច្នៃប្រឌិត និងមានប្រសិទ្ធភាពក្នុងការចាប់យកការគ្រប់គ្រង និងចែករំលែកព័ត៌មាន និងចំណេះដឹងសំខាន់ៗតាមរយៈមធ្យោបាយអេឡិចត្រូនិចដែលប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា (ICT) ។

ការិយាល័យកសិកម្មស្រុក (DAO) នឹងបង្កើតផែនការរួមមួយសម្រាប់ការផ្តល់ផ្សព្វផ្សាយ។ DAO ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសកសិកម្មស្រុក និងគណៈកម្មាធិការកសិកម្មឃុំ នឹងចុះកិច្ចសន្យាផ្តល់សេវាផ្សព្វផ្សាយដល់ដៃគូអភិវឌ្ឍន៍ក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាល។

គ្រប់សេវាកម្មផ្សព្វផ្សាយកសិកម្មទាំងអស់នៅក្នុងប្រទេសកម្ពុជា ដោយមិនគិតពីប្រភពមូលនិធិ នឹងអនុវត្តតាមឯកសណ្ឋានមួយនៃក្របខ័ណ្ឌស្ថាប័ន ដែលមានដូចជាគណៈកម្មាធិការកសិកម្មឃុំ ក្រុមការងារបច្ចេកទេសកសិកម្មស្រុក និងក្រុមការងារបច្ចេកទេសកសិកម្មខេត្ត ដើម្បីធានាឱ្យមានការចូលរួម ផ្តែកលើតម្រូវការមូលដ្ឋាន និងផ្តល់សេវាតាមតម្រូវការអ្នកប្រើប្រាស់។ គម្រោងទាំងអស់ ដោយមិនគិតពីប្រភពថវិកា នឹងត្រូវបានតម្រូវឱ្យប្រើប្រាស់សេវាកម្មរបស់ VEWs និង CEWs នៅក្នុងតំបន់រៀងៗខ្លួនដើម្បីឈានទៅដល់កសិករ និងបង្រៀនកសិករ។

MAFF/កម្មវិធី ASPIRE នឹងផ្តល់មូលនិធិសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយ ការស្រាវជ្រាវ ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍកសិកម្មដែលជួយសម្រួលដល់កត្តានានាដែលឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន។ នៅក្នុងគម្រោង ASPIRE មូលនិធិស្រុកគោលដៅនឹងត្រូវបានផ្ទេរទៅឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគាំទ្រសកម្មភាពផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ (ស្រុក)។ សំណើសុំមូលនិធិនឹងត្រូវធ្វើឡើងដោយក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុកទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ហើយមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងបែងចែកធនធានដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារផ្នែកបច្ចេកទេសកសិកម្មខេត្ត និងដៃគូអភិវឌ្ឍន៍/សហការីដែលប្រតិបត្តិការនៅក្នុងខេត្ត។

ជាថ្មីម្តងទៀតផែនការសកម្មភាពជាយុទ្ធសាស្រ្តនេះស្របទៅនឹងផែនការមេកសិកម្មឆ្នាំ២០៣០។ ផែនការសកម្មភាពនេះមានជាប់ទាក់ទងដោយផ្ទាល់ជាមួយយុទ្ធសាស្រ្តអនុវត្តន៍គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។ ផែនការសកម្មភាពនេះស្នើឡើងនូវប្រព័ន្ធផ្តល់ការផ្សព្វផ្សាយតាមបែបវិមជ្ឈការ ដោយមានការចូលរួម និងការផ្សព្វផ្សាយតាមតម្រូវការអ្នកប្រើប្រាស់ ដែលការិយាល័យកសិកម្មស្រុកនឹងមានការទទួលខុសត្រូវចម្បងក្នុងការរៀបចំផែនការ និងអនុវត្តសេវាផ្សព្វផ្សាយដោយមានការណែនាំនិងការគាំទ្រពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសម្របសម្រួលការរៀបចំផែនការ និងប្រតិបត្តិការសេវាផ្សព្វផ្សាយកសិកម្មជាមួយដៃគូអភិវឌ្ឍន៍។ ការផ្សព្វផ្សាយនេះនឹងអនុវត្តតាមអភិក្រមបែបពហុនិយមនៃការផ្តល់សេវា ឧទាហរណ៍ សេវា និងសកម្មភាពនានានឹងត្រូវបានគ្រោងទុក និងអនុវត្តដោយសហការជាមួយវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការកសិករ សហគមន៍ និង CEWs និង VEWs ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងផ្តល់ការសម្របសម្រួល និងការគាំទ្រថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយលើបញ្ហាដែលប្រទាក់ក្រឡាគ្នាដូចជា ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការបណ្តុះបណ្តាលសហគ្រិនវ័យក្មេងនៅជនបទ ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយ និង ការរក្សាគេហទំព័រផ្សព្វផ្សាយព័ត៌មានកសិកម្ម។ គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម និងអនុគណៈកម្មការរបស់ខ្លួននឹងដឹកនាំ អគ្គនាយកដ្ឋានកសិកម្ម និង នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។

ក្របខ័ណ្ឌអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដូច្នេះភាគីពាក់ព័ន្ធទាំងអស់យល់ដឹងអំពីការផ្លាស់ប្តូរដែលកំពុងកើតមាន ហើយយល់ដឹងពីរបៀបនៃការរៀបចំថ្មី ដែលនឹងធ្វើឱ្យប្រសើរឡើង នូវការចូលរួមចំណែកនៃការផ្សព្វផ្សាយទៅរកវិស័យកសិកម្មប្រកបដោយភាពស្វាហាប់។

ការផ្សព្វផ្សាយកសិកម្ម គឺជាផ្នែកសំខាន់នៃការអភិវឌ្ឍកសិកម្ម។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់មូលនិធិដល់បុគ្គលិក និងសម្ភារៈសំខាន់ៗ ដូចជា ទីតាំង(ការិយាល័យ) សម្ភារៈផ្គត់ផ្គង់ និងសេវាធ្វើដំណើរសម្រាប់សេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(ថ្នាក់ខេត្ត និងថ្នាក់ស្រុក)។ រាជរដ្ឋាភិបាលនឹងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តផ្តល់សេវាផ្សព្វផ្សាយដល់កសិករ និងអ្នកពាក់ព័ន្ធ។

**តារាងទី២. ថវិកាប៉ាន់ប្រមាណសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**

| ចង្កោមសកម្មភាព | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប៥ឆ្នាំ |
|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| ១.ក្របខ័ណ្ឌនៃការរៀបចំស្ថាប័ន និងនីតិបញ្ញត្តិ (គណៈកម្មាធិការសិក្ខាសាលា ត្រួតពិនិត្យគោលនយោបាយ និងការសិក្សាផ្សេងៗ) | $305,000 | $305,000 | $305,000 | $305,000 | $305,000 | $1,525,000 |
| ២.ការអភិវឌ្ឍធនធានមនុស្ស | $2,120,000 | $2,480,000 | $2,480,000 | $2,750,000 | $2,005,000 | $11,835,000 |
| ៣.ការតភ្ជាប់ការស្រាវជ្រាវ-ការផ្សព្វផ្សាយសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា | $332,000 | $332,000 | $332,000 | $332,000 | $332,000 | $1,660,000 |
| ៤.ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយ | $122,000 | $122,000 | $122,000 | $122,000 | $122,000 | $610,000 |
| ៥.ការផ្តល់សេវាផ្សព្វផ្សាយ | $672,000 | $6,72,000 | $672,000 | $672,000 | $672,000 | $9,410,000 |
| ៦.ការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្ម | $500,000 | $1,000,000 | $1,000,000 | $1,000,000 | $1,000,000 | $4,500,000 |
| ៧.ការគ្រប់គ្រង ការធ្វើដំណើរ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ | $800,000 | $800,000 | $800,000 | $800,000 | $800,000 | $4,000,000 |
| **សរុប** | **$4,851,000** | **$11,761,000** | **$5,711,000** | **$5,981,000** | **$5,236,000** | **$33,540,000** |

# ផ្នែកទី ១៖ ផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម

## សេចក្តីផ្តើម និងសាវតា

កសិកម្មគឺជាវិស័យនាំមុខគេសម្រាប់កំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ វិស័យនេះទទួលបន្ទុកចំនួន ២៨% នៃផលិតផលដុលក្នុងស្រុក ហើយផ្តល់ការងាដល់ពលកម្មសរុប៦៧%(FAO, 2014)។ ដោយហេតុនេះរាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យក្នុងការធ្វើទំនើបកម្ម និងប្រពលវប្បកម្ម វិស័យកសិកម្មកម្ពុជា ហើយស្របពេលជាមួយគ្នានោះក៏ធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធផលចំពោះដីបរិស្ថាននិងធនធានធម្មជាតិ។ពីរភាគបីនៃដីកសិកម្មសរុបត្រូវបានប្រើប្រាស់សម្រាប់ការដាំដុះរដូវវស្សា(២,២លានហិចតា)។ ទំហំនេះស្មើនឹងប្រមាណប្រាំមួយដងខ្ពស់ជាងផ្ទៃដីប្រើប្រាស់សម្រាប់ការដាំដុះនៃរដូវប្រាំង ក្នុងរដូវវស្សា៣២%នៃផ្ទៃដីកសិកម្មសរុប មានទឹកស្រោចស្រព ប៉ុន្តែក្នុងការដាំដុះរដូវប្រាំងវិញមានតែ១០%ប៉ុណ្ណោះនៃដីកសិកម្មដែលមានទឹកស្រោចស្រព (វិទ្យាស្ថានជាតិស្ថិតិ ២០១៦)។ ផលិតភាពវិស័យកសិកម្មមានកម្រិតទាបបើធៀបជាមួយបណ្តាប្រទេសជិតខាងដោយសារហេតុផលផ្សេងៗជាច្រើន។

គោលដៅទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ(MAFF) គឺគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជាតាមរយៈការធានាសន្តិសុខស្បៀង និងលើកកម្ពស់សេដ្ឋកិច្ចជនបទ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ផែនការមេអភិវឌ្ឍកសិកម្មឆ្នាំ២០៣០ របស់ក្រសួងមានចក្ខុវិស័យធ្វើទំនើបកម្មវិស័យកសិកម្មដើម្បីធ្វើឱ្យវិស័យនេះមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់ទ្រាំនិងមាននិរន្តរភាពដើម្បីចូលរួមចំណែកចំពោះសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា (នាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ២០១៧Cummins, 2017)។ ផែនការនេះមានគោលដៅពង្រីកកំណើនសេដ្ឋកិច្ចវិស័យកសិកម្មឱ្យបាន៥%ក្នុងមួយឆ្នាំតាមរយៈការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម ភាពប្រកួតប្រជែងនិងពាណិជ្ជូបនីយកម្មកសិកម្ម។ ផែនការនេះក៏មានបំណងលើកកម្ពស់ការប្រើប្រាស់ដីកសិកម្ម ធនធានព្រៃឈើ និងធនធាននេសាទប្រកបដោយនិរន្តរភាពសម្រាប់ការអភិវឌ្ឍ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមាននាយកដ្ឋានចំនួនប្រាំដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីគាំទ្រនូវជំនាញជាក់លាក់ដូចខាងក្រោម៖

១. អគ្គនាយកដ្ឋានកសិកម្មផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងវិស័យដំណាំ ផ្លែឈើ និងបន្លែ។

២. អគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្ម គាំទ្រដល់ផលិតកម្មបសុសត្វ និងការស្វែងរកទីផ្សារ។

៣. រដ្ឋបាលជលផលផ្តោតការយកចិត្តទុកដាក់លើផលិតកម្ម វារីវប្បកម្មក្នុងកសិដ្ឋាន បឹង និងទន្លេ។

៤. រដ្ឋបាលព្រៃឈើយកចិត្តទុកដាក់លើការគ្រប់គ្រងព្រៃឈើ រុក្ខវប្បកម្ម និងផលិតផលព្រៃឈើ។

៥. អគ្គនាយកដ្ឋានកៅស៊ូផ្តល់ការគាំទ្រដល់ផលិតកម្មចំការ ផ្តល់ការកែច្នៃ និងការរកទីផ្សារកៅស៊ូ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មបំពេញមុខងារនៅក្រោមអគ្គនាយកដ្ឋានកសិកម្ម (GDA)។ នាយកដ្ឋាននេះផ្តល់សេវាអប់រំ និងព័ត៌មានជូនដល់កសិករ និងប្រតិបត្តិករធុរៈកិច្ចកសិកម្ម។ អគ្គនាយកដ្ឋានទទួលស្គាល់ថាបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗមានភាពចាំបាច់ដើម្បីធ្វើទំនើបកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម(MAFF, 2015)។

ថ្វីបើសកម្មភាពផ្សព្វផ្សាយកសិកម្មបានចាប់ផ្តើមក្នុងឆ្នាំ១៩៥៧ ក្តីប៉ុន្តែសង្រ្គាមស៊ីវិលក្នុងទសវត្សរ៍ឆ្នាំ១៩៧០ បានបំផ្លិចបំផ្លាញសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ហើយហេដ្ឋារចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មស្ទើរទាំងស្រុងត្រូវបានបំផ្លាញ។ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មជូនកសិករបានវិលត្រឡប់មកវិញក្នុងឆ្នាំ១៩៨៦ដោយមានការិយាល័យផ្សព្វផ្សាយកសិកម្មនៅក្រោមក្រសួងកសិកម្មក្នុងឆ្នាំ១៩៩៥ បានក្លាយជានាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) ត្រូវបានបង្កើតឡើង (MAFF, 2015)។

ការផ្សព្វផ្សាយកសិកម្មអាចដើរតួនាទីដ៏សំខាន់ក្នុងការជួយកសិករនិងសហគមន៍កសិកម្មដើម្បីបង្កើនផលិតភាពកសិកម្ម ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការក្នុងមូលដ្ឋានក៏ដូចជា ដើម្បីពង្រីកការចែកចាយផលិតផលកសិកម្មរបស់កម្ពុជាទៅកាន់ទីផ្សារថ្នាក់តំបន់ និងសកល។ ប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយកសិកម្មរងផលប៉ះពាល់ពីបញ្ហាប្រឈមដូចខាងក្រោម៖

- យន្តការមិនគ្រប់គ្រាន់ ពោលគឺ នៅមានតម្រូវការឱ្យមានលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាដើម្បីគាំទ្រដល់ការសម្របសម្រួលនិងប្រតិបត្តិការសេវាផ្សព្វផ្សាយកសិកម្ម។
- ធនធានមនុស្ស និងសមត្ថភាពក្នុងការផ្សព្វផ្សាយកសិកម្ម (ចំនួនបុគ្គលិក ជំនាញកែច្នៃ និងសមត្ថភាពផ្នែកបច្ចេកទេស) នៅមានកម្រិតកំណត់ ជាពិសេសនៅថ្នាក់ក្រោមជាតិ (ពោលគឺថ្នាក់ស្រុក និងឃុំ)
- មានការផ្សារភ្ជាប់អន់ខ្សោយរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ កសិករ និងទីផ្សារ។
- កង្វះបច្ចេកវិទ្យាកសិកម្ម និងព័ត៌មានសមស្របដើម្បីបង្កើនផលិតភាព និងចំណូល។
- សេវាផ្សព្វផ្សាយកសិកម្មនៅដាច់ៗពីគ្នា និង/ឬមានការសម្របសម្រួលអន់ខ្សោយក្នុងចំណោមអ្នកផ្តល់សេវានានាពីវិស័យរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។

ដើម្បីឆ្លើយតបបញ្ហាប្រឈមដែលបានលើកឡើងខាងលើក៏ដូចជាបរិបទ និងតម្រូវការដែលមានការផ្លាស់ប្តូររបស់កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានប្រកាសឱ្យប្រើប្រាស់នូវ គោលនយោបាយផ្សព្វផ្សាយកសិកម្មក្នុងឆ្នាំ២០១៥ ដើម្បីធានានិរន្តរភាពរយៈពេលវែងនៃប្រព័ន្ធផ្សព្វផ្សាយកសិកម្មដើម្បីពង្រីក និងបង្កើនប្រសិទ្ធភាពប្រព័ន្ធកសិកម្ម និងដើម្បីបង្កើនសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ អនុលោមតាមពាក្យស្លោក **"សេវាផ្សព្វផ្សាយកសិកម្មដើម្បីសុខុមាលភាពកាន់តែប្រសើរ"** គោលបំណងនៃឯកសារគោលនយោបាយផ្សព្វផ្សាយកសិកម្មនេះគឺដើម្បីគាំទ្រ ជួយជ្រោមជ្រែងនិងសម្របសម្រួលការងាររបស់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់នៅក្នុងប្រទេសកម្ពុជាដើម្បីឱ្យកសិករនិងសហគមន៍កសិកម្មមានលទ្ធភាពបានទទួលសេវាទាន់ពេលវេលា និងធ្វើឱ្យពួកគាត់អាចរៀនសូត្រអំពីព័ត៌មានថ្មីៗ និងទទួលយកបច្ចេកវិទ្យានិងនវានុវត្តន៍ទំនើបៗ។

គោលនយោបាយការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ត្រូវបានអភិវឌ្ឍឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយគម្រោងជួយដោះស្រាយភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី (គម្រោង HARVEST កម្ពុជា)ដែលផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID)។ ឯកសារគោលនយោបាយផ្តល់នូវទិសដៅទូទៅសម្រាប់កម្មវិធីផ្សព្វផ្សាយកសិកម្ម និងសកម្មភាពផ្សព្វផ្សាយកសិកម្មក្នុងប្រទេស

កម្ពុជា។ ផែនការសកម្មភាពជាយុទ្ធសាស្ត្រនេះមានបំណងឆ្លើយតបចំពោះសេចក្តីត្រូវការគោលការណ៍ណែនាំជាក់លាក់សម្រាប់ការអនុវត្តពេញទំហឹងនូវគោលនយោបាយការផ្សព្វផ្សាយកសិកម្មនេះ។

## គោលនយោបាយផ្សព្វផ្សាយកសិកម្ម៖ ចក្ខុវិស័យ បេសកម្ម និងគោលដៅ

**ចក្ខុវិស័យ៖** ចក្ខុវិស័យរបស់គោលនយោបាយការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា គឺដើម្បីពង្រីកនិងបង្កើនប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាឲ្យកាន់តែល្អ។

**បេសកកម្ម៖** កសិករ និងសហគមន៍កសិករនឹងទទួលបាននិងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើ ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម ពាណិជ្ជូបនីយកម្មកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**គោលដៅ៖** កសិករកម្ពុជា និងសហគមន៍កសិកម្មទាំងអស់នឹងមានលទ្ធភាពទទួលបាន និងទទួលយកចំណេះដឹង ព័ត៌មាននិងបច្ចេកវិទ្យាកសិកម្មកាន់តែប្រសើរឡើងដើម្បីពង្រឹងផលិតភាពកសិកម្ម ពិពិធកម្ម ការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

## គោលបំណង

១. ដើម្បីបង្កើនប្រសិទ្ធភាពស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅគ្រប់កម្រិតទាំងអស់ ដើម្បីឱ្យមានប្រតិបត្តិការ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនងរវាងភាគីពាក់ព័ន្ធទាំងអស់នេះ។

២. ដើម្បីបង្កើនសមត្ថភាពធនធានមនុស្ស និងលទ្ធភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មជាកិច្ចឆ្លើយតបជាមួយសេចក្តីត្រូវការថ្នាក់មូលដ្ឋាន និងតម្រូវការទីផ្សារ។

៣. ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាសមស្របនឹងធ្វើឱ្យមានបច្ចេកវិទ្យាទាំងនោះដែលកសិករអាចទទួលយកបាន និងអាចយកទៅអនុវត្តបាន។

៤. ដើម្បីអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយ និងលើកកម្ពស់លទ្ធភាពទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មប្រកបដោយប្រសិទ្ធភាព។

៥. ដើម្បីផ្តល់សេវាផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើឱ្យការសម្រេចចិត្តរបស់កសិករ និងសហគមន៍កសិកម្មមានភាពប្រសើរឡើងដើម្បីបង្កើនផលិតភាពកសិកម្ម ពិពិធកម្ម ការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម និងការបង្កើតចំណូល។

## ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ (SWOT) របស់ការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា

**ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ (SWOT)** គឺជាគោលវិធីបែបគុណភាពដើម្បីកំណត់រកស្ថានភាពបរិស្ថាននាពេលបច្ចុប្បន្នដែលអង្គភាពមួយកំពុងប្រតិបត្តិការ។ វិធីសាស្ត្រចម្បងនៃការវិភាគ SWOT គឺដើម្បីជួយដល់អង្គភាពនោះក្នុងការអភិវឌ្ឍការយល់ដឹងពេញលេញអំពីកត្តាទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍគោលនយោបាយ ឬធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រ។ ការដឹងអំពីជាតុផ្សំជាវិជ្ជមាន និងអវិជ្ជមានអាចជួយអង្គភាពនោះឱ្យឆ្លើយតបកាន់តែមានប្រសិទ្ធភាពថែមទៀតទៅលើផ្នែកណានៃអង្គភាពនោះដែលចាំបាច់ត្រូវរៀបចំឡើងវិញ ឬ ពង្រឹងបន្ថែមដើម្បីអាចសម្រេចបានគោលដៅរបស់ខ្លួន (Fallon, 2018)។ អក្សរពីរដំបូងនៅក្នុងអក្សរកាត់ជាភាសាអង់គ្លេស ពោលគឺ អក្សរ S (ចំណុចខ្លាំង) និងអក្សរ W (ចំណុចខ្សោយ) សំដៅទៅលើកត្តាខាងក្នុងដូចជា ធនធាន និងបទពិសោធន៍ដែលមានរួចជាស្រេចចំពោះអង្គភាពនោះ។ ចំណុចខ្លាំង និងចំណុចខ្សោយអាចរួមមានដូចជា ធនធានហិរញ្ញវត្ថុ (មូលនិធិ ឱកាសវិនិយោគ) ធនធានរូបវ័ន្ត (ទីកន្លែង ទីតាំង ឧបករណ៍) ធនធានមនុស្ស (និយោជិត អ្នកស្ម័គ្រចិត្ត អតិថិជន) និងលទ្ធភាពទទួលបានធនធានធម្មជាតិ។ អក្សរពីរខាងក្រោយគឺពាក់ព័ន្ធជាមួយកត្តាខាងក្រៅ ឬការជះឥទ្ធិពលពីខាងក្រៅដែលអាចប៉ះពាល់ដល់អង្គភាពនោះផ្ទាល់ ឬ ដោយប្រយោលក្នុងនាមជាឱកាស ឬការគម្រាមកំហែង (Pickton and Wright, 1998)។ កត្តាពីរខាងក្រៅនេះជាទូទៅគឺជាអ្វីដែលអង្គភាពនោះមានលទ្ធភាពតិចតួច ឬពុំមានលទ្ធភាពគ្រប់គ្រងលើរឿងទាំងនោះឡើយ។ ឧទាហរណ៍ដូចជា និន្នាការទីផ្សារ បម្រែបម្រួលសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ និន្នាការហិរញ្ញវត្ថុនៅថ្នាក់ជាតិ និងអន្តរជាតិ កម្រិតមូលនិធិ ការប្រែប្រួលផ្នែកប្រជាសាស្ត្រដូចជា ការកើនឡើងនៃចំនួនប្រជាជនវ័យចំណាស់ ស្ថេរភាពនយោបាយ និងស្ថានភាពបរិស្ថានជាដើម។

ការវិភាគបរិស្ថានគឺជាផ្នែកដ៏ចាំបាច់ខ្វះមិនបាននៃដំណើរការធ្វើផែនការជាយុទ្ធសាស្ត្រ។ ក្របខ័ណ្ឌការងារ SWOT តែងតែបានប្រើប្រាស់ដោយអង្គការជាច្រើនដើម្បីកំណត់រក និងចាត់ប្រភេទកត្តាបរិស្ថានគួរជាទីកត់សម្គាល់ទាំងនៅខាងក្នុងអង្គភាព និងនៅខាងក្រៅអង្គភាព។ ថ្វីបើ SWOT ត្រូវបានទទួលយកយ៉ាងទូលំទូលាយអង្គភាពអាជីវកម្មក្តី ប៉ុន្តែការប្រើប្រាស់ក្របខ័ណ្ឌការងារនេះត្រូវបានទទួលយកដោយពុំមានការរិះគន់។ ក្របខ័ណ្ឌការងារ SWOT គឺជាឧបករណ៍មុខពីរដែលអាចនាំឱ្យមានកំហុសជាយុទ្ធសាស្ត្រ។ដូច្នេះគំហើញដែលបានទទួលពីការវិភាគ SWOT ត្រូវបានប្រើប្រាស់ដោយប្រុងប្រយ័ត្នក្នុងនាមជាដំណើរការគ្រប់គ្រងទំនាក់ទំនងដែលមានលក្ខណៈបត់បែន។

ការវិភាគ SWOT ដែលបានបង្ហាញជូនក្នុងរបាយការណ៍នេះគឺផ្អែកលើការពិនិត្យឡើងវិញនៃការសិក្សាលើការផ្សព្វផ្សាយកសិកម្មដែលធ្លាប់បានធ្វើកន្លងមកក្នុងប្រទេសកម្ពុជាដោយអ្នកនិពន្ធរូបនេះ របាយការណ៍វិភាគ SWOT រៀបចំដោយ Dr. Norman Welsh ជាទីប្រឹក្សារបស់កម្មវិធី ASPIRE កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៧ និងយោបល់ត្រឡប់បានមកពីសិក្ខាកាមក្នុងសិក្ខាសាលាថ្នាក់ជាតិអភិវឌ្ឍយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្ម និងការពិភាក្សាក្រុមធ្វើឡើងនៅថ្ងៃទី២៤-២៦ ខែធ្នូ ឆ្នាំ២០១៧។ សិក្ខាកាមក្នុងសិក្ខាសាលាទាំងពីរមកពីតំបន់

ផ្សេងៗក្នុងប្រទេស ហើយក្នុងនោះរួមមានទាំងមន្ត្រីផ្សព្វផ្សាយ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ វិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនផងដែរ។

ការពិនិត្យឡើងវិញលើឯកសារនានាបង្ហាញឱ្យឃើញថា មានការកើនឡើងជាបណ្តើរៗនូវចំនួនភ្នាក់ងារផ្សព្វ ផ្សាយកសិកម្មសាធារណៈ សមាមាត្រភ្នាក់ងារផ្សព្វផ្សាយកសិកម្មធៀបនឹងចំនួនកសិករមានអត្រាខ្ពស់ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មពុំមានវត្តមាននៅក្នុងស្រុកជាច្រើនភ្នាក់ងារផ្សព្វផ្សាយកសិកម្មបានទទួលការបណ្តុះបណ្តាលតិចតួចហើយពួកគាត់នៅខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសជាមូលដ្ឋានស្តីពីដំណើរការនៃការផ្សព្វផ្សាយកសិកម្ម (Suvedi & Sarom, 2017; MAFF, 2015; Welsh, 2017)។ ថវិកាមិនគ្រប់គ្រាន់ ការគាំទ្រផ្នែកស្ថាប័នអន់ខ្សោយនិងល័ក្ខខ័ណ្ឌការងារមិនសូវល្អសម្រាប់បុគ្គលិកនៅថ្នាក់មូលដ្ឋានជារឿយៗត្រូវបានលើកឡើងថា ជាឧបសគ្គដែលសេវាផ្សព្វផ្សាយកសិកម្មត្រូវជួបប្រទះ។

គំហើញពីការវិភាគ SWOT ធ្វើឡើងក្នុងខែតុលា ឆ្នាំ២០១៧ បញ្ជាក់ឱ្យឃើញថា ចំណុចខ្លាំងនៃសេវាផ្តល់មូលនិធិដោយវិស័យសាធារណៈគឺពាក់ព័ន្ធជាមួយរចនាសម្ព័ន្ធនិងបរិស្ថានរបស់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ប៉ុន្តែនៅកន្លែងដែលពុំមានរចនាសម្ព័ន្ធទាំងនេះទេ ឬមានរចនាសម្ព័ន្ធទាំងនេះខ្សត់ខ្សោយ បញ្ហាដដែលនេះពេលខ្លះក៏ត្រូវបានមើលឃើញថា ជាចំណុចខ្សោយផងដែរ។ **ចំណុចខ្លាំងជាក់លាក់រួមមានដូចជា** គោលនយោបាយផ្សព្វផ្សាយកសិកម្មថ្មីដែលបច្ចុប្បន្នត្រូវបានអនុម័តរួច មានបុគ្គលិកខ្លះ មានថវិកាគាំទ្រ ហើយក៏មានសម្ភារៈបណ្តុះបណ្តាលមួយចំនួនរួចហើយដែរ។ ទំនាក់ទំនងរវាង អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងអ្នកបង្កើតផ្នែកបច្ចេកវិទ្យាពោលគឺទីភ្នាក់ងារស្រាវជ្រាវនានាដូចជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា (CARDI) គឺជាចំណុចខ្លាំង ប៉ុន្តែកង្វះយន្តការដើម្បីប្រែក្លាយលទ្ធផលការស្រាវជ្រាវឱ្យក្លាយទៅជាសារសម្រាប់កសិករគឺជាចំណុចខ្សោយ។ ចំណុចខ្លាំងដទៃទៀតដែលសិក្ខាកាមក្នុងសិក្ខាសាលាបានលើកឡើងរួមមានដូចជា ការមានប្រព័ន្ធព័ត៌មានវិទ្យា (ICT) និងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍក្នុងបណ្តាខេត្តជាច្រើន។ វត្តមានរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ (CEWs) និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) ក្នុងស្រុកមួយចំនួនបាននាំយកកសិករឱ្យខិតកាន់តែជិតជាមួយការផ្សព្វផ្សាយកសិកម្ម។ បើទោះបីជាក្នុងករណីខ្លះ CEW ពុំមែនជាបុគ្គលិកស្ថិតក្រោមទីប្រឹក្សាឃុំក្តី ប៉ុន្តែប្រព័ន្ធរដ្ឋាភិបាលជារឿយៗនៅតែមានការគ្របដណ្តប់ទូទាំងប្រទេសចុះទៅដល់ថ្នាក់ស្រុកផងដែរ។

**នៅផ្នែកចំណុចខ្សោយ** បញ្ហាជាក់លាក់ចំនួនពីរត្រូវបានកំណត់ឃើញពោលគឺ កង្វះប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃល្អ និងកង្វះលទ្ធភាពធ្វើផែនការបែបការចូលរួមដែលចាំបាច់ត្រូវឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កសិករ។ មានកង្វះខាតភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក។ ថ្វីបើមានសេវាអ៊ីនធើណេតនៅទូទាំងប្រទេសក្តី ប៉ុន្តែគេហទំព័រផ្សព្វផ្សាយកសិកម្មដែលមានព័ត៌មានគួរជាទីទុកចិត្តបានគឺនៅមិនទាន់បានអភិវឌ្ឍ ឬធ្វើឱ្យមានបច្ចុប្បន្នភាពនៅឡើយទេ ជាពិសេសគឺលទ្ធផលនៃការស្រាវជ្រាវនានាពុំបានទៅដល់ដៃរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឡើយ។

**នៅត្រង់ចំណុចឱកាស** ការផ្សព្វផ្សាយកសិកម្មអាចទាញយកប្រយោជន៍ដោយងាយស្រួលពីគោលនយោបាយ និងនីតិវិធីរបស់បណ្តាប្រទេសសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ដើម្បីធ្វើឱ្យការផ្តល់សេវារបស់ខ្លួនកាន់តែសម្បូរបែបថែមទៀត។ នៅខ្សែជួរមុខថ្នាក់ជាតិ ការផ្សព្វផ្សាយកសិកម្មអាចទាញយកប្រយោជន៍ ពីវត្តមាននៃការផ្សព្វផ្សាយរបស់វិស័យឯកជន ដើម្បីឱ្យអាចផ្តល់សេវាប្រកបដោយប្រសិទ្ធភាពថែមទៀតជូនដល់កសិករ។

ការប្រែប្រួលអាកាសធាតុត្រូវបានសិក្ខាកាមក្នុងសិក្ខាសាលាចាត់ទុកថាជាឧបសគ្គ (Treat)។ ថ្វីបើមានវត្តមានការផ្សព្វផ្សាយរបស់វិស័យឯកជនដោយមានការគាំទ្រពី INGOs/NGOs និងអ្នកផ្គត់ផ្គង់ធាតុចូលពាណិជ្ជកម្មនិងអ្នកទិញផលិតផលកសិកម្មត្រូវបានមើលឃើញថាជាឧបសគ្គចំពោះប្រព័ន្ធសាធារណៈ។ ជាចុងក្រោយតែងតែមានឧបសគ្គផ្នែកនយោបាយថ្វីបើស្ថានភាពនយោបាយជាទូទៅហាក់មានស្ថេរភាពក្តី។

ការផ្សព្វផ្សាយកសិកម្មរបស់វិស័យឯកជនមាន**ចំណុចខ្លាំង**នៅត្រង់សមត្ថភាពរបស់វិស័យនេះ ដែលអាចបត់បែនបាន និងផ្តោតគោលដៅសេវារបស់ខ្លួន។ វិស័យនេះបានបង្កើតជាចំណងតភ្ជាប់ដ៏រឹងមាំជាមួយកសិករដែលខ្លួនបម្រើឱ្យ។ បុគ្គលិកមានមូលនិធិសម្រាប់ការធ្វើដំណើរ។ សមាមាត្រនៃភ្នាក់ងារផ្សព្វផ្សាយកសិកម្មធៀបជាមួយចំនួនកសិករ មានអត្រាទាបជាងសេវាផ្តល់ដោយរដ្ឋាភិបាលយ៉ាងខ្លាំង។ ចំណុចខ្សោយដ៏ធំគឺនៅក្នុងវិស័យគុណវុឌ្ឍរបស់បុគ្គលិកពោលគឺ បុគ្គលិកទាំងអស់នេះជារឿយៗតែងមានគុណវុឌ្ឍទាបជាងទីភ្នាក់ងារផ្សព្វផ្សាយកសិកម្មរបស់រដ្ឋាភិបាល។ **ចំណុចខ្សោយចម្បង**គឺ NGOs មានភាពប្រែប្រួល ពោលគឺ គម្រោងផ្តល់មូលនិធិដោយម្ចាស់ជំនួយអាចមានវត្តមានសម្រាប់រយៈពេលមានកម្រិតកំណត់ ហើយភ្នាក់ងារផ្សព្វផ្សាយកសិកម្មអាចផ្លាស់ចេញពីតំបន់នោះក្រោយពេលគម្រោងបញ្ចប់។

ប៉ុន្តែនៅមានឱកាសសម្រាប់សេវាផ្សព្វផ្សាយកសិកម្មរបស់វិស័យឯកជន។ រដ្ឋាភិបាលបានទទួលស្គាល់វត្តមានរបស់ពួកគេ ហេតុនេះអនុញ្ញាតឱ្យអ្នកផ្តល់សេវាអាចពង្រីកពីសកម្មភាពដែលផ្សារភ្ជាប់ជាមួយការទិញ និងការលក់ផលិតផលឈានទៅបង្កើតប្រព័ន្ធផ្តល់ប្រឹក្សាយោបល់ឯករាជ្យអំពីការលក់។ ឱកាសសម្រាប់ការពង្រីកក៏ត្រូវបានសម្របសម្រួលដោយគោលនយោបាយរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មផងដែរ។

វិស័យឯកជនក៏មើលឃើញថា ការប្រែប្រួលអាកាសធាតុគឺជាឧបសគ្គផងដែរ។ សមត្ថភាពរបស់កសិករក្នុងការបង់ថ្លៃសេវាផ្សព្វផ្សាយកសិកម្ម ក៏អាចឧបសគ្គចំពោះការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយកសិកម្មក្នុងវិស័យឯកជនប្រកបដោយនិរន្តរភាពផងដែរ។ ម្យ៉ាងវិញទៀតគម្រោងអភិវឌ្ឍរបស់ NGO បានជួបប្រទះបញ្ហាថយចុះមូលនិធិ ជាពិសេសមូលនិធិដែលផ្តល់ដោយរដ្ឋាភិបាលបរទេស។ ជាចុងក្រោយបរិយាកាសនយោបាយក្នុងប្រទេសកម្ពុជាក៏អាចប៉ះពាល់ដល់ NGOs ផងដែរដោយអាជ្ញាធរមូលដ្ឋានអាចបដិសេធ ឬដកការអនុញ្ញាតមិនឱ្យរៀបចំកិច្ចប្រជុំជាមួយសហគមន៍កសិកម្ម បើទោះបីជាការពិភាក្សានោះពុំមានខ្លឹមសារនយោបាយក្តី។

ការរកឃើញដែលត្រូវបានរាយការណ៍ពីប្រភពព័ត៌មានខាងលើត្រូវបានសំយោគ និងបង្ហាញជូនតារាងទី៣ខាងក្រោម។

## តារាងទី ៣. សង្ខេបអំពីគំហើញ SWOT[1]

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| ▪ មានរចនាសម្ព័ន្ធកាផ្សព្វផ្សាយកសិកម្មពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ<br>▪ មានគោលនយោបាយផ្សព្វផ្សាយកសិកម្មថ្មី (ប្រកាសលេខ ២២០ បានចេញជាមួយឯកសារផ្លូវច្បាប់ និងគោលការណ៍ណែនាំនានា)<br>▪ មានការគាំទ្រពីគ្រឹះស្ថានបណ្តុះបណ្តាល ស្រាវជ្រាវ និងការិយាល័យជំនាញ<br>▪ CEWs និងVEWs កំពុងប្រតិបត្តិការនៅថ្នាក់មូលដ្ឋាននៅក្បែរអតិថិជនជាកសិករ<br>▪ បុគ្គលិកយល់ពីការងារអភិវឌ្ឍន៍ជនបទ និងតួនាទីនៃការផ្សព្វផ្សាយដែលត្រូវនឹងតម្រូវការរបស់សហគមន៍<br>▪ បុគ្គលិកមានលទ្ធភាពទទួលបានកម្មវិធីបណ្តុះបណ្តាលក្នុងកន្លែងធ្វើការ និងពេលកំពុងបំពេញការងារល្អ<br>▪ បុគ្គលិកទើបចូលបំពេញការងារមានសមត្ថភាពអនុវត្តការងារ<br>▪ មានធនធានស្ទើរតែល្អទាំងអស់<br>▪ កម្មវិធីនានាមានភាពរស់រវើកក្នុងការតម្រូវជាមួយការផ្លាស់ប្តូរនូវសេចក្តីត្រូវការ និងកត្តាបរិស្ថាន<br>▪ មានសម្ភារៈព័ត៌មានវិទ្យា ហើយកំពុងបានប្រើប្រាស់<br>▪ មានការគាំទ្រពីក្រុមប្រឹក្សាឃុំក្នុងការរៀបចំវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន<br>▪ មានបុគ្គលិកដែលមានការប្តេជ្ញាចិត្តលើការងារការផ្សព្វផ្សាយ។ | ▪ ខ្វះនូវធនធានមនុស្សផ្សព្វផ្សាយនៅក្នុងស្រុក និងខេត្ត<br>▪ ភ្នាក់ងារផ្សព្វផ្សាយឃុំ (CEWs) មិនគ្រប់គ្រាន់នៅក្នុងខេត្តមួយចំនួន<br>▪ ការគ្រប់គ្រងរបៀបពីលើចុះក្រោមបានធ្វើឱ្យមានភាពយឺតយ៉ាវនវានុវត្តន៍នៅទីវាល<br>▪ តួនាទី និងភារកិច្ចនៃការិយាល័យផ្សព្វផ្សាយមិនទាន់ឯកភាពគ្នា និងមិនស្របតាមគោលនយោបាយផ្សព្វផ្សាយកសិកម្ម<br>▪ យឺតយ៉ាវធ្វើការផ្លាស់ប្តូរទៅរកប្រព័ន្ធថ្មី ឬជម្រុញបច្ចេកវិទ្យាថ្មី<br>▪ លក្ខខណ្ឌការងារបានរារាំងដោយសារបទបញ្ញត្តិសេវាសាធារណៈ<br>▪ ការិយាធិបតេយ្យជាមួយនឹងបណ្តាញទំនាក់ទំនងវែងឆ្ងាយ<br>▪ ខ្វះការត្រួតពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់ការផ្សព្វផ្សាយ ការធ្វើរបាយការណ៍មិនបានល្អ<br>▪ ខ្វះថវិកាសម្រាប់ការលើកំពស់បច្ចេកវិទ្យាថ្មី<br>▪ ធនធានមិនបានបែងចែកស្មើៗគ្នារវាងខេត្ត គ្មានសម្ភារៈប្រកបដោយស្តង់ដា<br>▪ ខ្វះមជ្ឈមណ្ឌលបណ្តុះបណ្តាលការផ្សព្វផ្សាយ និងបង្ហាញនូវបច្ចេកវិទ្យាកសិកម្មសម្រាប់តំបន់ខ្ពង់រាប និងតំបន់ឆ្នេរ<br>▪ ខ្វះសម្ភារៈផ្សព្វផ្សាយដែលជឿទុកចិត្តបាន<br>▪ ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតសម្រាប់ព័ត៌មានវិទ្យាមិនមានលក្ខណៈល្អប្រសើរ ហើយទូរស័ព្ទចល័តមិនអាចប្រើប្រាស់បាននៅគ្រប់ភូមិ<br>▪ ការសហការជាមួយវិស័យឯកជនមានដែនកំណត់ ហើយផ្សេងៗពីគ្នាជាមួយនឹងបុគ្គលិកមាន |

[1] ខ្លឹមសារក្នុងតារាងនេះគឺដកស្រង់ចេញពី Welsh (2017) និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (2017)។

| | |
|---|---|
| | លក្ខណៈផ្សេងៗគ្នា<br>▪ សមាជិកបុគ្គលិកត្រូវមានការត្រួតពិនិត្យយ៉ាងដិតដល់<br>▪ សង្កត់ធ្ងន់លើការធ្វើកសិកម្មសម្រាប់ចិញ្ចឹមជីវិតជាជាងការធ្វើកសិកម្មតម្រូវតាមទីផ្សារ។ |
| **ឱកាស** | **ឧបសគ្គ** |
| ▪ ពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើការងារ<br>▪ ឱកាសធ្វើការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន<br>▪ តភ្ជាប់ទៅវេទិកាកសិករជាស្ត្រីថ្នាក់ជាតិ ក្រុមកសិករ ហើយសហគមន៍កសិករអាចសម្របសម្រួលក្នុងការចែកចាយព័ត៌មាន<br>▪ វិមជ្ឈការក្នុងការផ្តល់សេវាផ្សព្វផ្សាយដោយផ្ទាល់តាមរយៈភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន<br>▪ ធ្វើឲ្យប្រសើរឡើងនូវកិច្ចសហការ និងប្រសិទ្ធភាពតាមរយៈការរៀបចំឡើងវិញរបស់នាយកដ្ឋាន<br>▪ ផ្តួចផ្តើមឱ្យមានកម្មវិធី និងសេវាផ្សព្វផ្សាយសម្រាប់ការកែទម្រង់កសិកម្ម ដូចជាកម្មវិធីធ្វើពាណិជ្ជូបនីយកម្ម និងកម្មវិធីស្តារឡើងវិញនូវការចំណាយ<br>▪ ការផ្លាស់ប្តូរការចាប់អារម្មណ៍ ដើម្បីបញ្ចូលការធ្វើកសិកម្មទៅជាអាជីវកម្មមួយ និងមិនគ្រាន់តែនៅលើបច្ចេកវិទ្យា<br>▪ ធ្វើឱ្យមានលក្ខណៈផ្តោតលើតម្រូវការកសិករ និងឆ្លើយតបតាមទីផ្សារឱ្យបានកាន់តែច្រើនឡើង<br>▪ សម្របសម្រួលឲ្យមានការរៀនសូត្រពីកសិករទៅកសិករ និងប្រើប្រាស់ វិធីសាស្ត្រកសិករគំរូសម្រាប់ការផ្សព្វផ្សាយកសិកម្ម<br>▪ ពង្រីកCEW ទៅដល់គ្រប់ឃុំទាំងអស់ដូច្នេះកសិករទាំងអស់ដែលមកពីប្រភពជិតៗអាចទំនាក់ទំនងបាន។ | ▪ ការយល់ដឹងមិនគ្រប់គ្រាន់ពីការប្រែប្រួលអាកាសធាតុ ដើម្បីផ្តល់នូវធនធាន<br>▪ អំពើពុករលួយកាត់បន្ថយនូវធនធាន<br>▪ សមាជិកបុគ្គលិកដែលមានសមត្ថភាពខ្ពស់ទៅបម្រើការងារឱ្យអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន<br>▪ ប្រាក់បៀវត្សរ៍តិចអាចនាំឱ្យភ្នាក់ងារផ្សព្វផ្សាយខ្លះរកផលចំណេញពីកសិករ<br>▪ ភ្នាក់ងារផ្សព្វផ្សាយមើលឃើញឱកាសវិនិយោគសម្រាប់ខ្លួនពួកគេជាជាងសម្រាប់សហគមន៍កសិកម្ម<br>▪ ការបង្វែរបុគ្គលិកទៅធ្វើសកម្មភាពនយោបាយនៅពេលដែលពេលវេលាបោះឆ្នោតកើតឡើង<br>▪ បរិយាកាសម៉ាក្រូសេដ្ឋកិច្ច និងនយោបាយ គ្មានស្ថេរភាព<br>▪ ម្ចាស់ជំនួយនឿយណាយ<br>▪ ការកាត់បន្ថយបុគ្គលិក ដែលចាប់ផ្តើមពីកម្រិតថ្នាក់ក្រោម (ពួកគេទាំងនោះជាអ្នកមានទំនាក់ទំនងជាមួយកសិករ)<br>▪ ខ្វះហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវ ប្រព័ន្ធធារាសាស្ត្រ។ល។<br>▪ ចំណាកស្រុករបស់យុវជនទៅកាន់តំបន់ទីក្រុង កសិករមានវ័យកាន់តែចាស់ និងប្រជាជនមានលក្ខណៈជនបទ<br>▪ កង្វះកិច្ចសហប្រតិបត្តិការពីអាជ្ញាធរមូលដ្ឋានមួយចំនួន<br>▪ ទំនាស់ផលប្រយោជន៍រវាងស្ថាប័ន។ |

ផ្អែកលើលទ្ធផលនៃការវិភាគ SWOT និងការពិភាក្សាក្រុមស្តីពីយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្មរយៈពេលប្រាំឆ្នាំ (២០១៩-២០២៣) អនុសាសន៍ខាងក្រោមនេះត្រូវបានធ្វើឡើងសម្រាប់ការពិចារណាធ្វើផែនការសកម្មភាពយុទ្ធសាស្ត្រៈ

- ស្នើសុំធនធានថ្មីៗសម្រាប់ការផ្សព្វផ្សាយកសិកម្មពីរាជរដ្ឋាភិបាលកម្ពុជា និងបង្កើតទំនាក់ទំនង ការងារជាមួយដៃគូអភិវឌ្ឍដើម្បីប៉ះប៉ូវសងបញ្ហាកង្វះខាតថវិកា
- ជ្រើសរើសបុគ្គលិកថ្មីៗឱ្យចូលមកធ្វើការ និងផ្តល់ការបណ្តុះបណ្តាលក្នុងពេលបំពេញសេវាលើវិស័យប្រធានបទផ្សេងៗសម្រាប់បុគ្គលិកនាពេលបច្ចុប្បន្នដើម្បីឆ្លើយតបបញ្ហាកង្វះខាតធនធានមនុស្សប្រកបដោយគុណភាព
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មដើម្បីតំណាងឱ្យតំបន់ អាកាសធាតុ ភូមិសាស្ត្រ ធំៗក្នុងប្រទេសកម្ពុជា។ គ្រឿងបរិក្ខារទាំងនេះគួរបង្ហាញអត្ថប្រយោជន៍ក្នុងការទទួលយកបច្ចេកវិទ្យាថ្មីៗ និងដើរតួនាទីជាទីកន្លែងផ្តល់កម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់
- អភិវឌ្ឍឱ្យមានសម្ភារៈនិងឯកសារផ្សព្វផ្សាយកសិកម្មគួរជាទីទុកចិត្តមានគុណភាពខ្ពស់(ផ្ទាំងបដា កូនសៀវភៅ ព្រឹត្តិបត្របច្ចេកទេស វីឌីអូ និងធនធានតាមគេហទំព័រ) ដែលសមស្របតាមសេចក្តីត្រូវរបស់កសិករក្នុងមូលដ្ឋាន
- បង្កើតគោលការណ៍ណែនាំច្បាស់លាស់សម្រាប់វាយតម្លៃបុគ្គលិក និងដំឡើងឋានៈ
- ផ្តួចផ្តើមឱ្យមានប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃមានឯកភាពគ្នាមួយសម្រាប់ការផ្សព្វផ្សាយកសិកម្ម និងធ្វើឱ្យការពិនិត្យតាមដាននិងវាយតម្លៃឯកភាពគ្នានេះក្លាយជាការតម្រូវមួយចាំបាច់សម្រាប់ដៃគូទាំងក្នុងវិស័យសាធារណៈនិង NGO/ឯកជន
- អភិវឌ្ឍកម្មវិធីអប់រំដើម្បីទាក់ទាញយុវជនជនបទឱ្យទៅសិក្សាផ្នែកកសិកម្មជាជំនាញវិជ្ជាជីវៈ។ លើកទឹកចិត្តយុវជនវ័យក្មេងឱ្យជាអ្នកដឹកនាំរបស់សហគមន៍កសិកម្ម
- ផ្តោតការយកចិត្តទុកដាក់លើការកែលម្អគុណភាពផលិតកម្មក្នុងមូលដ្ឋានតាមរយៈការប្រើប្រាស់ធនធានឱ្យបានប្រសើរដើម្បីកាត់បន្ថយតម្រូវការផលិតផលនាំចូល
- លើកកម្ពស់វិធីសាស្ត្រច្នៃប្រឌិតបង្កើតថ្មីដើម្បីផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារ ឧ.លើកកម្ពស់ការធ្វើកសិកម្មតាមកិច្ចសន្យា និង/ឬតាមរយៈការបន្ថែមតម្លៃទៅលើផលិតផលកសិកម្ម
- ព្យាយាមអនុវត្តការដាក់បញ្ចូលយេនឌ័រ ទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃសេវាផ្សព្វផ្សាយកសិកម្មជាការផ្តួចផ្តើមគំនិត កំណែទម្រង់ស្ថាប័នដ៏ធំមួយ
- អភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ឃុំ និងថ្នាក់ភូមិ (ដូចជា ប្រធាន និងអនុប្រធាន) ដើម្បីជួយជ្រោមជ្រែងក្នុងការលើកកម្ពស់ និងការសហការជាមួយកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានា
- បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មនៅថ្នាក់តំបន់ ឬថ្នាក់ខេត្ត ចងក្រងរឿងជោគជ័យដើម្បីចែករំលែកជាមួយកសិករ និងបង្កើតវេទិកាសាធារណៈដើម្បីសម្របសម្រួលដល់ការបញ្ជូនសារទៅដល់កសិករ
- គំហើញពីការវិភាគ SWOT មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយបញ្ហាប្រឈមដែលសេវាផ្សព្វផ្សាយកសិកម្មកំពុងជួបប្រទះ ហើយដែលមានផលប៉ះពាល់ដោយផ្ទាល់ទៅលើយុទ្ធសាស្ត្រ PAEC ។ ហេតុនេះយើងបានដាក់បញ្ចូលមតិយោបល់ និង អនុសាសន៍ក្នុងការអភិវឌ្ឍផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍ PAEC ។

## ក្របខ័ណ្ឌការងារផែនការសកម្មភាពយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្ម

សេវាផ្សព្វផ្សាយកសិកម្មតួនាទីដ៏ចាំបាច់ខ្វះមិនបានក្នុងការចែករំលែកចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាជាមួយកសិករ និងអ្នកដើរតួនាទីដទៃទៀតក្នុងសេដ្ឋកិច្ច។ ចំណេះដឹងអំពីបច្ចេកវិទ្យា និងការអនុវត្តថ្មីៗមានភាពចាំបាច់ណាស់ សម្រាប់ការទទួលយកបច្ចេកវិទ្យាក្នុងទ្រង់ទ្រាយធំពីសំណាក់ប្រជាកសិករ។ ហេតុនេះ សេវាផ្សព្វផ្សាយកសិកម្មជួយដល់ការប្រែក្លាយកសិកម្មយថាផលទៅការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្មបានយ៉ាងចាំបាច់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់សេវាផ្សព្វផ្សាយកសិកម្មជូនដល់ប្រជាកសិករ។ ក្រសួងមើលការខុសត្រូវនិងធ្វើនិយ័តកម្មលើសេវាផ្សព្វផ្សាយកសិកម្មគ្រប់ប្រភេទដែលផ្តល់ដោយស្ថាប័នសាធារណៈដៃគូអភិវឌ្ឍ និងវិស័យឯកជន។ រូបភាពទីមួយខាងក្រោមបង្ហាញរចនាសម្ព័ន្ធ សេវាផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា។

**រូបភាពទី ១៖ រចនាសម្ព័ន្ធការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា។ (ប្រភព៖** MAFF, 2015)



គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា អំពាវនាវឱ្យមានសេវាផ្សព្វផ្សាយកសិកម្មដែលជម្រុញដោយតម្រូវការ មានលក្ខណៈវិមជ្ឈការ និងមានលក្ខណៈចូលរួមដែលអនុវត្តតាមគំរូការផ្តល់សេវាបែបពហុនិយម មានការសម្របសម្រួលអម។ PAEC កំណត់ឃើញ និងពិពណ៌នាកំណែទម្រង់ ឬកែលម្អសេវាផ្សព្វផ្សាយកសិកម្ម (MAFF, 2015)។

ផែនការសកម្មភាពយុទ្ធសាស្ត្រ (SAP) សម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មចាំបាច់ត្រូវឆ្លើយតបបញ្ហាប្រឈមសំខាន់ៗដែល ការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជាកំពុងជួបប្រទះ។ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មត្រូវមានចំណងទាក់ទងយ៉ាងរឹងមាំរវាងកសិករ អ្នកស្រាវជ្រាវ និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មចាំបាច់ត្រូវដើរតាមយុទ្ធវិធីដែលមានការសម្របសម្រួលល្អ មានលក្ខណៈវិមជ្ឈការ ជម្រុញដល់ទីផ្សារ និងមានលក្ខណៈចូលរួម។ ម្យ៉ាងទៀតការផ្តល់សេវានេះចាំបាច់ត្រូវដើរតាមគំរូការផ្តល់សេវាបែបពហុនិយម មានន័យថាចាំបាច់ត្រូវលើកកម្ពស់ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជននៅក្នុងការផ្តល់សេវា។ ជាចុងក្រោយ SAP ចាំបាច់ត្រូវបន្សុីចក្នុវិស័យរបស់ខ្លួនជាមួយផែនការមេកសិកម្មឆ្នាំ ២០៣០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយត្រូវបង្កើតល័ក្ខខ័ណ្ឌសម្រាប់ការអភិវឌ្ឍ PAEC ប្រកបដោយប្រសិទ្ធភាព។ផែនការសកម្មភាពជាយុទ្ធសាស្ត្រដែលក្របខ័ណ្ឌការងារសម្រាប់ពង្រឹងសេវាផ្សព្វផ្សាយកសិកម្មគឺមានបង្ហាញជូនក្នុងរូបភាពទី២ ខាងក្រោម។

## រូបភាពទី ២៖ ក្របខ័ណ្ឌការងារយុទ្ធសាស្ត្រដើម្បីពង្រឹងការផ្សព្វផ្សាយកសិកម្ម




ក្របខ័ណ្ឌការងារខាងលើទទួលស្គាល់ថា ក្របខ័ណ្ឌការងារផ្នែកស្ថាប័ន និងផ្នែកច្បាប់គឺជាស្នូលដ៏ចាំបាច់នៃសេវាផ្សព្វផ្សាយកសិកម្ម ហេតុនេះការបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ភាគីពាក់ព័ន្ធ និងការរៀបចំរចនាសម្ព័ន្ធនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម(DAE) មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (PDAFF) និងការិយាល័យកសិកម្មស្រុកឡើងវិញដោយដាក់ឱ្យមានតួនាទី និងការទទួលខុសត្រូវថ្មីៗ គឺជាការងារដ៏ចាំបាច់។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ត្រូវគោរពតាមរចនាសម្ព័ន្ធស្ថាប័នបែបវិមជ្ឈការ ដើម្បីកែលម្អការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ អគ្គនាយកដ្ឋានកសិកម្ម (GDA) និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ចាំបាច់ត្រូវពុះពារដើម្បីផ្សារភ្ជាប់កសិករ/អង្គការកសិករ (FOs) ជាមួយអ្នកស្រាវជ្រាវផ្នែកកសិកម្ម និងទីផ្សារដោយប្រើប្រាស់វិធីសាស្ត្រ និងយុទ្ធវិធីច្នៃប្រឌិតបង្កើតថ្មីដែលមានលក្ខណៈច្នៃប្រឌិតបង្កើតថ្មី។ សម្ភារៈអប់រំ និងឯកសារបោះពុម្ពផ្សាយដែលមានព័ត៌មានបច្ចុប្បន្នភាពថ្មីៗដែលចាំបាច់ត្រូវបង្កើតឡើង និងផ្សព្វផ្សាយ។ ប្រទេសកម្ពុជាចាំបាច់ត្រូវទាញយកប្រយោជន៍ពីវិធីសាស្ត្រផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ដែលមានលក្ខណៈបង្កើតថ្មីដូចជា ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង (ICTs) សាលារៀនស្រែកសិករ និងវាលស្រែបង្ហាញនៅវាលស្រែរបស់កសិករក្នុងមូលដ្ឋាន។ ការងារនេះទាមទារជាចាំបាច់ឱ្យមានធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាលល្អ។ ហេតុនេះផែនការសកម្មភាពជាយុទ្ធសាស្ត្រត្រូវឆ្លើយតបចំពោះបញ្ហាប្រឈមសំខាន់ៗ តាមរយៈការផ្តល់ការពិពណ៌នាច្បាស់លាស់អំពីយន្តការនិងរចនាសម្ព័ន្ធទាំងអស់ដែលចាំបាច់សម្រាប់ការអនុវត្តPAEC ប្រកបដោយប្រសិទ្ធភាព។ រូបភាពទី ៣ បង្ហាញឱ្យឃើញនូវក្របខ័ណ្ឌការងារទូទៅសម្រាប់អនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាពក្នុងប្រទេស

កម្ពុជា។ ក្របខ័ណ្ឌការងារនេះរួមមានវិធានការផ្នែកគោលនយោបាយ ឬយុទ្ធសាស្ត្រសកម្មភាពដែលគាំទ្រដល់សេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈវិមជ្ឈការ ផ្អែកតាមសេចក្តីត្រូវការជាក់លាក់ ជម្រុញដោយទីផ្សារនិងមានលក្ខណៈចូលរួមដើម្បីសម្រេចបានគោលបំណងអភិវឌ្ឍកសិកម្មជាតិ។ បេសកម្ម គោលដៅ និងគោលបំណងត្រូវបានកែសម្រួលចេញពី Cummins (2017)។ ផែនការសកម្មភាពនេះត្រូវបានបន្សុីយ៉ាងជិតស្និទ្ធជាមួយយុទ្ធសាស្ត្រ PAEC និងផែនការមេកសិកម្មឆ្នាំ ២០៣០។

## ផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់ការអនុវត្ត PAEC

ការផ្សព្វផ្សាយកសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ សេវាផ្សព្វផ្សាយកសិកម្មចែករំលែកចំណេះដឹង បច្ចេកវិទ្យា និងព័ត៌មានថ្មីជាមួយកសិករ ហើយក៏ជួយតភ្ជាប់កសិករទៅកាន់អ្នកដើរតួនាទីដទៃទៀតនៅក្នុងសេដ្ឋកិច្ចផងដែរ។ហេតុនេះការផ្សព្វផ្សាយកសិកម្មគឺជាសេវាដ៏ចាំបាច់មួយសម្រាប់កែលម្អសន្តិសុខស្បៀងរបស់គ្រួសារក៏ដូចជាដើម្បីផ្លាស់ប្តូរកសិកម្មយថាផលទៅជាការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម។

តាំងពីដំបូងមក ការផ្សព្វផ្សាយកសិកម្មបានទទួលការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ហើយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាអ្នកទទួលបន្ទុកចម្បងក្នុងការពង្រីកសេវានេះជូនដល់ប្រជាកសិករ។ ទោះយ៉ាងណាក្តីក្នុងទសវត្សរ៍កន្លងមកនេះមានឧបសគ្គជាច្រើន ដែលបានរារាំងការបំពេញមុខងារយ៉ាងត្រឹមត្រូវរបស់ប្រព័ន្ធ និងសេវាផ្សព្វផ្សាយកសិកម្ម។ បញ្ហាប្រឈមសំខាន់ៗបំផុតរួមមានដូចជា៖ ការថមថយធនធានមនុស្ស ធនធានមូលធន និងធនធានហិរញ្ញវត្ថុសម្រាប់ការផ្សព្វផ្សាយកសិកម្មរបស់រដ្ឋដោយពុំមានធាតុចូលជាកិច្ចឆ្លើយតបពីវិស័យឯកជន ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មពហុនិយមដោយពុំមានសម្របសម្រួល និងការតភ្ជាប់យ៉ាងអន់ខ្សោយរវាងការស្រាវជ្រាវកសិកម្ម ការអប់រំ និងការបណ្តុះបណ្តាលផ្នែកកសិកម្ម សេវាផ្សព្វផ្សាយកសិកម្ម និងវិស័យឯកជន។

ដោយទទួលស្គាល់សារៈសំខាន់នៃសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីពង្រីកកំណើនកសិកម្មដើម្បីពង្រឹងការរីកលូតលាស់វិស័យកសិកម្មប្រកបដោយបរិយាប័ន្ន និងសន្តិសុខស្បៀងនិងសន្តិសុខអាហារូបត្ថម្ភ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រកាសឱ្យប្រើប្រាស់គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាឆ្នាំ២០១៥។ គោលនយោបាយថ្មីនេះអំពាវនាវឱ្យមានការផ្តល់សេវាដែលមានលក្ខណៈវិមជ្ឈការមានលក្ខណៈចូលរួមជម្រុញដោយតម្រូវនិងមានលក្ខណៈពហុនិយមតាមរយៈការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការកំណត់អំពីសេចក្តីត្រូវការក្នុងមូលដ្ឋាន ការផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់កម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលបានទទួលការបណ្តុះបណ្តាលល្អ និងត្រូវបានសម្របសម្រួលឱ្យអនុវត្តភារៈកិច្ចរបស់ខ្លួនមានសម្ភារៈផ្សព្វផ្សាយកសិកម្មប្រកបដោយគុណភាព មានការប្រាស្រ័យទាក់ទងជាប្រចាំរវាងភ្នាក់ងារផ្សព្វផ្សាយកសិកម្មជាមួយអង្គភាពទទួលបន្ទុកផ្នែកការស្រាវជ្រាវ និងបរិស្ថានអំណោយផល សម្រាប់អតិថិជនការផ្សព្វផ្សាយកសិកម្មឱ្យយល់ និងយកចំណេះដឹងដែលខ្លួនបានទទួលទៅអនុវត្ត។

ការពិនិត្យឡើងវិញទៅលើPAEC ការវិភាគSWOT និងក្របខ័ណ្ឌការងារយុទ្ធសាស្ត្រដើម្បីពង្រឹងសេវាផ្សព្វផ្សាយកសិកម្ម បានផ្តល់លទ្ធផលឱ្យកើតមានសមាសធាតុផែនការសកម្មភាពយុទ្ធសាស្ត្រទូលំទូលាយចំនួនប្រាំគឺ៖ ក្របខ័ណ្ឌការងារផ្នែកស្ថាប័ន និងផ្នែកច្បាប់ ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម ការ

ផ្តល់សេវាផ្សព្វផ្សាយដែលមានភាពប្រសើរឡើង ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម និងការតភ្ជាប់ការស្រាវជ្រាវ ការអប់រំ និងការផ្សព្វផ្សាយកសិកម្មសម្រាប់អភិវឌ្ឍបច្ចេកវិទ្យា។ ផ្នែកខាងក្រោមនេះពិពណ៌នាអំពីចក្ខុវិស័យ គោលដៅ គោលបំណង លទ្ធផលរំពឹងទុក និងផែនការសកម្មភាព ព្រមទាំងសកម្មភាពសម្រាប់សមាសធាតុនីមួយៗរបស់ផែនការសកម្មភាពយុទ្ធសាស្ត្រ។

## រូបភាពទី ៣៖ ក្របខ័ណ្ឌការងារផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម

| | |
|---|---|
| **ចក្ខុវិស័យ** | កសិករ និងសហគមន៍កសិកម្មទាំងអស់មានលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មមានគុណភាពខ្ពស់ដែលចាំបាច់សម្រាប់វិស័យកសិកម្មទំនើបដែលមានលក្ខណៈប្រកួតប្រជែងបរិយាប័ណ្ណធនទ្រាំ និងនិរន្តរភាពដើម្បីចូលរួមចំណែកចំពោះ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ |
| **បេសកកម្ម** | ដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មជម្រុញដោយតម្រូវការតាមរយៈការធ្វើឱ្យមានការចូលរួមពីអ្នកផ្តល់សេវាទាំងអស់រួមទាំង វិស័យសាធារណៈ វិស័យឯកជន សង្គមស៊ីវិល និងអង្គការកសិករដើម្បីចូលរួមចំណែកចំពោះសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ |
| **គោលដៅ** | ដើម្បីជួយជ្រោមជ្រែងកសិករ និងសហគមន៍កសិកម្មឱ្យមានលទ្ធភាពទទួលបាន និងទទួលយកបច្ចេកវិទ្យាកសិកម្មទំនើប និង នវានុវត្តដើម្បីពង្រឹងផលិតភាពកសិកម្ម ពិពិធភាព ការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ |
| **គោលបំណង** | • ដើម្បីកែលម្អប្រសិទ្ធភាពអង្គការផ្សព្វផ្សាយកសិកម្មទៅគ្រប់កម្រិតដើម្បីឱ្យអាចប្រតិបត្តិការ សហប្រតិបត្តិការ និងសម្របសម្រួលគ្នាប្រកបដោយប្រសិទ្ធភាព និងដើម្បីពង្រឹងការតភ្ជាប់រវាងភាគីពាក់ព័ន្ធទាំងអស់<br>• ដើម្បីកែសមត្ថភាពធនធានមនុស្សក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មជាកិច្ចឆ្លើយតបចំពោះសេចក្តីត្រូវការក្នុងមូលដ្ឋាន និងតម្រូវការទីផ្សារ<br>• ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាសមស្រប និងដើម្បីដាក់ឱ្យមានបច្ចេកវិទ្យាទាំងនោះជូនដល់កសិករ កសិករអាចទទួលយកបាន និងអាចយកទៅអនុវត្តបាន<br>• ដើម្បីអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម និងធ្វើឱ្យសម្ភារៈទាំងអស់នោះអាចមានសម្រាប់កសិករ និងភាគីពាក់ព័ន្ធផ្សព្វផ្សាយកសិកម្ម<br>• ដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាពក្នុងការកែលម្អការសម្រេចចិត្តរបស់កសិករ និងសហគមន៍កសិកម្មក្នុងការបង្កើនផលិតភាពកសិកម្ម ពិពិធភាព និងការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម។ |
| **យុទ្ធសាស្ត្រ** | • លើកកម្ពស់សេវាផ្អែកលើតម្រូវការ និងជម្រុញដោយតម្រូវការ<br>• ធ្វើវិមជ្ឈការការផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត & ថ្នាក់ស្រុក)<br>• សេវាពហុនិយមតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន<br>• ការតភ្ជាប់ការស្រាវជ្រាវ ការអប់រំ ការផ្សព្វផ្សាយកសិកម្ម និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា<br>• ពង្រឹងស្ថាប័នអប់រំ និងបណ្តុះបណ្តាលកសិកម្ម<br>• ប្រើប្រាស់វិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្ម<br>• បញ្ជ្រាបបញ្ហាអន្តរវិស័យ (យេនឌ័រ អាកាសធាតុ យុវជន។ល។)<br>• ពង្រឹងការផ្តល់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព |
| **ផែនការសកម្មភាព** | ១.ក្របខ័ណ្ឌការងារផ្អែកស្ថាប័ន/ច្បាប់<br>២.ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម<br>៣.ការតភ្ជាប់ការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា<br>៤.ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម<br>៥.ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម |

## ១. ការរៀបចំស្ថាប័ន និងក្របខ័ណ្ឌការងារផ្នែកច្បាប់

គោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា(PAEC)នឹងគាំទ្រដល់ប្រព័ន្ធផ្សព្វផ្សាយកសិកម្មដែលជម្រុញដោយតម្រូវការ មានលក្ខណៈចូលរួមមានលក្ខណៈវិមជ្ឈការ និងពហុនិយមដោយមានកិច្ចសហការយ៉ាងរឹងមាំរបស់ភាគីពាក់ព័ន្ធ និងស្ថាបនាបណ្តាញដើម្បីកសាងការប្រមូលផ្តុំកម្លាំង និងពង្រឹងប្រសិទ្ធផលក្នុងការប្រើប្រាស់ធនធាន។ ថ្វីបើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានត្រួសត្រាយគួរជាកត់សម្គាល់រួចហើយក្តី ប៉ុន្តែ PAEC នៅពុំទាន់បានប្រតិបត្តិការពេញលេញនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកនៅឡើយ។ ដើម្បីឱ្យ PAEC អាចមានប្រតិបត្តិការពេញលេញ ចាំបាច់ត្រូវមានការចូលរួមគាំទ្រពីរដ្ឋាភិបាលថ្នាក់ខេត្ត។

**គោលដៅ៖** ការស្ថាបនាឱ្យក្លាយទៅជាស្ថាប័ននូវសេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈវិមជ្ឈការជម្រុញដោយតម្រូវការមានលក្ខណៈចូលរួម និងពហុនិយមក្នុងប្រទេសកម្ពុជា។

**គោលបំណង៖** ការអភិវឌ្ឍ និងការអនុវត្តក្របខ័ណ្ឌការងារផ្នែកស្ថាប័ន និងផ្នែកច្បាប់សម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្មដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ និងអាជីវកម្មកសិកម្មប្រកប ដោយប្រសិទ្ធភាពក្នុងប្រទេសកម្ពុជា។

**លទ្ធផលចុងក្រោយ៖** អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានគោលការណ៍ណែនាំច្បាស់លាស់ និងការបណ្តុះបណ្តាលស្តីពីការធ្វើផែនការ និងការអនុវត្តផ្តល់សេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈវិមជ្ឈការ ផ្អែកលើតម្រូវការទីផ្សារ និងមានលក្ខណៈពហុនិយម។

**ផែនការសកម្មភាព និងសកម្មភាព៖**

### ១.១ ការបង្កើតគណៈកម្មាធិការភាគីពាក់ព័ន្ធសម្រាប់ការផ្សព្វផ្សាយកសិកម្មដែលបំពេញមុខងារប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

គណៈកម្មាធិការភាគីពាក់ព័ន្ធនៅថ្នាក់ជាតិនឹងជាអ្នកចង្អុលបង្ហាញផ្លូវសម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្ម។ គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) និងអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC) នឹងត្រូវបង្កើតឡើងដើម្បីបម្រើការងារជាក្រុមប្រឹក្សាយោបល់ និង "**ធនាគារគំនិត**" សម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ ពួកគេត្រូវជួបប្រជុំរៀងរាល់ខែ ហើយផ្តល់ប្រឹក្សាដល់ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ស្តីពីបញ្ហាការអនុវត្តគោលនយោបាយ។

នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ក្រុមការងារផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត (PAEWG) និងក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST) នឹងត្រូវបង្កើតឡើង។ គណៈកម្មាធិការទាំងនេះនឹងធ្វើផែនការ ព្រមទាំងអនុវត្តសេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្មផ្អែកតាមតម្រូវការសម្រាប់ខេត្ត ឬស្រុករបស់ខ្លួនរៀងៗខ្លួនអនុលោមតាមគោលការណ៍ណែនាំរបស់ AEAC និង NATSC។ គណៈកម្មាធិការទាំងនេះត្រូវជួបប្រជុំរៀងរាល់ពីរខែម្តង។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) នឹងបន្តផ្តល់ការដឹកនាំនៅថ្នាក់ជាតិសម្រាប់សេវាផ្សព្វផ្សាយកសិកម្មដោយអនុលោមតាមគោលការណ៍ណែនាំរបស់ PAEC និងការផ្តល់ប្រឹក្សាពី AEAC និង NATSC។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) នឹងបង្កើតវេទិកាអភិវឌ្ឍកសិកម្មមួយមានឈ្មោះថា ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST) នៅថ្នាក់ការិយាល័យកសិកម្មស្រុក (DAO)។ សមាជិករបស់ DATST រួមមានអ្នកតំណាងមកពីភាគីពាក់ព័ន្ធនានា ហើយត្រូវធានាឱ្យមានការតំណាងផ្នែកយេនឌ័រយ៉ាងរឹងមាំ។ ដោយយោងតាមដំបូន្មាន និងចង្អុលបង្ហាញពី DATST DAO នឹងធ្វើផែនការ អនុវត្ត និងវាយតម្លៃលើកម្មវិធីផ្សព្វផ្សាយកសិកម្មថ្នាក់មូលដ្ឋាន សម្របសម្រួលដល់ការងារអភិវឌ្ឍកសិកម្ម និងបញ្ជ្រាបកម្មវិធី និងសកម្មភាពទាំងនេះទៅក្នុងកម្មវិធីអភិវឌ្ឍឃុំ។ DAO នឹងសម្របសម្រួលជាមួយគណៈកម្មាធិការកសិកម្មឃុំ (CAC) នីមួយៗ ដើម្បីកំណត់រកសេចក្តីត្រូវការ និងអាទិភាពក្នុងវិស័យកសិកម្មក្នុងមូលដ្ឋាន។ បន្ទាប់មកផែនការទាំងអស់នេះនឹងត្រូវយកមកពិភាក្សាក្នុងសិក្ខាសាលាដាក់បញ្ចូលថ្នាក់ស្រុក មុនពេលយកទៅអនុវត្ត។

គួរកត់សម្គាល់ថា តួនាទីរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) បានផ្លាស់ប្តូរពីតួនាទីជាអ្នកអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្មទៅជាអ្នកសម្របសម្រួល អ្នកគាំទ្រ និងអ្នកធានាគុណភាព (MAFF, 2017)។ ដើម្បីអនុវត្តតួនាទីថ្មីនេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាពនានាជាច្រើនរួមមានទាំងវិស័យឯកជន NGOs និងគម្រោងមូលនិធិដោយដៃគូអភិវឌ្ឍ។ ហេតុនេះជំនួសឱ្យការផ្តោតការយកចិត្តទុកដាក់ទាំងស្រុងតែលើការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃសេវាផ្សព្វផ្សាយកសិកម្ម PDAFF នឹងធ្វើការងារដើម្បីបង្កើតឱ្យមានកិច្ចការ និងភាពជាដៃគូជាមួយវិស័យឯកជន NGOs និងដៃគូអភិវឌ្ឍកំពុងមានប្រតិបត្តិការក្នុងខេត្ត។ មន្ទីរក៏នឹងជួយសម្របសម្រួលការបណ្តុះបណ្តាល ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ (CEWs) និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs)។ បន្ថែមលើនេះទៀត PDAFF នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយការិយាល័យកសិកម្មស្រុកដើម្បីធានាថា សេវាផ្សព្វផ្សាយកសិកម្មត្រូវបានផ្តល់ជូនតាមរយៈដៃគូវិស័យឯកជនរួមទាំង NGOs អង្គការកសិករ និងអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្មដែលកំពុងផ្តល់ការសហការដូចជា គ្រាប់ពូជ ជី ថ្នាំពុលកសិកម្ម និងឥណទាន ហើយផ្តោតការយកចិត្តទុកដាក់លើការរៀនសូត្រពីគ្នាទៅវិញទៅមករបស់កសិករ ព្រមទាំងការផ្ទេរបច្ចេកវិទ្យា។ គួរកត់សម្គាល់ថា ថ្មីៗនេះ NGOs កំពុងធ្វើការងារក្រោមដំបូលថ្មីនៃភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងភាពជាដៃគូរវាង NGO និងវិស័យឯកជន។

**តារាងទី ៤៖ ខ្លឹមសារសង្ខេបនៃការរៀបចំផ្នែកស្ថាប័នសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធនានាក្នុងការអនុវត្ត PAEC**

| | | |
|---|---|---|
| គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) | ស្ថាប័នប្រឹក្សាយោបល់នៅកម្រិត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង "**ធនាគារគំនិត**" ដែលទទួលការរាយការណ៍សង្ខេបជាប្រចាំពី NATSC និងគណៈកម្មាធិការដទៃទៀតស្តីពីវឌ្ឍនភាពនៃការអនុវត្ត និងឆ្លើយតបចំពោះបញ្ហាទាំងឡាយណាដែលទាមទារដំណោះស្រាយពីថ្នាក់ខ្ពស់។ | មានរដ្ឋលេខាធិការជាប្រធាន ទទួលការគាំទ្រផ្នែករដ្ឋបាលពីលេខាធិការដ្ឋាន ASPIRE |
| អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC) | អនុគណៈកម្មាការបច្ចេកទេសកសិកម្ម ទទួលខុសត្រូវក្នុងការគ្រប់គ្រងការស្រាវជ្រាវ ការអប់រំ ការផ្សព្វផ្សាយកសិកម្ម និងការតភ្ជាប់ជាមួយ | មានរដ្ឋលេខាធិការជាប្រធាន ទទួលការគាំទ្រផ្នែករដ្ឋបាលពីលេខាធិការដ្ឋាន ASPIRE |

| | | |
|---|---|---|
| | វិស័យឯកជន និងដោះស្រាយបញ្ហាផ្នែកបច្ចេកទេស អភិវឌ្ឍ និងជម្រុញការអនុវត្តលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការធានាគុណភាព។ | |
| ក្រុមការងារផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត (PAEWG) | ទទួលខុសត្រូវលើការអនុវត្តសេវាផ្សព្វផ្សាយកសិកម្ម ដែលផ្តល់មូលនិធិតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និង ផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍ/ម្ចាស់ជំនួយ។ | មានប្រធាន PDAFF ជាប្រធាន ទទួលការគាំទ្របច្ចេកសពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) |
| ក្រុមការងារបច្ចេកទេសកសិកម្មស្រុក (DATST) | សម្របសម្រួលទូទៅលើការធ្វើផែនការ និងការអនុវត្ត សេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក។ | មានអភិបាលរងស្រុកជាប្រធាន ទទួលការគាំទ្រផ្នែក រដ្ឋបាលពីការិយាល័យកសិកម្មស្រុក (DAO) |
| គណៈកម្មាធិការកសិកម្មឃុំ (CAC) | គណៈកម្មាធិការកសិកម្មឃុំ | មានជំទប់ទី ១ របស់ឃុំជាប្រធាន ទទួលការគាំទ្រពី CEWs/VEWs/NGOs/FOs |

**១.២ រៀបចំគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការវិមជ្ឈការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក និងបណ្តុះបណ្តាលសមាជិកគណៈកម្មាធិការភាគីពាក់ព័ន្ធថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មស្តីពីសេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈចូលរួមផ្អែកលើសេចក្តីត្រូវការជម្រុញដោយតម្រូវការទីផ្សារ។**

សេវាផ្សព្វផ្សាយកសិកម្មក្នុងយុគសម័យនេះទទួលស្គាល់ភាពគ្នា នៃសហគមន៍កសិកម្ម និងសេចក្តីត្រូវការឱ្យមាននានាភាពនៅក្នុងប្រព័ន្ធផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ មានអង្គការជាច្រើនរួមទាំងអង្គការរបស់វិស័យសាធារណៈ និងមិនមែនសាធារណៈដែលផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ការអនុវត្ត PAEC ក៏ត្រូវអនុវត្តតាមគំរូការផ្តល់សេវាបែបពហុនិយមផងដែរ ពោលគឺមានពហុអ្នកផ្តល់សេវាទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនជាអ្នកផ្តល់សេវាទាំងនេះ។ ដោយហេតុថាការផ្សព្វផ្សាយកសិកម្មនឹងអនុវត្តតាមគោលវិធីបែបវិមជ្ឈការ សេវានានាត្រូវស្ថិតក្រោមការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ ពោលគឺនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ការធ្វើផែនការ និងការអនុវត្តបែបវិមជ្ឈការជួយធានាឱ្យសេវាផ្សព្វផ្សាយកសិកម្មមានលក្ខណៈផ្អែកទៅតាមសេចក្តីត្រូវការ និងមានលក្ខណៈចូលរួម។ ការងារនេះទាមទារឱ្យមានគោលការណ៍ណែនាំ និងនីតិវិធីថ្មីៗ ហើយសមាជិកគណៈកម្មាធិការភាគីពាក់ព័ន្ធ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មត្រូវការការបណ្តុះបណ្តាលស្តីពីការអនុវត្តការវាយតម្លៃសេចក្តីត្រូវការសហគមន៍ ការកំណត់អាទិភាព ការបែងចែកធនធាន និងការពិនិត្យតាមដាន និងវាយតម្លៃ។

ហេតុនេះការពង្រឹងស្ថាប័នសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំគួរកម្រិតនៅត្រឹមតែរដ្ឋាភិបាលថ្នាក់កណ្តាលនោះឡើយ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុកត្រូវការការគាំទ្រ និងការបណ្តុះបណ្តាលក្នុងការគ្រប់គ្រងកម្មវិធី ការគ្រប់គ្រងបុគ្គលិក និងថវិកា ការអនុវត្តកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មដោយអនុវត្តតាមយុទ្ធវិធីបែបការចូលរួម និងផ្អែកលើសេចក្តីត្រូវការ និងការកសាងសមត្ថភាពសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ។ ដូចបានបង្ហាញក្នុងរូបភាពទី៣ ខាងលើហើយថា ក្របខ័ណ្ឌការងារផ្នែកស្ថាប័ន និងផ្នែកច្បាប់គឺជាស្នូលដើម្បីឱ្យសេវាផ្សព្វផ្សាយកសិកម្មអាចបំពេញមុខងារប្រកបដោយប្រសិទ្ធភាព ហើយផែនការសកម្មភាពនេះសូមផ្តល់អនុសាសន៍យ៉ាងខ្លាំងក្លាឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសគ្រប់គ្រាន់ សម្រាប់ការអនុវត្តគោលនយោបាយធ្វើការស្រាវជ្រាវផ្អែកគោលនយោបាយផ្អែកលើភស្តុតាងនិងកសាងសមត្ថភាពថ្នាក់មូលដ្ឋានសម្រាប់ការពិនិត្យតាមដាននិងការវាយតម្លៃ។

### ១.៣ ជម្រើសសេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈជាពាណិជ្ជកម្ម ឬឯកជនភាវូបនីយកម្ម

ឯកជនភាវូបនីយកម្មគឺជាដំណើរការការកាត់បន្ថយតួនាទីរបស់រដ្ឋាភិបាល និង បង្កើនតួនាទីរបស់វិស័យឯកជននៅក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ចំណុចនេះមានន័យថា វិស័យសាធារណៈដកខ្លួនចេញពីការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងអនុញ្ញាតឱ្យវិស័យឯកជនជាអ្នកទទួលភារៈកិច្ចនេះវិញ។ ទោះយ៉ាងណាក្តីនៅក្រោមភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន វិស័យសាធារណៈអាចធ្វើកិច្ចសន្យាជួលវិស័យឯកជនឱ្យអនុវត្តសេវាទាំងនេះជំនួសឱ្យខ្លួន។ ភាពជាដៃគូមានចេតនាដើម្បីបំពេញបន្ថែមទៅលើកិច្ចខិតខំរបស់រដ្ឋាភិបាលក្នុងទស្សនៈដើម្បីពង្រឹងប្រសិទ្ធផល ភាពប្រកួតប្រជែង និងនិរន្តរភាពនៃសេវាផ្សព្វផ្សាយកសិកម្ម។

ឯកជនភាវូបនីយកម្មសេវាផ្សព្វផ្សាយកសិកម្មពុំចាំបាច់ត្រូវតែមានន័យថា កសិករ ឬអតិថិជនចាំបាច់ត្រូវបង់ថ្លៃសេវានោះទេ។ ឧទាហរណ៍ NGOs, CBOs និងអង្គការឯកជនដទៃទៀតផ្តល់ការគាំទ្រតាមរយៈដៃគូអភិវឌ្ឍផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយឥតគិតថ្លៃ។

អំឡុងពេលអនុវត្ត PAEC នឹងធ្វើឱ្យមានការចូលរួមពីវិស័យឯកជនក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ឃុំ និង ថ្នាក់ស្រុកតាមរយៈការដកខ្លួនជាបណ្តើរៗរបស់វិស័យសាធារណៈក្នុងវិស័យការផ្តល់សេវានៅទីណាដែលមានអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មឯកជន និងមានឆន្ទៈបម្រើឱ្យអតិថិជន ហើយចុះកិច្ចសន្យាជួលវិស័យឯកជនឱ្យផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅទីកន្លែងណា ដែលវិស័យសាធារណៈពុំអាចអនុវត្តភារៈកិច្ចនេះបានប្រកបដោយប្រសិទ្ធផល ឬប្រកបដោយសមត្ថភាពខ្ពស់។

ដើម្បីឱ្យមានគុណវុឌ្ឍគ្រប់គ្រាន់ក្លាយជាអ្នកចុះកិច្ចសន្យាផ្តល់សេវា អ្នកផ្តល់សេវាចាំបាច់ត្រូវតែមានលក្ខណៈសម្បត្តិស្របតាមលក្ខណៈវិនិច្ឆ័យផ្នែកបច្ចេកទេស និងលក្ខណៈវិនិច្ឆ័យក្នុងការផ្តល់បុគ្គលិកវិជ្ជាជីវៈ ត្រូវចុះបញ្ជីជាមួយអាជ្ញាធរសមស្រប និងត្រូវមានសម្ភារៈ និងឧបករណ៍ពាក់ព័ន្ធ ព្រមទាំងឆ្លើយតបតាមការតម្រូវដទៃទៀតដែលមាន។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង DAC នឹងអភិវឌ្ឍឱ្យមានឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃសមស្របដើម្បីធានាថាសេវាត្រូវបានផ្តល់ឱ្យក្នុងលក្ខណៈទាន់ពេលវេលា និងគួរជាទីពេញចិត្តចំពោះអតិថិជន។

ហេតុនេះកិច្ចសហការជាមួយដៃគូអភិវឌ្ឍ NGOs និង អ្នកផ្តល់សេវាវិស័យឯកជននឹងអនុញ្ញាតឱ្យការផ្តល់សេវាផ្សព្វផ្សាយកសិកម្មអាចធ្វើឡើងបានប្រកបដោយប្រសិទ្ធភាពដូចជា ការបណ្តុះបណ្តាលកសិករនាំមុខ និងប្រតិបត្តិករថ្នាលបណ្តុះកូនឈើ និងផ្ទះកញ្ចក់ និងការធ្វើបង្ហាញស្តីពីការអនុវត្តកសិកម្មល្អនៅថ្នាក់ឃុំ និងថ្នាក់ស្រុក។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង DAO គួរផ្តល់អំណាចដល់អង្គការមិនមែនរដ្ឋាភិបាល និង/ឬវិស័យឯកជនតាមរយៈការបណ្តុះបណ្តាល និងហិរញ្ញប្បទានសេវាផ្សព្វផ្សាយកសិកម្មសម្រាប់កសិករខ្នាតតូច (GESS) ដើម្បីអនុវត្ត សេវាផ្សព្វផ្សាយកសិកម្មផ្សេងៗជាច្រើនដូចជា ផលិតកម្ម និងការចែកចាយពូជស្រូវ ពូជបន្លែ និងកូនសំណាបបែបទំនើប និងថ្នាលកូនឈើ កន្លែងភ្ញាស់កូនត្រី និងថ្នាលរុក្ខជាតិសម្រាប់ដាំព្រៃដែលវិស័យឯកជនអាចទទួលយកភារៈកិច្ចនេះទៅអនុវត្ត។

### ១.៤ បង្កើតគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់សេវាផ្សព្វផ្សាយកសិកម្មបែបពហុនិយមតាមរយៈភាពជាដៃគូផ្នែកសាធារណៈ និងឯកជន

តាមប្រពៃណី សេវាផ្សព្វផ្សាយកសិកម្មគឺជាការទទួលខុសត្រូវផ្តាច់មុខរបស់វិស័យសាធារណៈ។ ប៉ុន្តែប៉ុន្មានឆ្នាំថ្មីៗនេះមានអង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការសហគមន៍ (CBOs) ដៃគូអភិវឌ្ឍ និងក្រុមហ៊ុនពាណិជ្ជកម្មជាច្រើនបានចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយកសិកម្ម និងការងារផ្សព្វផ្សាយបច្ចេកវិទ្យាជនបទ។ ឯកជនភាវូបនីយកម្មក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មកំពុងកើតមានឡើងក្នុងបណ្តាប្រទេសជាច្រើន។

ដូចបានគូសបញ្ជាក់ក្នុងផែនការសកម្មភាពក្រោមចំណុច ១.៣ ខាងលើ ប្រទេសកម្ពុជានឹងលើកទឹកចិត្តព្រមទាំងគាំទ្រដល់យន្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មពហុនិយម។ សកម្មភាពផ្សព្វផ្សាយកសិកម្ម និងការបណ្តុះបណ្តាលកសិករភាគច្រើននៅថ្នាក់ភូមិ និងថ្នាក់ឃុំនឹងត្រូវផ្តល់កិច្ចសន្យាទៅឱ្យ NGOs និង/ឬ អង្គការវិស័យឯកជន។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) នឹងផ្តល់ដឹកនាំថ្នាក់ជាតិក្នុងការឆ្លើយតបបញ្ហាអន្តរវិស័យដូចជា ការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់ និងការបង្កើនសិទ្ធអំណាចដល់យុវជនសម្រាប់ការដាំដុះនិងការអភិវឌ្ឍកសិកម្ម។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងធ្វើជាម្ចាស់ផ្ទះសម្រាប់មជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មដើម្បីឱ្យមានការផ្សព្វផ្សាយព័ត៌មានទាន់ពេលវេលាទៅដល់ការិយាល័យកសិកម្មស្រុក កសិករធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្មកសិធុរកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការកសិករ/អង្គការសហគមន៍ ដែលគ្រប់គ្រងការបណ្តុះបណ្តាល VEWs និងCEWs។

## ១.៥ ការផ្តួចផ្តើមគំនិតដំណើរការដើម្បីកំណត់អត្តសញ្ញាណ ចុះបញ្ជី និងផ្តល់អាជ្ញាប័ណ្ណដល់សេវាផ្សព្វផ្សាយកសិកម្ម

មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត (PDAFF) នឹងស្នើសុំការិយាល័យកសិកម្មស្រុកស្ថិតក្នុងខេត្តទាំងមូលឱ្យបង្កើតដេតាបេស (Database) អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម (ESPs) ទាំងអស់។ ESPs នឹងត្រូវបានតម្រូវឱ្យចុះបញ្ជីអាជីវកម្ម/ក្រុមហ៊ុនរបស់ខ្លួនជាមួយការិយាល័យកសិកម្មស្រុក។ បន្ទាប់ពីបានពិនិត្យដោយយកចិត្តទុកដាក់ និងបានទទួលអនុសាសន៍ពីក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុករួចមក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចេញអាជ្ញាប័ណ្ណសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយនីមួយៗ។ ESPs ដែលមានអាជ្ញាប័ណ្ណនេះអាចដាក់ពាក្យសុំមូលនិធិដើម្បីអនុវត្តសេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ឃុំ និងថ្នាក់ស្រុក។

ដេតាបេស ESPs ទាំងអស់នឹងត្រូវបានរៀបចំឡើងនិងដាក់ឱ្យមានជូនដល់ភាគីពាក់ព័ន្ធទាំងអស់។ ដេតាបេសអាចរួមមានឈ្មោះរបស់អ្នកផ្តល់សេវា អាសយដ្ឋានអ៊ីម៉ែល និងបុគ្គលទំនាក់ទំនង ហើយក៏រួមមានព័ត៌មានអំពីចំនួនបុគ្គលិក អ្នកជំនាញឯកទេស និងតំបន់គ្របដណ្តប់សេវាផងដែរ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងរក្សាឱ្យមានបញ្ជីឈ្មោះអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មសម្រាប់ស្រុកនីមួយៗ។

## ១.៦ ការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការផ្សព្វផ្សាយកសិកម្ម

ការសម្របសម្រួលការផ្លាស់គោលវិធីផ្សព្វផ្សាយកសិកម្មពីបែបប្រពៃណីមានលក្ខណៈមជ្ឈការ ទៅជាគោលវិធីផ្តល់ផ្សព្វផ្សាយកសិកម្មមានលក្ខណៈវិមជ្ឈការជម្រុញដោយតម្រូវការ និងពហុនិយមតម្រូវឱ្យមានការពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់លើអនុវត្តគោលនយោបាយ។ ការងារនេះតម្រូវឱ្យមានដេតាបេសគ្រប់ជ្រុងជ្រោយលើសូចនាករគន្លឹះ និងការប្រមូលទិន្នន័យជាលក្ខណៈប្រព័ន្ធ។ របាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃផ្តល់ភស្តុតាងស្តីពីប្រសិទ្ធភាពការផ្សព្វផ្សាយកសិកម្ម ដើម្បីធានាឱ្យមានការគាំទ្រចំពោះកម្មវិធីផ្សព្វផ្សាយកសិកម្មពីសំណាក់រដ្ឋាភិបាលថ្នាក់ខេត្ត វិស័យឯកជន អង្គការកសិករ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងតាក់តែង និងអនុវត្តការពិនិត្យតាមដាន ការសិក្សា និង ការវាយតម្លៃសព្វជ្រុងជ្រោយ ផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយដើម្បីពង្រឹងប្រតិបត្តិការ និងការគ្រប់គ្រងការផ្សព្វផ្សាយកសិកម្ម។ ការពិនិត្យតាមដាន និងការវាយតម្លៃផ្អែកលើភស្តុតាងនឹងចូលរួមចំណែកដល់កិច្ចពិភាក្សាផ្អែកគោលនយោបាយលើមុខងារសំខាន់ៗរបស់ការផ្សព្វផ្សាយកសិកម្មដូចជាការរៀនសូត្ររបស់កសិករ និងកំណើនចំណូលរបស់កសិករប្រកបដោយនិរន្តរភាពតាមរយៈការទទួលយកបច្ចេកវិទ្យាសមស្រប។ ថវិកាប៉ាន់ប្រមាណមួយសម្រាប់ការអនុវត្តក្របខ័ណ្ឌការងារផ្អែកស្ថាប័នថ្មីនេះគឺមានបង្ហាញជូនក្នុងតារាងទី ៥។

**តារាងទី ៥៖ ថវិកាសម្រាប់អនុវត្តសមាសធាតុផ្នែកការរៀបចំស្ថាប័ន និងក្របខ័ណ្ឌការងារស្ថាប័ន**

| សកម្មភាពក្នុងផែនការសកម្មភាព | ឆ្នាំទី១ ២០១៨ | ឆ្នាំទី២ ២០១៩ | ឆ្នាំទី៣ ២០២០ | ឆ្នាំទី៤ ២០២១ | ឆ្នាំទី៥ ២០២២ | សម្គាល់ |
|---|---|---|---|---|---|---|
| ការចំណាយសម្រាប់កិច្ចប្រជុំប្រចាំខែរបស់ NATSC និង AEAC និងកិច្ចប្រជុំរៀងរាល់ពីរខែម្តងរបស់ PAEWG, DATSC និង CAC | $45,000 | $45,000 | $45,000 | $45,000 | $45,000 | @ $1000/ប្រជុំរបស់ NATSC និង AEAC; @ $500/កិច្ចប្រជុំរៀងរាល់ពីរខែម្តងរបស់ PAEWG, DATSC និង CAC ក្នុងគម្រោង ASPIRE ទាំង 11 |
| សមាជិកគណៈកម្មាធិការបណ្តុះបណ្តាលភាគីពាក់ព័ន្ធថ្នាក់ខេត្ត និងថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មស្តីពីគោលវិធីផ្សព្វផ្សាយកសិកម្មបែបថ្មី | $110,000 | $110,000 | $110,000 | $110,000 | $110,000 | ខេត្តទាំង11 របស់ ASPIRE @ $10,000/province |
| ការកំណត់អត្តសញ្ញាណ ការចុះបញ្ជី និងការផ្តល់អាជ្ញាប័ណ្ណដល់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម | $110,000 | $110,000 | $110,000 | $110,000 | $110,000 | $10,000 ក្នុងមួយខេត្តសម្រាប់ខេត្តទាំង11 របស់ ASPIRE |
| ការពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្ត PAEC | $40,000 | $40,000 | $40,000 | $40,000 | $40,000 | DAE នឹងពិនិត្យតាមដានគោលនយោបាយថ្មី |
| **សរុប** | **$305,000** | **$305,000** | **$305,000** | **$305,000** | **$305,000** | **$1,525,000** |

## ២. ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម

PAEC ទទួលស្គាល់សេចក្តីត្រូវការក្នុងការអភិវឌ្ឍ និងពង្រឹងកម្លាំងពលកម្មផ្នែកផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា។ ក្នុងអំឡុងរយៈពេល ១០ ឆ្នាំកន្លងទៅនេះ GDA/នាយកដ្ឋានផ្សព្វផ្សាយកសិកម្មបានបាត់បង់បុគ្គលិកបច្ចេកទេសរបស់ខ្លួនចំនួនពាក់កណ្តាល (ចាប់ពីជាង 1,200 នាក់ នៅត្រឹមក្រោម 600 នាក់) ដោយសារការចូលនិវត្តន៍ ការបោះបង់ការងារ ឬមរណៈភាព។ ការសិក្សានាពេលថ្មីៗនេះបានបង្ហាញថា ដើម្បីបង្កើតសេវាផ្សព្វផ្សាយកសិកម្មដ៏រស់រវើក បុគ្គលិកត្រូវការការបណ្តុះបណ្តាលយ៉ាងម៉ត់ចត់ និងការបណ្តុះបណ្តាលបែបអនុវត្តជាក់ស្តែងបន្ថែមទៀតស្តីពីជំនាញផ្សព្វផ្សាយកសិកម្ម (Suvedi, Ghimire, and Channa, 2017; Welsh, 2017)។ ហេតុនេះ សាកលវិទ្យាល័យ និងមហាវិទ្យាល័យកសិកម្មចាំបាច់ត្រូវខិតខំបន្ថែមទៀតមិនត្រឹមតែផ្តល់ការបណ្តុះបណ្តាលកសិកម្មសម្រាប់ការអប់រំផ្នែកតាមតម្រូវការដែលផលិតភ្នាក់ងារផ្សព្វផ្សាយកសិកម្មមានសមត្ថភាពដែលមានចំណេះដឹងល្អស្តីពីប្រធានបទបច្ចេកទេស ក៏ដូចជាជំនាញដំណើរការផ្សព្វផ្សាយកសិកម្ម។ នេះជាពេលវេលាដ៏ចាំបាច់បំផុតសម្រាប់កម្ពុជាក្នុងការកែសម្រួល ឬធ្វើវឌ្ឍនភាពកម្មវិធីសិក្សាការបណ្តុះបណ្តាលមុនចូលបម្រើការងាររបស់ខ្លួននិងផ្តួចផ្តើមឱ្យមានកម្មវិធីបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មតាមរយៈការបញ្ចូលបច្ចេក

វិទ្យាថ្មីៗ និងការអនុវត្តល្អក្នុងវិស័យកសិកម្ម។ PAEC កំណត់ឃើញថា មានភ្នាក់ងារផ្សព្វផ្សាយកសិកម្មបួនប្រភេទ (រូបភាពទី ៤)។

### រូបភាពទី ៤៖ ប្រភេទ និងកម្រិតភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា

| កម្រិតភ្នាក់ងារផ្សព្វផ្សាយ | គុណវុឌ្ឍិ | រយៈពេលការបណ្តុះបណ្តាល |
|---|---|---|
| ភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWs) | កសិករឆ្នើម ឬឈានមុខគេ | ជំនាញផ្សព្វផ្សាយកសិកម្ម ២-៤ សប្តាហ៍ |
| ភ្នាក់ងារផ្សព្វផ្សាយឃុំ (CEWs) | បញ្ចប់ថ្នាក់វិទ្យាល័យ,កសិករឆ្នើម ឬឈានមុខគេ | ជំនាញផ្សព្វផ្សាយកសិកម្ម ២-៤ ខែ |
| ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) | សញ្ញាបត្រមហាវិទ្យាល័យ បច្ចេកទេសរយៈពេល ២ឆ្នាំ ឬការអប់រំដែលមានតម្លៃស្មើ | ជំនាញផ្សព្វផ្សាយកសិកម្ម ៣-៦ ខែ |
| អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) | សញ្ញាបត្រមហាវិទ្យាល័យរយៈពេល ៤ឆ្នាំ ក្នុងផ្នែកកសិកម្ម រុក្ខាប្រមាញ់ ឬជលផល | សញ្ញាប័ត្រនៃការផ្សព្វផ្សាយកសិកម្ម៦-៩ ខែ |

ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) គឺជាកសិករដែលមានស្រាប់នៅក្នុងភូមិដែលមានចំណាប់អារម្មណ៍ជួយដល់កសិករដទៃទៀតក្នុងមូលដ្ឋាន។ ពួកគាត់បម្រើការងារជាកសិករនាំមុខ ឬកសិករគំរូដែលនឹងចែករំលែកចំណេះដឹងព័ត៌មាន និងជំនាញជាមួយកសិករជាអ្នកជិតខាងរបស់ខ្លួន។

ភ្នាក់ងារផ្សព្វផ្សាយឃុំ(CEWs) គឺជាអ្នកបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ និងកសិករដែលមានស្រាប់ដែលមានការប្តេជ្ញាចិត្តបម្រើដល់កសិករជាអ្នកជិតខាង។

ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) មានសញ្ញាបត្រមហាវិទ្យាល័យបច្ចេកទេសរយៈពេលពីរឆ្នាំ ឬការអប់រំដែលមានតម្លៃស្មើ ហើយជាការល្អគួរតែជាមនុស្សដែលមកពីស្រុកជនបទដែលខ្លួនកំពុងបម្រើការងារឱ្យ។

អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) មានសញ្ញាបត្រមហាវិទ្យាល័យរយៈពេលបួនឆ្នាំក្នុងផ្នែកកសិកម្ម រុក្ខាប្រមាញ់ ឬនេសាទ។ ការជ្រើសរើសគឺផ្អែកលើគុណសម្បត្តិផ្ទាល់តាមរយៈការប្រឡងចូល។ ចាំបាច់ត្រូវមានកិច្ចខិតខំដើម្បីជ្រើសរើសឱ្យមានបេក្ខភាពស្ត្រីមកពីស្រុកជនបទ និងក្រុមជួបការលំបាក។

គោលនយោបាយជម្រុញឱ្យការផ្តួចផ្តើមកម្មវិធីបណ្តុះបណ្តាល សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មទាំងបួនកម្រិត ពោលគឺ ការបណ្តុះបណ្តាលស្តីពីការបណ្តុះបណ្តាលកសិកម្មរយៈពេលពីរទៅបួនសប្តាហ៍សម្រាប់ VEWs រយៈពីរទៅបួនខែស្តីពីជំនាញផ្សព្វផ្សាយកសិកម្មសម្រាប់CEWs ការបណ្តុះបណ្តាលរយៈបីទៅប្រាំមួយខែស្តីពីជំនាញផ្សព្វផ្សាយកសិកម្មសម្រាប់ AEAs និងការបណ្តុះបណ្តាល សញ្ញាបត្រស្តីពីការផ្សព្វផ្សាយកសិកម្មរយៈពេលប្រាំមួយទៅប្រាំបួនខែសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (MAFF, 2015)។

**គោលដៅ៖**អភិវឌ្ឍសមត្ថភាពផ្នែកស្ថាប័នសម្រាប់ការអភិវឌ្ឍធនធានមនុស្សដើម្បីបម្រើសេវាផ្សព្វផ្សាយកសិកម្ម។

**គោលបំណង៖** បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មដើម្បីឱ្យពួកគេមានសមត្ថភាពធ្វើផែនការ អនុវត្ត និងវាយតម្លៃ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដែលជម្រុញដោយតម្រូវការមានលក្ខណៈវិមជ្ឈការមានការចូលរួម និងមានលក្ខណៈពហុនិយមក្នុងប្រទេសកម្ពុជា។

**លទ្ធផលចុងក្រោយ៖** ប្រទេសកម្ពុជាមានភ្នាក់ងារផ្សព្វផ្សាយកសិកម្មបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវក្នុងចំនួនគ្រប់គ្រាន់ដើម្បីបម្រើសេចក្តីត្រូវការកសិករ និងភាគីពាក់ព័ន្ធក្នុងវិស័យកសិកម្មនៅថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ។

**ផែនការសកម្មភាព និងសកម្មភាព៖**

**២.១ បង្កើតឱ្យមានប្រព័ន្ធបណ្តុះបណ្តាលតាម ម៉ូឌុលសម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកផ្សព្វផ្សាយកសិកម្ម**

ប្រទេសកម្ពុជាចាំបាច់ត្រូវអភិវឌ្ឍឱ្យមានភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងចំនួនច្រើន ដើម្បីអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត។ កម្ពុជាក៏ត្រូវការអ្នកឯកទេសផ្សព្វផ្សាយកសិកម្មដែលបម្រើការងារជាអ្នកឯកទេសតាមប្រធានបទផ្តល់ការបណ្តុះបណ្តាលនៅក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទនិងការិយាល័យកសិកម្មស្រុកផ្តល់ភាពជាអ្នកដឹកនាំដើម្បីអាចអនុវត្តកម្មវិធីអន្តរវិស័យប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រងលើមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មថ្នាក់តំបន់។

វិធីសាស្រ្តបណ្តុះបណ្តាលតាមបែបម៉ូឌុល សម្រាប់បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មនឹងត្រូវបានទទួលយក ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅកម្រិតផ្សេងៗជាច្រើន (រូបភាពទី៥)។ គុណសម្បត្តិចម្បងនៃការទទួលយកវិធីសាស្រ្តបណ្តុះបណ្តាលតាមបែបម៉ូឌុល គឺដើម្បីឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្មទាំងអស់បានទទួលការបណ្តុះបណ្តាលសមត្ថភាពស្នូលស្តីពី វិទ្យាសាស្រ្តផ្សព្វផ្សាយកសិកម្មនិងវិធីសាស្រ្តផ្សព្វផ្សាយកសិកម្ម ព្រមទាំងមានឱកាសសម្រាប់ការឈានឡើងផ្នែកវិជ្ជាជីវៈអាជីពក្នុងអាជីពរបស់ខ្លួន។ ឧទាហរណ៍ VEWs ឬ CEWS ដែលមានលក្ខណៈគ្រប់គ្រាន់អាចចុះឈ្មោះចូលរៀនក្នុងម៉ូឌុលបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មជាន់ខ្ពស់ និងសុំការដំឡើងឋានៈទៅជាទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម ឬអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម។ វិធីសាស្រ្តបណ្តុះបណ្តាលតាមបែបម៉ូឌុលក៏ផ្តល់លទ្ធភាពអាចបត់បែនបានតាមរយៈវគ្គសិក្សានៅតាមវិទ្យាស្ថានផ្សេងៗផងដែរ។

**រូបភាពទី ៥៖ វិធីសាស្ត្របណ្តុះបណ្តាលតាមបែបម៉ូឌុល សម្រាប់បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម...**




### ២.២ អនុវត្តផែនការអភិវឌ្ឍធនធានមនុស្ស សម្រាប់នាយកដ្ឋាន និងទីភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំង RUA, PNCA និង KNSA

បច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ផ្តល់ការគាំទ្រដល់វិទ្យាស្ថានបណ្តុះបណ្តាលកសិកម្មចំនួនបីគឺ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) សាលាជាតិកសិកម្មព្រែកលៀប (PNCA) និងសាលាជាតិកសិកម្មកំពង់ចាម (KNSA)។ស្ថាប័នទាំងអស់នេះទទួលខុសត្រូវចម្បងក្នុងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ស្ថាប័នទាំងនេះពុំមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយ កសិកម្មទេ។ សេចក្តីត្រូវការទីមួយ គឺត្រូវពង្រឹងបុគ្គលិកបង្រៀន។ ទីពីរគឺត្រូវពង្រឹងកម្មវិធីបណ្តុះបណ្តាលរបស់ស្ថាប័ន និងអភិវឌ្ឍឱ្យមានបរិក្ខាររៀនសូត្របែបអនុវត្ត និង ហ្វឹកហាត់ផ្ទាល់។ ដូច្នេះផែនកសកម្មភាពសូមផ្តល់អនុសាសន៍ឱ្យអភិវឌ្ឍបុគ្គលិកសិក្សា កែសម្រួលកម្មវិធីសិក្សា និងការបណ្តុះបណ្តាលគ្រូបង្គោល (ToT) នៅតាមស្ថាប័នទាំងនេះ។

### ២.៣ ភាពជាដៃគូសាធារណៈឯកជនសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

ការអនុវត្ត PAEC តម្រូវឱ្យមាន VEWs និង CEWs ក្នុងចំនួនដ៏ច្រើនដើម្បីធ្វើការជាមួយកសិករ និងភាគីពាក់ព័ន្ធក្នុងវិស័យកសិកម្មនៅថ្នាក់មូលដ្ឋានផ្ទាល់។ VEWs និង CEWs គឺជាកសិករនាំមុខក្នុងសហគមន៍ផ្ទាល់ ដែលត្រូវការការបណ្តុះបណ្តាលស្តីពីកសិកម្មកម្រិតមូលដ្ឋាន និងសមត្ថភាពជំនាញស្តីពីការដំណើរការដែលចាំបាច់

សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ដោយសារសេចក្តីត្រូវការចំពោះមុខក្នុងការបណ្តុះបណ្តាលក្រុម VEWs និង CEWs ផែនការសកម្មភាពសូមផ្តល់អនុសាសន៍ឱ្យអគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវធ្វើឱ្យមានការចូលរួមពីស្ថាប័នបណ្តុះបណ្តាលកសិកម្ម ដៃគូអភិវឌ្ឍ និង/ឬ អង្គការមិនមែនរដ្ឋាភិបាល ទាំងអស់នៅក្នុងខេត្តនីមួយៗក្នុងការផ្តល់ការបណ្តុះបណ្តាល។

ដោយសារមានតម្រូវការការបណ្តុះបណ្តាលបច្ចេកទេសកម្រិតខ្ពស់សម្រាប់ AEAs ស្ថាប័នបណ្តុះបណ្តាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (RUA, PNCA និង KNSA) នឹងត្រូវចូលរួមក្នុងការផ្តល់ការបណ្តុះបណ្តាល AEA ។

ការបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្មទាមទារឱ្យបុគ្គលិកសិក្សាត្រូវទទួលបានការបណ្តុះបណ្តាលជាន់ខ្ពស់ និងមានមន្ទីរពិសោធន៍ និងធនធានសិក្សារៀនសូត្រទាន់សម័យ។ ដោយឈរលើមូលដ្ឋានសមត្ថភាពរបស់បុគ្គលិកសិក្សានាពេលបច្ចុប្បន្នផែនការសកម្មភាពនេះ ផ្តល់អនុសាសន៍ឱ្យសាកលវិទ្យាល័យភូមិន្ទកសិកម្មត្រូវបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម និងផ្តល់ការបណ្តុះបណ្តាលសម្រាប់វិញ្ញាប័ណ្ណបត្រក្នុងប្រទេស (នៅថ្នាក់អនុបណ្ឌិតនិងថ្នាក់បណ្ឌិត)សម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកអភិវឌ្ឍកសិកម្ម។

### ២.៤ លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្មតាមរយៈការបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារ។ កសាងសមត្ថភាពថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោល (ToT)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានអ្នកប្រកបវិជ្ជាជីវៈកសិកម្មប្រមាណ ៦០០នាក់ ដែលធ្វើការក្រោមអគ្គនាយកដ្ឋានកសិកម្ម (GDA) និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ហើយបុគ្គលិកទាំងអស់នោះចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពទាក់ទងជាមួយការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មថ្មីៗ តាមរយៈវគ្គសិក្សារំលឹកឡើងវិញ ឬសិក្ខាសាលាបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារ។ បុគ្គលិកក្នុងនាយកដ្ឋានបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានបណ្តុះបណ្តាល រួមទាំងបុគ្គលិកសិក្សា និងគ្រូបង្រៀននៅ RUA, PNCA និង KNSA ត្រូវការវគ្គបណ្តុះបណ្តាលគ្រូបង្គោល (ToT)។

នៅពេលក្រុមការងារគ្រូបណ្តុះបណ្តាលស្នូលត្រូវបានអភិវឌ្ឍឡើងហើយ វិទ្យាស្ថានបណ្តុះបណ្តាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំការបណ្តុះបណ្តាលក្នុងពេលបំពេញការងារជារយៈៗ និង/ឬសិក្ខាសាលាសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសហគមន៍។

### ២.៥ បង្កើតប្រព័ន្ធចុះបញ្ជី និងទទួលស្គាល់គុណភាពសម្រាប់វិទ្យាស្ថានផ្សព្វផ្សាយកសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម (ឧ. អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ អង្គការកសិករ)

ប្រទេសកម្ពុជានឹងអនុវត្តតាមគោលវិធីពហុនិយមក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ដៃគូអភិវឌ្ឍ NGOs និងវិទ្យាស្ថានបណ្តុះបណ្តាលជាច្រើនអាចផ្តល់ការបណ្តុះបណ្តាលជំនាញផ្នែកបច្ចេកទេស និងជំនាញដំណើរការជូនដល់ VEWs, CEWs, AEAs និងអ្នកឯកទេសផ្នែកផ្សព្វផ្សាយកសិកម្ម។

ការបណ្តុះបណ្តាល VEW និង CEW នឹងត្រូវជួលទៅឱ្យ INGO/NGOs នៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ គម្រោងដែលគួរអភិវឌ្ឍ ឬអង្គការក្នុងមូលដ្ឋានដែលមានគុណវុឌ្ឍគ្រប់គ្រាន់តាមរយៈមូលនិធិមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដំណើរការប្រហាក់ប្រហែលគ្នានេះនឹងត្រូវយកមកអនុវត្តសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា និងសម្រាប់ការបណ្តុះបណ្តាលគ្រូបង្គោលដើម្បីបណ្តុះបណ្តាលទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) ប៉ុន្តែការបណ្តុះបណ្តាល AEAs នឹងត្រូវធ្វើឡើងដោយ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកិច្ចសហការជាមួយ RUA, PNCA និង KNSA តាមរយៈមូលនិធិមកពីកម្មវិធី ASPIRE ។

ថ្វីបើ AEAC និង NATSC អាចផ្តល់អនុសាសន៍ឱ្យមានកម្មវិធីបណ្តុះបណ្តាលឯកភាពគ្នាមួយនៅទូទាំងប្រទេសក្តី ប៉ុន្តែអាចមានភាពខុសប្លែកគ្នាមួយចំនួនទាក់ទងជាមួយគុណភាពធនធានមនុស្ស បរិក្ខារបង្ហាត់បង្រៀនដូចជា ថ្នាក់រៀន មន្ទីរពិសោធន៍ អន្តេវាសិកដ្ឋាន (លំនៅស្ថានសម្រាប់សិក្ខាកាមក្នុងការបណ្តុះបណ្តាល) និងបរិក្ខារសម្រាប់ការចុះហ្វឹកហាត់នៅទីវាល។ ដើម្បីធានាគុណភាពការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តួចផ្តើមគំនិតឱ្យមានប្រព័ន្ធទទួលស្គាល់គុណភាពដើម្បីចេញវិញ្ញាបនបត្របញ្ជាក់ វិទ្យាស្ថានបណ្តុះបណ្តាលទាំងឡាយណាដែលបានឆ្លើយតបតាមបទដ្ឋានការបណ្តុះបណ្តាល។

ការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាល អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (ESs) នឹងត្រូវអនុវត្តតាមនីតិវិធីប្រហាក់ប្រហែលគ្នាជាមួយនីតិវិធីដែលពិពណ៌នាខាងលើ។ ប៉ុន្តែអាស្រ័យដោយកម្រិតឯកទេសរបស់បុគ្គលិកសិក្សា ថ្នាក់រៀន មន្ទីរពិសោធន៍ បណ្ណាល័យ និងបរិក្ខារបណ្តុះបណ្តាលនាពេលបច្ចុប្បន្ននេះមានតែសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) ប៉ុណ្ណោះដែលបានទទួលភារកិច្ចគ្រប់គ្រងការបណ្តុះបណ្តាល AESs សម្រាប់រយៈពេលបួនទៅប្រាំឆ្នាំខាងមុខនេះ។

នាយកដ្ឋានបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតឱ្យមានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ (National Accreditaion Committee)។ NAC នឹងត្រូវទទួលបន្ទុកក្នុងការអភិវឌ្ឍស្តង់ដារសម្រាប់ការទទួលស្គាល់គុណភាពការអប់រំ និងត្រូវអនុវត្តការពិនិត្យឡើងវិញដើម្បីផ្តល់ការទទួលគុណភាពការអប់រំ។ ដោយឈរលើមូលដ្ឋាននៃការពិនិត្យឡើងវិញទាំងអស់នេះ NAC នឹងផ្តល់អនុសាសន៍ស្តីពីកម្រិតនៃការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលនឹងត្រូវផ្តល់ឱ្យ (ពោលគឺ VEWs, CEWs, AEAs ឬ ESs) ចំនួនកម្មវិធីបណ្តុះបណ្តាល និងចំនួនសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលនីមួយៗ។ NAC ក៏នឹងផ្តល់អនុសាសន៍អំពីផែនការរយៈពេលខ្លី និងរយៈពេលវែង ដើម្បីពង្រឹងវិទ្យាស្ថានបណ្តុះបណ្តាលផងដែរ។

## ២.៦ ការពង្រឹងការបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារ និងការបណ្តុះបណ្តាលដើម្បីយកសញ្ញាបត្រ (កម្រិតអនុបណ្ឌិត និងបណ្ឌិត) សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងប្រទេស និងក្រៅប្រទេសកម្ពុជា

ជាចុងក្រោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរពង្រឹងកម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅគ្រប់កម្រិតទាំងអស់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/កម្មវិធី ASPIRE បានអភិវឌ្ឍគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មសម្រាប់វគ្គបណ្តុះបណ្តាល (Khieu, 2017) ហើយគ្រូបណ្តុះបណ្តាលនឹងត្រូវអនុវត្តតាមគោលការណ៍ណែនាំទាំងអស់នេះ។

តាមរយៈការប្រកាសឱ្យប្រើ PAEC និងផែនការសកម្មភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងអភិវឌ្ឍឱ្យមានក្រុមភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកឯកទេសផ្សព្វផ្សាយកសិកម្មតាមរយៈការផ្តួចផ្តើមគំនិតផ្នែកការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដ៏រឹងមាំមួយ។ ជាដំបូងកម្មវិធីសិក្សាសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មគ្រប់កម្រិត

ទាំងអស់នឹងត្រូវអភិវឌ្ឍឡើង និងអនុម័តដោយ NATSC និង AEAC។ បទដ្ឋានសម្រាប់ការជ្រើសរើសការទទួលយកឱ្យចូលរៀន និងការបណ្តុះបណ្តាល VEW និង CEW នឹងត្រូវអភិវឌ្ឍឡើងដើម្បីធានាគុណភាពរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ទីពីរ ការបណ្តុះបណ្តាលគ្រូបង្គោល (ToT) សម្រាប់ការបណ្តុះបណ្តាល VEWs និងCEWs នឹងត្រូវបានរៀបចំឡើងក្នុងកិច្ចសហការជាមួយ RUA, PNCAនិងKNSA។ ការបណ្តុះបណ្តាល ToT នឹងត្រូវធ្វើឡើងនៅ RUA សាលាកសិកម្មព្រែកលៀប ឬវិទ្យាស្ថានសមស្របនៅក្រៅប្រទេស។

ដើម្បីអនុវត្ត PAEC ប្រកបដោយប្រសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវការឱ្យមានអ្នកប្រកបវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្មថ្មីៗក្នុងចំនួនជាច្រើន។ មានការប៉ាន់ប្រមាណថាតម្រូវការ VEWs ប្រមាណ ៥០០នាក់ CEWs ២០០នាក់ និងទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម ១០០នាក់ នឹងត្រូវទទួលការបណ្តុះបណ្តាលក្នុងពេលមួយឆ្នាំៗសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។ កម្មវិធីសិក្សាការបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្មនឹងត្រូវបានរៀបឡើងក្នុងឆ្នាំ២០១៨ ហើយចាប់ផ្តើមក្នុងឆ្នាំ២០១៩ អ្នកឯកទេសផ្សព្វផ្សាយចំនួន ៦០ នាក់ក្នុងមួយឆ្នាំនឹងបានទទួលការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម (តារាងទី៦)។ គោលដៅរបស់ MAFF គឺត្រូវរក្សាសមមាត្រភ្នាក់ងារផ្សព្វផ្សាយកសិកម្មធៀបជាមួយកសិករក្នុងចំនួន ១:១០០០ ពោលគឺនឹងមានភ្នាក់ងារផ្សព្វផ្សាយកសិកម្មម្នាក់សម្រាប់កសិករ ១០០០នាក់។ ប្រធានបទដែលត្រូវគ្របដណ្តប់ដោយការបណ្តុះបណ្តាល VEWs និង CEWs អាចខុសប្លែកគ្នាទៅតាមសេចក្តីត្រូវការរបស់ឃុំ និងស្រុក។ ឧទាហរណ៍ឃុំ/ស្រុកមួយចំនួនអាចចង់ឱ្យ CEWs របស់ខ្លួនបានទទួលការបណ្តុះបណ្តាលស្តីពីកៅស៊ូឧស្សាហកម្ម ចំណែកឃុំ/ស្រុកមួយចំនួនទៀតចង់ឱ្យ CEWs របស់ខ្លួនបានទទួលការបណ្តុះបណ្តាលអំពីផលិតកម្មបន្លែសម្រាប់ពាណិជ្ជកម្ម។

វិទ្យាស្ថានបណ្តុះបណ្តាលកម្ពុជា ក៏ចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពបុគ្គលិកសិក្សាកម្រិតជាន់ខ្ពស់ផងដែរ។ ផែនការសកម្មភាពសូមផ្តល់អនុសាសន៍ថាបុគ្គលិកសិក្សា/គ្រូឧទ្ទេសចំនួន១៥នាក់នឹងបានទទួលការបណ្តុះបណ្តាលសញ្ញាបត្រថ្នាក់អនុបណ្ឌិត ក្នុងមុខវិជ្ជាអភិវឌ្ឍការផ្សព្វផ្សាយកសិកម្ម/កសិកម្មក្នុងមួយឆ្នាំៗ រយៈពេល៥ឆ្នាំ។ ស្រដៀងគ្នានេះដែរគ្រូឧទ្ទេសចំនួន២០រូប នឹងបានទទួលការបណ្តុះបណ្តាលកម្រិតបណ្ឌិត ក្នុងរយៈ៥ឆ្នាំខាងមុខ (តារាងទី៦)។

សូមកត់សម្គាល់ថា អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកផ្សព្វផ្សាយកសិកម្មនឹងមានឋានៈប្រហាក់ប្រហែលជាមួយអ្នកប្រកបរបរកសិកម្មដទៃទៀតដែរ។ យេនឌ័រនឹងត្រូវបានយកមកពិចារណាជាពិសេសក្នុងការអភិវឌ្ឍធនធានមនុស្ស ការជ្រើសរើសឱ្យចូលធ្វើការនិងបញ្ជូនទៅបំពេញការងារ។ឯកសណ្ឋានដែលមានលក្ខណៈអព្យាក្រឹត្យផ្នែកយេនឌ័រអាចត្រូវបានផ្តល់ជូនសម្រាប់ VEWs, CEWs, AEAs និងអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម។

គុណភាពធនធានមនុស្សគឺជាកត្តាដ៏ចាំបាច់បំផុត ដែលជះឥទ្ធិពលលើប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្ម។ ទោះយ៉ាងណាក្តីវិទ្យាស្ថានបណ្តុះបណ្តាលនៅក្នុងប្រទេសកម្ពុជានៅខ្វះសមត្ថភាពគ្រប់គ្រាន់ ដើម្បីបណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកការអភិវឌ្ឍកសិកម្ម។ ការអប់រំ និងវិទ្យាស្ថានបណ្តុះបណ្តាលកសិកម្មភាគច្រើនបានប្រែជាចាស់ទ្រុឌទ្រោមអាស្រ័យដោយកង្វះខាតថវិកា។ កម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាល រួមទាំងសម្រាប់ការផ្សព្វផ្សាយកសិកម្ម ដោយពុំទាន់ជាមួយការរីកចម្រើនផ្នែកបច្ចេកវិទ្យា បរិស្ថានការធ្វើកសិកម្ម និងតម្រូវការពង្រីកភាពបត់បែននោះទេ។ គ្រូបង្ហាត់បង្រៀននៅសាកលវិទ្យាល័យ មហាវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលពុំបានធ្វើបច្ចុប្បន្នភាព ឬពុំទាន់សភាពការលើប្រធានបទសិក្សា។ ជាលទ្ធផល អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកផ្សព្វផ្សាយកសិកម្មបានទទួលការបណ្តុះបណ្តាលយ៉ាងអន់ខ្សោយលើវិស័យជាកម្មវត្ថុ និងខ្វះសមត្ថភាពស្នូលដែលចាំបាច់សម្រាប់ការងារ

ផ្សព្វផ្សាយកសិកម្មប្រកបដោយជោគជ័យ។

ភ្នាក់ងារផ្សព្វផ្សាយកសិកម្មបច្ចុប្បន្នកំពុងធ្វើការនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិត្រូវការការបណ្តុះបណ្តាលរំលឹកឡើងវិញដើម្បីរក្សាបច្ចុប្បន្នភាពឬធ្វើឱ្យពួកគេមានភាពទាន់សភាពការណ៍ខាងផ្នែកវិជ្ជាជីវៈរបស់ខ្លួន។ វិស័យសម្រាប់ការបណ្តុះបណ្តាលក្នុងការបំពេញការងារអាចរួមមានដូចជា គោលការណ៍នៃការរៀនសូត្ររបស់មនុស្សពេញវ័យ ជំនាញនៃការសម្របសម្រួលក្រុម ការប្រាស្រ័យទាក់ទង និងការនិយាយជាសាធារណៈ ការសរសេរសំណើ និងការបណ្តុះបណ្តាល ICT។

**តារាងទី ៦៖ ផែនការរយៈពេលប្រាំឆ្នាំសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ចំនួនមនុស្ស)**

| ប្រភេទនៃការបណ្តុះបណ្តាល | ឆ្នាំ 1 | ឆ្នាំទី 2 | ឆ្នាំទី 3 | ឆ្នាំទី 4 | ឆ្នាំទី 5 | សម្គាល់ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| ការបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាល (ក្នុងប្រទេស) | 20 | 20 | 20 | 20 | 20 | មូលនិធិគម្រោង MAFF |
| ការបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាល (ក្រៅប្រទេស) | 5 | 5 | 5 | 5 | 5 | ប្រទេសវៀតណាម ថៃ ហ្វីលីពីន ឥណ្ឌា |
| ភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWs) | 500 | 500 | 500 | 500 | 500 | ជួលការបណ្តុះបណ្តាលទៅខាងក្រៅឱ្យដល់ NGOs នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ធនធានបណ្តុះបណ្តាលមកពី PDAFF |
| ភ្នាក់ងារផ្សព្វផ្សាយឃុំ (CEWs) | 200 | 200 | 200 | 200 | 200 | ជួលការបណ្តុះបណ្តាលទៅខាងក្រៅដល់ NGOs នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ធនធានការបណ្តុះបណ្តាលមកពី PDAFF/DAE |
| ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) | 100 | 100 | 100 | 100 | 100 | DAE |
| អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) | 60 | 60 | 60 | 60 | 60 | RUA/PNCA |
| ថ្នាក់អនុបណ្ឌិត | 15 | 15 | 15 | 15 | 15 | ២នាក់ ក្នុងមួយខេត្ត +២០នាក់ សម្រាប់កម្រិត MAFF/ GDA/DAE RUA ឬប្រទេសថៃ |
| ថ្នាក់បណ្ឌិត | 5 | 5 | 5 | 5 | - | កម្រិត MAFF/GDA/DAE |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងវិនិយោគលើការអភិវឌ្ឍធនធានមនុស្សរបស់ RUA, PNCA និង KNSA ដើម្បីអភិវឌ្ឍសមត្ថភាពបុគ្គលិកសិក្សាក្នុងការគ្រប់គ្រងការបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងចំនួនច្រើន។ ការបណ្តុះបណ្តាលបុគ្គលិកសិក្សាអាចធ្វើឡើងនៅ RUA (តាមរយៈគ្រូឧទ្ទេសបរទេសសម្រាប់ផ្តល់ការបង្ហាត់បង្រៀនដើម្បីបំពេញបន្ថែមដល់សមត្ថភាព RUA) ឬ នៅប្រទេសជាសមាជិកអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (SEAMEO)។ ប្រទេសថៃផ្តល់ជាជម្រើសគួរជាទីចាប់អារម្មណ៍ បើគិតទៅលើចម្ងាយនៅកៀកគ្នា ការចំណាយសម្រាប់ការបណ្តុះបណ្តាល និងការប្រើប្រាស់ភាសាអង់គ្លេសជាមធ្យោបាយសម្រាប់ការបង្ហាត់បង្រៀន។ ប្រទេសហ្វីលីពីនក៏ជាជម្រើសដែលអាចធ្វើបានផងដែរ សម្រាប់ការបណ្តុះបណ្តាលកម្រិតជាន់ខ្ពស់។

ការបណ្តុះបណ្តាលសញ្ញាបត្រជាន់ខ្ពស់នៅថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិតត្រូវបានផ្តល់អនុសាសន៍ឱ្យធ្វើដោយសារសេចក្តីត្រូវការកម្លាំងបុគ្គលិកសម្រាប់ការអភិវឌ្ឍគោលនយោបាយថ្នាក់ជាតិ ការបង្វឹកបង្ហាត់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ការតភ្ជាប់ការស្រាវជ្រាវជាមួយការផ្សព្វផ្សាយកសិកម្ម ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្ម។

## ថវិកាប៉ាន់ប្រមាណ៖

### តារាងទី ៧៖ ផែនការថវិកាសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ដុល្លាអាមេរិក)

| ប្រភេទនៃការបណ្តុះបណ្តាល | ឆ្នាំទី 1 | ឆ្នាំទី 2 | ឆ្នាំទី 3 | ឆ្នាំទី 4 | ឆ្នាំទី 5 | សរុបសម្រាប់រយៈពេល 5 ឆ្នាំ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| ការបណ្តុះបណ្តាលគ្រូបង្គោល (នៅក្នុងប្រទេស) | $30,000 | $30,000 | $30,000 | $30,0000 | $30,000 | ការបណ្តុះបណ្តាល រយៈពេល២សប្តាហ៍ @ $1,500/នាក់ |
| ការបណ្តុះបណ្តាលគ្រូបង្គោល (នៅក្រៅប្រទេស) | $25,000 | $25,000 | $25,000 | $25,000 | $25,000 | ការបណ្តុះបណ្តាល រយៈពេល២សប្តាហ៍ @ $5,000/នាក់ |
| ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ(VEWs) | $350,000 | $350,000 | $350,000 | $350,000 | $350,000 | ការបណ្តុះបណ្តាល រយៈពេល២សប្តាហ៍ សម្រាប់ VEWS ៥០០នាក់/ឆ្នាំ @ $700/នាក់ |
| ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ (CEWs) | $220,000 | $220,000 | $220,000 | $220,000 | $220,000 | ការបណ្តុះបណ្តាល រយៈពេល ២ខែ សម្រាប់ CEWs ២០០នាក់/ឆ្នាំ @ $1,100 /នាក់ |
| ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) | $330,000 | $330,000 | $330,000 | $330,000 | $330,000 | ការបណ្តុះបណ្តាល រយៈពេល៣ខែ សម្រាប់ AEAs ១០០នាក់/ឆ្នាំ @ $3,300/នាក់ |
| អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) | - | $360,000 | $360,000 | $360,000 | $360,000 | ការបណ្តុះបណ្តាល រយៈពេល៦ខែ សម្រាប់ ESs ៦០ នាក់/ឆ្នាំ, @ $6,000/ នាក់ |
| ការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិតRUA: 40 នាក់ ក្រៅប្រទេស៖ 20 នាក់ | $255,000 | $255,000 | $255,000 | $255,000 | $80,000 | ការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិតសម្រាប់មនុស្ស៥០ នាក់នៅ RUA @ $8,000/ នាក់;ការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិតក្នុងប្រទេសថៃ/ហ្វីលីពីន @ $35,000/នាក់ |
| ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត | $300,000 | $300,000 | $300,000 | $300,000 | - | ក្រៅប្រទេស៖ ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតមនុស្ស |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ២០នាក់<br>@ $60,000/នាក់ |
| ការបណ្តុះបណ្តាលក្នុងពេលបំពេញការងារសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ក្នុងប្រទេស) | $600,000 | $600,000 | $600,000 | $600,000 | $600,000 | ការបណ្តុះបណ្តាលក្នុងប្រទេសមួយវគ្គ/ខេត្តសម្រាប់មនុស្ស ៣០នាក់<br>@ $200/នាក់ |
| គណៈកម្មាធិការទទួលស្គាល់គុណភាព | $10,000 | $10,000 | $10,000 | $10,000 | $10,000 | ការផ្តល់មូលនិធិប្រចាំឆ្នាំ @$10,000 |
| **សរុប** | **$2,120,000** | **$2,480,000** | **$2,480,000** | **$2,750,000** | **$2,005,000** | **$11,835,000** |

## ៣. ការតភ្ជាប់ការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា

ការផ្សព្វផ្សាយកសិកម្មគឺទាក់ទងជាមួយការចែករំលែកគំហើញពីការស្រាវជ្រាវ និងបច្ចេកទេសជាមួយកសិករ។ ស្ថានីយស្រាវជ្រាវកសិកម្ម នៅសាកលវិទ្យាល័យនានាធ្វើការស្រាវជ្រាវបង្កើតចំណេះដឹង ឬបច្ចេកវិទ្យាផ្សេងៗដែលជាដំបូងត្រូវបានបញ្ជូនទៅឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្មតាមរយៈការបណ្តុះបណ្តាល ការអនុវត្តបង្ហាញ ឬប្រព័ន្ធផ្សព្វផ្សាយ។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មបញ្ជូនបច្ចេកវិទ្យា និងបច្ចេកទេសថ្មីៗទៅឱ្យកសិករ ឬអ្នកប្រើប្រាស់ចុងក្រោយដទៃទៀត។ ដ្យាក្រាមស្តីពីទំនាក់ទំនងរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំគឺច្រើនត្រូវបានគេហៅថា ត្រីកោណចំណេះដឹង។ ត្រីកោណចំណេះដឹងដែលលេចធ្លោត្រូវបានបង្ហាញឱ្យឃើញនូចំណងទាក់ទងយ៉ាងរឹងមាំ ក្នុងចំណោមចំណងទាក់ទងទាំងអស់នេះ។ ចំណងទាក់ទងត្រូវបានពង្រឹងនៅពេលដែលមានការប្រាស្រ័យទាក់ទងជាប្រចាំ និងមានទំនាក់ទំនងការងារល្អ។ ការតភ្ជាប់ត្រូវបានសម្របសម្រួលនៅពេលអង្គការនានាមើលឃើញគុណតម្លៃនៃព័ត៌មានដែលបានចែករំលែកគ្នាឬព័ត៌មានបំពេញបន្ថែមឱ្យគ្នា។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មនៅកម្ពុជា (CARDI) គឺជាអង្គការពាក់កណ្តាលស្វយ័តដែលទទួលខុសត្រូវជាចម្បងក្នុងការស្រាវជ្រាវកសិកម្ម។ អគ្គនាយកដ្ឋានកសិកម្ម (GDA) គ្រប់គ្រងលើភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក និងសម្របសម្រួលប្រតិបត្តិការរបស់កសិដ្ឋានស្រាវជ្រាវកសិកម្ម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មថ្នាក់តំបន់ទាំងអស់។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) ប្រតិបត្តិការនៅក្រោម GDA និងផ្ទេរបច្ចេកទេសទៅដល់បុគ្គលិកថ្នាក់ខេត្ត និងថ្នាក់ស្រុក។ នាយកដ្ឋានដទៃទៀតនៅក្រោម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានដូចជា ផលិតកម្មសត្វ និងសុខភាពសត្វ, រដ្ឋបាលជលផល, រដ្ឋបាលព្រៃឈើ, គ្រឿងចក្រកសិកម្ម និងកៅស៊ូ ដែលធ្វើការស្រាវជ្រាវ ព្រមទាំងផ្តល់សេវាផ្សព្វផ្សាយកសិកម្មផងដែរជូនកសិករ និងកសិធុរៈកិច្ច។ ការបណ្តុះបណ្តាលខណៈពេលមុនបម្រើការងារសម្រាប់អ្នកប្រកបវិជ្ជាជីវៈ គឺជាការទទួលខុសត្រូវរបស់មហាវិទ្យាល័យ និងសាកលវិទ្យាល័យកសិកម្មដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) សាលាជាតិកសិកម្ម សាលាកសិកម្មព្រែកលៀប (PNCA) និងសាកលវិទ្យាល័យជាតិកសិកម្មខេត្តកំពង់ចាម (KNSA)។ វិស័យឯកជន និងសហគមន៍ក៏ចូលរួមក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍដើម្បីលើកកម្ពស់ផលិតកម្មកាហ្វេ ម្រេចស និងក្រវ៉ាញផងដែរ។ បច្ចុប្បន្ននេះ ការចែករំលែកព័ត៌មាន ចំណេះដឹង និងជំនាញរវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម ការអប់រំ និងអ្នកផ្តល់សេវាវិស័យឯកជន មានភាពទន់ខ្សោយ។ រចនាសម្ព័ន្ធបច្ចុប្បន្នពុំផ្តល់ឱ្យមានយន្តការវិមជ្ឈការ ដើម្បីធានាឱ្យមានការផ្តល់ភាពរឹងមាំចំពោះអតិថិជនផ្សព្វផ្សាយកសិម្ម ទាក់ទងនឹងការចែករំលែកព័ត៌មាន និងចំណេះដឹងទេ។ បន្ថែមលើនេះទៀតរចនាសម្ព័ន្ធបច្ចុប្បន្នពុំឆ្លើយតបយ៉ាងគ្រប់គ្រាន់ឱ្យមានយន្តការដើម្បីបញ្ជ្រាបបញ្ហាអន្តរវិស័យនានាដូចជាការគ្រប់គ្រងធនធានធម្មជាតិ កសិកម្មវៃឆ្លាត និងអាកាសធាតុ និងការដាក់បញ្ចូលយេនឌ័រនោះឡើយ។

**គោលដៅ៖** ស្វែងយល់ និងផ្សព្វផ្សាយចំណេះដឹងផ្អែកលើការស្រាវជ្រាវដើម្បីធានានូវសុវត្ថិភាពស្បៀង អាហារូបត្ថម្ភ ការពារធនធានធម្មជាតិ និងបរិស្ថានសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**គោលបំណង៖** អភិវឌ្ឍ និងផ្សព្វផ្សាយព័ត៌មានផ្អែកលើការស្រាវជ្រាវ និងបច្ចេកវិទ្យាដើម្បីកែលម្អផលិតកម្មកសិកម្ម និងការអភិរក្សធនធានធម្មជាតិ។

**លទ្ធផលចុងក្រោយ៖**

- ប្រទេសកម្ពុជាមានផលិតផលកសិកម្មប្រកបដោយនិរន្តរភាព និងបច្ចេកវិទ្យាអភិរក្សធនធានធម្មជាតិសមស្របសម្រាប់ល័ក្ខខ័ណ្ឌកសិអាកាសធាតុក្នុងមូលដ្ឋាន។
- ប្រទេសកម្ពុជានឹងរក្សាទំនាក់ទំនងប្រកបដោយភាពសុខដុមរវាងវិស័យការស្រាវជ្រាវកសិកម្ម ការផ្សព្វផ្សាយកសិកម្ម ការអប់រំ និងវិស័យឯកជន។

**ផែនការសកម្មភាព និងសកម្មភាព៖**

ចំណងទាក់ទងទន់ខ្សោយរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំបានផ្តល់លទ្ធផលឱ្យមានលំហូរព័ត៌មានមិនមានប្រសិទ្ធភាពក្នុងចំណោមអ្នកស្រាវជ្រាវ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងស្ថាប័នអប់រំ/បណ្តុះបណ្តាល។ CARDI គឺជាស្ថាប័នពាក់កណ្តាលស្វយ័ត និងការគ្រប់គ្រងរបស់នាយកមួយរូបដែលរាយការណ៍ជូនទៅក្រុមប្រឹក្សាភិបាលចាត់តាំងដោយរដ្ឋាភិបាល។ ស្រដៀងគ្នានេះដែរ ការបណ្តុះបណ្តាល និងការអប់រំផ្នែកកសិកម្មត្រូវបានផ្តល់ដោយមហាវិទ្យាល័យ និងសាកលវិទ្យាល័យជាច្រើនស្ថិតក្រោមការគ្រប់គ្រងរួមគ្នារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអប់រំ យុវជន និងកីឡា។

ជារឿយៗកម្មវិធីផ្សព្វផ្សាយកសិកម្ម និងបុគ្គលិកត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ MAFF/GDA។ ពុំមានយន្តការសម្រាប់ការប្រាស្រ័យទាក់ទងជាប្រចាំរវាងអ្នកស្រាវជ្រាវរបស់ CARDI បុគ្គលិកចុះមូលដ្ឋានរបស់ GDA និងបុគ្គលិកសិក្សារបស់ RUA/PNCA/KNSA នោះឡើយ។ មានអន្តរកម្មតិចតួចបំផុតក្នុងចំណោមកសិដ្ឋានស្រាវជ្រាវ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលស្ថិតក្រោមការគ្រប់គ្រង GDA មជ្ឈមណ្ឌលបណ្តុះបណ្តាលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងប្រតិបត្តិករវិស័យឯកជន។ ទិដ្ឋភាពនេះបានផ្តល់លទ្ធផលឱ្យមានលំហូរព័ត៌មានអន់ខ្សោយរវាងអ្នកស្រាវជ្រាវ អ្នកផ្សព្វផ្សាយ និងអង្គភាពអប់រំ ព្រមទាំងវិស័យឯកជន ហើយជារឿយៗត្រូវបានលើកឡើងថា ជាបុព្វហេតុឫសគល់មួយដែលធ្វើកសិករមានការទទួលយកបច្ចេកវិទ្យាកសិកម្មកម្រិតទាប។

ដូចបានបញ្ជាក់ក្នុងគោលនយោបាយផ្សព្វផ្សាយកសិកម្មថ្មីរួចហើយថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងមានគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) ដើម្បីផ្តល់ប្រឹក្សាលើការសម្របសម្រួលទីភ្នាក់ងារពាក់ព័ន្ធផ្សេងៗនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចង្អុលបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម និងអនុម័តលើខ្លឹមសារបច្ចេកទេសនៃសម្ភារៈផ្សព្វផ្សាយកសិកម្ម។ អនុកម្មាធិការ AEAC/ការស្រាវជ្រាវ-ការផ្សព្វផ្សាយកសិកម្មដ៏សកម្មមួយទទួលបន្ទុកឱ្យមានលំហូរព័ត៌មានទៅ និងមក តាមរយៈសិក្ខាសាលារួមគ្នា និងកិច្ចប្រជុំធ្វើផែនការរួមគ្នាក្នុងចំណោមអ្នកស្រាវជ្រាវ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករ និងវិស័យឯកជន នឹងអាចជួយធានាឱ្យមានការតភ្ជាប់ដោយរលូន។

ផែនការសកម្មភាព និង/ឬសកម្មភាពខាងក្រោមនេះត្រូវបានដាក់ចេញសម្រាប់ការអនុវត្ត៖

- ចំណងទាក់ទងរវាងការស្រាវជ្រាវ-ការផ្សព្វផ្សាយកសិកម្ម-ការអប់រំតាមរយៈកិច្ចប្រជុំជាប្រចាំ សិក្ខាសាលា និងការបោះពុម្ពផ្សព្វផ្សាយរួមគ្នា។ កិច្ចប្រជុំរវាងបុគ្គលិកស្រាវជ្រាវ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម នឹងត្រូវធ្វើ

ឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អ្នកវិទ្យាសាស្ត្ររបស់ CARDI នឹងចូលរួមយ៉ាងសកម្មនៅក្នុងសន្និសីទផ្សព្វផ្សាយកសិកម្មជាតិប្រចាំឆ្នាំ។អ្នកវិទ្យាសាស្ត្រស្រាវជ្រាវនឹងសហការជាមួយភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដើម្បីធ្វើការអនុវត្តសាកល្បងផ្ទៀងផ្ទាត់បច្ចេកវិទ្យានៅវាលស្រែរបស់កសិករដែលអាចផ្តល់លទ្ធផលឱ្យមានការបោះពុម្ពផ្សាយរួមគ្នា។ ក្រុមការងារលេចធ្លោរបស់អ្នកសហការផ្នែកស្រាវជ្រាវផ្សព្វផ្សាយនឹងត្រូវបានជ្រើសរើស និងទទួលស្គាល់នៅក្នុងសន្និសីទជាតិ

- អភិវឌ្ឍបច្ចេកវិទ្យា ដែលមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ និងលើកកម្ពស់ការដាក់បញ្ចូលយេនឌ័រ។ ការដាក់បញ្ចូលយេនឌ័រក៏រួមមានការអភិវឌ្ឍកុមារ និងការការពារកុមារនៅក្នុងវិស័យកសិកម្មផងដែរ
- គាំទ្រ/ពង្រឹងCARDIឱ្យអភិវឌ្ឍបច្ចេកវិទ្យាធនជាមួយអាកាសធាតុសមស្របសម្រាប់លក្ខខ័ណ្ឌក្នុងមូលដ្ឋាន។ គម្រោងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងផ្តួចផ្តើមឱ្យមានប្រព័ន្ធគាំទ្រហិរញ្ញប្បទានដើម្បីធ្វើការស្រាវជ្រាវ និង គម្រោងអនុវត្តបង្ហាញស្តីពីកសិកម្មវៃឆ្លាតនិងអាកាសធាតុ
- CARDI នឹងធ្វើជាដៃគូជាមួយ INGOs និងមជ្ឈមណ្ឌល CGIAR អន្តរជាតិដើម្បីអភិវឌ្ឍ/កែសម្រួលបច្ចេកវិទ្យាថ្មីៗដែលសមស្របសម្រាប់លក្ខខ័ណ្ឌក្នុងមូលដ្ឋាន
- អភិវឌ្ឍនិងលើកកម្ពស់បច្ចេកវិទ្យាដែលចូលរួមចំណែកដល់ការបង្កើតមុខរបរឱ្យយុវជននិងទាក់ទាញយុវជនឱ្យចាប់យកជំនាញវិជ្ជាជីវៈផ្នែកកសិកម្ម។ យុវជនគឺជាអនាគតរបស់ប្រទេស ហើយការទាក់ទាញពួកគេឱ្យមកកាន់វិស័យកសិកម្ម ការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ គឺជាការចាំបាច់ណាស់សម្រាប់ជីវភាពរស់នៅប្រកបដោយនិរន្តរភាព
- គាំទ្រភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជនដើម្បីអភិវឌ្ឍ ធ្វើតេស្តសាកល្បងនៅទីវាល និងផ្សព្វផ្សាយលទ្ធផលការស្រាវជ្រាវជូនដល់អ្នកប្រើប្រាស់ ឬកសិករគោលដៅ
- អភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មានកសិកម្មនិងគេហទំព័រផ្សព្វផ្សាយកសិកម្មជាប្រព័ន្ធគ្រប់គ្រងចំណេះដឹងអេឡិចត្រូនិចសម្រាប់ការផ្សព្វផ្សាយកសិកម្ម។ កិច្ចសហការរវាង CARDI និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងជួយធានាថាអត្ថប្រយោជន៍នៃលទ្ធផលការស្រាវជ្រាវកសិកម្ម ត្រូវបានបកស្រាយទៅជាការអនុវត្តបានយ៉ាងមានប្រសិទ្ធផលខ្ពស់នៅកម្រិតមូលដ្ឋាននឹងត្រូវបានកសិករទទួលយកទៅកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ខ្លួន។

វេទិកាថ្នាក់ជាតិស្តីពីការស្រាវជ្រាវកសិកម្ម ការអប់រំ និងការផ្សព្វផ្សាយនឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំដើម្បីបង្កើតការយល់ដឹង ស្ពានចំណេះដឹង ផ្លាស់ប្តូរគំនិតគ្នាទៅវិញទៅមកស្តីពីបច្ចេកវិទ្យាថ្មីៗ និងការច្នៃប្រឌិតថ្មី ព្រមទាំងចែករំលែកបទពិសោធន៍ និងមេរៀនដែលបានទទួលពីមូលដ្ឋាន។ ទាំងវិស័យសាធារណៈ និងវិស័យឯកជននឹងត្រូវអញ្ជើញឱ្យចូលរួមក្នុងវេទិកាប្រចាំឆ្នាំ។

**ថវិកាប៉ាន់ប្រមាណ៖**

**តារាងទី ៨៖ ថវិកាប៉ាន់ប្រមាណសម្រាប់ការតភ្ជាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្មសម្រាប់អភិវឌ្ឍបច្ចេកវិទ្យា (ដុល្លារអាមេរិក)**

| សកម្មភាពក្នុងផែនការសកម្មភាព | ឆ្នាំទី 1 | ឆ្នាំទី 2 | ឆ្នាំទី 3 | ឆ្នាំទី 4 | ឆ្នាំទី 5 | សម្គាល់ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| ការចំណាយសម្រាប់កិច្ចប្រជុំប្រចាំខែរបស់ AEAC/ អនុគណៈកម្មាធិការស្រាវជ្រាវ-ការផ្សព្វផ្សាយ | $12,000 | $12,000 | $12,000 | $12,000 | $12,000 | @ $500/កិច្ចប្រជុំ AEAC/ អនុគណៈកម្មាធិការស្រាវជ្រាវ-ផ្សព្វផ្សាយ |
| សន្និសិទជាតិប្រចាំឆ្នាំសម្រាប់ការស្រាវជ្រាវការផ្សព្វផ្សាយ | $100,000 | $100,000 | $10,000 | $100,000 | $100,000 | $100,000/ឆ្នាំសម្រាប់សន្និសិទនិងការផ្តល់រង្វាន់សម្រាប់ការស្រាវជ្រាវ-ផ្សព្វផ្សាយ |
| ការស្រាវជ្រាវបែបអនុវត្ត និងការផ្សព្វផ្សាយដើម្បីផ្តល់មូលនិធិការរួមបញ្ចូលយេនឌ័រ និងការអភិវឌ្ឍកុមារ | $110,000 | $110,000 | $110,000 | $110,000 | $110,000 | $10,000 ក្នុងមួយខេត្តសម្រាប់ខេត្តក្នុងគម្រោង ASPIRE |
| អភិវឌ្ឍ និងធ្វើតេស្តសាកល្បងនៅទីវាលចំពោះការអនុវត្តកសិកម្មធន់ទៅនឹងអាកាសធាតុ | $110,000 | $110,000 | $110,000 | $110,000 | $110,000 | $10,000 ក្នុងមួយខេត្តសម្រាប់ខេត្តក្នុងកម្មវិធី ASPIRE |
| **សរុប** | **$332,000** | **$332,000** | **$332,000** | **$332,000** | **$332,000** | **$1,660,000** |

## ៤. ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម

ការផ្សព្វផ្សាយកសិកម្មគឺជាដំណើរការអប់រំមួយ។ មុខងារចម្បងរបស់ការផ្សព្វផ្សាយកសិកម្ម គឺដើម្បីសម្របសម្រួលការរៀនសូត្រ និងពង្រីកចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗនៅក្នុងបរិយាកាសការអប់រំក្រៅប្រព័ន្ធដើម្បីកែលម្អផលិតភាពកសិកម្ម និងបង្កើនចំណូលរបស់កសិករ។

ការផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាព ប្រើប្រាស់ព័ត៌មាន និងសម្ភារៈការអប់រំដែលផ្អែកលើសេចក្តីត្រូវការ និងមានលក្ខណៈបំពេញបន្ថែមទៅលើការទទួលយកបច្ចេកវិទ្យា និងការអនុវត្តថ្មីៗ។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មច្រើនតែប្រើប្រាស់សម្ភារៈផ្សព្វផ្សាយកសិកម្ម ប្រសិនបើសម្ភារៈទាំងនោះជាសម្ភារៈទាន់សម័យ ឬមានបច្ចុប្បន្នភាពមានព័ត៌មានផ្អែកលើការស្រាវជ្រាវ និងអាចចូលទៅបើកមើលបានភ្លាមៗ និងងាយស្រួលយល់សម្រាប់កសិករ។

**គោលដៅ៖** អភិវឌ្ឍព័ត៌មាន និងសម្ភារៈការបណ្តុះបណ្តាលកសិកម្មដែលមានលក្ខណៈងាយស្រួលយល់សម្រាប់អ្នកប្រើប្រាស់ និងផ្អែកលើការស្រាវជ្រាវដើម្បីឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករនាំមុខ និងដៃគូអភិវឌ្ឍយកទៅប្រើប្រាស់។

**គោលបំណង៖**

- បង្កើតមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មនៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

- រៀបចំបោះពុម្ពផ្សាយឯកសារ និងសម្ភារៈ ICT ដែលទុកចិត្តបាន សម្រាប់ឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករនាំមុខ និងដៃគូអភិវឌ្ឍយកទៅប្រើប្រាស់ជាមួយអតិថិជន
- ផ្សព្វផ្សាយការបោះពុម្ពផ្សាយ និងសម្ភារៈ ICT ផ្សព្វផ្សាយកសិកម្មតាមរយៈបណ្តាញសមស្របដូចជា ការប្រាស្រ័យទាក់ទងអន្តរបុគ្គល ក្រុម និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយទ្រង់ទ្រាយធំ។

**លទ្ធផលចុងក្រោយ៖** ព័ត៌មាននៅលើក្រដាស (របាយការណ៍សង្ខេប កូនសៀវភៅព្រឹត្តបត្រព័ត៌មាន សៀវភៅទិនានុលេខកសិកម្ម) និងសម្ភារៈ ICT (គេហទំព័រ ព្រមជាមួយធនធានអេឡិចត្រូនិចផ្សេងៗជាច្រើន ការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍) ផ្តោតការយកចិត្តទុកដាក់ការច្នៃប្រឌិតបង្កើតថ្មីផ្នែកកសិកម្ម និងអនុសាសន៍ស្តីពីដំណាំនៅទីវាល ផ្លែឈើ និងបន្លែ និងប្រវាក់តម្លៃសត្វ ព្រៃឈើ និងជលផល។ សម្ភារៈផ្សព្វផ្សាយកសិកម្មក៏ត្រូវរួមបញ្ចូលអនុសាសន៍ស្តីពីការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រ ការអភិវឌ្ឍកុមារ និងការធ្វើកសិកម្មជាវិជ្ជាជីវៈអាជីពសម្រាប់មនុស្សវ័យក្មេង។

ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈគួរជាទីទុកចិត្ត និងមានប្រយោជន៍ទាមទារការធ្វើការងាររួមគ្នាពីសំណាក់ អ្នកស្រាវជ្រាវផ្នែកកសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ព្រមទាំងបុគ្គលិកនៅក្នុង វិស័យឯកទេសផ្នែកព័ត៌មាន និងបច្ចេកវិទ្យាការប្រាស្រ័យទាក់ទង (ICT)។ ដំណើរការដ៏រឹងមាំមួយដែលត្រូវអនុវត្តតាមសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មគឺមានគូសបញ្ជាក់ជូនក្នុងរូបភាពទី៦។ ដំណើរការនេះជួយធានាថាឱ្យការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មមានគុណភាពសម្រាប់ឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករ និងដៃគូអភិវឌ្ឍនៅថ្នាក់មូលដ្ឋានយកទៅប្រើប្រាស់បាន។

**រូបភាពទី ៦. ក្រាហ្វិកលំហូរការងារសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម**




លក្ខណៈវិនិច្ឆ័យខាងក្រោមនឹងជួយធានាគុណភាពសម្ភារៈផ្សព្វផ្សាយកសិកម្ម៖ ព័ត៌មានដែលបង្ហាញជូនគឺផ្អែកលើការស្រាវជ្រាវផ្នែកកសិកម្មចុងក្រោយបំផុត ព័ត៌មាន គំនិត និងគោលគំនិតនានាត្រូវបានបង្ហាញក្នុងលក្ខណៈច្បាស់លាស់ និងខ្លីៗ (ពោលគឺប្រើប្រាស់ពាក្យឱ្យបានតិចបំផុតតាមដែលអាចធ្វើបាន និងដាក់បញ្ចូលរូបភាព និងជំនួយសម្រាប់ការមើលដូចជា ដ្យាក្រាម រូបភាព និងរូបថត បច្ចេកវិទ្យា/ការអនុវត្តថ្មីៗដែលត្រូវបានណែនាំឱ្យធ្វើមានលក្ខណៈស៊ីសង្វាក់ជាមួយវប្បធម៌ និងគុណតម្លៃក្នុងលំនៅស្ថាន ហើយឯកសារបោះពុម្ពផ្សាយសម្រាប់ការផ្សព្វផ្សាយកសិកម្មដូចជា ព្រឹត្តិបត្រ ខិតប័ណ្ណ ផ្ទាំងបដា រូបភាព វីឌីអូ គេហទំព័រ សារាចរ ។ល។ ត្រូវបានពិនិត្យឡើងវិញ និងអនុម័តដោយអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម មុនពេលយកទៅផ្សព្វផ្សាយតាមរយៈមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និង គេហទំព័រផ្សព្វផ្សាយកសិកម្ម ឬ ប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។

**ផែនការសកម្មភាព និងសកម្មភាព៖**

- បង្កើតអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC) ទទួលបន្ទុកការអភិវឌ្ឍសម្ភារៈការផ្សព្វផ្សាយកសិកម្មដោយមានតំណាងមកពី CARDI នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងនាយកដ្ឋាននានារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសនាយកដ្ឋានពាក់ព័ន្ធជាមួយ បសុសត្វ ព្រៃឈើ ជលផល ការគ្រប់គ្រងដី និងកៅស៊ូ។

- ប្រគល់ភារកិច្ចឱ្យអនុគណៈកម្មាធិការបច្ចេកទេស ទទួលបន្ទុកអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម ក្នុងការ អភិវឌ្ឍ សម្ភារៈឧបករណ៍ និងធនធាន (ឧ. ព្រឹត្តិបត្រ ផ្ទាំងបដា រូបភាព វីឌីអូ គេហទំព័រ។ល។) ដែលបាន ធានាគុណភាព ដែលបានឆ្លើយតបតាមសេចក្តីត្រូវការរបស់កសិករ និងដៃគូអភិវឌ្ឍនៅកម្រិតមូលដ្ឋាន ការ អភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មគួរអនុវត្តតាមអនុសាសន៍បានបង្ហាញជូនក្នុង រូបភាពទី៦
- ផលិតសម្ភារៈផ្សព្វផ្សាយកសិកម្មដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយលើក្រដាស និងប្រព័ន្ធផ្សព្វផ្សាយអេឡិច ត្រូនិច រួមទាំងការប្រកាសសេវាសាធារណៈតាមទូរទស្សន៍ វិទ្យុ និងសារគោលដៅចំពោះអ្នកទទួលព័ត៌មាន ជាក់លាក់
- អភិវឌ្ឍ និង/ឬ រៀបចំទម្រង់ធនធានផ្សព្វផ្សាយកសិកម្មឱ្យផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និង/ ឬគេហទំព័រផ្សព្វផ្សាយកសិកម្មដែលនឹងត្រូវបានចែករំលែកដោយអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងអភិវឌ្ឍកម្មវិធីអប់រំ និងព័ត៌មានដែលឆ្លើយតបបញ្ហាអន្តរវិស័យនានា ដូចជាការដាក់បញ្ចូលយេនឌ័រក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការ អភិវឌ្ឍសហគ្រិនភាពយុវជនជាដើម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/កម្មវិធី ASPIRE នឹងគាំទ្រឱ្យមានការបង្កើតមជ្ឈមណ្ឌលព័ត៌មាន កសិកម្ម (AIH) នៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។ AIH នឹងក្លាយជាយន្តការមួយសម្រាប់សម្របសម្រួលការ ប្រាស្រ័យទាក់ទងនឹងផែនការការងារសម្រាប់នាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា អង្គការវិស័យឯកជន ដៃគូអភិវឌ្ឍ និង អង្គការ មិនមែនរដ្ឋាភិបាល។ មុខងារជាក់លាក់របស់ AIH អាចរួមមាន៖

- ប្រមូល និងរក្សាទុកឯកសារពាក់ព័ន្ធពីនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ទីភ្នាក់ងារនានារួមមានដូចជា CARDI, RUA, PNCA និង KNSA
- ប្រមូលផ្តុំព័ត៌មានស្តីពីសេចក្តីត្រូវការរបស់កសិករ តម្រូវការទីផ្សារ និងនិន្នាការតម្លៃសម្រាប់មុខទំនិញកសិកម្ម ទៅតាមខេត្ត/ស្រុក
- រក្សាឱ្យមានដេតាបេសមួយសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រួមទាំងដៃគូអភិវឌ្ឍទៅតាមខេត្ត ស្រុក និងឃុំ
- បម្រើការងារជាទីកន្លែងបកស្រាយបញ្ជាក់ព័ត៌មានឱ្យច្បាស់ សម្រាប់ការអភិវឌ្ឍកសិកម្មក្នុងប្រទេសកម្ពុជា ពោលគឺជាអ្នកប្រមូល និងរក្សាទុកឯកសារ និងជួយសម្របសម្រួលក្នុងការស្វែងរកសំណៅឯកសារលើ ក្រដាស និង/ឬឯកសារឌីជីថលត្រឡប់មកវិញ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងក្លាយជាទីតាំងសម្រាប់ AIH ហើយ NATSC នឹងចង្អុលបង្ហាញប្រតិបត្តិ ការរបស់ AIH រួមទាំងការកំណត់អត្តសញ្ញាណការជ្រើសរើស និងការអនុម័តលើខ្លឹមសារគេហទំព័រ។ AIH និងគេហ ទំព័រផ្សព្វផ្សាយកសិកម្មនឹងអាចបើកមើលបាន សម្រាប់អតិថិជនដែលបានចុះឈ្មោះទាំងនៅក្នុងវិស័យរដ្ឋ និង ឯកជន។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មក៏ផ្តល់ទីតាំងសម្រាប់គេហទំព័រពីរភាសា គេហទំព័រផ្សព្វផ្សាយកសិកម្មសម្រាប់ ការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មាន។ គេហទំព័រផ្សព្វផ្សាយកសិកម្មអាចជាផ្នែកមួយនៃ AIH ឬជាគេហទំព័រ ឯករាជ្យដាច់ដោយឡែក។ គេហទំព័រនេះជាគេហទំព័រនៅលើប្រព័ន្ធអ៊ីនធើណេតដោយក្នុងនោះព័ត៌មានគួរជាទីជឿ ជាក់ និងទាន់ពេលវេលា ពីប្រភពនានា និងក្នុងទ្រង់ទ្រាយ និងទម្រង់ផ្សេងៗដូចជា សៀវភៅ អត្ថបទក្នុង

ព្រឹត្តិបត្រ សៀវភៅណែនាំ ព្រឹត្តិបត្រ ខិតប័ណ្ណ សារាចរ វីឌីអូ ប្លក់។ល។ ត្រូវបានរក្សាទុកជាប័ណ្ណសារដ្ឋានរៀបជាកាតាឡុក និងចាត់ចែងក្នុងលក្ខណៈឯកភាពគ្នា ហើយដាក់ជូនឱ្យមានសម្រាប់អតិថិជន អ្នកប្រើប្រាស់ចុងក្រោយ។

គេហទំព័រផ្សព្វផ្សាយកសិកម្មរួមមានកម្រងឧបករណ៍ ICT ដែលផ្តល់មុខងារផ្នែកការប្រមូលទិន្នន័យសម្រាប់ AIH (និងការគ្រប់គ្រងគុណភាពលើមុខងារទាំងនេះ) ជួយសម្រួលក្នុងការផ្សព្វផ្សាយ និងគ្រប់គ្រងគុណភាពលើសម្ភារៈផ្សព្វផ្សាយកសិកម្ម សម្របសម្រួលដល់ការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ក្រោមជាតិ និងជួយជម្រុញចំណងទាក់ទងរវាងអ្នកដើរតួនាទីនានាក្នុងបណ្តុំការផ្សព្វផ្សាយកសិកម្មជាមួយការស្រាវជ្រាវ (Pommier, 2017)។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងអភិវឌ្ឍធនធានអប់រំដទៃទៀតដូចជា ទិនានុលេខកសិកម្ម ឬ ប្រតិទិនដែលមានព័ត៌មានតាមរដូវសម្រាប់កសិករ។ ប្រតិទិននេះរួមមានព័ត៌មានដើម្បីជំនួយក្នុងសម្រេចចិត្តគ្រប់គ្រងកសិដ្ឋានផ្អែកតាមរដូវ។ ប្រតិទិននេះក៏អាចមានសារបច្ចេកទេសសំខាន់ៗដូចជា របៀបពិនិត្យតាមដានទីវាលដើម្បីរកសត្វល្អិត កត្តាចង្រៃ និងជម្ងឺ អត្ថប្រយោជន៍នៃវិធានការថែទាំដំណាំ (IPM) ការគ្រប់គ្រងថ្នាល គោលការណ៍ណែនាំសម្រាប់ការដាំដុះ។ល។ បន្ថែមលើនេះទៀត គេហទំព័រអាចដាក់ឱ្យមានគោលការណ៍ណែនាំសម្រាប់ការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងការផ្តល់កិច្ចសន្យាសេវាផ្សព្វផ្សាយកសិកម្មទៅឱ្យអង្គការក្នុងមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន។

គេហទំព័រផ្សព្វផ្សាយកសិកម្ម ត្រូវរក្សាឱ្យមានលក្ខណៈសាមញ្ញ ងាយស្រួលបើក និងមានប្រសិទ្ធភាពចំណាយ។ អ្នកទទួលព័ត៌មានគោលដៅជាចម្បង គឺភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករនាំមុខ និងអ្នកផ្តល់សេវា។ គេហទំព័រ ក៏ជាម្ចាស់ផ្ទះសម្រាប់មជ្ឈមណ្ឌលទទួលទូរសព្ទ ឬលេខទូរសព្ទទាន់ហេតុការណ៍សម្រាប់កសិករផងដែរ។ បុគ្គលិកនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងបានទទួលការបណ្តុះបណ្តាល ដើម្បីគ្រប់គ្រងលើគេហទំព័រផ្សព្វផ្សាយកសិកម្ម។

ការប្រកាសសេវាសាធារណៈតាមទូរទស្សន៍ និងវិទ្យុ (PSAs) នឹងត្រូវបានអភិវឌ្ឍឡើង និងប្រើប្រាស់តាមការសមស្រប។ PSAs ទាំងអស់នេះ នឹងត្រូវបានបង្កើតឡើងលើបញ្ហា/ប្រធានបទដែលត្រូវបានជ្រើសរើសដោយ AEAC និងនាយកដ្ឋាន និងទីភ្នាក់ងារកណ្តាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ថវិការប៉ាន់ប្រមាណៈ**

**តារាងទី ៩. ថវិកាប៉ាន់ប្រមាណសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម (ដុល្លារអាមេរិក)**

| សកម្មភាពក្នុងផែនការសកម្មភាព | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | សម្គាល់ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| ការចំណាយសម្រាប់កិច្ចប្រជុំប្រចាំខែរបស់ AEAC/ អនុគណៈកម្មាធិការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម (EMD) | $12,000 | $12,000 | $12,000 | $12,000 | $12,000 | @ $500/កិច្ចប្រជុំរបស់ AEAC/អនុគណៈកម្មាធិការ EMD |
| ការបោះពុម្ពផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយលើ | $50,000 | $50,000 | $50,000 | $50,000 | $50,000 | $2000 - $3,000/ ការបោះពុម្ពផ្សាយ |

| | | | | | | |
|---|---|---|---|---|---|---|
| ក្រដាស៖ របាយការណ៍សង្ខេប,ព្រឹត្តបត្រព័ត៌មាន, ទិនានុប្បវត្តិកសិកម្ម | | | | | | |
| ការអភិវឌ្ឍធនធានអេឡិចត្រូនិចសម្រាប់ AIH, គេហទំព័រផ្សព្វផ្សាយកសិកម្ម | $50,000 | $50,000 | $50,000 | $50,000 | $50,000 | ការប៉ាន់ប្រមាណកញ្ចប់សរុប |
| ប្រតិបត្តិការរបស់ AIH និងគេហទំព័រផ្សព្វផ្សាយកសិកម្ម | $10,000 | $10,000 | $10,000 | $10,000 | $10,000 | ហាតវែរ និងសូហ្វវែរសម្រាប់ AIH និងគេហទំព័រផ្សព្វផ្សាយកសិកម្ម |
| **សរុប** | **$122,000** | **$122,000** | **$122,000** | **$122,000** | **$122,000** | **$510,000** |

## ៥. ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម

គោលដៅរបស់សេវាផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា គឺដើម្បីពង្រឹងផលិតភាពកសិកម្ម ពិពិធកម្ម និងការធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ សេវាផ្សព្វផ្សាយកសិកម្ម ក៏មានគោលដៅកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់កសិករខ្នាតតូចក្រីក្រ និងងាយរងគ្រោះផងដែរ។ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា គឺជាគន្លឹះដើម្បីសម្រេចបានគោលដៅទាំងនេះ។

ជាទូទៅ ច្រើនតែមានការជាន់គ្នាមួយចំនួននៅក្នុងតួនាទី និងការទទួលខុសត្រូវផ្នែកសេវាផ្សព្វផ្សាយកសិកម្ម រវាងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង អគ្គនាយកដ្ឋានកសិកម្ម។ ក្របខ័ណ្ឌការងារប្រតិបត្តិការ របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ហួសសម័យដែលនាំឱ្យកើតមានអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មជាជម្រើសជំនួសផ្សេងទៀតដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម វិស័យឯកជន។ ក្របខ័ណ្ឌការងារផ្នែកស្ថាប័នដែលមានស្រាប់ពុំរួមបញ្ចូលយន្តការនិយ័តកម្ម ដើម្បីបង្កើត និងជំរុញការអនុវត្តបទដ្ឋានសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម កែលម្អលក្ខណៈវិជ្ជាជីវៈ បង្កើតគណនេយ្យភាព ឬពិនិត្យតាមដានលទ្ធផលការងារឡើយ។

ការពិនិត្យ SWAT និងការពិនិត្យឯកសារនានាស្តីពីប្រសិទ្ធភាពការផ្សព្វផ្សាយកសិកម្មបានចង្អុលបង្ហាញថា ការច្នៃប្រឌិតបង្កើតថ្មី និង បច្ចេកវិទ្យានានាដែលបានផ្សព្វផ្សាយ នៅពុំទាន់បានក្តោបយកបរិស្ថានសង្គម សេដ្ឋកិច្ចរបស់អតិថិជន ច្រវាក់តម្លៃ និងតម្រូវការទីផ្សារឱ្យបានពេញលេញនៅឡើយ។ បច្ចេកវិទ្យាមួយចំនួនត្រូវបានផ្សព្វផ្សាយដោយពុំបានពិចារណាលើពិពិធភាពផ្នែកក្សេត្រ-បរិស្ថាន និងចំណេះដឹងរបស់អតិថិជនឡើយ។ បន្ថែមលើនេះទៀត ការច្នៃប្រឌិតបង្កើតថ្មីដើម្បីឆ្លើយតបការប្រែប្រួលអាកាសធាតុ និងការបញ្ចូលយេនឌ័រ គឺនៅខ្វះខាតនៅឡើយ។ ដូចគ្នានេះដែរ ពុំមានគំរូណាមួយសម្រាប់កែលម្អកិច្ចសហការ និងការស្ថាបនាបណ្តាញរវាងអ្នកស្រាវជ្រាវការផ្សព្វផ្សាយ ការអប់រំ និងវិស័យឯកជន ដើម្បីជាមូលដ្ឋានរួមសម្រាប់ផ្តល់សេវាអភិវឌ្ឍន៍កសិកម្មរួមគ្នានោះ

ឡើយ។ ជំនួសឱ្យការស្ថាបនាការទុកចិត្តគ្នាទៅវិញទៅមក និងសម្រេចបានសេវាដែលមានលក្ខណៈសុខដុមនីយកម្ម វិស័យសាធារណៈ និងឯកជន (ឧ. NGOs/CBOs) ជារឿយៗតែងប្រជែងគ្នាដើម្បីបានទទួលធនធាន។ អនុលោមតាម PAEC និងផែនការមេវិស័យកសិកម្មឆ្នាំ ២០៣០ គោលបំណងនៃផែនការសកម្មភាពនេះ គឺដើម្បីពង្រឹងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មឈានទៅពង្រឹងសន្តិសុខស្បៀងសម្រាប់ប្រទេសកម្ពុជា។

**គោលដៅ៖** ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងផលិតភាពកសិកម្ម ពិពិធកម្ម និងការធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**គោលបំណង៖** កែលម្អប្រសិទ្ធភាពការផ្តល់សេវាផ្សព្វផ្សាយកសិកម្មតាមរយៈប្រតិបត្តិការតាមបែបវិមជ្ឈការ ភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន សេវាផ្អែកលើសេចក្តីត្រូវការ និងតម្រូវការទីផ្សារ និងការប្រើប្រាស់កសិករនាំមុខ និង ICTs សម្រាប់ការផ្តល់សេវា។

**លទ្ធផលចុងក្រោយ៖** កសិករមានចំណេះដឹង និងបានទទួលព័ត៌មានអំពីគំនិតបង្កើតថ្មី និងបច្ចេកវិទ្យាកសិកម្មថ្មីៗ និងទទួលយកបច្ចេកវិទ្យាថ្មីៗទាក់ទងជាមួយផលិតកម្មកសិកម្ម ពិពិធកម្មកសិដ្ឋាន ការធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម និងបង្កើនការអភិរក្សធនធានធម្មជាតិ។

## ផែនការសកម្មភាព និងសកម្មភាព៖

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលស្គាល់ថា សមត្ថភាពរបស់អង្គការផ្សព្វផ្សាយកសិកម្មក្នុងការផ្តល់សេវាប្រកបដោយគុណភាពនៅមានភាពទន់ខ្សោយ ហើយតួនាទីការផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋាន និងទីភ្នាក់ងារនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមានភាពស្រពិចស្រពិល។ ដើម្បីឆ្លើយតបចំណុចខ្សោយទាំងនេះ PAEC (២០១៥) បានផ្តល់អនុសាសន៍ឱ្យធ្វើវិមជ្ឈការប្រតិបត្តិការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ នៅក្រោមគោលនយោបាយថ្មីនេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក ដើម្បីអភិវឌ្ឍផែនការរួមបញ្ចូលមួយសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងទទួលខុសត្រូវក្នុងការពិនិត្យតាមដាន និងវាយតម្លៃលើសេវាផ្សព្វផ្សាយកសិកម្មនៅក្នុងខេត្តផងដែរ។ ការិយាល័យកសិកម្មស្រុក នឹងធ្វើផែនការកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់មូលដ្ឋានក្នុងកិច្ចសហការជាមួយគណៈកម្មាធិការភាគីពាក់ព័ន្ធ ដូចជាក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក និងគណៈកម្មាធិការកសិកម្មឃុំជាដើម។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក នឹងរក្សាបញ្ជីបច្ចុប្បន្នភាពនៃអ្នកផ្តល់សេវា និងអនុវត្តកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មជាភាពជាដៃគូរវាងរដ្ឋ និងឯកជន ឬដោយគ្រាន់តែចុះកិច្ចសន្យាជួលអ្នកផ្តល់សេវា។

ផែនការសកម្មភាពនេះ សូមផ្តល់អនុសាសន៍យ៉ាងខ្លាំងក្លាឱ្យសេវាផ្សព្វផ្សាយកសិកម្ម និងសកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវមានលក្ខណៈផ្អែកលើសេចក្តីត្រូវការ ឬជំរុញដោយតម្រូវការ ពោលគឺពុំមែនជំរុញដោយការផ្គត់ផ្គង់ឡើយ។ គណៈកម្មាធិការកសិកម្មឃុំ (CAC) និងក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក (DATSC) នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើការវាយតម្លៃសេចក្តីត្រូវការក្នុងមូលដ្ឋាន ការកំណត់អាទិភាពក្នុងចំណោមសេចក្តីត្រូវការផ្សព្វផ្សាយកសិកម្មក្នុងមូលដ្ឋាន និងធ្វើឱ្យមានការចូលរួម និងផ្តល់មូលនិធិ (ការផ្តល់កិច្ចសន្យាជួល) សេវាដល់អ្នកផ្តល់សេវាក្នុងមូលដ្ឋាន ឧទាហរណ៍ ដូចជា NGOs អង្គការកសិករ និង អង្គការវិស័យឯកជន។ លក្ខណៈវិនិច្ឆ័យដែលត្រូវបានផ្តល់អនុសាសន៍ដោយធនាគារពិភពលោក (ពោលគឺ ទម្ងន់ ៤០% សម្រាប់អត្តសញ្ញាណអង្គភាព ៣០% សម្រាប់សមត្ថ

ភាព និងបទពិសោធន៍របស់អង្គការ ២០% សម្រាប់ប្រព័ន្ធគ្រប់គ្រង និង១០% ដែលនៅសល់សម្រាប់កត្តាដែលត្រូវពិចារណាដទៃទៀត) នឹងត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃលើអ្នកផ្តល់សេវា។ គួរកត់សម្គាល់ថា លក្ខខណ្ឌវិនិច្ឆ័យទាំងអស់នេះ ត្រូវបានផ្តល់សុពលភាពដោយ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងឆ្នាំ ២០១៧។

គេអាចចោទសួរថា តើវិមជ្ឈការ ឯកជនភាវូបនីយកម្ម និងយន្តការផ្តល់សេវាបែបពហុនិយម អាចកែលម្អប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្មឬយ៉ាងណា។ ភស្តុតាងបង្ហាញឱ្យឃើញថា ការឈានឆ្ពោះទៅការផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈវិមជ្ឈការ ពហុនិយម និងជំរុញដោយតម្រូវការទីផ្សារ គឺមានប្រសិទ្ធភាពចំណាយខ្ពស់ ព្រោះសេវាផ្សព្វផ្សាយកសិកម្មដែលផ្អែកលើសេចក្តីត្រូវការ និងបូករួមជាមួយលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានធាតុចូលកសិកម្ម និងទីផ្សារមានសក្តានុពលកែលម្អផលិតកម្មអាហារ។ ជាលទ្ធផល មានចរន្តដែលពេញចិត្តចំពោះការបង្កើតឱ្យមានប្រព័ន្ធពហុនិយមក្នុងការផ្តល់សេវាដែលមានលក្ខណៈចូលរួមនិងដឹកនាំដោយតម្រូវការ។ ទោះយ៉ាងណាក្តី អង្គភាពផ្សព្វផ្សាយកសិកម្មចាំបាច់ត្រូវចៀសវាងទំនាស់តួនាទី និងត្រូវអនុវត្តតាមគោលការណ៍ដែលចាត់ទុកថាពុំអាចមានការផ្សព្វផ្សាយបានទេ ប្រសិនបើគ្មានខ្លឹមសារ។ ចំណុចនេះតម្រូវឱ្យ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ត្រូវត្រួតពិនិត្យយ៉ាងហ្មត់ចត់លើប្រតិបត្តិការវិមជ្ឈការនៃការផ្សព្វផ្សាយកសិកម្ម ដើម្បីធានាថាកសិករបានទទួលដំបូន្មានល្អៗ។

ផែនការសកម្មភាព និងសកម្មភាពដែលមានបង្ហាញជូនខាងក្រោម នឹងជួយធានាឱ្យមានការផ្តល់សេវាផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាពក្នុងប្រទេសកម្ពុជា៖

- និយមន័យច្បាស់លាស់ស្តីពីតួនាទី និងការទទួលខុសត្រូវផ្នែកការផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋាន ទីភ្នាក់ងារនានារបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រួមទាំងការពិពណ៌នាពីការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការវាយតម្លៃបុគ្គលិក ដើម្បីទទួលបានរង្វាន់ និងទទួលស្គាល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មសម្រាប់ការបំពេញការងារលេចធ្លោ
- នាយកដ្ឋានទាំងអស់ក្រោមអគ្គនាយកដ្ឋានកសិកម្ម ត្រូវផ្ទេរមុខងារនិងការទទួលខុសត្រូវផ្នែកការផ្សព្វផ្សាយកសិកម្មទៅឱ្យស្ថិតនៅក្រោមការសម្របសម្រួលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រទេសកម្ពុជា នឹងអនុវត្តតាមការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយពហុនិយម (ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន) នៅថ្នាក់ស្រុក ឃុំ និងភូមិ។ ការផ្សព្វផ្សាយកសិកម្ម នឹងលើកកម្ពស់ឱកាសការរៀនសូត្រពីកសិករទៅកសិករ ដោយប្រើប្រាស់ហិរញ្ញប្បទានសម្រាប់សេវាផ្សព្វផ្សាយកសិកម្មជូនដល់កសិករខ្នាតតូច (GESS) ដើម្បីអនុវត្តការធ្វើបង្ហាញ និងលើកកម្ពស់ការអនុវត្តកសិកម្មល្អ (GAPs)។
- មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករ និង អនុវត្តបង្ហាញបច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្មីចំនួនបីបន្ថែមទៀតដែលផ្តោតគោលដៅលើកសិកម្មតំបន់ខ្ពង់រាប កសិកម្មតំបន់ឆ្នេរ និងកសិកម្មក្នុងតំបន់ទន្លេសាប
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនឹងអភិវឌ្ឍ ព្រមទាំងអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្មបែបច្នៃប្រឌិតបង្កើតថ្មី (ឧ. ការអនុវត្តបង្ហាញ ការបណ្តុះបណ្តាលកសិករនាំមុខ) ដោយផ្តោតគោលដៅលើប្រធានបទអន្តរវិស័យ រួម

ទាំងការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រ ការអភិវឌ្ឍកុមារ និងការទាក់ទាញយុវជនមកក្នុងកសិកម្ម។

- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងអភិវឌ្ឍ និងអនុវត្តផែនការសម្រាប់ការបណ្តុះបណ្តាលក្នុងរយៈកំពុងបម្រើការងារសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញដំណើរការ និងលើការប្រើប្រាស់ ICTs និងប្រព័ន្ធផ្សព្វផ្សាយក្នុងការផ្សព្វផ្សាយកសិកម្ម។

ប្រទេសកម្ពុជា នឹងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ការិយាល័យកសិកម្មស្រុកដោយមានការចូលរួមយ៉ាងសកម្មពី**ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក** និង**គណៈកម្មាធិការកសិកម្មឃុំ** នឹងធ្វើផែនការលើកម្មវិធីផ្សេងៗជាច្រើន ដើម្បីបម្រើឱ្យកសិករក្នុងប្រភេទផ្សេងៗ និងដាក់ផែនការជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការអនុម័ត និងការផ្តល់ថវិកា។ សេវាផ្សព្វផ្សាយកសិកម្ម ដូចជាការបណ្តុះបណ្តាលកសិករនាំមុខ VEWs និង CEWs ធ្វើការអនុវត្តបង្ហាញនៅតាមកសិដ្ឋាន និងតាមផ្ទះ រៀបចំសាលារៀនស្រែកសិករ ចាត់ចែងផ្តល់ធាតុចូល (គ្រាប់ពូជ ថ្នាំសម្លាប់សត្វល្អិត និងជី) ផ្តល់សេវា និងការតភ្ជាប់កសិករទៅកាន់ទីផ្សារ និងត្រូវផ្តល់កិច្ចសន្យាជួលទៅឱ្យ NGOs, CBOs និងអង្គការកសិករដែលមានគុណវុឌ្ឍិគ្រប់គ្រាន់។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក នឹងសម្របសម្រួលដល់ការកសាងសមត្ថភាពអង្គការក្នុងមូលដ្ឋាន (ពោលគឺ អង្គការកសិករ អង្គការសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក ឬគណៈកម្មាធិការកសិកម្មឃុំ) និងធានាឱ្យមានការពិនិត្យតាមដាន និងវាយតម្លៃសមស្របលើកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មក្នុងមូលដ្ឋាន។

សេវារបស់វិស័យឯកជន ឬឯកជនភាវូបនីយកម្មលើសេវាផ្សព្វផ្សាយកសិកម្ម ពុំមែនសុទ្ធតែមានន័យថាអតិថិជនត្រូវតែបង់ប្រាក់សម្រាប់សេវានោះឡើយ។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា និងអង្គការឯកជនដទៃទៀត ឬបុគ្គលនានាអាចផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយឥតគិតថ្លៃ។ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគីជាច្រើនផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយឥតគិតថ្លៃតាមរយៈ NGOs និង/ឬ អង្គការឯកជន។ បន្ថែមលើនេះទៀត សេវាផ្សព្វផ្សាយកសិកម្ម ដែលត្រូវបានជ្រើសរើស និងបន្តទទួលបានមូលនិធិតាមរយៈមូលនិធិសាធារណៈ ហើយនៅតែអាចផ្តល់សេវាដោយឥតគិតថ្លៃ។

ប្រទេសកម្ពុជា នឹងអភិវឌ្ឍឱ្យមានក្រុម CEWs និង VEWS ជាសហគ្រិនក្នុងមូលដ្ឋាន ប៉ុន្តែពុំមែនជាអ្នក បច្ចេកទេសសេវាស៊ីវិលនោះឡើយ។ CEWs និង VEWS អាចធ្វើការដោយឯករាជ្យក្នុងនាមជាសហគ្រិន ឬធ្វើការជូនដល់វិស័យឯកជន ឬ NGO ឬសម្រាប់គម្រោងដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍ។ គោលដៅ គឺដើម្បីស្ថាបនាសមត្ថភាពក្នុងមូលដ្ឋានរបស់វិស័យឯកជន និង NGO ដើម្បីលើកកម្ពស់ពហុភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្រិតមូលដ្ឋាន។ គំរូនេះ គឺជាគំរូដែលមានលក្ខណៈច្នៃប្រឌិតបង្កើតថ្មី មានប្រសិទ្ធភាពចំណាយ និងមាននិរន្តរភាព។

សេវាផ្សព្វផ្សាយកសិកម្ម និងសកម្មភាពនានា នឹងត្រូវជួលទៅអ្នកផ្តល់សេវាក្នុងមូលដ្ឋាន ដូចជា CEWs និង VEWS NGOs និងអង្គការកសិករ។ វិធីសាស្រ្តផ្សព្វផ្សាយកសិកម្ម គឺរួមមានទាំងដំបូន្មានជាលក្ខណៈបុគ្គល និងការពិគ្រោះយោបល់តាមរយៈការចុះទៅដល់កសិដ្ឋាន និងផ្ទះ ការអនុវត្តបង្ហាញអំពីវិធីសាស្រ្ត និងលទ្ធផល កិច្ចប្រជុំក្រុម និងដំណើរទស្សនកិច្ច សាលារៀនស្រែកសិករ សកម្មភាពក្រុម ដូចជាការរកទីផ្សារសម្រាប់ផលិតផលតាមរយៈសហ

ករ និងការប្រើប្រាស់សម្ភារៈ ICT ជាដើម។ កម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម នឹងសង្កត់ធ្ងន់លើការប្រើប្រាស់ការរៀនសូត្រពីគ្នាទៅវិញទៅមករវាងកសិករ និងកសិករ។ សេវាផ្សព្វផ្សាយកសិកម្ម នឹងអភិវឌ្ឍសារថ្មីៗដែលទាញប្រយោជន៍ពីបច្ចេកវិទ្យា ICT ដែលមានលក្ខណៈច្នៃប្រឌិតបង្កើតថ្មី និងសមស្របតាមមូលដ្ឋាន (ទូរសព្ទវៃឆ្លាត គេហទំព័រ និងអ៊ីនធឺណិត) និងប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស (វិទ្យុ និងទូរទស្សន៍) សម្រាប់ការផ្សព្វផ្សាយព័ត៌មាន។

ការប្រើប្រាស់ ICTs ក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម នឹងត្រូវបានលើកកម្ពស់ដើម្បីពន្លឿនលទ្ធផលក្នុងលក្ខណៈមានប្រសិទ្ធភាពចំណាយខ្ពស់។ ការបង្កើត និង/ឬការផ្តល់ភាពរឹងមាំដល់អ្នកផ្តល់សេវាក្នុងមូលដ្ឋាន រួមទាំងសមាគមកសិករ និងសមាគមអ្នកនេសាទ ក៏នឹងបានទទួលការសម្របសម្រួលផងដែរ ជាពិសេសនៅក្នុងតំបន់ដែលពួកគេអាចផ្តល់ការផ្សព្វផ្សាយកសិកម្មបានប្រកបដោយប្រសិទ្ធភាព។

ការប្រើប្រាស់គោលវិធីច្រវាក់តម្លៃដើម្បីតភ្ជាប់កសិករជាមួយទីផ្សារ នឹងក្លាយជាអាទិភាពមួយនៃសេវាផ្សព្វផ្សាយកសិកម្ម។ ដើម្បីអនុញ្ញាតឱ្យកសិករអាចឆ្លើយតបចំពោះតម្រូវការទីផ្សារ គេហទំព័រផ្សព្វផ្សាយកសិកម្ម នឹងដាក់បង្ហាញព័ត៌មានអំពីតម្លៃមុខទំនិញម្ហូបអាហារនានាក្នុងទីផ្សារធំៗរបស់ប្រទេសកម្ពុជាជារៀងរាល់សប្តាហ៍/រៀងរាល់ថ្ងៃ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងធ្វើពិពិធកម្មកម្លាំងភ្នាក់ងារផ្សព្វផ្សាយកសិកម្មរបស់ខ្លួន។ បច្ចុប្បន្ននេះភ្នាក់ងារផ្សព្វផ្សាយកសិកម្មភាគច្រើន គឺជាបុរស ហើយកម្មវិធីផ្សព្វផ្សាយកសិកម្ម និងសកម្មភាពរបស់ពួកគេច្រើនតែចូលទៅរកកសិករភាគច្រើនគឺជាបុរស។ ស្ត្រីចូលរួមយ៉ាងសកម្មក្នុងវិស័យកសិកម្ម ដូចជាក្នុងផលិតកម្មដំណាំ បន្លែ និងត្រី។ ស្ត្រីក៏ចូលរួមក្នុងសកម្មភាពចិញ្ចឹមបសុសត្វខ្នាតតូចផងដែរ។ ស្ត្រីទទួលខុសត្រូវជាចម្បងក្នុងការធ្វើម្ហូបអាហារ មើលថែទាំកូន និងការលក់ដូរផលិតផលកសិកម្ម។ ហេតុនេះ ស្ត្រីនឹងបានទទួលអត្ថប្រយោជន៍យ៉ាងធំធេញពីការចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្ម។ បន្ថែមលើនេះទៀត ជារឿយៗបុរស គឺជាអ្នកដែលត្រូវធ្វើចំណាកស្រុក ហេតុនេះ ការបណ្តុះបណ្តាលស្ត្រី អាចជួយបង្កើនលទ្ធភាពក្នុងការកែលម្អជំនាញដែលបន្តស្ថិតនៅក្នុងសហគមន៍ និងផ្តល់អត្ថប្រយោជន៍ឱ្យប្រជាជនកាន់តែច្រើន។ ហេតុនេះ ការផ្តល់ឱកាសឱ្យស្ត្រីអាចរកចំណូលបន្ថែមពីការងារកសិកម្មតាមរយៈការទទួលយកបច្ចេកវិទ្យាកែលម្អថ្មីៗ អាចជាអាទិភាពមួយសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ ការចូលរួមរបស់ស្ត្រីក្នុងការផ្សព្វផ្សាយកសិកម្ម ក៏នឹងអាចជួយឱ្យពួកគាត់មានសំឡេង ក្នុងការសម្រេចចិត្តរបស់សហគមន៍ផងដែរ។

នៅក្រោមផែនការសកម្មភាពយុទ្ធសាស្ត្រនេះ យើងនឹងទទួលស្គាល់ការចូលរួមចំណែករបស់ស្ត្រីទៅក្នុងកសិកម្ម និងជីវភាពរស់នៅ ហើយដែលនឹងគាំទ្រដល់ការជ្រើសរើសចូលបម្រើការងារ និងបណ្តុះបណ្តាល VEWs, CEWs, និង AEAs ជាស្ត្រី។ គួរកត់សម្គាល់ថា VEWs និង CEWs នឹងបំពេញមុខងារជាសហគ្រិនកសិកម្មក្នុងមូលដ្ឋាន។ ការិយាល័យកសិកម្មស្រុក NGOs ក្រុមប្រឹក្សាឃុំ និងអង្គភាពវិស័យឯកជន អាចចុះកិច្ចសន្យាធ្វើការផ្តល់សេវាជូនពួកគេ។

សេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្ម ដូចជាការបណ្តុះបណ្តាលកសិករ និងការអនុវត្តបង្ហាញ នឹងត្រូវប្រារព្ធឡើងនៅតាមទីតាំង និងពេលវេលា ដែលផ្តល់ភាពងាយស្រួលចំពោះការចូលរួមរបស់ស្ត្រី។ ការផ្សព្វផ្សាយកសិកម្ម

នឹងទទួលស្គាល់ស្ត្រីក្នុងនាមជាដៃគូស្មើភាពនៅក្នុងការអភិវឌ្ឍសហគមន៍ ហើយស្ត្រី នឹងមានអ្នកតំណាងនៅក្នុងគណៈកម្មាធិការក្រុមប្រឹក្សា និងក្រុមការងារទាំងអស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តួចផ្តើមឱ្យមានប្រព័ន្ធវាយតម្លៃបុគ្គលិក ដើម្បីផ្តល់ការលើកទឹកចិត្ត ការទទួលស្គាល់ និងផ្តល់រង្វាន់ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មលេចធ្លោ។ ក្រសួងក៏នឹងប្រើប្រាស់ការវាយតម្លៃដែលបានកំណត់គោលដៅ ដើម្បីបង្ហាញអំពីផលប៉ះពាល់នៃប្រព័ន្ធការផ្តល់សេវាផ្សព្វផ្សាយកសិកម្មបែបវិមជ្ឈការ និងបែបពហុនិយម។

**ថវិកាប៉ាន់ប្រមាណ៖**

**តារាងទី ១០. ថវិកាប៉ាន់ប្រមាណសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម (ដុល្លារអាមេរិក)**

| សកម្មភាពក្នុងផែនការសកម្មភាព | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| វគ្គតម្រង់ទិសសម្រាប់បុគ្គលិក PDAFF/ADO ស្តីពីការអនុវត្ត PAEC | $22,000 | $22,000 | $22,000 | $22,000 | $22,000 | @ $2,000/ខេត្តសម្រាប់ខេត្តក្នុងកម្មវិធី ASPIRE |
| ផ្តល់មូលនិធិដល់ NGOs / វិស័យឯកជនឱ្យអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្ម៖ ការអនុវត្តបង្ហាញ ការបណ្តុះបណ្តាលកសិករនាំមុខ សាលារៀនស្រែកសិករ។ល។ | $550,000 | $550,000 | $550,000 | $550,000 | $550,000 | $50,000/ឆ្នាំក្នុងមួយខេត្តក្នុងកម្មវិធី ASPIRE |
| ផ្តល់មូលនិធិសម្រាប់ DAE ដើម្បីអភិវឌ្ឍ/ អនុវត្តកម្មវិធីអន្តរវិស័យ | $100,000 | $100,000 | $100,000 | $100,000 | $100,000 | $25,000 ក្នុងមួយកម្មវិធីអន្តរវិស័យសម្រាប់ ៤ កម្មវិធី គឺ៖ អាកាសធាតុ យេនឌ័រ យុវជន និងការអភិវឌ្ឍកុមារ |
| **សរុប** | **$672,000** | **$672,000** | **$672,000** | **$672,000** | **$672,000** | **$3,360,000** |

## ការផ្តល់ហិរញ្ញវត្ថុដល់សេវាផ្សព្វផ្សាយកសិកម្ម

ការផ្សព្វផ្សាយកសិកម្ម គឺជាសមាសធាតុដ៏សំខាន់កាត់ផ្តាច់មិនបាននៃការអភិវឌ្ឍកសិកម្ម។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តល់មូលនិធិសម្រាប់បុគ្គលិក និងបរិក្ខារចាំបាច់នានា ដូចជាទីតាំងការិយាល័យ សម្ភារៈប្រើប្រាស់ និសេវាធ្វើដំណើរសម្រាប់សេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ខេត្ត និងស្រុក)។ ក្រោមផែនការវិសហមជ្ឈមការ ឬវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងមានសមត្ថកិច្ចកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងលើការធ្វើផែនការ និងការធ្វើថវិកា។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបានទទួលថវិកាកម្មវិធីរបស់ខ្លួនដោយផ្ទាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏អាចទទួលបានមូលនិធិពីក្រសួងពាក់ព័ន្ធដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដើម្បីគាំទ្រដល់សេវាផ្សព្វផ្សាយកសិកម្មនៅក្នុងខេត្ត។ ថវិកាប៉ាន់ប្រមាណសម្រាប់ការអនុវត្ត PAEC គឺមានបង្ហាញជូនក្នុងតារាងទី១១។

### តារាងទី ១១. ការចំណាយសម្រាប់ការអនុវត្ត PAEC សម្រាប់រយៈពេល ៥ ឆ្នាំ

| សកម្មភាពជាសមាសធាតុ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | សរុបរយៈពេល ៥ ឆ្នាំ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| ១.ក្របខ័ណ្ឌការងារផ្នែកស្ថាប័ន និងផ្នែកច្បាប់(គណៈកម្មាធិការ សិក្ខាសាលា ការពិនិត្យឡើងវិញលើគោនយោបាយ និងការសិក្សា) | $305,000 | $305,000 | $305,000 | $305,000 | $305,000 | $1,525,000 |
| ២.ការអភិវឌ្ឍធនធានមនុស្ស | $2,120,000 | $2,480,000 | $2,480,000 | $2,750,000 | $2,005,000 | $11,835,000 |
| ៣. ការតភ្ជាប់ទំនាក់ទំនងរវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា | $332,000 | $332,000 | $332,000 | $332,000 | $332,000 | $1,660,000 |
| ៤. ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម | $122,000 | $122,000 | $122,000 | $122,000 | $122,000 | $610,000 |
| ៥. ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម | $672,000 | $6,72,000 | $672,000 | $672,000 | $672,000 | $9,410,000 |
| ៦. ការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាល ផ្សព្វផ្សាយកសិកម្ម | $500,000 | $1,000,000 | $1,000,000 | $1,000,000 | $1,000,000 | $4,500,000 |
| ៧. ការចំណាយផ្នែកការគ្រប់គ្រង (ការធ្វើដំណើរក្នុងមូលដ្ឋាន M&E។ល។) | $800,000 | $800,000 | $800,000 | $800,000 | $800,000 | $4,000,000 |
| **សរុប** | **$4,851,000** | **$11,761,000** | **$5,711,000** | **$5,981,000** | **$5,236,000** | **$33,540,000** |

តួនាទីរបស់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្លាស់ប្តូរពីតួនាទីជាអ្នកអនុវត្តការផ្សព្វផ្សាយកសិកម្មទៅជាតួនាទីជាអ្នកសម្របសម្រួលភាពជាដៃគូ។ ដើម្បីអនុវត្តតួនាទីថ្មីនេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាពផ្សេងៗជាច្រើន៖ ក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គភាពវិស័យឯកជន គម្រោងផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍ និង អង្គការមិនមែនរដ្ឋាភិបាល។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចក្លាយជាសហវិនិយោគិនជាមួយអង្គភាពទាំងអស់នេះ ដើម្បីសម្រេចបាននូវគោលបំណងអភិវឌ្ឍកសិកម្មក្នុងខេត្តរបស់ខ្លួន។

តាមរយៈការបម្រើការងារនៅក្នុងគណៈកម្មាធិការភាគីពាក់ព័ន្ធ រដ្ឋាភិបាលថ្នាក់មូលដ្ឋាននៅថ្នាក់ស្រុក និងថ្នាក់ឃុំ នឹងចូលរួមយ៉ាងសកម្មក្នុងការធ្វើផែនការអនុវត្តកម្មវិធីអភិវឌ្ឍកសិកម្មក្នុងមូលដ្ឋាន។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តួចផ្តើមឱ្យមានការបណ្តុះបណ្តាលអភិវឌ្ឍភាពជាអ្នកដឹកនាំមួយសម្រាប់អ្នកដឹកនាំថ្នាក់ខេត្ត និងថ្នាក់ស្រុក ដើម្បីអាចឱ្យពួកគាត់ចូលរួមយ៉ាងសកម្មក្នុងការគាំទ្រ និង/ឬ សហវិនិយោគនៅក្នុងការងារផ្សព្វផ្សាយកសិកម្ម។ ពួកគេអាចសហការវិនិយោគក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មក្នុងមូលដ្ឋាន រួមទាំងការងាររបស់ VEWs និង CEWs ក្នុងមូលដ្ឋានផងដែរ។

នៅក្រោមផែនការសកម្មភាពនេះ VEWs និង CEWs ពុំមែនជាបុគ្គលិកជម្មតាក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នោះទេ ប៉ុន្តែពួកគេនឹងបម្រើការងារជាអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មឯកជន និង/ឬសហគ្រិនដែលការងាររបស់ពួកគាត់ នឹងបានទទួលមូលនិធិតាមរយៈការចុះកិច្ចសន្យាផ្តល់សេវាពីទីភ្នាក់ងារ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងហិរញ្ញប្បទានសម្រាប់សេវាផ្សព្វផ្សាយកសិកម្មសម្រាប់កសិករខ្នាតតូច (GESS) និងពីអង្គភាពដទៃទៀត។ ហេតុនេះ ការជ្រើសរើស និងការបណ្តុះបណ្តាល VEWs និង CEWs គឺជាការចាំបាច់ណាស់ចំពោះនិរន្តរភាពរបស់គោលវិធីនេះ។ VEWs និង CEWs នឹងបង្ហាញខ្លួនជាគំរូរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឯកជន ហេតុនេះពួកគេត្រូវមានទាំងចំណេះដឹងបច្ចេកទេស និងសមត្ថភាពជំនាញទាក់ទងជាមួយដំណើរការ។ ពួកគេនឹងបានទទួលការបណ្តុះបណ្តាលជាសហគ្រិនកសិកម្មក្នុងមូលដ្ឋាន។

## ការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ

ការតាមដាន គឺពាក់ព័ន្ធជាមួយការវាយតម្លៃ ប៉ុន្តែខុសពីការវាយតម្លៃ។ ការតាមដានជួយធានាឱ្យបានថា កម្មវិធីត្រូវបានអនុវត្តអនុលោមតាមអ្វីដែលបានគាក់តែងមក។ ការតាមដានជួយឆ្លើយសំណួរ ដូចជាតើយើងកំពុងធ្វើរឿងត្រឹមត្រូវ ឬទេ និងតើយើងកំពុងធ្វើបានត្រឹមត្រូវឬទេ? ការពិនិត្យតាមដាន នឹងត្រូវស្ថាបនាឱ្យកើតមានក្នុងគម្រោងដើម្បីអាចតាមដានលើសូចនាករវឌ្ឍនភាពសំខាន់ៗក្នុងកម្មវិធីឬគម្រោងទាំងមូល។ ឧទាហរណ៍ស្តីពីសូចនាករតាមដានរួមមានដូចខាងក្រោម៖

- ការបង្កើតគណៈកម្មាធិការភាគីពាក់ព័ន្ធ និងកិច្ចប្រជុំរបស់គណៈកម្មាធិការជាទៀងទាត់
- ចំនួនដៃគូអភិវឌ្ឍដែលបានចូលរួមក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មទៅតាមខេត្ត និងស្រុក
- កម្រិតមូលនិធិសម្រាប់សកម្មភាពសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក
- ចំនួនភាពជាដៃគូរវាងវិស័យសាធារណៈ និង ឯកជនដែលបានបង្កើតឡើងនៅថ្នាក់ខេត្ត និង ថ្នាក់ស្រុក

- ប្រភេទការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលបានធ្វើឡើងនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ និងចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលបានទទួលការបណ្តុះបណ្តាល
- ចំនួន និងភាគរយកសិករគោលដៅដែលបានដឹងអំពី VEWs, CEWs និង AEAs
- សមាមាត្រចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្មធៀបជាមួយចំនួនកសិករ និង ភាគរយនៃភ្នាក់ងារផ្សព្វផ្សាយកសិកម្មជាស្ត្រី
- ចំនួនការអនុវត្តបង្ហាញនៅតាមកសិដ្ឋាន សាលារៀនស្រែកសិករ សិក្ខាសាលាការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម ក្រុមកសិករដែលត្រូវបានរៀបចំឡើង និងទទួលបានការគាំទ្រ និងកសិករដែលបានចូលរួមក្នុងកម្មវិធីអប់រំ ឬកម្មវិធីបណ្តុះបណ្តាលទាំងនេះ
- លទ្ធភាពទទួលបាន និង ប្រើប្រាស់ ICTs ពីសំណាក់កសិករនាំមុខ អ្នកផ្គត់ផ្គង់ធាតុចូល NGOs, VEWs, CEWs, AEAs និង AESs
- ចំនួនកសិករដែលទទួលយកការអនុវត្តកសិកម្មដែលបានផ្តល់អនុសាសន៍ឱ្យប្រើ
- ទិន្នផលក្នុងមួយហិចតាសម្រាប់ដំណាំចម្បង (គិតជាមធ្យម)។
- កំណើនទិន្នផលប្រៀបធៀបជាមួយឆ្នាំដំបូង ឬប្រសិទ្ធភាពផលិតកម្មដែលសម្រេចបាន
- ការពេញចិត្តរបស់កសិករជាមួយសេវាផ្សព្វផ្សាយកសិកម្ម និងសកម្មភាពផ្សព្វផ្សាយកសិកម្ម។

ការវាយតម្លៃឆ្លើយតបជាមួយសំណួរ "បើដូច្នេះ តើយ៉ាងដូចម្តេច" ពោលគឺ តើមានអ្វីកើតឡើងជាលទ្ធផលកម្មវិធី ឬគម្រោងនោះ? ការវាយតម្លៃផលប៉ះពាល់ផ្តល់ភស្តុតាងគួរជាទីជឿជាក់ថាតើកម្មវិធីផ្សព្វផ្សាយកសិកម្មនោះ គឺជាការវិនិយោគដ៏ល្អ ឬមិនល្អ។ តាមធម្មតាការវាយតម្លៃតែងប្រើប្រាស់ការវិភាគបែបបរិមាណវិស័យ ដោយប្រើព័ត៌មានធៀបជាមួយការពិតជាក់ស្តែង ដើម្បីប៉ាន់ប្រមាណទំហំនៃការផ្លាស់ប្តូរដែលកើតមានក្នុងផលប៉ះពាល់ដែលអាចអះអាងថា កើតចេញពីគម្រោង ឬអន្តរាគមន៍។ ដោយហេតុថា PAEC នឹងត្រូវអនុវត្តទូទាំងប្រទេស ប្រសិទ្ធភាព និង/ឬផលប៉ះពាល់ នឹងត្រូវបានវាស់វែងតាមរយៈការប្រៀបធៀបអ្នកចូលរួមក្នុងការផ្សព្វផ្សាយកសិកម្មជាមួយអ្នកពុំបានចូលរួម។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងមានអង្គភាពពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំមួយ។ បុគ្គលិក នឹងបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងប្រព័ន្ធការពិនិត្យតាមដាន និង ការវាយតម្លៃដ៏រឹងមាំសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/កម្មវិធី ASPIRE នឹងជួយជ្រោមជ្រែងក្នុងការស្ថាបនាសមត្ថភាពការពិនិត្យតាមដាន និងការវាយតម្លៃនៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការអនុវត្ត PAEC នឹងត្រូវបានវាយតម្លៃទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មុខងាររបស់ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង គណៈកម្មាធិការថ្នាក់ជាតិដូចជា AEAC និង NATSC និងការប្រើប្រាស់មជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្ម នឹងបានទទួលការវាយតម្លៃ។ ប្រសិទ្ធភាពនៃប្រតិបត្តិការបែបវិមជ្ឈការ និងបែបការចូលរួមនឹងបានទទួលការវាយតម្លៃផងដែរ។ ការពិនិត្យតាមដានលើការអនុវត្តការងាររបស់កម្មវិធីផ្សព្វផ្សាយកសិកម្ម និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក និងថ្នាក់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងត្រូវបានតាមដាន ហើយរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ នឹងត្រូវបានចងក្រងនៅថ្នាក់ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

មេរៀនទទួលបានពីការវាយតម្លៃក៏នឹងត្រូវបានចែករំលែកក្នុងពេលសន្និសីទជាតិប្រចាំឆ្នាំស្តីពីការផ្សព្វផ្សាយកសិកម្ម។ អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកផ្សព្វផ្សាយកសិកម្ម និង/ឬ ដៃគូផ្សព្វផ្សាយកសិកម្មឆ្នើម នឹងត្រូវបានជ្រើសរើស និងទទួលស្គាល់ចំពោះលទ្ធផលការងាររបស់ខ្លួន។

**តារាងទី ១២. សង្ខេបអនុសាសន៍សម្រាប់ផែនការសកម្មភាពយុទ្ធសាស្ត្រ**

| សមាសធាតុផែនការសកម្មភាព (នៅក្នុង PAEC) | អនុសាសន៍ |
|---|---|
| **១. ការរៀបចំផ្នែកស្ថានប័ន និងក្របខ័ណ្ឌការងារផ្នែកច្បាប់** | |
| | ១.១ បង្កើត និងធានាឱ្យមានការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពនៃគណៈកម្មាធិការភាគីពាក់ព័ន្ធផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ឧ. NATSC, AEAC, PAEWG, DATSC និង CAC)។ |
| | ១.២ ធ្វើវិមជ្ឈការប្រតិបត្តិការសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក |
| | ១.៣ សហការជាមួយដៃគូអភិវឌ្ឍ NGOs និងអ្នកផ្តល់សេវាក្នុងវិស័យឯកជនក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ឃុំ និងថ្នាក់ស្រុក។ |
| | ១.៤ អភិវឌ្ឍគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងបែបវិមជ្ឈការលើសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ |
| | ១.៥ បណ្តុះបណ្តាលសមាជិកគណៈកម្មាធិការភាគីពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ព្រមទាំងភ្នាក់ងារផ្សព្វផ្សាយកសិកម្មស្តីពីសេវាផ្សព្វផ្សាយកសិកម្មបែបចូលរួម ផ្អែកលើសេចក្តីត្រូវការ និងជំរុញដោយតម្រូវការទីផ្សារ។ |
| | ១.៦ ជ្រើសរើសធ្វើឱ្យសេវាផ្សព្វផ្សាយកសិកម្មមានលក្ខណៈពាណិជ្ជកម្ម និង/ឯកជនភាវូបនីយកម្ម។ |
| | ១.៧ អភិវឌ្ឍគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ផ្តល់មូលនិធិដល់ប្រព័ន្ធផ្តល់សេវាផ្សព្វផ្សាយកសិកម្មបែបពហុនិយម តាមរយៈភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន។ |
| | ១.៨ ផ្តួចផ្តើមដំណើរការក្នុងការកំណត់អត្តសញ្ញាណ ចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ |
| | ១.៩ អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំមួយសម្រាប់ការផ្សព្វផ្សាយកសិកម្ម។ |
| **២. ការអភិវឌ្ឍធនធានមនុស្ស** | |
| | ២.១ ទទួលយកប្រព័ន្ធបណ្តុះបណ្តាលបែបម៉ូឌុលសម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកផ្សព្វផ្សាយកសិកម្ម។ |
| | ២.២ អនុវត្តផែនការអភិវឌ្ឍធនធានមនុស្សសម្រាប់នាយកដ្ឋាន និងទីភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំង RUA, PLNSA, និង |

| | |
|---|---|
| | KNSA។ |
| | ២.៣ ប្រើប្រាស់ភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជនសម្រាប់ការបណ្តុះបណ្តាល VEWs និង CEWs និង AEAs។ RUA និង PNCA ជាអ្នកផ្តល់ការបណ្តុះបណ្តាលដល់ AES ហើយ RUA ជាអ្នកផ្តល់ការបណ្តុះបណ្តាលដែលមានការចេញវិញ្ញាបនបត្រនៅក្នុងប្រទេស |
| | ២.៤ ពង្រឹងការអភិវឌ្ឍសមត្ថភាពរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មតាមរយៈការបណ្តុះបណ្តាលក្នុងរយៈពេលបម្រើការងារ។ ក៏សាងសមត្ថភាពថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងរយៈពេលបម្រើការងារតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោល។ |
| | ២.៥ អភិវឌ្ឍ និងអនុវត្តប្រព័ន្ធចុះបញ្ជី និងទទួលស្គាល់គុណភាពសម្រាប់វិទ្យាស្ថានការបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម (ឧ. NGOs, CBOs, FOs)។ |
| | ២.៦ ពង្រឹងការបណ្តុះបណ្តាលក្នុងរយៈពេលបម្រើការងារ និងការបណ្តុះបណ្តាលសម្រាប់ការផ្តល់វិញ្ញាបនបត្រ (ថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិត) សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅក្នុងប្រទេស និងក្រៅប្រទេសកម្ពុជា។ |
| **៣. ការតភ្ជាប់រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា** | |
| | ៣.១ ពង្រឹងការតភ្ជាប់រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម និងការអប់រំតាមរយៈកិច្ចប្រជុំជាប្រចាំសិក្ខាសាលា និងការបោះពុម្ពផ្សាយរួមគ្នា។ |
| | ៣.២ ធ្វើជាដៃគូជាមួយ INGOs និងមជ្ឈមណ្ឌល CGIAR អន្តរជាតិ ដើម្បីអភិវឌ្ឍ/កែសម្រួលបច្ចេកវិទ្យានានាសមស្របសម្រាប់លក្ខខណ្ឌក្នុងមូលដ្ឋាន។ |
| | ៣.៣ ពង្រឹងភាពជាដៃគូរវាង GDA, DAE, និង CARDI ដើម្បីអភិវឌ្ឍ ធ្វើតេស្តនៅទីវាល និងផ្សព្វផ្សាយលទ្ធផលការស្រាវជ្រាវទៅដល់អ្នកប្រើប្រាស់ចុងក្រោយជាគោលដៅ ឬកសិករជាគោលដៅ។ |
| | ៣.៤ ពង្រឹង CARDI ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាធន់ទៅនឹងអាកាសធាតុសមស្របសម្រាប់លក្ខខណ្ឌក្នុងមូលដ្ឋាន។ |
| | ៣.៥ អភិវឌ្ឍ និងលើកកម្ពស់បច្ចេកវិទ្យាមានការយកចិត្តទុកដាក់ផ្នែកយេនឌ័រ។ អនុវត្តគម្រោងអភិវឌ្ឍកុមារ និងមុខរបរសម្រាប់យុវជន។ |
| **៤. ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម** | |
| | ៤.១ បង្កើតអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC) ទទួលបន្ទុកអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម ដោយមានអ្នកតំណាងមកពី CARDI, DAE, RUA និងនាយកដ្ឋានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ |
| | ៤.២ អភិវឌ្ឍសម្ភារៈ ឧបករណ៍ និងធនធានផ្សព្វផ្សាយកសិកម្ម ដែលមានលក្ខណៈគួរជាទីជឿជាក់ និងមានការធានាគុណភាព (ឧ. ព្រឹត្តិបត្រ ផ្ទាំងបដា វីដេអូ គេហទំព័រ។ល។) ផ្អែកលើសេចក្តីត្រូវការ និងអាទិភាពរបស់កសិករ។ |
| | ៤.៣ អភិវឌ្ឍការប្រកាសសាធារណៈតាមទូរទស្សន៍ និងវិទ្យុ និងសារផ្សេងៗជូនដល់ |

| | |
|---|---|
| | ភាគីពាក់ព័ន្ធជាក់លាក់។ |
| | ៤.៤ អភិវឌ្ឍធនធានផ្សព្វផ្សាយកសិកម្មដែលត្រូវផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និង/ឬគេហទំព័រផ្សព្វផ្សាយកសិកម្ម ដែលនឹងត្រូវចែករំលែកដោយអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់។ |
| | ៤.៥ ពង្រឹងមជ្ឈមណ្ឌលផ្សព្វផ្សាយកសិករ និងការអនុវត្តបង្ហាញបច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងបង្កើតមជ្ឈមណ្ឌលថ្មីៗ ដោយផ្តោតគោលដៅលើកសិកម្មតំបន់ខ្ពង់រាប កសិកម្មតំបន់ឆ្នេរ និងកសិកម្មតំបន់ទន្លេសាប។ |
| **៥. ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម** | |
| | ៥.១ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលខុសត្រូវក្នុងការធ្វើផែនការ និងអនុវត្តសេវាផ្សព្វផ្សាយកសិកម្ម។ |
| | ៥.២ ប្រទេសកម្ពុជា នឹងទទួលយកគោលវិធីផ្តល់សេវាផ្សព្វផ្សាយកសិកម្មបែបពហុនិយម។ |
| | ៥.៣ អភិវឌ្ឍកម្មវិធីផ្សព្វផ្សាយកសិកម្មថ្មីៗ ដឹកនាំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ផ្តោតគោលដៅលើប្រធានបទអន្តរវិស័យ ដូចជាការប្រែប្រួលអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រ និងការទាក់ទាញយុវជនមកក្នុងវិស័យកសិកម្ម។ |
| | ៥.៤ ពង្រឹងឱកាសការរៀនសូត្រពីគ្នាទៅវិញទៅមករវាងកសិករ និងកសិករដោយប្រើប្រាស់មូលនិធិដំបូង ដើម្បីលើកកម្ពស់ការអនុវត្តល្អផ្នែកកសិកម្ម។ |
| | ៥.៥ បង្កើតមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មនៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាប្រព័ន្ធគ្រប់គ្រងចំណេះដឹងអេឡិចត្រូនិច។ |
| | ៥.៦ ប្រើប្រាស់ការវាយតម្លៃផ្តោតគោលដៅដើម្បីបង្ហាញផលប៉ះពាល់នៃកម្មវិធីផ្សព្វផ្សាយកសិកម្ម។ |

# សន្និដ្ឋាន

PAEC គូសបញ្ជាក់យុទ្ធសាស្ត្រជាច្រើនសម្រាប់ការអនុវត្តគោលនយោបាយ។ យុទ្ធសាស្ត្រខាងក្រោមនេះមានសារៈសំខាន់ជាពិសេសដើម្បីអនុវត្តផែនការសកម្មភាពនេះ៖

ប្រទេសកម្ពុជា នឹងទទួលយកប្រព័ន្ធផ្តល់សេវាដែលមានលក្ខណៈចូលរួមផ្តែកលើសេចក្តីត្រូវការ ជំរុញដោយត្រូវការ។ ការផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងធ្វើការសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកដើរតួនាទីវិស័យឯកជន ដើម្បីអនុវត្តគោលនយោបាយដោយប្រើប្រាស់អង្គការផ្សព្វផ្សាយកសិកម្មឯកភាពគ្នាសម្រាប់ការអភិវឌ្ឍកសិកម្ម។ ប្រទេសកម្ពុជា នឹងដាក់បញ្ចូលទៅក្នុងស្ថាប័ននូវប្រព័ន្ធផ្តល់សេវាមាន លក្ខណៈពហុនិយម គោរពតាមយន្តការភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន។ ការធ្វើផែនការកម្មវិធី ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃ នឹងត្រូវធ្វើឱ្យមានលក្ខណៈវិមជ្ឈការទៅថ្នាក់ក្រោមជាតិ (ខេត្ត និងស្រុក)។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងសហការជាមួយអ្នកស្រាវជ្រាវរបស់ CARDI ដើម្បីអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាល ការអនុវត្តបង្ហាញ និងគេហទំព័រផ្សព្វផ្សាយកសិកម្ម។ ការបណ្តុះបណ្តាល និងការអនុវត្តបង្ហាញសម្រាប់ការផ្សព្វផ្សាយបច្ចេកវិទ្យា ក៏នឹងត្រូវធ្វើឡើងតាមរយៈភាពជាដៃគូរវាង រដ្ឋ និងឯកជន និងតាមរយៈការផ្តល់កិច្ចសន្យាជួលឱ្យ អង្គការមិនមែនរដ្ឋាភិបាល ក្នុងមូលដ្ឋាន អង្គការកសិករ VEWs, និង CEWS ជាអ្នកអនុវត្តសេវាផ្សព្វផ្សាយកសិកម្ម។

នៅថ្នាក់ជាតិ សេវាផ្សព្វផ្សាយកសិកម្ម នឹងទាញប្រយោជន៍ពីវិធីសាស្ត្របែបច្នៃប្រឌិតបង្កើតថ្មីនានា (ពោលគឺមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្ម) សម្រាប់ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយបច្ចេកវិទ្យា។ ស្ត្រី នឹងត្រូវបានដាក់បញ្ចូលក្នុងគ្រប់គណៈកម្មាធិការប្រឹក្សាយោបល់ទាំងអស់ និងបានទទួលអាទិភាពក្នុងកម្មវិធីបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្ម រួមទាំងការបណ្តុះបណ្តាលយកសញ្ញាបត្រផងដែរ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងដើរតួនាទីជាអ្នកដឹកនាំក្នុងការបញ្ជ្រាបបញ្ហាអន្តរវិស័យនានា ដូចជា ការដាក់បញ្ចូលយេនឌ័រ ការទទួលយកការអនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ និងការធ្វើឱ្យមានការចូលរួមពីយុវជនក្នុងការអភិវឌ្ឍសហគ្រិនភាពវិស័យកសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងវិនិយោគលើការអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម (ការអប់រំមុនពេលចូលបម្រើការងារ និងក្នុងរយៈពេលបម្រើការងារ ឬការបណ្តុះបណ្តាលដោយអនុវត្តផ្ទាល់ក្នុងពេលបំពេញការងារ។ កម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម នឹងត្រូវកែលម្អ ធនធានមនុស្សសម្រាប់ការធ្វើការបណ្តុះបណ្តាលប្រកបដោយគុណភាព នឹងត្រូវអភិវឌ្ឍឡើង ហើយប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃជាលក្ខណៈប្រព័ន្ធ នឹងត្រូវដាក់ឱ្យមាន។ អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម នឹងត្រូវបានដាក់ឱ្យមានគណនេយ្យភាពចំពោះការងាររបស់ខ្លួន។ ការអនុវត្តការងារលេចធ្លោនឹងត្រូវបានទទួលស្គាល់ និងផ្តល់រង្វាន់។ និរន្តរភាពនៃសេវាផ្សព្វផ្សាយកសិកម្ម នឹងត្រូវបានធានាតាមរយៈការផ្តល់ហិរញ្ញវត្ថុរវាងវិស័យរដ្ឋ និងឯកជន កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងការលើកកម្ពស់ភាពជាម្ចាស់នៅថ្នាក់មូលដ្ឋានចំពោះកម្មវិធីផ្សព្វផ្សាយកសិកម្ម។

# ឯកសារពិគ្រោះ

Cummins, J. (2017). ASPIRE Agricultural Extension Implementation Strategy (draft document). Phnom Penh, Cambodia: ASPIRE.

Department of Agricultural Extension. (2017). Results of SWOT Analysis. Phnom Penh, Cambodia: National Agriculture Extension and Agriculture Extension Startegy Development Workshop, December 26.

Department of Planning and Statistics. (2017). Agricultural Master Plan 2030: Strategic Framework for Agricultural Sector Development toward 2030. Phnom Penh, Cambodia: MAFF.

Fallon, N. (2018). SWOT Analysis: What Is It and When To Use It? Business News Daily. March 2.

FAO. (2014). Country Fact Sheet on Food and Agriculture Policy Trends. Rome, Italy: Food and Agricultural Organization of the United Nations. http://www.fao.org/docrep/field/009/i3761e/i3761e.pdf

International Fund for Agricultural Develoment. (2017). ASPIRE Mid-Term Review: The Way forward. Asia and the Pacific Division, Programme Management Department.

Khieu, H. (2017). Guidelines for Extension Materials Development. Agriculture Services Programme for Innovation, Resilience and Extension (ASPIRE) Report. Phnom Penh, Cambodia: MAFF/ASPIRE project.

Knowledge Management and ICT Advisors. (n.d.). Extension Hub Operational and Process Review of Extension Materials. PowerPoint Presentation. Phnom Penh, Cambodia: ASPIRE project.

Ministry of Agriculture, Forestry, and Fisheries. (2015). Agricultural Extension Policy in Cambodia 2015. Phnom Penh, Cambodia. Retrieved from http://extwprlegs1.fao.org/docs/pdf/cam152453.pdf

National Institute of Statistics. (2016). Cambodia Socioeconomic Survey 2015. Phnom Penh, Cambodia: National Institute of Statistics, Ministry of Planning. https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202015.pdf

Pickton, D. & Wright, S. (1998). What is SWOT in Strategic Analysis? Strategic Change, 7(2), 101-109.

Pommier, L. (2017). Extension Hub Full Operational Manual. Agriculture Services Programme for Innovation, Resilience and Extension (ASPIRE) Report. Phnom Penh, Cambodia: MAFF/ASPIRE project.

Suvedi, M., Ghimire, R. P., & Channa, T. (2018). Examination of Core Competencies of Agricultural Development Professionals in Cambodia. Evaluation and Program Planning Journal, 67, 89-96.

Suvedi, M., and Sarom, M. (2017). Assessment of Agricultural Extension Services in Cambodia: Needs and Constraints: Perceptions of Farmers on Agricultural Extension Services. In M. Suvedi, M. Kaplowitz and R. Ghimire (Eds.), Case Study Reports (pp. 6-39). East Lansing, MI: Department of Community Sustainability and Department of Agriculture, Food and Resource Economics, Michigan State University.

Welsh, N. (2017). Agricultural Extension System in Cambodia: SWOT Analysis. Agriculture Services Programme for Innovation, Resilience and Extension (ASPIRE) Report. Phnom Penh, Cambodia: MAFF/ASPIRE project.

GDA/DAE. (2017). Quality Assurance Guidelines for Agricultural Extension in Cambodia (ASPIRE Programme).

# ផ្នែកទី ២. គោលការណ៍ណែនាំសម្រាប់ ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា

## សេចក្តីផ្តើម និងសារតា

គោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា(PAEC) កំណត់នូវចក្ខុវិស័យនៃការអភិវឌ្ឍកសិកម្ម ព្រមទាំងប្រតិបត្តិការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា។ គោលនយោបាយនេះសង្កត់ធ្ងន់លើការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈវិមជ្ឈការ ជំរុញដោយតម្រូវការ និងមានលក្ខណៈពហុនិយម ដើម្បីផ្លាស់ប្រែវិស័យកសិកម្ម និងធ្វើឱ្យវិស័យកសិកម្មមានលក្ខណៈពាណិជ្ជកម្មតាមរយៈការចាត់ទុកការធ្វើកសិកម្មជាអាជីវកម្ម។ ការអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ ទាមទារនូវការសម្របសម្រួលរបស់ទីភ្នាក់ងារ និងភាគីពាក់ព័ន្ធនានា ព្រមទាំងគោលវិធីបែបច្នៃប្រឌិតបង្កើតថ្មី ដើម្បីជួយសម្របសម្រួលដល់ការអនុវត្តគោលនយោបាយប្រកបដោយជោគជ័យ។ តាមការអនុវត្តពីមុនមក មន្ត្រីរបស់ក្រសួងកសិកម្ម និងនាយកដ្ឋានទទួលបន្ទុករបស់ខ្លួនជាអ្នកដឹកនាំដំណើរការអនុវត្ត។ នៅក្នុងគោលវិធីបែបច្នៃប្រឌិតបង្កើតថ្មី ភាគីពាក់ព័ន្ធសំខាន់ៗរបស់វិស័យកសិកម្ម រួមមាន កសិករ ក្រុមស្ត្រី សហករ និងកសិធុរកិច្ចឯកជន ក្លាយជាអ្នកដើរតួនាទីជួរមុខក្នុងការអនុវត្តគោលនយោបាយ ហើយមន្ត្រីជាន់ខ្ពស់ដើរតួនាទីជាគ្រូបង្វឹកនិងជួយសម្របសម្រួលដល់ការអនុវត្តគោលនយោបាយ។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់សារៈសំខាន់របស់វិស័យកសិកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ធានាសមធម៌ និងសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍនៅទីជនបទ។ អនុលោមតាមគោលដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) បានប្រកាសឱ្យប្រើប្រាស់នូវគោលនយោបាយថ្មីស្តីពីការផ្សព្វផ្សាយកសិកម្មក្នុងឆ្នាំ ២០១៥ ដើម្បីផ្តល់សេវាដែលមានលក្ខណៈសម្របសម្រួលគ្នាបានល្អ មានលក្ខណៈវិមជ្ឈការ ជំរុញដោយទីផ្សារ និងមានលក្ខណៈបែបការចូលរួមជូនដល់កសិករ (Cummins, ២០១៧) ។ ក្រសួងក៏នឹងមើលខុសត្រូវ ព្រមទាំងធ្វើនិយ័តកម្មលើសេវាផ្សព្វផ្សាយកសិកម្មផ្តល់ដោយគម្រោងទទួលបានមូលនិធិពីម្ចាស់ជំនួយឱ្យគោរពតាមគោលការណ៍ណែនាំឯកភាពគ្នាមួយ។ មានការទទួលស្គាល់ថា ការអនុវត្តគោលនយោបាយថ្មីនេះ ទាមទារឱ្យមានការសម្របសម្រួលរវាងកម្មវិធីថ្នាក់ជាតិ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) ហើយសេចក្តីត្រូវការ និងអាទិភាពថ្នាក់ស្រុក ព្រមទាំងកម្មវិធីស្បៀងអាហារ និងអាហារូបត្ថម្ភដទៃទៀតដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍ ( ដូចជា កម្មវិធី Feed the Future ផ្តល់មូនិធិដោយUSAID គម្រោងនានាដែលផ្តល់មូលនិធិដោយ SNV និង AusAid World Food Program និងកម្មវិធីផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍដទៃទៀតនៅក្រោមដំបូលទីស្តីការគណៈរដ្ឋមន្ត្រី) ដើម្បីធានាបានថា សេវាប្រកបដោយគុណភាព បានទៅដល់ដៃអ្នកទទួលផលជាគោលដៅ ក្នុងនោះរួមមាន កសិករ ប្រជានេសាទ អ្នករកស៊ីចិញ្ចឹមជីវិតពឹងផ្អែកលើព្រៃឈើក្នុងលក្ខណៈទាន់ពេលវេលា។

ឯកសារនេះ ត្រូវបានតាក់តែងឡើង ដើម្បីគាំទ្រដល់ការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃលើកម្មវិធីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ អនុលោមតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា។ គោលនយោបាយនេះ ផ្តល់ការចង្អុលបង្ហាញជូនដល់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការផ្សព្វផ្សាយកសិកម្មដើម្បីនាំយកមកនូវគោលវិធីស៊ីសង្វាក់គ្នាក្នុងការអនុវត្តគោលនយោបាយ។ ដោយឡែកគោលការណ៍ណែនាំក៏ផ្តល់នូវ

ផែនការសកម្មភាពដែលមានលក្ខណៈទូលំទូលាយ និងអាចអនុវត្តបានដើម្បីឱ្យមានការអនុវត្តគោលនយោបាយថ្មីនេះក្នុងលក្ខណៈឯកភាពគ្នា។

## ការរៀបចំការងារផ្នែកស្ថាប័ន ក្របខ័ណ្ឌការងារផ្នែកច្បាប់

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ការសម្របសម្រួលទូទៅផ្នែកគោលនយោបាយដោយមានការចូលរួមយ៉ាងពេញលេញពីនាយកដ្ឋានទទួលបន្ទុក/វិទ្យាស្ថាន/សាកលវិទ្យាល័យ ដូចជាអគ្គនាយកដ្ឋានកសិកម្ម (GDA) នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មនៅកម្ពុជា (CARDI) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)។ល។ ក្នុងការអនុវត្តគោលនយោបាយថ្មីៗនេះ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដែលចំណុះឱ្យអគ្គនាយកដ្ឋានកសិកម្ម នឹងផ្តល់ជាអ្នកដឹកនាំនៅថ្នាក់ជាតិក្នុងការអនុវត្ត PAEC ហើយចំណុចនេះ ធ្វើឱ្យមានភាពចាំបាច់ ត្រូវមានការផ្លាស់ប្តូរមួយចំនួននៅក្នុងរចនាសម្ព័ន្ធអង្គភាព តួនាទី និង ការទទួលខុសត្រូវរបស់ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា គាំទ្រដល់គោលវិធីបែបវិមជ្ឈការ និងពហុនិយមក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ចំណុចនេះ មានន័យថា ការផ្សព្វផ្សាយកសិកម្ម នឹងត្រូវស្ថិតក្រោមការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ។ អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន អង្គការកសិករ អង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពវិស័យឯកជនអាចផ្តល់សេវាអប់រំ និងសេវាព័ត៌មាន ជូនដល់កសិករ និងកសិធុរកិច្ចដែលពាក់ព័ន្ធ។ គោលនយោបាយនេះ ទាមទារឱ្យមានគោលវិធីជំរុញដោយតម្រូវការផ្អែកលើសេចក្តីត្រូវការរបស់មូលដ្ឋាន និងឱកាសផ្នែកទីផ្សារ។ PAEC ក៏រួមមានបទប្បញ្ញត្តិសម្រាប់ផ្តល់សេវាគុណភាពខ្ពស់ តាមរយៈការវាយតម្លៃសេចក្តីត្រូវការបែបការចូលរួម និងបែបការកំណត់អាទិភាព ការកែលម្អចំពោះការបណ្តុះបណ្តាលបុគ្គលិក និងការប្រើប្រាស់គោលវិធីជាក្រុម និងបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង (ICT) សម្រាប់ផ្តល់សេវាតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន។

រូបភាពទី ៧ បង្ហាញអំពីរចនាសម្ព័ន្ធផ្នែកស្ថាប័នរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដែលត្រូវបានផ្តល់អនុសាសន៍ឱ្យបង្កើតឡើង ដោយក្នុងនោះរួមមានសមាសធាតុ ការិយាល័យចំនួន ៤ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់តំបន់ចំនួន៥។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងមានអង្គភាពផែនការ និងវាយតម្លៃមួយ ទទួលបន្ទុកក្នុងការសម្របសម្រួល ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី។ អង្គភាពនេះ ក៏ជាទីតាំងសម្រាប់មជ្ឈមណ្ឌលព័ត៌មានកសិកម្ម ហើយក៏គ្រប់គ្រងលើគេហទំព័រផ្សព្វផ្សាយកសិកម្ម ផ្តល់ការបណ្តុះបណ្តាលក្នុងរយៈពេលកំពុងបម្រើការងារស្តីពីសមត្ថភាពស្នូល សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មទូទាំងប្រទេស និងផ្តល់កម្មវិធីអប់រំច្បាស់លាស់ស្តីពីបញ្ហាអន្តរវិស័យ ដូចជាការធ្វើកសិកម្មដែលធន់ទៅនឹងអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រនៅក្នុងកម្មវិធីអភិវឌ្ឍកសិកម្ម ការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍកុមារសម្រាប់គ្រួសារជនបទ និងការទាក់ទាញយុវជនមកក្នុងការងារកសិកម្ម។

**រូបភាពទី ៧. រចនាសម្ព័ន្ធរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (ដែលត្រូវបានស្នើឡើង)**




នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងផ្តល់ការសម្របសម្រួលថ្នាក់ជាតិទៅលើព័ត៌មាន និងការបណ្តុះបណ្តាលស្តីពីបញ្ហាអន្តរវិស័យ ដូចជាការប្រែប្រួលអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រនៅក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម ការបណ្តុះបណ្តាលសហគ្រិនភាពយុវជន និងការអប់រំយុវជនឱ្យចាប់យកជំនាញវិជ្ជាជីវៈកសិកម្ម។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងបន្តធ្វើជាម្ចាស់ផ្ទះលើកម្មវិធីផ្សេងៗ ដូចជា ការតាំងបង្ហាញ និងពិព័រណ៍កសិកម្ម កម្មវិធីបង្ហាញផ្នែកពាណិជ្ជកម្ម និងសន្និសីទផ្សព្វផ្សាយកសិកម្មប្រចាំឆ្នាំនៅថ្នាក់ជាតិ និង/ឬ ថ្នាក់ក្រោមជាតិ ដោយអញ្ជើញដៃគូទាំងអស់ឱ្យចែករំលែកបទពិសោធន៍។

ការចូលរួមពីវិស័យសាធារណៈ ឯកជន និង អង្គការមិនមែនរដ្ឋាភិបាល គឺមានភាពចាំបាច់ណាស់សម្រាប់ការអនុវត្តសេវាផ្សព្វផ្សាយកសិកម្មដែលជំរុញដោយទីផ្សារ មានលក្ខណៈវិមជ្ឈការ និងពហុនិយម។ ហេតុនេះវិស័យឯកជន រួមទាំងដៃគូអភិវឌ្ឍផងដែរ នឹងត្រូវបានអញ្ជើញឱ្យចូលរួមយ៉ាងសកម្ម និងចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយនៅគ្រប់កម្រិតទាំងអស់របស់រដ្ឋាភិបាល តាំងពីថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិក្នុងនាមជាសមាជិកគណៈកម្មាធិការប្រឹក្សាយោបល់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ។

ប្រតិបត្តិការ និងការគ្រប់គ្រងការផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ នឹងត្រូវបានសម្របសម្រួលដោយគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) និងអនុគណៈកម្មាធិការមានឈ្មោះថា អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC)។ AEAC នឹងប្រឹក្សាដល់ NATSC ស្តីពីបញ្ហាផ្នែកគោលនយោបាយ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មបម្រើការងារជាលេខាធិការដ្ឋានសម្រាប់គណៈកម្មាធិការទាំងអស់នេះ។ នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកម្ពុជា (CARDI) និងវិទ្យាស្ថានបណ្តុះបណ្តាលកសិកម្ម ដូចជាសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) សាលាជាតិកសិកម្មព្រែកលៀប (PNCA) និងសាលាជាតិកសិកម្មកំពង់ចាម (KNSA) និងវិស័យឯកជន នឹងត្រូវបានអញ្ជើញឱ្យធ្វើជាសមាជិក។

សេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្ម នឹងត្រូវបានផ្ទេរទៅថ្នាក់ក្រោមជាតិ។ នៅថ្នាក់ក្រោមជាតិ សេវាផ្សព្វផ្សាយកសិកម្ម នឹងត្រូវបានសម្របសម្រួលដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) និងការិយាល័យកសិកម្មស្រុក។ ក្រុមការងារប្រឹក្សាការផ្សព្វផ្សាយកសិកម្ម នឹងមើលខុសត្រូវលើប្រតិបត្តិការ និងការគ្រប់គ្រងសេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្មទាំងអស់នៅក្នុងខេត្តនីមួយៗ។ ការិយាល័យកសិកម្មស្រុក ដោយមានការគាំទ្រផ្នែកប្រឹក្សាយោបល់ពីក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST) នឹងសម្របសម្រួលលើសេវាទាំងអស់នៅថ្នាក់ក្រុង/ស្រុក/ខណ្ឌ។

ក្នុងពេលអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម និងរដ្ឋលេខាធិការក្រសួងកសិកម្មនឹងបានទទួលការរាយការណ៍ជាសង្ខេបជាប្រចាំស្ដីពីវឌ្ឍនភាពក្នុងការអនុវត្តនិងឆ្លើយតបចំពោះបញ្ហានានាដែលត្រូវការសេចក្ដីសម្រេចចិត្តនៅថ្នាក់កំពូល។ រដ្ឋមន្ត្រី នឹងធ្វើជាអ្នកតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងវេទិកាជាតិនានា រួមទាំងនៅទីស្ដីការគណៈរដ្ឋមន្ត្រី និងសន្និសីទកសិកម្មប្រចាំឆ្នាំ។ សមាសភាពរបស់គណៈកម្មាធិការភាគីពាក់ព័ន្ធនានាត្រូវពិចារណាឱ្យមានអ្នកតំណាងពីក្រសួង និងមន្ទីរពាក់ព័ន្ធ វិស័យឯកជន NGOs និងដៃគូអភិវឌ្ឍន៍។

ការចូលរួមយ៉ាងពេញលេញរបស់ភាគីពាក់ព័ន្ធ នឹងអាចធានាបានតាមរយៈគណៈកម្មាធិការភាគីពាក់ព័ន្ធកម្រិតនានាដូចមានពិពណ៌នាដូចខាងក្រោម។

## គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ

គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ (AEAC) នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ការប្រឹក្សាយោបល់ និងសម្របសម្រួលការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃលើសេវាផ្សព្វផ្សាយកសិកម្ម។ AEAC នឹងជួយធានាថា គោលនយោបាយកសិកម្មត្រូវបានបន្សុីជាមួយផែនការមេកសិកម្ម ឆ្នាំ២០៣០ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបន្សុីជាមួយសេចក្ដីត្រូវការរបស់កសិករ។ គណៈកម្មាធិការនេះផ្ដល់ការចង្អុលបង្ហាញទិសដៅយ៉ាងច្បាស់លាស់ស្ដីពីអាទិភាពជាតិសម្រាប់ការអភិវឌ្ឍកសិកម្មជូនដល់អ្នកផ្ដល់មូលនិធិ/ម្ចាស់ជំនួយ និង អង្គភាពវិស័យឯកជនស្ដីពីសេចក្ដីត្រូវការរបស់កសិករ កសិធុរកិច្ច និងទីផ្សារ។ គណៈកម្មាធិការនេះ ជួយធានាថា គោលនយោបាយអភិវឌ្ឍកសិកម្មមានភាពស៊ីសង្វាក់គ្នានៅក្នុងគោលនយោបាយទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។

តួនាទីរបស់ AEAC គឺដើម្បីផ្ដល់ភាពជាអ្នកដឹកនាំផ្នែកគោលនយោបាយ និងមគ្គុទ្ទេសក៍ច្បាស់លាស់នៅក្នុងការអភិវឌ្ឍ ការសម្របសម្រួល និងការអនុវត្តកម្មវិធី និងសេវាផ្សព្វផ្សាយកសិកម្ម។ គណៈកម្មាធិការនេះ ផ្ដល់ប្រឹក្សាយោបល់ជូនចំពោះនាយកដ្ឋានបច្ចេកទេសទាំងអស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការសិក្សាស្រាវជ្រាវលើគោលនយោបាយ កំណត់បទដ្ឋានសម្រាប់ចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កំណត់តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងផ្ដល់ប្រឹក្សាស្ដីអំពីការបណ្ដុះបណ្ដាលមុនពេលចូលបម្រើការងារ និង ក្នុងរយៈពេលកំពុងបម្រើការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។

សមាជិកភាពរបស់ AEAC រួមមានអ្នកតំណាងមកពី៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានក្សេត្រសាស្ត្រ
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មនៅកម្ពុជា
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាលាជាតិកសិកម្មព្រែកលៀប
- សាលាជាតិកសិកម្មកំពង់ចាម
- រដ្ឋបានជលផល
- រដ្ឋបាលព្រៃឈើ
- អគ្គនាយកដ្ឋានផលិតកម្មសត្វ និងសុខភាពសត្វ
- នាយកដ្ឋានផែនការ និងស្ថិតិ
- អគ្គនាយកដ្ឋានកៅស៊ូ
- វិស័យឯកជន។

**ការកាន់តំណែងក្នុងគណៈកម្មាធិការ៖** សមាជិកត្រូវបានតែងតាំងក្នុងអាណត្តិរយៈពេលបីឆ្នាំ ហើយអាចបន្តអាណត្តិជាថ្មីបាន។ ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងបម្រើការងារជាលេខារបស់គណៈកម្មាធិការ ហើយកម្មវិធី ASPIRE នឹងជួយសម្របសម្រួល ដល់កិច្ចប្រជុំជាប្រចាំ ដើម្បីបង្កើត/ធ្វើបច្ចុប្បន្នភាពគោលនយោបាយនានាដែលចាំបាច់ ដើម្បីផ្តល់ទិសដៅច្បាស់លាស់។

**តួនាទី និងការទទួលខុសត្រូវ៖**

- បម្រើការងារជា "**ឃ្លាំងគំនិត**" សម្រាប់សេវាផ្សព្វផ្សាយកសិកម្មជូនដល់នាយកដ្ឋានបច្ចេកទេសទាំងអស់នៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ធានាឱ្យបានថា គោលនយោបាយផ្សព្វផ្សាយកសិកម្មដែលបានអភិវឌ្ឍឡើងមានភាពពាក់ព័ន្ធ និងមានភាពស្រួលអនុវត្ត
- ផ្តល់អនុសាសន៍វិស័យជាក់លាក់សម្រាប់ការសិក្សាផ្នែកគោលនយោបាយ ដូចជាការវាយតម្លៃជារយៈៗ ទៅលើការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្ម ការឧបត្ថម្ភលើជីកសិកម្ម ប្រសិទ្ធភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្មបែបពហុនិយម និង គម្រោងកំណត់តម្លៃអប្បបរមាសម្រាប់ទំនិញនានា ដូចជា ស្រូវ ទឹកដោះគោ និងកៅស៊ូ
- ធានាឱ្យមានកិច្ចសហការរវាងភាគីពាក់ព័ន្ធនានាក្នុងការលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្មបែបពហុនិយម
- ផ្តល់អនុសាសន៍នូវគំរូសម្រាប់ការផ្តល់មូលនិធិពីខាងក្រៅ(ម្ចាស់ជំនួយ) សម្រាប់សេវាផ្សព្វផ្សាយកសិកម្ម
- ស្នើឡើងនូវយុទ្ធសាស្ត្រសម្រាប់ការធានាគុណភាព ក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម
- កំណត់គុណវុឌ្ឍិសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅកម្រិតផ្សេងៗ និងគោលវិធីផ្សព្វផ្សាយកសិកម្មដែលត្រូវអនុវត្តតាម និង វិស័យដែលត្រូវគ្របដណ្តប់សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនីមួយៗ
- ផ្តល់អនុសាសន៍នូវយុទ្ធសាស្ត្រផ្សេងៗ សម្រាប់ការអភិវឌ្ឍធនធានមនុស្សជូនដល់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម

- ធានាឱ្យបានថា ការផ្សព្វផ្សាយកសិកម្ម គឺត្រូវបានជំរុញដោយទីផ្សារ ហើយភាគីពាក់ព័ន្ធទាំងអស់ចូលរួមនៅក្នុងការធ្វើផែនការកម្មវិធីការផ្តល់សេវា និងការវាយតម្លៃលើសេវាផ្សព្វផ្សាយកសិកម្ម
- ធានាថានាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ផ្តល់ភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍ និងអនុវត្តកម្មវិធីអប់រំ ដើម្បីឆ្លើយតបចំពោះបញ្ហាអន្តរវិស័យ ដូចជា ការដាក់បញ្ចូលយេនឌ័រ និងភាពធន់ទៅនឹងអាកាសធាតុ
- ផ្តល់ប្រឹក្សាស្តីពីផែនការបុគ្គលិក រួមទាំងការពិពណ៌នាអំពីការងារ គោលការណ៍ណែនាំអំពីប្រាក់បៀវត្សរ៍ និងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ ការអនុវត្តការងារសម្រាប់ការដំឡើងឋានៈ ការផ្ទេរ និងការបញ្ឈប់ការងារ
- កំណត់រកខ្លឹមសារបច្ចេកទេសផ្អែកលើការស្រាវជ្រាវ និង អនុសាសន៍ដែលត្រៀមរួចជាស្រេចសម្រាប់ការផ្សព្វផ្សាយ និងការផ្តល់គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មដែលល្អត្រឹមត្រូវតាមបែបបច្ចេកទេស។

ការអនុវត្ត PAEC ប្រកបដោយជោគជ័យ ទាមទារកិច្ចខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពពីសំណាក់ស្ថាប័នផ្សេងៗ រួមទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានរបស់ខ្លួន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ។ ការបង្កើតគណៈកម្មាធិការផ្សេងៗ ចាំបាច់ត្រូវធានាឱ្យមានការចូលរួមពីនាយកដ្ឋាន និងទីភ្នាក់ងារសំខាន់ៗ និងមានអ្នកតំណាងរបស់ស្ត្រី។ កម្មវិធី ASPIRE នឹងផ្តល់ការគាំទ្រសម្រាប់កិច្ចសម្របសម្រួលជាទូទៅក្នុងការអនុវត្ត។

**តារាងទី ១៣. ការរៀបចំផ្នែកស្ថាប័នសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងការអនុវត្ត PAEC**

| | | |
|---|---|---|
| គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ (AEAC) | ស្ថាប័នប្រឹក្សាយោបល់នៅថ្នាក់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង "ធនាគារគំនិត" ដែលទទួលព័ត៌មានជាប្រចាំពី NATSC និងគណៈកម្មាធិការដទៃទៀតស្តីពីវឌ្ឍនភាពនៃការអនុវត្ត និងការដោះស្រាយបញ្ហានានាដែលទាមទារសេចក្តីសម្រេចចិត្តថ្នាក់ខ្ពស់។ | មានរដ្ឋលេខាធិការជាប្រធាន ទទួលការគាំទ្ររដ្ឋបាលពីលេខាធិការដ្ឋាន ASPIRE |
| អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មទទួលបន្ទុកបច្ចេកទេសកសិកម្ម (NATSC) | គណៈកម្មាធិការបច្ចេកទេសថ្នាក់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវក្នុងការតភ្ជាប់រវាងការគ្រប់គ្រងលើការស្រាវជ្រាវ ការអប់រំ ការផ្សព្វផ្សាយ និងវិស័យឯកជន និងបញ្ហាផ្នែកបច្ចេកទេស (សម្ភារៈផ្សព្វផ្សយ ការអភិវឌ្ឍបច្ចេកវិទ្យា) និងធ្វើនិយ័តកម្ម និងជំរុញការអនុវត្តបទដ្ឋានសម្រាប់ការធានាគុណភាព។ | មានរដ្ឋលេខាធិការជាប្រធាន ទទួលការគាំទ្ររដ្ឋបាលពីលេខាធិការដ្ឋាន ASPIRE |
| គណៈកម្មាធិការមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្ម | ធានាការប្រាស្រ័យទាក់ទង និងលំហូរព័ត៌មានទាន់ពេលវេលាក្នុងចំណោមការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអប់រំ និងវិស័យឯកជន | មានប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាប្រធាន ទទួលការគាំទ្រផ្នែករដ្ឋបាលពីលេខាធិការដ្ឋាន ASPIRE |

| | | |
|---|---|---|
| ក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត(PAEWG) | មើលការខុសត្រូវលើការអនុវត្តសេវាផ្សព្វផ្សាយកសិកម្ម ផ្តល់មូលនិធិតាមរយៈ RGC និងដៃគូអភិវឌ្ឍ/ម្ចាស់ជំនួយ | មានប្រធាន PDAFF ជាប្រធាន ទទួលការគាំទ្រផ្នែកបច្ចេកទេសពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) |
| ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST) | សម្របសម្រួលទូទៅលើការធ្វើផែនការ និងការអនុវត្តសេវាផ្សព្វផ្សាយកសិកម្ម និងសកម្មភាពនានានៅថ្នាក់ស្រុក | មានអភិបាលរងស្រុកជាប្រធាន ទទួលការគាំទ្រផ្នែករដ្ឋបាលពីការិយាល័យកសិកម្មស្រុក(DAO) |
| គណៈកម្មាធិការកសិកម្មឃុំ | គណៈកម្មាធិការថ្នាក់ឃុំ | មានជំទប់ទីមួយជាប្រធាន ទទួលការគាំទ្រផ្នែករដ្ឋបាលពីភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ឬ NGOsអង្គការកសិករ |

## អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម (NATSC)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទីភ្នាក់ងារផ្សេងៗជាច្រើន និងនាយកដ្ឋានបច្ចេកទេសដែលផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករ ប្រជានេសាទ និងអ្នកប្រកបរបរចិញ្ចឹមជីវិតផ្អែកលើព្រៃឈើ។ គោលការណ៍ណែនាំឯកភាពគ្នាសម្រាប់ការធ្វើផែនការការអនុវត្ត និងការវាយតម្លៃលើ សេវាផ្សព្វផ្សាយកសិកម្ម គឺជាសេចក្តីត្រូវការជាបន្ទាន់។ សេចក្តីត្រូវការមួយទៀត គឺឱ្យមានស្ថាប័នមួយ ដើម្បីអនុម័តលើខ្លឹមសារបច្ចេកទេសនៃសម្ភារៈផ្សព្វផ្សាយកសិកម្ម។ NATSC នឹងផ្តល់ការសម្របសម្រួលទូទៅលើទីភ្នាក់ងារពាក់ព័ន្ធនានានៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្តល់ការគាំទ្រក្នុងការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មថ្មីៗ និងគំនិតបង្កើតថ្មី។

NATSCនឹងសម្របសម្រួលកម្មវិធី និងសកម្មភាពនានារបស់ក្រសួង/ទីភ្នាក់ងារពាក់ព័ន្ធទាំងអស់។ NATSC មានអនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន ហើយនិងកោះប្រជុំទីភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការអនុវត្តកម្មវិធីកសិកម្មជារយៈៗ និងសម្របសម្រួលសកម្មភាពនានា។

យន្តការសម្របស្រួលប្រហាក់ប្រហែលគ្នានេះ គឺមាននៅថ្នាក់ខេត្ត ហៅថា ក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត (PAEWG) ដែលមានអភិបាលរងខេត្តជាប្រធាន និងសម្របសម្រួលដោយប្រធាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនៅថ្នាក់ស្រុក គឺមានក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST), ដែលមានអភិបាលស្រុកជាប្រធាន និងសម្របសម្រួលដោយការិយាល័យកសិកម្មស្រុក។ ចាំបាច់ត្រូវពង្រឹងយន្តការទាំងអស់នេះ និង ធ្វើឱ្យយន្តការទាំងនេះរស់រានមានជីវិតឡើងវិញដោយមានការគាំទ្រពីកម្មវិធី ASPIRE។

NATSC ត្រូវរួមមានសមាសភាពសមាជិកជាអ្នកតំណាងមកពីស្ថាប័នដូចខាងក្រោម៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (GDA និង DAE)
- នាយកដ្ឋានផែនការ និងស្ថិតិ (DPS)
- នាយកដ្ឋានកសិឧស្សាហកម្ម
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា (CARDI)
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)

- សាលាជាតិកសិកម្មព្រែកលៀប (PNCA)
- សាលាជាតិកសិកម្មកំពង់ចាម (KNSA)
- រដ្ឋបាលជលផល (FiA)
- រដ្ឋបាលព្រៃឈើ
- អគ្គនាយកដ្ឋានផលិតកម្មសត្វ និងសុខភាពសត្វ
- អគ្គនាយកដ្ឋានកៅស៊ូ (GDR)
- វិស័យឯកជន។

**សិទ្ធិកាន់កាប់របស់គណៈកម្មាធិការ៖** សមាជិកត្រូវបានចាត់តាំងសម្រាប់អាណត្តិរយៈពេលបីឆ្នាំ ហើយអាចបន្តសារជាថ្មីបាន។ អ្នកគ្រប់គ្រងកម្មវិធី **ASPIRE** នឹងត្រូវធ្វើជាលេខារបស់សមាជិក ហើយគម្រោង ASPIRE នឹងផ្តល់ការសម្របសម្រួលដល់ការធ្វើផែនការកិច្ចប្រជុំ និងធ្វើការតាមដានបន្តដោយចាំបាច់លើការអនុវត្តសេចក្តីសម្រេចចិត្ត និងអនុសាសន៍ផ្សេងៗរបស់គណៈកម្មាធិការថ្នាក់ជាតិ។

**តួនាទី និងការទទួលខុសត្រូវ៖**

- ធានាថា គោលនយោបាយផ្សព្វផ្សាយកសិកម្ម មានលក្ខណៈសមហេតុផល និងស៊ីសង្វាក់ជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- ធានាការអនុវត្តគោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្មតាមរយៈការឆ្លើយតបការផ្លាស់ប្តូរផ្នែករដ្ឋបាល និងផ្នែកច្បាប់នៅក្នុងស្ថាប័នទទួលខុសត្រូវ
- ធានាការសម្របសម្រួល ការកៀងគរធនធានទាំងពីរប្រភពខាងក្នុង (វិស័យសាធារណៈ និងឯកជន) និងប្រភពខាងក្រៅ (មូលនិធិម្ចាស់ជំនួយ)
- ផ្តល់ការចង្អុលបង្ហាញដល់ក្រសួងពាក់ព័ន្ធ មន្ទីរពាក់ព័ន្ធ និង ភាគីពាក់ព័ន្ធនានា ដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយកសិកម្ម ចាប់ពីថ្នាក់មូលដ្ឋានទៅដល់ថ្នាក់ជាតិ
- ធ្វើការវាយតម្លៃជារយៈៗលើការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្ម និងផ្តល់អនុសាសន៍ឱ្យមានការកែសម្រួល
- បង្កើត "**ចក្ខុវិស័យរួម**" សម្រាប់ការស្រាវជ្រាវ-ការផ្សព្វផ្សាយកសិកម្ម-ការអប់រំ ឬការបណ្តុះបណ្តាល និងការចូលរួមពីវិស័យឯកជន។ ទិដ្ឋភាពនេះ មានភាពចាំបាច់ណាស់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម
- ផ្តល់អនុសាសន៍គោលការណ៍ណែនាំស្តីពីការដាក់បុគ្គលិក សម្រាប់ការផ្សព្វផ្សាយកសិកម្ម និងសម្រាប់ការបណ្តុះបណ្តាលមុនពេលបំពេញការងារ និងក្នុងរយៈពេលបម្រើការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មរួមទាំងការអនុម័តលើកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ផ្តល់ការសម្របសម្រួលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយទីស្តីការគណៈរដ្ឋមន្ត្រីទាក់ទងជាមួយការអភិវឌ្ឍកសិកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងសុវត្ថិភាពចំណីអាហារ
- បង្កើតបទដ្ឋានបច្ចេកទេសសម្រាប់សម្ភារៈផ្សព្វផ្សាយកសិកម្ម និងធនធាន ICT ដែលឆ្លុះបញ្ចាំងអំពីប៉ារាម៉ែត្រធានាគុណភាពរបស់សេវាផ្សព្វផ្សាយកសិកម្ម
- អនុវត្តការធ្វើការវិនិច្ឆ័យបញ្ហា/ការវាយតម្លៃសេចក្តីត្រូវការរួមគ្នាដើម្បីធ្វើឱ្យការផ្សព្វផ្សាយកសិកម្មមានលក្ខណៈជំរុញដោយទីផ្សារ និងជំរុញដោយតម្រូវការ ការកំណត់អាទិភាពរួមគ្នា ការសាកល្បងនៅទីវាល

កសិករបែបសហការ និងការអនុវត្តបង្ហាញ ការសម្រេចចិត្តរួមគ្នាក្នុងការចេញផ្សាយអនុសាសន៍ការស្រាវជ្រាវ និងទស្សនកិច្ចនៅមូលដ្ឋានរួមគ្នាជាប្រចាំ និងការចែករំលែកក្រៅផ្លូវការនូវភារកិច្ច និងការទទួលខុសត្រូវ

- រៀបចំសិក្ខាសាលាជារយៈៗ និងវគ្គបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើការងារ ដើម្បីចែករំលែកការរកឃើញពីការស្រាវជ្រាវ រួមទាំងការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត និងថ្នាក់ស្រុក និងអ្នកវិជ្ជាជីវៈអាជីពនៅស្ថានីយស្រាវជ្រាវ
- ផ្តល់ការសម្របសម្រួលរវាងស្ថាប័នស្រាវជ្រាវ ផ្សព្វផ្សាយ និងអប់រំ (CARDI, GDA, DAE សាកលវិទ្យាល័យភូមិន្ទកសិកម្ម) និងសហករ
- ផ្តល់ជំនួយបច្ចេកទេសក្នុងការពិនិត្យឡើងវិញ និង អនុម័តលើបច្ចេកវិទ្យាផ្អែកលើការស្រាវជ្រាវ ឬការអនុវត្តថ្មីៗសម្រាប់ការផ្សព្វផ្សាយទូលំទូលាយ រួមទាំងសម្ភារៈផ្សព្វផ្សាយកសិកម្ម និងការបោះពុម្ពផ្សាយផ្អែកលើ ICT
- អភិវឌ្ឍផែនការផ្សព្វផ្សាយបច្ចេកវិទ្យាស្តីពីគំហើញរបស់ CARDI, RUA និង ការស្រាវជ្រាវក្នុងវិស័យឯកជនដែលត្រូវបានសេចក្តីត្រូវការរបស់កសិករ
- ធ្វើផែនការសម្រាប់ការកៀងគរធនធានទាំងពីរប្រភពខាងក្នុង (សាធារណៈ និងឯកជន) និងប្រភពខាងក្រៅ (ការផ្តល់មូលនិធិពីម្ចាស់ជំនួយ) សម្រាប់ការងារសហការ ឧ. ការបោះពុម្ពផ្សាយរួមគ្នា កម្មវិធីវិទ្យុ និងវីដេអូ ឬគេហទំព័រ ឬសូហ្វវែរដទៃទៀត
- ទទួលស្គាល់ និងផ្តល់រង្វាន់ចំពោះការចូលរួមចំណែកឆ្នើម និងការបំពេញការងារវិជ្ជាជីវៈឆ្នើមរបស់អ្នកស្រាវជ្រាវ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម បុគ្គលិកសិក្សារបស់មហាវិទ្យាល័យ កសិករនាំមុខ ឬក្រុមការងារអ្នកប្រកបវិជ្ជាជីវៈអាជីព
- រៀបចំសន្និសីទថ្នាក់ជាតិ ផ្តល់ការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗ ដែលសេវាផ្សព្វផ្សាយកសិកម្មត្រូវជួបប្រទះ
- ពិនិត្យតាមដាន និងវាយតម្លៃគោលការណ៍ណែនាំ បទដ្ឋានបច្ចេកវិទ្យា ការស្រាវជ្រាវផ្សព្វផ្សាយកសិកម្ម និងការអភិវឌ្ឍគំនិតបង្កើតថ្មី
- ពិនិត្យឡើងវិញ និងអនុម័តលើប្រធានបទ ឯកសារ និងសម្ភារៈនានា ក៏ដូចជាមធ្យោបាយ វិធីសាស្ត្រសម្រាប់ផ្តល់សេវាផ្សព្វផ្សាយកសិកម្ម
- គាំទ្រអភិវឌ្ឍដេតាបេសសម្រាប់ពិនិត្យតាមដានគោលនយោបាយផ្សព្វផ្សាយកសិកម្ម
- ផ្តួចផ្តើមឱ្យមានប្រព័ន្ធដើម្បីចុះបញ្ជីនិងចេញអាជ្ញាបណ្ណសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ បច្ចុប្បន្នពុំមានលិខិតបទដ្ឋានគតិយុត្តិស្តីពីថាតើនរណាអាចផ្តល់សេវាផ្សព្វផ្សាយកសិកម្មបាន តើអ្នកសេវាផ្សព្វផ្សាយកសិកម្មគួរមានគុណវុឌ្ឍិអ្វីខ្លះ និងតើក្រមសីលធម៌អ្វីខ្លះដែលគេត្រូវអនុវត្តតាម។ NATSC ក៏ត្រូវអភិវឌ្ឍឱ្យមានក្រមប្រតិបត្តិសម្រាប់អ្នកប្រកបវិជ្ជាជីវៈកសិកម្មផ្សព្វផ្សាយកសិកម្មរួមទាំងគោលការណ៍ដែលគ្របដណ្តប់លើជម្រើសខ្លឹមសារ វិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម និងគោលវិធីផងដែរ
- ផ្តួចផ្តើម និង ជំរុញការអនុវត្តប្រព័ន្ធទទួលស្គាល់គុណភាពសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដើម្បីធានាគុណភាពនៅក្នុងស្ថាប័នបណ្តុះបណ្តាលទាំងអស់
- កំណត់កម្រិតអប្បបរមានៃគុណវុឌ្ឍិវិជ្ជាជីវៈ ដែលអាចទទួលយកបានសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

- ប្រើប្រាស់ប្រព័ន្ធវាយតម្លៃបុគ្គលិក ដើម្បីផ្តល់ការលើកទឹកចិត្ត ការទទួលស្គាល់ និងរង្វាន់ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មលេចធ្លោ។
- រៀបចំវេទិកាថ្នាក់ជាតិស្តីពីការផ្សព្វផ្សាយកសិកម្មជាប្រចាំឆ្នាំ ដើម្បីបង្កើតការយល់ដឹង បង្កើតចំណេះដឹង ផ្លោះប្តូរគំនិត និងចែករំលែកបទពិសោធន៍ និងមេរៀនដែលទទួលបាន។

NATSC អាចបង្កើតក្រុមការងារអ្នកឯកទេសតូចមួយ ដើម្បីអភិវឌ្ឍគោលការណ៍ណែនាំសម្រាប់ប្រព័ន្ធចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណ ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងប្រព័ន្ធទទួលស្គាល់គុណភាពសម្រាប់អ្នកផ្តល់ការបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្ម គុណវុឌ្ឍិអប្បបរមាសម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្មសម្រាប់ការធានាគុណភាព និង គោលការណ៍វាយតម្លៃលទ្ធផលការងារសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។

NATSC ក៏នឹងទទួលការប្រាស្រ័យទាក់ទងជាប្រចាំស្តីពីការអនុវត្ត PAEC ពីក្រុមការងារបច្ចេកទេសទទួលបន្ទុកកសិកម្ម និងទឹក និងអនុក្រុមការងារទទួលបន្ទុកការផ្សព្វផ្សាយកសិកម្ម។

NATSC នឹងត្រូវពង្រឹងតាមរយៈសេវាលេខាធិការដ្ឋានផ្តល់ដោយកម្មវិធី ASPIRE។ បន្ថែមលើនេះទៀត កម្មវិធី ASPIREនឹងទទួលបន្ទុកក្នុងការកែលម្អការសម្របសម្រួលក្នុងការអនុវត្តគោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្ម រួមមាន៖

- ការសម្របសម្រួលរវាងអគ្គនាយកដ្ឋានកសិកម្ម (GDA), នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បសុព្យាបាល ជលផល ព្រៃឈើ និងការផ្សព្វផ្សាយកៅស៊ូ
- ផ្តល់ការកសាងសមត្ថភាពស្តីពីការវិភាគគោលនយោបាយ និងការពិនិត្យតាមដានគោលនយោបាយ និងសមាហរណកម្មផែនការ
- ពង្រឹងចំណងទាក់ទងរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងអង្គភាពអប់រំ ឧ. CARDI, អគ្គនាយកដ្ឋានកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- គាំទ្រដល់ការបង្កើត និងការធ្វើវិសោធនកម្មលើគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិដែលមានស្រាប់ ដើម្បីបន្សីជាមួយគោលនយោបាយស្តីពីការផ្សព្វផ្សាយកសិកម្ម និងផែនការមេកសិកម្ម ឆ្នាំ ២០៣០
- គាំទ្រដល់ការអភិវឌ្ឍដេតាបេសសម្រាប់ការពិនិត្យតាមដាន និង គោលនយោបាយផ្សព្វផ្សាយកសិកម្ម
- ផ្តល់ការសម្របសម្រួលរវាងអង្គភាពសាធារណៈ និងអង្គភាពវិស័យឯកជន សមាគម កសិធុរកិច្ចផ្អែកសហគមន៍ និងអង្គការកសិករ
- ផ្តល់ការសម្របសម្រួលរវាងវិស័យរដ្ឋាភិបាលជាមួយអង្គការមិនមែនរដ្ឋាភិបាល
- ផ្តល់ការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជា/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការវិនិយោគ និងកម្មវិធីរបស់ដៃគូអភិវឌ្ឍ ពាក់ព័ន្ធនៅក្នុងការអនុវត្តគោលនយោបាយ
- ផ្តល់ការសម្របសម្រួលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយទីស្តីការគណៈរដ្ឋមន្ត្រីទាក់ទងជាមួយការអភិវឌ្ឍវិស័យកសិកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងសុវត្ថិភាពចំណីអាហារ។

អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបំពេញមុខងារជាប្រធាន អគ្គនាយកនៃអគ្គនាយដ្ឋានកសិកម្ម បម្រើការងារជាលេខាធិការសមាជិករបស់ NATSC ហើយកម្មវិធី ASPIRE នឹងជួយសម្របសម្រួលការអនុវត្តសកម្មភាពរបស់ NATSC។

ភាគីពាក់ព័ន្ធចម្បងៗ រួមមាន កសិករ សហករ កសិធុរកិច្ចឯកជន និងរចនាសម្ព័ន្ធរបស់ពួកគេ (ឧ. សមាគមស្រូវពូជ សមាគមទឹកដោះគោ)។ មានរចនាសម្ព័ន្ធប្រហាក់ប្រហែលគ្នានៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ហើយក្នុងករណីរបស់កសិករក៏មាននៅថ្នាក់ឃុំ និងថ្នាក់ភូមិផងដែរ។ កសិករ គឺមានរួមមានទាំងកសិករមានលក្ខណៈជាពាណិជ្ជកម្ម និងកសិករដែលធ្វើគ្រាន់តែផ្គត់ផ្គង់ក្នុងគ្រួសារ កសិធុរកិច្ច គឺរួមមានទាំងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ។ ការអនុវត្តគោលនយោបាយថ្មីប្រកបដោយជោគជ័យ ទាមទារឱ្យមានការចូលរួម និងភាពជាម្ចាស់យ៉ាងពិតប្រាកដពីសំណាក់រចនាសម្ព័ន្ធកសិករ សហគមន៍ និងវិស័យឯកជន។ ហេតុដូច្នេះ ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងគណៈកម្មាធិការក្រុមការងារ និង/ឬក្រុមប្រឹក្សានៅគ្រប់កម្រិតទាំងអស់ រួមទាំងថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ គឺមានសារៈសំខាន់ណាស់។ ដោយហេតុនេះ កសិករ និងភាគីពាក់ព័ន្ធវិស័យកសិកម្មដទៃទៀត នឹងត្រូវបានដាក់បញ្ចូលក្នុងគណៈកម្មាធិការប្រឹក្សាយោបល់នៅក្នុងការិយាល័យផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។

NATSC និងអនុគណៈកម្មាធិការរបស់ខ្លួន នឹងមើលខុសត្រូវលើប្រតិបត្តិការ និងការគ្រប់គ្រងរបស់គណៈកម្មាធិការភាគីពាក់ព័ន្ធនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីធានាឱ្យមានគោលវិធីការសម្របសម្រួលគ្នាក្នុងការផ្សព្វផ្សាយកសិកម្ម។

## មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF)

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងមានក្រុមការងារមន្ត្រីកសិកម្ម (Agriculture Extension Officer-AEOs) និងអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម ឬ អ្នកឯកទេសតាមវិស័យ (Subject Matter Specialis-SMS) ដែលទទួលខុសត្រូវក្នុងការបង្កើតចំណងទាក់ទងរវាងការស្រាវជ្រាវជាមួយការផ្សព្វផ្សាយកសិកម្ម ពិនិត្យតាមដានកម្មវិធីផ្សព្វផ្សាយកសិកម្មស្រុក និងបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់ស្រុក និង ថ្នាក់ឃុំ។ រចនាសម្ព័ន្ធស្ថាប័នត្រូវបានបង្ហាញជូនក្នុងឧបសម្ព័ន្ធ ក-១។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវក្នុងការសម្របសម្រួលប្រតិបត្តិការ និងការគ្រប់គ្រងកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម រួមទាំងខណ្ឌរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលព្រៃឈើ មជ្ឈមណ្ឌលបណ្តុះបណ្តាល ស្ថានីយស្រាវជ្រាវកសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍកសិកម្ម។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងគ្រប់គ្រងលើការផ្តល់មូលនិធិសាធារណៈសម្រាប់សេវាផ្សព្វផ្សាយកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការផ្តល់មូលនិធិពីដៃគូអភិវឌ្ឍដទៃទៀត និងវិស័យឯកជន។

## ក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនីមួយៗ នឹងមានក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត (PAEWG)។ ក្រុមការងារ គឺមានអភិបាលរងម្នាក់ជាប្រធាន និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បម្រើការជាលេខា

សមាជិក ហើយទទួលខុសត្រូវចំពោះការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពរបស់ក្រុមការងារនេះ។ សមាជិករបស់ក្រុមការងារមានសមាសភាពមកពី៖

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកសិករនៅក្នុងខេត្ត
- CARDI និងមជ្ឈមណ្ឌល/វិទ្យាស្ថានបណ្តុះបណ្តាលកសិកម្មនៅក្នុងខេត្ត
- រដ្ឋាភិបាលថ្នាក់ខេត្ត
- វិស័យឯកជន
- អង្គការកសិករដែលចូលរួមក្នុងការអនុវត្តកម្មវិធីកសិកម្មនៅក្នុងខេត្ត
- ការិយាល័យកសិកម្មស្រុក។

មុខងារចម្បងរបស់ PAEWG គឺក្នុងការសម្របសម្រួលកម្មវិធី និងសេវាអភិវឌ្ឍកសិកម្ម។ តួនាទី និងការទទួលខុសត្រូវដទៃទៀត រួមមាន៖

- គាំទ្រ និងសម្របសម្រួលកម្មវិធី គម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅថ្នាក់ខេត្ត និងថ្នាក់ស្រុក រួមទាំងធនធានហិរញ្ញវត្ថុ (ថវិកា) និងធនធានមនុស្ស
- គាំទ្រ និងសម្របសម្រួលការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅក្នុងលក្ខណៈពហុនិយម ដោយក្នុងនោះត្រូវរួមមានទាំងភាគីពាក់ព័ន្ធនានា ដូចជាអង្គភាពសាធារណៈ និង វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការថ្នាក់សហគមន៍
- សម្របសម្រួលក្នុងការតភ្ជាប់រវាងការស្រាវជ្រាវ និង ការផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជូនដល់មន្ត្រីផ្សព្វផ្សាយកសិកម្មស្រុកនិងភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់មូលដ្ឋាន
- គៀងគរធនធាន និងថវិកាដើម្បីគាំទ្រដល់កម្មវិធី គម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក
- វាយតម្លៃលើសេចក្តីត្រូវការផ្នែកការផ្សព្វផ្សាយកសិកម្ម និងបញ្ហានានានៅថ្នាក់ខេត្ត នៅថ្នាក់ស្រុកនិងកំណត់អាទិភាព
- ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក និងបណ្តុះបណ្តាលមន្ត្រីកសិកម្មនៅថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន
- រៀបចំវេទិកាប្រចាំឆ្នាំសម្រាប់មន្ត្រីផ្សព្វផ្សាយកសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅក្នុងខេត្ត
- ពិនិត្យតាមដាន វាយតម្លៃ និងទាញចេញនូវមេរៀន ឬបទពិសោធន៍ទទួលបាន ព្រមជាមួយការច្នៃប្រឌិតបង្កើតថ្មី ឯកសារបច្ចេកទេសកសិកម្ម និងសារនានានៅក្នុងខេត្ត។

## ការិយាល័យកសិកម្មស្រុក

PAEC លើកកម្ពស់ការគ្រប់គ្រងបែបវិមជ្ឈការ និងមានលក្ខណៈពហុនិយមនៅក្នុងការផ្សព្វផ្សាយកសិកម្ម និងសេវាទីប្រឹក្សា។ ឧបសម្ព័ន្ធក-២ បង្ហាញអំពីរចនាសម្ព័ន្ធស្ថាប័នរបស់ការិយាល័យកសិកម្មស្រុក (ការិយាល័យកសិកម្ម

ក្រុង/ខ័ណ្ឌ)។ ដោយមានសមត្ថកិច្ចក្នុងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋានលើសេវាផ្សព្វផ្សាយកសិកម្ម និងអាទិភាព ព្រមទាំងលក្ខណៈនៃអ្នកផ្តល់សេវា DAO នឹងមានសមត្ថភាពអាចធ្វើផែនការ និងអនុវត្តសេវាផ្សព្វផ្សាយកសិកម្មដែល ផ្អែកលើសេចក្តីត្រូវការថ្នាក់មូលដ្ឋាន និងជំរុញដោយតម្រូវទីផ្សារ។ ម្យ៉ាងវិញទៀត ការមានជម្រើសក្នុងលក្ខណៈទាក់ទងជាមួយអ្នកផ្តល់សេវា ពោលគឺការផ្តល់សេវាដែលមានលក្ខណៈពហុនិយម និងជួយធានាឱ្យអាចអនុវត្តកម្មវិធីប្រកប ដោយប្រសិទ្ធភាពចំណាយខ្ពស់។ អតិថិជនចាំបាច់ត្រូវដឹង ថាតើមានអ្នកផ្តល់សេវាណាខ្លះ ហើយមានសេវាប្រភេទណាខ្លះដែលត្រូវបានផ្តល់ឱ្យ។ ទិដ្ឋភាពនេះ នឹងអាចជួយឱ្យពួកគាត់អាចទទួលបានសេវាប្រកបដោយគុណភាព និងទាន់ពេលវេលាពីអ្នកផ្តល់សេវាវិស័យឯកជន។ គោលនយោបាយផ្សព្វផ្សាយកសិកម្មក៏លើកកម្ពស់ការសម្របសម្រួល បែបវិមជ្ឈការ និងការសម្រេចចិត្តនៅថ្នាក់ក្រោម ដើម្បីបង្កើនបរិយាប័ន្នចំពោះកសិករក្នុងប្រភេទផ្សេងៗជាច្រើន និងយេនឌ័រនៅថ្នាក់ DATST និង CAC ដែលនឹងអាចជួយពង្រឹងគុណភាពសេវាកាន់តែច្រើនថែមទៀត។ ការិយាល័យកសិកម្មស្រុក (DAO) នឹងទទួលយកចរិកាកម្មវិធីប្រចាំឆ្នាំតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការិយាល័យកសិកម្មស្រុក ក៏អាចទទួលមូលនិធិពីដៃគូអភិវឌ្ឍដទៃទៀត អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនផងដែរ។ ការិយាល័យកសិកម្មស្រុក នឹងជួយសម្របសម្រួលសេវាផ្សព្វផ្សាយកសិកម្មទាំងអស់នៅក្នុងប្រទេស។ ការិយាល័យកសិកម្មស្រុកនឹងអាចអនុញ្ញាតឱ្យអ្នកតំណាងកសិករក្នុងមូលដ្ឋាន និងកសិធុរកិច្ច អាចកំណត់ និងរៀបចំសេចក្តីត្រូវការផ្នែកកសិកម្មសម្រាប់សកម្មភាពសមស្របដោយភាគីពាក់ព័ន្ធ។

ការិយាល័យកសិកម្មស្រុក នឹងមានមុខងារសំខាន់ៗចំនួនបួន៖

- **ការរៀបចំតម្រូវការរបស់កសិករ៖**
  ដំណើរការនេះ នឹងអនុញ្ញាតឱ្យអ្នកតំណាងកសិករថ្នាក់មូលដ្ឋានក្នុងគណៈកម្មាធិការកសិកម្មឃុំ អាចកំណត់ និងចាត់អាទិភាពសេចក្តីត្រូវការផ្នែកកសិកម្ម រួចសម្រេចចិត្តរកគន្លងសកម្មភាពសមស្របដែលត្រូវធ្វើឡើង
- **រៀបចំការឆ្លើយតបរបស់អ្នកផ្តល់សេវាជូនទៅតាមសេចក្តីត្រូវការរបស់កសិករ៖**
  នេះ គឺជាដំណើរការក្នុងការកំណត់អត្តសញ្ញាណ និងធ្វើឱ្យមានការចូលរួមពីអ្នកផ្តល់សេវា ដែលអាចឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កសិករជាអង្គភាពទោល ឬក្នុងកិច្ចសហការជាមួយអង្គការដទៃទៀត
- **ការសម្របសម្រួលភាគីពាក់ព័ន្ធកិច្ចសហការនិងការផ្តល់ទីតាំងរួមគ្នា៖**
  អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងសេវាប្រឹក្សាយោបល់កសិកម្ម កំណត់រកបញ្ហា អន្តរាគមន៍ និងសេចក្តីត្រូវការដែលបង្ហាញដោយកសិករ ដែលពួកគាត់អាចផ្តល់ការគាំទ្រក្នុងនាមជារចនាសម្ព័ន្ធបុគ្គល ឬក្នុងកិច្ចសហការជាមួយភាគីពាក់ព័ន្ធដទៃទៀត។ ភាគីពាក់ព័ន្ធក៏អាចកំណត់រកអង្គការ ឬបុគ្គលដែលមានគុណសម្បត្តិប្រហាក់ប្រហែល ដើម្បីផ្តល់សេវា ជាក់លាក់ ដើម្បីធានាឱ្យបានថា អតិថិជនបានទទួលសេវាគុណភាពខ្ពស់ពីអ្នកដែលមានសមត្ថភាពបំផុតក្នុងការផ្តល់សេវាទាំងនោះ។ ការចុះបញ្ជី និងការផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវា នឹងអាចជួយកំណត់រក និងជ្រើសរើសដៃគូល្អបំផុត ដើម្បីអនុវត្តសកម្មភាពនៅថ្នាក់ស្រុក ថ្នាក់ឃុំ និងថ្នាក់ភូមិ។
- **ការទទួលបានមូលនិធិ៖**
  **ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក៖** ចាំបាច់ត្រូវស្វែងរកវិធីក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់សេវាផ្សព្វផ្សាយកសិកម្មពីប្រភពមូលនិធិនានាដែលមាននៅស្រុក។ ប្រភពដែលត្រូវស្វែងរកអាចរួមមានដូចជាមូល

និធិមកពី ក្រសួង/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មូលនិធិអភិវឌ្ឍស្រុក និងមូលនិធិអភិវឌ្ឍឃុំ និងមូលនិធិមកពីដៃគូអភិវឌ្ឍ។

## ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក

នៅថ្នាក់ស្រុក ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក (DATST) នឹងផ្តល់សេវាទីប្រឹក្សាដល់ការិយាល័យកសិកម្មស្រុក។ គណៈកម្មាធិការនេះ រួមមានសមាសភាពប្រធានផ្នែកបច្ចេកទេសកសិកម្មទាំងអស់ (ដំណាំ បសុសត្វ ជលផល ព្រៃឈើ ធារាសាស្ត្រ ផែនការ) នៅថ្នាក់ស្រុក ក្រសួងមហាផ្ទៃ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលផ្តល់សេវាអភិវឌ្ឍកសិកម្ម ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងវិស័យឯកជន រួមទាំងអ្នកផ្គត់ផ្គង់ធាតុចូល និងអង្គការកសិករ។ មន្ត្រីកសិកម្មស្រុក នឹងផ្តល់សេវាលេខាសម្រាប់ DATST។ ប្រធានគណៈកម្មាធិការ និងអនុប្រធាន នឹងត្រូវបានបោះឆ្នោតជ្រើសរើសចេញពីភាគីពាក់ព័ន្ធមិនមែនរដ្ឋ។

### មុខងាររបស់ DATST

មុខងាររបស់ DATST រួមមាន៖

- ពិនិត្យឡើងវិញលើសេចក្តីត្រូវការ និងអាទិភាពផ្នែកការអភិវឌ្ឍកសិកម្មដាក់ជូនដោយគណៈកម្មាធិការកសិកម្មឃុំ និងកំណត់សេចក្តីត្រូវការ និងអាទិភាពរបស់ស្រុក ដើម្បីអភិវឌ្ឍផែនការការងារប្រចាំឆ្នាំសម្រាប់ DAO
- បង្កើតបញ្ជីអ្នកផ្តល់សេវាសម្រាប់ប្រើប្រាស់ក្នុងការសម្រេចចិត្តស្តីពីការចាត់ចែងធនធាន
- ផ្តល់វេទិកាសម្រាប់ភាគីពាក់ព័ន្ធ ដើម្បីបង្ហាញផែនការការងារ និងរបាយការណ៍វឌ្ឍនភាពរបស់ពួកគេស្តីពីការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មនៅក្នុងស្រុក
- ផ្តល់ប្រឹក្សាដល់ DAO ស្តីពីការចាត់ចែងធនធានជូនដល់អ្នកផ្តល់សេវា
- ដើរតួនាទីជាធនាគារខួរក្បាល ដើម្បីពិនិត្យឡើងវិញលើគម្រោងកសិកម្ម និងផ្តល់ប្រឹក្សាដល់ DAO ស្តីពីបញ្ហាបច្ចេកទេស
- បង្កើតបទដ្ឋានអប្បបរមាសម្រាប់សេវាផ្សព្វផ្សាយកសិកម្មតាមរយៈការអភិវឌ្ឍគោលការណ៍ណែនាំជាក់លាក់សម្រាប់ការអនុវត្តសេវា និង/ឬអន្តរាគមន៍នៅក្នុងស្រុក
- បង្កើតក្រុមការងារដើម្បីអនុវត្តភារកិច្ចជាក់លាក់ ឧ. សាលារៀនស្រែកសិករ ការអនុវត្តបង្ហាញនៅកសិដ្ឋាន និងអភិវឌ្ឍ និងសម្របសម្រួលសារបច្ចេកទេសសម្រាប់កសិករក្នុងមូលដ្ឋាន
- ផ្តល់អនុសាសន៍ស្តីពីការជ្រើសរើស និងការបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (CEWs និង VEWs) និងកសិករនាំមុខ
- ទទួលស្គាល់ និង ផ្តល់រង្វាន់ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និង កសិករនាំមុខចំពោះលទ្ធផលការងារលេចធ្លោរបស់ពួកគេ។

ការិយាល័យកសិកម្មស្រុក ដោយមានការគាំទ្រពី**ក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក** នឹងរៀបចំវេទិកាប្រចាំឆ្នាំមួយរបស់ភាគីពាក់ព័ន្ធកសិកម្ម។ អ្នកចូលរួម រួមមាន CEWs/VEWs, NGOs កសិករនាំមុខ ប្រធានកសិករកសិកម្ម បុគ្គលិកអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក , MFIs/ធនាគារ (MFIs ដែលធ្វើការជាមួយកសិករខ្នាតតូច) អាជ្ញាធរមូលដ្ឋាន (អ្នកដឹកនាំភូមិ ប្រធានក្រុមប្រឹក្សាឃុំ និងអភិបាលស្រុក) និងអ្នកតំណាងវិស័យឯក

ជន។ ឧបសម្ព័ន្ធ ក-៣ ខាងក្រោមបង្ហាញអំពីយន្តការសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាសមស្របនៅថ្នាក់មូលដ្ឋានសម្រាប់កសិករ។

ជាការល្អ វេទិកាប្រចាំឆ្នាំគួរត្រូវបានធ្វើឡើងក្នុងចន្លោះខែមេសា-មិថុនា ជារៀងរាល់ឆ្នាំដើម្បីផ្តល់ឱកាសឱ្យកសិករ អ្នកផ្គត់ផ្គង់ធាតុចូល អ្នកប្រមូលទិញ និងអ្នកទិញ ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាអំពីសេចក្តីត្រូវការផ្នែកកសិកម្មក្នុងមូលដ្ឋាន ផលិតកម្មកសិកម្ម និងតម្រូវការទីផ្សារ។ ការពិភាក្សាក៏អាចរួមបញ្ចូលនូវសេចក្តីត្រូវការកិច្ចសហការ និងកិច្ចសហការរវាងអ្នកដើរតួនាទីទាំងឡាយនៅក្នុងច្រវាក់តម្លៃ ឈ្មួញកណ្តាល កសិករ អ្នកទិញ អាជ្ញាធរ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម CEWs, និងអ្នកផ្គត់ផ្គង់ធាតុចូល។ DATST នឹងផ្តល់អនុសាសន៍ជូនដល់ផ្នែកពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដូចជា PDA, DAE, ឬ GDA) ដើម្បីដោះស្រាយបញ្ហា និងរឿងទាំងឡាយដែលកើតមាន។ DATST នឹងអញ្ជើញដៃគូអភិវឌ្ឍវិស័យកសិកម្មទាំងអស់មកចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំនេះ ដើម្បីចែករំលែកបទពិសោធន៍នៅថ្នាក់ស្រុក។

ការិយាល័យកសិកម្មស្រុក ក៏អាចរៀបចំការកសាងសមត្ថភាពបន្ថែមទៀតដែលទទួលបានពីអ្នកផ្តល់សេវាដទៃទៀត ដូចជាសាលាភូមិន្ទកសិកម្ម(RUA) សាលាជាតិកសិកម្មព្រែកលៀប (NSAPL) ឬសាលាបច្ចេកទេស ឬវិជ្ជាជីវៈដទៃទៀត។ DAO អាចផ្តួចផ្តើមគំនិតឱ្យមានអនុស្សរណៈនៃការយោគយល់គ្នា ឬកិច្ចសន្យាដោយផ្ទាល់ជាមួយគម្រោងផ្តល់មូលនិធិដោយម្ចាស់ជំនួយ NGOs និងអ្នកផ្តល់សេវាឯកជនផងដែរ។ ឧបសម្ព័ន្ធ ក-៤ បង្ហាញអំពីរចនាសម្ព័ន្ធសេវាផ្សព្វផ្សាយកសិកម្ម និងថាតើមន្ត្រីថ្នាក់ខេត្ត ស្រុក និងឃុំ អាចទទួលបានកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីដៃគូអភិវឌ្ឍ NGOs និងវិស័យឯកជនបានដោយរបៀបណា។

## មជ្ឈមណ្ឌលកសិកម្មឃុំ

គោលបំណងទូទៅនៃមជ្ឈមណ្ឌលកសិកម្មឃុំ គឺដើម្បីសម្របសម្រួលសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ឃុំ និងថ្នាក់ភូមិ និង ដើម្បីឆ្លើយតបការទាមទារ និង សេចក្តីត្រូវការរបស់កសិករជាបុគ្គល។ គណៈកម្មាធិការកសិកម្មឃុំ (CAC) ដើរតួនាទីយ៉ាងសំខាន់ក្នុងការសេវាផ្សព្វផ្សាយកសិកម្មបែបវិមជ្ឈការ។ CAC ពិភាក្សាអំពីសកម្មភាពអភិវឌ្ឍពាក់ព័ន្ធជាមួយកសិកម្ម និងរាយការណ៍ជូនទៅ DATST។ បញ្ហាកសិកម្មដែលទាមទារការយកចិត្តទុកដាក់ពី PDAFF/GDA/DAE របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនអាចធ្វើទៅដោយពុំមានការអនុម័តពី CAC និង DATST។ CACs នឹងកំណត់អត្តសញ្ញាណ ជ្រើសរើស បណ្តុះបណ្តាល និងកៀងគរភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ (CEWs) និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) ដែលនឹងទទួលការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសពីវិទ្យាស្ថានបណ្តុះបណ្តាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មជ្ឈមណ្ឌលកសិកម្មឃុំ នឹងមានប្រតិបត្តិការនៅថ្នាក់មូលដ្ឋានបម្រើការងារដោយភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ (CEWs) ដែលជាអ្នកធ្វើផែនការ អនុវត្ត និងវាយតម្លៃលើកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មឃុំ ដោយមានការចង្អុលបង្ហាញផ្នែករដ្ឋបាលពីការិយាល័យកសិកម្មស្រុក។ គណៈកម្មាធិការកសិកម្មឃុំ នឹងបង្កើតការពិពណ៌នាពីការងារសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ និង បង្កើតគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃលទ្ធផលការងារ។

## គណៈកម្មាធិការកសិកម្មឃុំ

គណៈកម្មាធិការកសិកម្មឃុំ (CAC) រួមមានសមាសភាពអ្នកតំណាងអ្នកដើរតួនាទីផ្នែកកសិកម្មទាំងអស់ដែលមានប្រតិបត្តិការនៅថ្នាក់ឃុំ។ សមាសភាពទាំងនេះ រួមមានបុគ្គលិករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ NGOs កសិករជាលក្ខណៈពាណិជ្ជកម្ម និងពាក់កណ្ដាលពាណិជ្ជកម្ម អង្គការកសិករ ក្រុមកសិធុរកិច្ច និងកសិករ និងអ្នកផលិតនៅផ្ទះ។ យ៉ាងហោចណាស់ ២៥% នៃសមាជិកសរុបរបស់ CAC គឺជាស្ត្រី ហើយ ២៥% គឺជាយុវជនអាយុក្រោម ៣០ ឆ្នាំ។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ នឹងផ្ដល់សេវាលេខាធិការដ្ឋាន និងដំបូន្មានផ្នែកបច្ចេកទេសជូនដល់គណៈកម្មាធិការ។ សមាជិកភាគីពាក់ព័ន្ធ គួរត្រូវបានពិនិត្យឡើងវិញរៀងរាល់បីឆ្នាំម្ដង។ អ្នកដើរតួរសំខាន់ៗ ព្រមជាមួយសង្វាក់តម្លៃអាទិភាព ត្រូវមានវត្តមាន។ ក្នុងករណីអ្នកតំណាងក្រុមសំខាន់ៗណាមួយ ដូចជាក្រុមកសិធុរកិច្ច ស្ត្រី និងយុវជនមានចំនួនមិនគ្រប់គ្រាន់ ត្រូវធ្វើការអញ្ជើញចំគោលដៅទៅកាន់ក្រុមទាំងអស់នោះ។

### មុខងាររបស់គណៈកម្មាធិការកសិកម្មឃុំ

មុខងាររបស់គណៈកម្មាធិការកសិកម្មឃុំ រួមមាន៖

- ផ្ដល់វេទិកាសម្រាប់កសិករ និងអ្នកផលិតតាមផ្ទះឱ្យធ្វើបទបង្ហាញ និងពិភក្សាអំពីវឌ្ឍនភាពស្ដីពីអន្តរាគមន៍កសិកម្មនៅក្នុងភូមិស្ថិតនៅក្នុងឃុំនោះ។
- ផ្ដល់វេទិកាសម្រាប់កសិករឱ្យព្រមព្រៀងគ្នាលើបញ្ហាកសិកម្មជារួមដែលប៉ះពាល់ដល់ពួកគេ និងពិភាក្សារកវិធីដោះស្រាយបញ្ហាទាំងអស់នេះ។
- កំណត់រកសេចក្ដីត្រូវការផ្នែកកសិកម្មនៅក្នុងឃុំ ចាត់អាទិភាពសេចក្ដីត្រូវការ និងបញ្ហាទាំងអស់នេះ និងអភិវឌ្ឍផែនការសកម្មភាព ដើម្បីដោះស្រាយសេចក្ដីត្រូវការ និងបញ្ហា ជាអាទិភាពដែលត្រូវបានកំណត់ឃើញ
- កំណត់រកភាគីពាក់ព័ន្ធដែលចាប់អារម្មណ៍ក្នុងការផ្ដល់មូលនិធិ ឬគាំទ្រអន្តរាគមន៍ទាក់ទងជាមួយសេចក្ដីត្រូវការ និងបញ្ហាដែលកំពុងលេចឡើងនៅក្នុងភូមិ
- ធ្វើផែនការ និងអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្ម និងអន្តរាគមន៍នានាក្នុងកិច្ចសហការជាមួយភាគីពាក់ព័ន្ធទាំងអស់នៅក្នុងភូមិដែលស្ថិតក្នុងឃុំនោះ
- អភិវឌ្ឍ និង រក្សាឱ្យមានដេតាបេសអំពីអ្នកផ្ដល់សេវាផ្សព្វផ្សាយកសិកម្មដែលធ្វើការនៅក្នុងភូមិ
- អភិវឌ្ឍដេតាបេសហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធជាមួយកសិកម្ម ដូចជា បណ្ដាញផ្លូវថ្នល់ ទំនប់ទឹក ទីផ្សារ និងគម្រោងប្រព័ន្ធស្រោចស្រព ព្រមទាំងទីតាំងសក្ដានុពល
- ស្វែងរកកិច្ចសហការជាមួយមេភូមិ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិក្នុងការអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម
- រៀបចំ និងធ្វើបទបង្ហាញរបាយការណ៍ប្រចាំឆ្នាំជូនដល់ DAEC ស្ដីពីសកម្មភាពផ្សព្វផ្សាយកសិកម្មនៅក្នុងភូមិ
- ផ្ដល់ប្រឹក្សាដល់ភាគីពាក់ព័ន្ធស្ដីពីដៃគូនានា ដែលកំពុងអនុវត្តអន្តរាគមន៍ប្រហាក់ប្រហែលនៅក្នុងភូមិ ដើម្បីកំណត់រកវិស័យសហការ និងពង្រឹងការសម្របសម្រួល
- កំណត់រក និងណែនាំបេក្ខភាពសម្រាប់ការបណ្ដុះបណ្ដាលឱ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយឃុំ និងភ្នាក់ងារផ្សព្វផ្សាយភូមិ និងស្នើឡើងនូវសេចក្ដីត្រូវការការបណ្ដុះបណ្ដាលជាអាទិភាពសម្រាប់ពួកគេ
- ទទួលស្គាល់ និងផ្ដល់រង្វាន់ដល់ CEWS, VEWs និងកសិករនាំមុខ/កសិធុរកិច្ចចំពោះការងារលេចធ្លោរបស់ពួកគេ។

មជ្ឈមណ្ឌលកិសកម្មឃុំ នឹងផ្តល់ការគាំទ្រដល់កិច្ចប្រជុំជាប្រចាំរបស់ CAC និងផ្សព្វផ្សាយកំណត់ហេតុកិច្ចប្រជុំជូនដល់ភាគីពាក់ព័ន្ធនានា រួមទាំងការិយាល័យខេត្ត និងស្រុក។

កម្មវិធី ASPIRE នឹងជួយធានាឱ្យមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពរវាង AEAC និងអនុគណៈកម្មាធិការរបស់ខ្លួន NATSC និងគណៈកម្មាធិការភាគីពាក់ព័ន្ធថ្នាក់ខេត្ត និងថ្នាក់ស្រុក តាមរយៈការផ្គោតព័ត៌មានសង្ខេបជារយៈៗ។ ដោយមានការជួយជ្រោមជ្រែងពីអង្គភាពគាំទ្រការអនុវត្ត ASPIRE របាយការណ៍ប្រចាំឆ្នាំមួយរបស់ ASPIRE នឹងត្រូវបានរៀបចំឡើង និងត្រូវដាក់ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្ដីការគណៈរដ្ឋមន្ត្រី។

ការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពរបស់គណៈកម្មាធិការភាគីពាក់ព័ន្ធ គឺជាគន្លឹះដើម្បីទទួលបានជោគជ័យក្នុងការអនុវត្ត PAEC។ ការដាក់បញ្ចូលយេនឌ័រនៅក្នុងគណៈកម្មាធិការទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺមានភាពចាំបាច់ណាស់ ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់កសិករជាស្ត្រី។ កម្មវិធី ASPIRE នឹងគាំទ្រដល់ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់សមាជិកគណៈកម្មាធិការភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ភាពរឹងមាំឱ្យពួកគេអាចធ្វើផែនការ និងអនុវត្តសេវាផ្សព្វផ្សាយកសិកម្មផ្អែកលើតម្រូវការ និងជំរុញដោយទីផ្សារ។

## ការជ្រើសរើស និងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

PAEC កំណត់ឱ្យមានភ្នាក់ងារផ្សព្វផ្សាយកសិកម្មបួនកម្រិត ពោលគឺ ភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWs) ភ្នាក់ងារផ្សព្វផ្សាយឃុំ(CEWs) ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម(AEAs) និងអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs)។ ដូចយើងអាចឃើញនៅក្នុងឈ្មោះរបស់មុខតំណែងទាំងនេះហើយថា VEWs មានការគ្របដណ្តប់ផ្អែកភូមិសាស្ត្រតូចជាងគេបំផុតបន្ទាប់មកគឺ CEWs។ ទោះយ៉ាងណាក្តី តួនាទីក្នុងការអប់រំ គឺជាមូលដ្ឋានមានលក្ខណៈដូចគ្នា។ CEWs ធ្វើការនៅថ្នាក់ឃុំ ហេតុនេះ ពួកគេគ្រប់គ្រងលើកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មនៅតាមភូមិនានា និងក្នុងសហគមន៍។

ដោយគិតទៅលើការសង្កត់ធ្ងន់របស់ PAEC ចំពោះវិធីសាស្រ្តផ្សព្វផ្សាយកសិកម្មក្នុងការផ្តល់សេវាដែលមានលក្ខណៈវិមជ្ឈការ ជំរុញដោយសេចក្តីត្រូវការទីផ្សារ និងមានលក្ខណៈពហុនិយម តួនាទី និងការទទួលខុសត្រូវរបស់ VEWs និង CEWs គឺមានសារៈសំខាន់ខ្លាំងណាស់។ ហេតុនេះការជ្រើសរើស VEWs និង CEWs អាចពិចារណាលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

**ចំណេះដឹងអំពីសហគមន៍៖** VEWs និង CEWs គួរជាអ្នកមានលំនៅក្នុងសហគមន៍ដែលខ្លួនបម្រើការងារជូន។ ពួកគេគួរមានចំណេះដឹងជិតស្និទ្ធអំពីសហគមន៍ រួមទាំងលក្ខខណ្ឌសង្គមសេដ្ឋកិច្ចក្នុងមូលដ្ឋាន ការដាក់បញ្ចូលយេនឌ័រ វប្បធម៌ និងគុណតម្លៃ ប្រព័ន្ធកសិដ្ឋានដែលមានបច្ចុប្បន្ន សេចក្តីត្រូវការ និងឧបសគ្គរបស់កសិករ។

**មានទឹកចិត្តបម្រើឱ្យសហគមន៍៖** បុគ្គលនោះគួរមានចំណង់ដ៏ពិតប្រាកដក្នុងការបម្រើឱ្យសហគមន៍របស់ខ្លួន។

**កសិករនាំមុខ ឬអ្នកផលិតនៅផ្ទះ៖** បុគ្គលនោះ គួរជាកសិករ ឬអ្នកផលិតនៅតាមផ្ទះរួចជាស្រេចហើយ ដែលអាចជួយផ្តល់ភាពរឹងមាំដល់ប្រជាជនសហគមន៍តាមរយៈឧទាហរណ៍ ការអនុវត្តបង្ហាញ ឬការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ គាត់គឺជាជនគំរូសម្រាប់សហគមន៍មូលដ្ឋាន។

**មានបុគ្គលិកលក្ខណៈល្អ៖** VEWs និង CEWs ដើរតួនាទីជាអ្នកអប់រំសហគមន៍ និងជាអ្នកនាំមុខផ្នែកគំនិត ហេតុនេះ បុគ្គលិកលក្ខណៈផ្នែកចំណេះដឹង សុចរិតភាព និងភាពរួសរាយរាក់ទាក់ គឺមានភាពចាំបាច់ណាស់។

ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) ក៏គួរតែមានលក្ខណសម្បត្តិដូចខាងលើផងដែរ។ ប្រសិនបើអាចធ្វើបាន ពួកគាត់គួរតែជាអ្នកមានដើមកំណើតមកពីស្រុកនោះផ្ទាល់ ហើយយល់ដឹងអំពីសេចក្តីត្រូវការ និងឧបសគ្គផ្នែកកសិកម្មរបស់ស្រុក។

## តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

សេវាផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា នឹងត្រូវដាក់ឱ្យមានលក្ខណៈវិមជ្ឈការ ជំរុញដោយសេចក្តីត្រូវការ និងមានលក្ខណៈចូលរួម ហើយនឹងអនុវត្តតាមគំរូការផ្តល់សេវាបែបពហុនិយម។ ដោយមានការចាប់ផ្តើមការអនុវត្តការធ្វើផែនការនៅថ្នាក់ឃុំ និងថ្នាក់ស្រុក សេវាផ្សព្វផ្សាយកសិកម្ម នឹងត្រូវផ្លាស់ប្តូរចេញពីការថ្នាក់លើមកក្រោម ក្លាយទៅជាសេវាដែលដឹកនាំដោយសេចក្តីត្រូវការរបស់សហគមន៍កាន់តែច្រើនឡើង។ អង្គការកសិករ នឹងមានការចូលរួមកាន់តែច្រើនឡើងក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម ហើយវិស័យឯកជនគឺជាដៃគូដ៏រឹងមាំ ដើម្បីផ្តល់សម្ភារៈផ្គត់ផ្គង់ធាតុចូល និងសេវា។ សេណារីយ៉ូនេះ ពន្យល់អំពីតួនាទីរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលមានការប្រែប្រួលខុសពីមុន ព្រមទាំងមានតម្រូវការឱ្យផ្តោតការយកចិត្តទុកដាក់លើការស្ថាបនាលក្ខណៈពហុភាពឱ្យបានកាន់តែខ្លាំងឡើងក្នុងសេវាផ្សព្វផ្សាយកសិកម្ម។ នៅក្នុងបរិបទនេះ ការអប់រំ និងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មគួរត្រៀមខ្លួនពួកគេឱ្យអាចអនុវត្តតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ធ្វើការវាយតម្លៃសេចក្តីត្រូវការរបស់សហគមន៍ និងកំណត់អាទិភាពដើម្បីអភិវឌ្ឍកម្មវិធីផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈចូលរួម និងជំរុញដោយតម្រូវការសម្រាប់សហគមន៍មូលដ្ឋាន
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលរៀបចំដោយការិយាល័យកសិកម្មស្រុក និង/ឬ NGOs ស្តីពីបច្ចេកទេស ឬការអនុវត្តផ្នែកកសិកម្មបែបទំនើប
- ផ្សព្វផ្សាយចំណេះដឹង និងព័ត៌មានផ្នែកកសិកម្មថ្មីៗតាមរយៈកិច្ចប្រជុំជាលក្ខណៈបុគ្គល និងជាក្រុម ការអនុវត្តបង្ហាញ សាលារៀនស្រែកសិករ និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត
- បម្រើការងារជាចំណងតភ្ជាប់រវាងការស្រាវជ្រាវកសិកម្ម និង គោលនយោបាយជាមួយកសិករ
- រៀបចំបណ្តាញនៅក្នុងរចនាសម្ព័ន្ធមូលដ្ឋាន ធានាឱ្យមានការសម្របសម្រួលសេវា និងលើកកម្ពស់កិច្ចសហការជាមួយដៃគូអភិវឌ្ឍ
- ចងក្រងផលិតករទៅជាក្រុម និងសហគមន៍ ដើម្បីតភ្ជាប់កសិករជាមួយទីផ្សារ ដូចជាការកំណត់រកឱកាស និងវិភាគទីផ្សារ
- សម្របសម្រួលលទ្ធភាពទទួលបានឥណទាន និងការផ្គត់ផ្គង់ធាតុចូល
- លើកកម្ពស់សមភាពយេនឌ័រនិងធ្វើឱ្យមានការចូលរួមពីក្រុមមិនសូវមានសម្លេងនានានៅក្នុងកម្មវិធីផ្សព្វផ្សាយ

កសិកម្ម

- គាំទ្រដល់ការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ថាមពលកកើតឡើងវិញ ការដាក់បញ្ចូលយេនឌ័រនៅក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍកុមារ និងការទាក់ទាញយុវជនមកក្នុងវិជ្ជាជីវៈកសិកម្ម
- អនុវត្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈសហការ និងពហុនិយម
- វាយតម្លៃលើកម្មវិធីផ្សព្វផ្សាយកសិកម្មថ្នាក់មូលដ្ឋាន ដើម្បីរាយការណ៍អំពីវឌ្ឍនភាព និងចងក្រងជាឯកសារនូវផលប៉ះពាល់។

ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវខាងលើបាន ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ចាំបាច់ត្រូវយល់អំពីគោលការណ៍ការរៀនសូត្ររបស់មនុស្សពេញវ័យ ចំណងទំនាក់ទំនងនៅក្នុងក្រុម និង យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ចាំបាច់ត្រូវមានជំនាញក្នុងការរៀបចំ និងការធ្វើផែនការល្អ មានចំណេះដឹងអំពីធាតុសំខាន់ៗនៃប្រព័ន្ធកសិកម្មក្នុងមូលដ្ឋាន ចំណេះដឹងលើប្រធានបទបច្ចេកទេស ក៏ដូចជាជំនាញផ្នែកដំណើរការ ដើម្បីបង្រៀនចំណេះដឹងថ្មីៗជូនដល់អ្នកប្រើប្រាស់ចុងក្រោយ ឬកសិករជាគោលដៅ។ ជំនាញក្នុងការនិយាយជាសាធារណៈ ដូចជាការនិយាយអំពីគំនិតថ្មីៗ ការពន្យល់អំពីជំហាននីមួយៗនៅពេលកំពុងធ្វើការអនុវត្តបង្ហាញ ឬការចូលរួមនៅក្នុងកិច្ចពិភាក្សាសហគមន៍ គឺជាលក្ខណសម្បត្តិដ៏ចាំបាច់សម្រាប់អ្នកផ្សព្វផ្សាយកសិកម្មដ៏ជោគជ័យ។ VEWs និង CEWs គួរធ្វើយ៉ាងណាឱ្យខ្លួនក្លាយជាសហគ្រិនកសិកម្មដ៏ជោគជ័យ និងបំពេញមុខងារជាអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មឯកជន។ គុណភាពសេវារបស់ពួកគេ គួរត្រូវបានវាយតម្លៃដោយអតិថិជន។ ពួកគេរក្សាតួនាទីរបស់ខ្លួនបានតាមរយៈកិច្ចសន្យាផ្តល់សេវា។ ដូច្នេះពួកគេចាំបាច់ត្រូវធ្វើទីផ្សារចំណេះដឹងបច្ចេកទេស និងសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន ដើម្បីអាចទទួលបានកិច្ចសន្យាផ្តល់សេវាជាបន្តបន្ទាប់ពី DAOs ដៃគូអភិវឌ្ឍ និង NGOs។

ដូច្នេះ កម្មវិធីអភិវឌ្ឍធនធានមនុស្សសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ចាំបាច់ត្រូវពិចារណាអំពី តួនាទី និងការទទួលខុសត្រូវក្នុងការងារដែលត្រូវបានរំពឹងទុកសម្រាប់ពួកគេ។ ឧទាហរណ៍ អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) ត្រូវបានរំពឹងថាបម្រើការងារជាអ្នកឯកទេសផ្នែកបច្ចេកទេសលើប្រធានបទកសិកម្មផ្សេងៗ ជាបុគ្គលជំនាញសម្រាប់ការបណ្តុះបណ្តាល និងជាអ្នកសម្របសម្រួលរបស់កម្មវិធីថ្នាក់ខេត្ត ឬថ្នាក់ជាតិ ហេតុនេះ ពួកគាត់ត្រូវការបទពិសោធន៍ និងឯកទេសទូលំទូលាយខ្លាំង។ ស្រដៀងគ្នានេះដែរ ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) ត្រូវមានជំនាញបច្ចេកទេសពាក់ព័ន្ធជាមួយសេចក្តីត្រូវការផ្នែកកសិកម្មរបស់ស្រុកខ្លួន ហើយក៏ត្រូវការសមត្ថភាពលើជំនាញផ្នែកដំណើរការពាក់ព័ន្ធការធ្វើផែនការកម្មវិធីបែបការចូលរួម ការអនុវត្តកម្មវិធី ការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងការប្រាស្រ័យទាក់ទងជាក្រុម និងការវាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិកម្មផងដែរ។

ដូចបានបញ្ជាក់ខាងលើហើយថា ប្រទេសកម្ពុជាបានបាត់បង់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងចំនួនគួរជាទីកត់សម្គាល់អាស្រ័យដោយ ការចូលនិវត្តន៍ ការបោះបង់ការងារ ឬការស្លាប់។ ការអនុវត្តគោលនយោបាយថ្មីស្តីពីការផ្សព្វផ្សាយកសិកម្ម នឹងទាមទារឱ្យមានការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្មីចំនួនជាង ៣ ០០០ នាក់ រួមមានទាំង VEWs, CEWs, AEAs និង AESs។ បន្ថែមលើនេះទៀត ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនាពេលបច្ចុប្បន្ន ត្រូវការបណ្តុះបណ្តាលក្នុងពេលបំពេញការងារស្តីពីការធ្វើផែនការការអនុវត្ត និងការវាយតម្លៃសេវាផ្សព្វផ្សាយកសិកម្មបែបវិមជ្ឈការ ជំរុញដោយតម្រូវការ និងមានលក្ខណៈពហុនិយម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សគ្រប់ជ្រុងជ្រោយមួយដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ផ្នែកខាងក្រោមនេះផ្តល់គោលការណ៍ណែនាំ ស្តីពីការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម។

## ការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម

ប្រទេសកម្ពុជា គឺជាប្រទេសគ្របដណ្តប់ដោយវិស័យកសិកម្ម។ វិស័យកសិកម្មចូលរួមចំណែក ៣៧% នៃ GDP និងផ្តល់ការងារដល់ប្រមាណ ៦៧% នៃកម្លាំងពលកម្មសរុបរបស់ប្រទេស (FAO, ២០១៤)។ យុទ្ធសាស្ត្រចតុកោណ ដែលជាផែនការចក្ខុវិស័យរបស់ប្រទេសកម្ពុជា បានកំណត់ទិសដៅក្នុងការគាំទ្រកសិករឱ្យកែលម្អផលិតភាពកសិដ្ឋាន ពង្រឹងសង្វាក់តម្លៃកសិកម្ម និងពន្លឿនការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម (RGC ២០១៣)។ ប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចគួរជាទីស្ញើចសរសើរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុន្តែនៅតែមានបញ្ហាប្រឈមមួយចំនួន ដូចជា មានចន្លោះប្រហោង និងចំណុចខ្សោយនៅក្នុងការអនុវត្តគោលនយោបាយទាក់ទងជាមួយវិស័យកសិកម្ម អាស្រ័យដោយសមត្ថភាពរបស់កម្លាំងពលកម្មក្នុងប្រទេស នៅមានកម្រិតកំណត់រួមទាំងក្នុងការផ្សព្វផ្សាយកសិកម្មផងដែរជោគជ័យមានកម្រិតកំណត់ក្នុងការរក្សាបានការលូតលាស់ផ្នែកកសិកម្ម។ គោលនយោ បាយដែលត្រូវបានប្រកាសឱ្យប្រើប្រាស់នាពេលថ្មីៗនេះ ដូចជាគោលនយោបាយផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជាឆ្នាំ២០១៥បានគូសបញ្ជាក់អំពីភាពចាំបាច់ក្នុងការបណ្តុះបណ្តាល និងកៀងគរកម្លាំងពលកម្មក្នុងវិស័យកសិកម្មដែលមានគុណភាពខ្ពស់ ដើម្បីរក្សាបាននូវការលូតលាស់ក្នុងវិស័យកសិកម្ម (MAFF ២០១៥)។

ប្រទេសកម្ពុជា ចាំបាច់ត្រូវបណ្តុះបណ្តាលធនធានមនុស្សរបស់ខ្លួន ដើម្បីអនុញ្ញាតឱ្យពួកគេអាចអនុវត្តគម្រោងនាពេលបច្ចុប្បន្ន និងគម្រោងនាពេលអនាគត ឆ្លើយតបចំពោះបញ្ហានាពេលបច្ចុប្បន្ន និងនាពេលអនាគត និងទទួលផលប្រយោជន៍ពីឱកាសនានាដែលអាចកើតមាន។ ការសិក្សានាពេលថ្មីៗនេះក្នុងប្រទេសកម្ពុជាបង្ហាញឱ្យឃើញថា អ្នកប្រកបវិជ្ជាជីវៈផ្នែកវិស័យកសិកម្ម មើលឃើញជំនាញ និងសមត្ថភាពផ្នែកដំណើរការក្នុងការផ្សព្វផ្សាយកសិកម្ម ដូចជាការផែនការកម្មវិធី ការប្រាស្រ័យទាក់ទង ការអនុវត្តកម្មវិធី ការវាយតម្លៃ ពិពិធកម្ម ឯកទេសលើប្រធានបទបច្ចេកទេស ការអភិវឌ្ឍបុគ្គល និងការអភិវឌ្ឍវិជ្ជាជីវៈ និងការអប់រំបច្ចេកវិទ្យា និងព័ត៌មានវិទ្យាមានសារៈសំខាន់ ឬមានសារៈសំខាន់ណាស់ចំពោះការងាររបស់ពួកគេ ហើយពួកគេយល់ថាខ្លួននៅពុំមានសមត្ថភាពឱ្យបានគ្រប់គ្រាន់តាមអ្វីដែលខ្លួនគួរតែមានសមត្ថភាពនៅក្នុងវិស័យសមត្ថភាពទាំងអស់នេះ ដើម្បីបម្រើឱ្យអតិថិជនរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព (Suvedi, Ghimire, & Channa ២០១៧)។ ការស្ទាបស្ទង់មតិអំពីសមត្ថភាពរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា បង្ហាញឱ្យឃើញថា កម្រិតជំនាញ ឬសមត្ថភាពផ្នែកការផ្សព្វផ្សាយកសិកម្មនៅគ្រប់ប្រធានបទទាំងអស់នៅមានកម្រិតទាប ហើយចាំបាច់ត្រូវលើកកម្ពស់បន្ថែមទៀត ដើម្បីឱ្យប្រជាជនអាចមានផលិតភាពខ្ពស់នៅក្នុងវិស័យផ្សព្វផ្សាយកសិកម្ម (Welsh ២០១៧)។ ការសិក្សាដ៏មានតម្លៃដែលមានចំណងជើងថា Feed the Future Cambodia បានបញ្ជាក់ឱ្យឃើញថា បុគ្គលិកនៅពុំបានប្រែក្លាយទាំងស្រុង និងពុំទាន់ងាកទៅជ្រើសរើសយកការផ្សព្វផ្សាយកសិកម្មដែលជំរុញដោយតម្រូវការ និងមានលក្ខណៈចូលរួមទេ ហើយកសិករ ក៏ដូចជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ទាមទារនូវការបណ្តុះបណ្តាលបន្ថែមយ៉ាងហ្មត់ចត់ និងមានលក្ខណៈជាកម្មវិធីបន្ថែមទៀតទៅលើជំនាញផ្សព្វផ្សាយកសិកម្ម។ ដូច្នេះ មហាវិទ្យាល័យ និងសាកលវិទ្យាល័យកសិកម្មក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវធ្វើការបន្ថែមទៀត មិនត្រឹមតែផ្តល់ការបណ្តុះបណ្តាលកសិកម្មទូទៅតែប៉ុណ្ណោះទេ។ មហាវិទ្យាល័យ និងសាកលវិទ្យាល័យ ចាំបាច់ត្រូវផ្តល់ការអប់រំផ្អែកតាមសេចក្តីត្រូវការ ឬផ្អែកតាមតម្រូវការដែលផលិតបុគ្គលិកមានសមត្ថភាព មានការចេះចាំស្ទាត់ជំនាញលើផ្នែកបច្ចេកទេស ក៏ដូចជាជំនាញផ្នែកដំណើរការ ដែលចាំបាច់ដើម្បីបង្កើតសេវាផ្សព្វផ្សាយកសិកម្មដ៏រស់រវើក។ ដូចបានបញ្ជាក់ហើយថា នេះជាពេលវេលាដ៏សំខាន់បំផុតសម្រាប់ប្រទេសកម្ពុជា ក្នុងការកែសម្រួលឡើងវិញ/ធ្វើបច្ចុប្បន្នភាពការបណ្តុះបណ្តាលមុនពេលចូលបម្រើការងារ ក៏ដូចជាកម្មវិធី

សិក្សាការអប់រំក្នុងរយៈពេលកំពុងបម្រើការងារ តាមរយៈការដាក់បញ្ចូលបច្ចេកវិទ្យា និងការអនុវត្តដែលកើតមានថ្មីៗ និងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មដោយប្រើប្រាស់កម្មវិធីសិក្សាថ្មីៗ ដើម្បីឱ្យពួកគេអាចទទួលបានចំណេះដឹង និងបទពិសោធន៍អនុវត្តផ្ទាល់ក្នុងការឈានទៅបម្រើកសិករ និងកសិធុរកិច្ចប្រកបដោយប្រសិទ្ធភាព។

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា កំណត់ឃើញភ្នាក់ងារផ្សព្វផ្សាយកសិកម្មបួនកម្រិតៈ

ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) យ៉ាងតិចត្រូវមានការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិ ហើយត្រូវជាកសិករដែលមានស្រាប់នៅក្នុងភូមិ ដែលមានចំណាប់អារម្មណ៍ជួយដល់កសិករក្នុងមូលដ្ឋានដទៃទៀត។

ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ (CEWs) ជាអ្នកបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ និងជាកសិករដែលមានស្រាប់ដែលប្តេជ្ញាចិត្តបម្រើឱ្យកសិករជិតខាង។

បេក្ខភាពទីប្រឹក្សាផ្នែកផ្សព្វផ្សាយកសិកម្ម (AEAs) ត្រូវមានវិញ្ញាបនបត្រសាលាបច្ចេកទេសរយៈពេលពីរឆ្នាំ ឬការអប់រំសមមូល ហើយជាការល្អ គឺមកពីស្រុកជនបទ។ មន្ទីរកសិកម្មខេត្ត (PDA) ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាប្រឹក្សាយោបល់ផ្សព្វផ្សាយកសិកម្មស្រុក និង កំណត់អត្តសញ្ញាណជ្រើសរើស និងចាត់បេក្ខភាពសម្រាប់ការបណ្តុះបណ្តាល AEA ដោយសង្កត់ធ្ងន់លើស្ត្រី និងសិស្សមកពីក្រុមជួបការលំបាក។ អ្នកដាក់ពាក្យសុំការបណ្តុះបណ្តាល AEA ចាំបាច់ត្រូវប្រឡងជាប់ក្នុងការប្រឡង ដែលធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាលក្នុងកិច្ចសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) ត្រូវមានសញ្ញាបត្រមកពីសាលាបច្ចេកទេសរយៈពេលបួនឆ្នាំក្នុងផ្នែកកសិកម្ម រុក្ខាប្រមាញ់ ឬនេសាទ។ ការជ្រើសរើសត្រូវផ្អែកលើគុណសម្បត្តិតាមរយៈការប្រឡងចូលរៀបចំឡើងដោយ RUA។ ការជ្រើសរើសស្ត្រីឱ្យចូលរួម គឺនឹងត្រូវបានសង្កត់ធ្ងន់។

គោលនយោបាយអំពាវនាវឱ្យមានការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មបួនកម្រិតៈ ការអប់រំរយៈពេល ៦ទៅ៩ខែ សម្រាប់វគ្គបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រផ្នែកផ្សព្វផ្សាយកសិកម្មសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម ការបណ្តុះបណ្តាលរយៈពេលពី ៣ទៅ៦ខែ ស្តីពីជំនាញផ្សព្វផ្សាយកសិកម្មសម្រាប់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម វគ្គសិក្សារយៈពេល ២ទៅ៤ខែ ស្តីពីជំនាញផ្សព្វផ្សាយកសិកម្មសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ និង ការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយរយៈពេល ២ទៅ៤សប្តាហ៍សម្រាប់អ្នកផ្សព្វផ្សាយកសិកម្មភូមិ (MAFF ២០១៥)។ កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាបន្តសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅគ្រប់កម្រិតទាំងអស់ គឺមានភាពចាំបាច់ណាស់។ ដោយពិនិត្យលើការស្នើឡើងរបស់គោលនយោបាយជាតិ និងការសិក្សាដែលធ្លាប់មានកន្លងមករបាយការណ៍នេះគូសបញ្ជាក់អំពីកម្មវិធីបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មបួនប្រភេទក្នុងប្រទេសកម្ពុជា។

## គោលបំណងនៃការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម

ដើម្បីអភិវឌ្ឍធនធានមនុស្សដែលមានសមត្ថភាពអាចគ្រប់គ្រងធនធានកសិកម្ម ឱ្យសម្រេចបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយនិរន្តរភាពនៅថ្នាក់គ្រួសារ និងថ្នាក់ជាតិ កម្មវិធីអភិវឌ្ឍធនធានមនុស្សព្យាយាមសម្រេចបានគោលបំណងដូចខាងក្រោមៈ

- ផ្តល់ឱ្យសិស្ស ឬសិក្ខាកាមក្នុងការបណ្តុះបណ្តាលនូវការបណ្តុះបណ្តាលឯកភាពគ្នា និងការអប់រំស្តីពីការផ្សព្វផ្សាយកសិកម្ម និងប្រធានបទពាក់ព័ន្ធដែលចាំបាច់សម្រាប់ការអភិវឌ្ឍកសិកម្ម
- អភិវឌ្ឍធនធានមនុស្សផ្នែកការផ្សព្វផ្សាយកសិកម្ម ពោលគឺ ភ្នាក់ងារផ្សព្វផ្សាយភូមិ ភ្នាក់ងារផ្សព្វផ្សាយឃុំ ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម និងអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម ដែលមានសមត្ថភាពលើប្រធានបទបច្ចេកទេស ក៏ដូចជាជំនាញ និងសមត្ថភាពផ្នែកដំណើរការក្នុងការផ្សព្វផ្សាយកសិកម្ម។

## តម្រូវការបណ្តុះបណ្តាលបុគ្គលិក

ការអនុវត្ត PAEC ឱ្យបានពេញទំហឹង ទាមទារឱ្យមាន VEWs, CEWs, AEOs, និង SMSs ក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់។ តារាងទី១៤ បង្ហាញអំពីសេចក្តីត្រូវការការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មសម្រាប់រយៈពេលខ្លីក្នុងប្រទេសកម្ពុជា។ ការអនុវត្តគោលនយោបាយនេះឱ្យបានពេញលេញនៅក្នុងទូទាំងប្រទេស ទាមទារភ្នាក់ងារផ្សព្វផ្សាយកសិកម្មបន្ថែមទៀត ហេតុនេះក៏ត្រូវការឱ្យមានការបណ្តុះបណ្តាលបុគ្គលិកកសិកម្មបន្ថែមទៀតផងដែរ។

### តារាងទី ១៤. ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលត្រូវការសម្រាប់ប្រទេសកម្ពុជា

| កម្មវិធីបណ្តុះបណ្តាល | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | សម្គាល់ |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | |
| ការបណ្តុះបណ្តាលគ្រូបង្គោល(ToT) (ក្នុងប្រទេស) | 20 | 20 | 20 | - | - | កម្មវិធី ASPIRE |
| ToT (ក្រៅប្រទេស) | 5 | 5 | 5 | 5 | 5 | កម្មវិធីASPIRE(ប្រទេសថៃ ប្រទេសហ្វីលីពីនប្រទេសឥណ្ឌា) |
| ភ្នាក់ងារផ្សព្វផ្សាយភូមិ (VEWs) | 500 | 500 | 500 | 500 | 500 | ការបណ្តុះបណ្តាលជួលទៅឱ្យ NGOs នៅថ្នាក់ខេត្ត/ស្រុក |
| ភ្នាក់ងារផ្សព្វផ្សាយឃុំ (CEWs) | 200 | 200 | 200 | 200 | 200 | ការបណ្តុះបណ្តាលជួលទៅឱ្យ NGOs នៅថ្នាក់ស្រុក |
| ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម(AEAs) | 100 | 100 | 100 | 100 | 100 | DAE |
| អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs) | -- | 60 | 60 | 60 | 60 | RUA/PNCA |
| ថ្នាក់អនុបណ្ឌិត | 15 | 15 | 15 | 15 | 10 | កម្មវិធី ASPIRE (២នាក់ក្នុងមួយខេត្ត+២០សម្រាប់ថ្នាក់MAFF/ GDA/DAE ការបណ្តុះបណ្តាលនៅRUA ឬនៅប្រទេសថៃ) |
| ថ្នាក់បណ្ឌិត | 5 | 5 | 5 | 5 | - | សម្រាប់បុគ្គលិកនៅថ្នាក់ MAFF/GDA/DAE/ |

## វិធីសាស្ត្រក្នុងការបណ្តុះបណ្តាល

វិធីសាស្ត្របង្រៀនតាមម៉ូឌុល ត្រូវបានស្នើឡើងដើម្បីបណ្តុះបណ្តាលធនធានមនុស្សផ្នែកផ្សព្វផ្សាយកសិកម្ម ក្នុងប្រទេសកម្ពុជា។ កម្មវិធីបណ្តុះបណ្តាលដែលត្រូវបានស្នើឡើងមានផ្តល់ជូនក្នុងឧបសម្ព័ន្ធ២។ កម្មវិធីសិក្សានេះ រួមមានម៉ូឌុលបន្តបន្ទាប់ជាច្រើន ដើម្បីឱ្យសិស្សអាចឈានទៅក្នុងកម្រិតសមស្របបំផុតសម្រាប់ពួកគេ និងបន្ទាប់មកអាចឈានឡើងឱ្យបានខ្ពស់បំផុតតាមដែលអាចធ្វើបានឈានទៅកាន់ម៉ូឌុលបន្ទាប់ៗ។ មានកម្រិតចូលដំបូងចំនួន ៤ កម្រិត គឺ៖ ភ្នាក់ងារផ្សព្វផ្សាយភូមិ ភ្នាក់ងារផ្សព្វផ្សាយឃុំ ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម និងអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម។ ម៉ូឌុលខាងដើមៗ គឺជាបុរេលក្ខខណ្ឌសម្រាប់ម៉ូឌុលបន្ទាប់ៗទៀត។ VEWs និង CEWs គឺជាអ្នកធ្វើការងារនៅកម្រិតមូលដ្ឋាន ដែលផ្តល់សេវាផ្សព្វផ្សាយកសិកម្មកម្រិតមូលដ្ឋានដល់កសិករ។ CEWs មានការបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មច្រើនជាង VEWs បន្តិច ហើយគ្របដណ្តប់លើផ្ទៃដីធំទូលាយជាង។ AEAs បម្រើការងារនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ AESs ធ្វើការនៅក្រោមអគ្គនាយកដ្ឋានកសិកម្ម និង/ឬនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

វិធីសាស្ត្របងករៀនតាមម៉ូឌុលដូចបង្ហាញជូនក្នុងរបាយការណ៍នេះ អនុញ្ញាតឱ្យថ្នាក់គ្រប់គ្រងការផ្សព្វផ្សាយកសិកម្មអាចធ្វើផែនការ វិនិយោគ និងផ្តល់ការបណ្តុះបណ្តាលក្នុងវិស័យទាំងឡាយណាដែលជាតម្រូវការជាបន្ទាន់ ឬជាសេចក្តីត្រូវការ។ គោលវិធីនេះ គឺជាគោលវិធីពីក្រោមឡើងទៅលើ ហើយដឹកនាំដោយអ្នកទទួលផល ពោលគឺ អ្នកទទួលផលនៅថ្នាក់មូលដ្ឋាន ហើយភាគីពាក់ព័ន្ធជាអ្នកកំណត់អត្តសញ្ញាណ/ចាត់បេក្ខភាព VEWs/CEWs ជាសក្តានុពល ហើយស្នើឡើងនូវវិស័យសម្រាប់ការបណ្តុះបណ្តាល ឬប្រធានបទដែលផ្តោតការយកចិត្តទុកដាក់សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដោយឈរលើមូលដ្ឋាននៃសេចក្តីត្រូវការរបស់សហគមន៍ខ្លួន។ វិធីសាស្ត្រនេះ គឺត្រូវការតាក់តែងឡើង ដើម្បីផ្តល់លទ្ធផលឱ្យមានការរក្សាទុកបុគ្គលិកបានខ្ពស់បំផុត និងការបោះបង់ការងារទាបបំផុតចំពោះសិស្ស ជាហេតុធ្វើឱ្យអាចនាំទៅដល់ការគ្រប់គ្រងធនធានមនុស្សប្រកបដោយនិរន្តរភាព។ ចំណុចខាងក្រោមនេះ គូសបញ្ជាក់អំពីគុណសម្បត្តិនៃវិធីសាស្ត្របង្រៀនតាមបែបម៉ូឌុល៖

- សាកលវិទ្យាល័យ/មហាវិទ្យាល័យ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលជាច្រើនអាចចូលរួមក្នុងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ការប្រុងប្រយ័ត្ន បញ្ចូលសមត្ថភាពរបស់សិក្ខាកាមដែលត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបចំពោះបញ្ហាជាក់លាក់ ឬបញ្ហាត្រូវបានពង្រឹង
- សិក្ខាកាមអាចចូលរួមក្នុងវគ្គសិក្សាដែលខ្លួនបានជ្រើសរើសតាមតម្រូវការរបស់ខ្លួន ឧ. អ្នកដែលមិនសូវមានលទ្ធភាពចូលរួមក្នុងវគ្គសិក្សាពេញទាំងមូល គួរតែអាចទទួលបានជំនាញ និងចំណេះដឹងដែលពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាជាក់លាក់
- ម៉ូឌុលនីមួយៗ គឺមានភាពពេញលេញដោយខ្លួនឯង។ ទ្រឹស្តីនាំមុខការរៀនសូត្របែបអនុវត្តជាក់ស្តែង និង/ឬការអនុវត្តផ្ទាល់
- វិធីសាស្ត្រនេះលើកទឹកចិត្តឱ្យយកការរៀនសូត្រទៅអនុវត្តជាជាងគ្រាន់តែរៀនដើម្បីបានទទួលចំណេះដឹងតែប៉ុណ្ណោះ
- វិធីសាស្ត្រនេះជួយសម្រួលឱ្យអាចផ្តល់ការបណ្តុះបណ្តាលនៅតាមពេលវេលាដ៏សមស្រប ពោលគឺ ម៉ូឌុលភ្ជាប់ជាមួយរដូវកាលដាំដុះ ជាជាងកាលវិភាគរបស់មហាវិទ្យាល័យ

- សិក្ខាកាមអាចជ្រើសរើសពេលវេលា និងទីកន្លែងដើម្បីចូលរួមនៅក្នុងម៉ូឌុលជាក់លាក់ណាមួយ
- វិធីសាស្ត្ររៀនជាម៉ូឌុលបែបនេះ លើកទឹកចិត្តឱ្យមានការរៀនសូត្រជាបន្តបន្ទាប់ និង/ឬការរៀនសូត្រទៅតាមសេចក្តីត្រូវការតាមតួនាទីការងារ
- វិធីសាស្ត្រនេះ មានភាពបត់បែន និងការចំណាយមានប្រសិទ្ធភាពខ្ពស់
- ការបង្រៀន និងការរៀនសូត្រ គឺមានលក្ខណៈសន្សឹមៗសមហេតុផល ដោយឈានចេញពីកម្រិតមូលដ្ឋានទៅកម្រិតខ្ពស់ជាងមុន
- អាចប្រើប្រាស់គ្រូបណ្តុះបណ្តាលបន្ថែមដែលជាអ្នកមានជំនាញសមស្រប។

## នីតិវិធីសម្រាប់ការដាក់ពាក្យសុំ និងការជ្រើសរើស

ការិយាល័យកសិកម្មស្រុក ក្នុងកិច្ចពិគ្រោះយោបល់ជាមួយគណៈកម្មាធិការកសិកម្មឃុំ និងប្រធានភូមិ និងមេឃុំ និងភាគីពាក់ព័ន្ធដទៃទៀត ធ្វើការវាយតម្លៃសេចក្តីត្រូវការការបណ្តុះបណ្តាលរបស់តំបន់ខ្លួនរៀងៗខ្លួន ហើយរៀបចំបញ្ជីឈ្មោះបេក្ខភាពសមស្របសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (VEW និង CEW)។ DAO បញ្ជូនបញ្ជីនេះ ទៅឱ្យការិយាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) នីមួយៗ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចងក្រងបញ្ជីមកពីតាមភូមិ និងឃុំរបស់គម្រោង ពិនិត្យលើបញ្ជីឈ្មោះទាំងនោះតាមការចាំបាច់ និងបញ្ចូលបញ្ជីឈ្មោះទៅឱ្យនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) និង អគ្គនាយកដ្ឋានកសិកម្ម (GDA)។ អនុគណៈកម្មាធិការគាំទ្របច្ចេកទេសកសិកម្ម (NATSC) ដែលមានអ្នកតំណាងមកពីអគ្គនាយកដ្ឋានកសិកម្ម (GDA) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មនៅកម្ពុជា (CARDI) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) សាលាជាតិកសិកម្មព្រែកលៀប (PNCA) សាលាជាតិកសិកម្មកំពង់ចាម (KNSA) រដ្ឋបាលជលផល (FiA) អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្ម (DAHP) អគ្គនាយកដ្ឋានកៅស៊ូ (GDR) និងវិស័យឯកជន នឹងពិនិត្យឡើងវិញលើបញ្ជីឈ្មោះបេក្ខភាពដែលបានជ្រើសតាំង និងវិស័យការបណ្តុះបណ្តាលដែលខ្លួនបានទទួលពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចកំណត់ចំនួនចន្លោះទំនេរសម្រាប់ការបណ្តុះបណ្តាល ផ្តល់ការពិចារណាត្រឹមត្រូវទៅលើផែនការជាតិ អភិវឌ្ឍគោលដៅ ធនធានដែលមាន ដូចជាគ្រូបណ្តុះបណ្តាល សាកលវិទ្យាល័យ/មហាវិទ្យាល័យ/មជ្ឈមណ្ឌលបណ្តុះបណ្តាល និង ហេដ្ឋារចនាសម្ព័ន្ធរបស់ពួកគេទាំងនោះ។ល។ NATSC នឹងពិនិត្យបង្ហើយទៅលើបញ្ជីឈ្មោះសិក្ខាកាមសម្រាប់ឆ្នាំនីមួយៗ ចាត់ចែងការទទួលខុសត្រូវសម្រាប់ការបណ្តុះបណ្តាលទៅដល់សាកលវិទ្យាល័យ/មហាវិទ្យាល័យកសិកម្ម និងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងណែនាំឱ្យមានការចាត់ថវិកាទៅគម្រោងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បេក្ខភាពដែលមានឆន្ទៈចង់ឱ្យត្រូវបានពិចារណាជ្រើសរើសចូលក្នុងកម្មវិធីបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្ម ចាំបាច់ត្រូវដាក់ពាក្យទៅកាន់សាកលវិទ្យាល័យ/មហាវិទ្យាល័យដែលពាក់ព័ន្ធ និងផ្តល់សំណៅវិញ្ញាបនបត្រ ឬសក្ខីកម្មថតចម្លងដែលមានបញ្ជាក់ត្រឹមត្រូវ។ សាកលវិទ្យាល័យ/មហាវិទ្យាល័យ រក្សាសិទ្ធិក្នុងការផ្ទៀងផ្ទាត់លើភាពពិតប្រាកដនៃវិញ្ញាបនបត្រមុនពេលទទួលយកសិស្ស។

## វិទ្យាស្ថានបណ្តុះបណ្តាល (សាកលវិទ្យាល័យ/មហាវិទ្យាល័យ/មជ្ឈមណ្ឌលបណ្តុះបណ្តាល)

NATSC នឹងបង្កើតអនុគណៈកម្មាធិការស្តីពីការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅក្រោមការដឹកនាំរបស់អង្គភាពបណ្តុះបណ្តាលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។ សមាជិកអនុគណៈកម្មាធិការមកពីនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ RUA, PNCA និង KNSA។ អនុគណៈកម្មាធិការនេះ ធ្វើការជាក្រុម និងកំណត់លើសមត្ថភាពបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មរបស់វិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលទាំងអស់ ដោយឈរមូលដ្ឋានធនធានមនុស្សដែលមាន (ឧ. គ្រូឧទ្ទេស និងអ្នកជំនាញ) និងបរិក្ខាររូបវន្ត (បន្ទប់បណ្តុះបណ្តាល កន្លែងស្នាក់នៅ ឧបករណ៍ជំនួយការបណ្តុះបណ្តាលបរិក្ខារមន្ទីរពិសោធន៍ កសិដ្ឋានសម្រាប់ទំនិញផ្សេងៗ។ល។) និងបញ្ជាក់អំពីម៉ូឌុលបណ្តុះបណ្តាលដែលខ្លួននឹងផ្តល់ជូន។ អនុគណៈកម្មាធិការ ក៏នឹងផ្តល់អនុសាសន៍អំពីប្រព័ន្ធទទួលស្គាល់គុណភាព ដើម្បីសម្រេចបាន និងរក្សាបាននូវគុណភាពការបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្ម។ នៅពេលចូលជាធរមានហើយ នីតិវិធីទទួលស្គាល់គុណភាព នឹងជួយធានាឱ្យមានកម្មវិធីសិក្សាឯកភាពគ្នា និងស៊ីសង្វាក់គ្នាចំពោះលទ្ធផលការរៀនសូត្រ ដែលសិក្ខាកាមសម្រេចបាន។ អនុគណៈកម្មាធិការ ក៏នឹងផ្តល់អនុសាសន៍នូវសេចក្តីត្រូវការសម្រាប់គ្រូបង្គោល (ToTs) សម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មផងដែរ។

ការបណ្តុះបណ្តាល VEWs និង CEWs អាចធ្វើឡើងនៅថ្នាក់ក្រោមជាតិ និងនៅអគ្គនាយកដ្ឋានកសិកម្ម និង/ឬ មជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ ធនធានបណ្តុះបណ្តាលសម្រាប់ VEWs បានមកពី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្នុងនោះ ធនធានសម្រាប់ការបណ្តុះបណ្តាល CEWs បានមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ អង្គភាពបណ្តុះបណ្តាលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងធ្វើការបណ្តុះបណ្តាល ឬ ធ្វើការសម្របសម្រួលឱ្យមានការបណ្តុះបណ្តាលទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs)។ ដោយយោងទៅលើសមត្ថភាពរបស់បុគ្គលិកសិក្សា និងបរិក្ខារការបណ្តុះបណ្តាលនាពេលបច្ចុប្បន្ន មានតែ RUA និង PNCA ប៉ុណ្ណោះ ដែលជាអ្នកធ្វើការបណ្តុះបណ្តាលលើអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (AESs)។

NATSC ដោយមានអនុសាសន៍ពីអនុគណៈកម្មាធិការ នឹងអភិវឌ្ឍ ព្រមទាំងធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកឯកទេសបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្ម និងសមត្ថភាពអ្នកជំនាញសម្រាប់ការបណ្តុះបណ្តាលដែលពួកគាត់អាចផ្តល់ឱ្យ។ ក្នុងករណី ពុំមានអ្នកឯកទេសក្នុងស្រុក ឬពុំមានអ្នកឯកទេសក្នុងស្រុកគ្រប់គ្រាន់ដើម្បីបង្រៀនម៉ូឌុលទេនោះ រាជរដ្ឋាភិបាល/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបណ្តុះបណ្តាលបុគ្គលិកដែលបានជ្រើសរើស នៅតាមមហាវិទ្យាល័យ/សាកលវិទ្យាល័យក្នុងតំបន់ (ឧ. ប្រទេសថៃ វៀតណាម ហ្វីលីពីន) និងកៀងគរអ្នកឯកទេសដែលបានទទួលការបណ្តុះបណ្តាលទាំងអស់នោះ ជាធនធានមនុស្សក្នុងការបណ្តុះបណ្តាលនាពេលអនាគត។ ជាជម្រើសជំនួសមួយទៀត រាជរដ្ឋាភិបាលកម្ពុជា/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអញ្ជើញអ្នកឯកទេសពីអន្តរជាតិមកកម្ពុជា ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់អ្នកអប់រំរបស់ខ្លួននៅពេលណាដែលអាចធ្វើបាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/NATSC នឹងបង្កើតប្រព័ន្ធទទួលស្គាល់គុណភាព ដើម្បីទទួលបាន និងរក្សាបាននូវគុណភាពការអប់រំ និងការបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្ម។ ពេលចូលជាធរមានហើយ នីតិវិធីទទួលស្គាល់គុណភាព នឹងអាចជួយធានាឱ្យមានកម្មវិធីសិក្សាឯកភាពគ្នា និងភាពស៊ីសង្វាក់គ្នានៅក្នុងលទ្ធផលនៃការ

រៀនសូត្រដែលសិក្ខាកាមទទួលបាន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នទទួលខុសត្រូវរបស់ខ្លួន រួមមានដូចជា RUA, PNCA, និង KNSA ក៏នឹងព្យាយាមទទួលបានការទទួលស្គាល់គុណភាព ចំពោះកម្មវិធីផ្សព្វផ្សាយកសិកម្មរបស់ខ្លួនពី NATSC ផងដែរ។ ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម អាចចាប់ផ្តើមឡើងនៅពេលម៉ូឌុលសិក្សាត្រូវបានរៀបចំរួចជាស្ថាបពរ ហើយបុគ្គលិក/គ្រូបណ្តុះបណ្តាល ត្រូវបានជ្រើសរើស និងទទួលបានការបណ្តុះបណ្តាលរួចរាល់ហើយ។ NATSC អាចទទួលស្គាល់គុណភាពវិទ្យាស្ថានជាច្រើន ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ទោះយ៉ាងណាក្តី អាស្រ័យដោយកម្រិតឯកទេសដែលមាននាពេលបច្ចុប្បន្ន មានតែ RUA ប៉ុណ្ណោះ នឹងត្រូវបានប្រគល់សមត្ថកិច្ចឱ្យផ្តល់ការបណ្តុះបណ្តាល AES ក្នុងរយៈពេលបួន ទៅប្រាំឆ្នាំខាងមុខ។

## ប្រព័ន្ធការវាយតម្លៃ និងដាក់ពិន្ទុ

កម្មវិធីបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មសង្កត់ធ្ងន់លើផ្នែកទ្រឹស្តី និងផ្នែកការអនុវត្តស្មើគ្នា ហេតុនេះសិស្សត្រូវបានរំពឹងថា នឹងត្រូវប្រឡងជាប់ទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្តនៅក្នុងកម្មវិធីសិក្សានៃការបណ្តុះបណ្តាល។ ការវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្សសម្រាប់ម៉ូឌុលនីមួយៗ ត្រូវបានធ្វើឡើង ដើម្បីផ្តួងលទ្ធផលរំពឹងទុកពីការរៀនសូត្រចំពោះម៉ូឌុលនីមួយៗ។ វិធីសាស្ត្រវាយតម្លៃផ្សេងៗ ត្រូវបានបញ្ជាក់ក្នុងម៉ូឌុលទាំងអស់នោះ។ ដូចមានបង្ហាញជូនក្នុងតារាងទី ១៥ ហើយថា ប្រព័ន្ធពិន្ទុមធ្យមភាគ (GPA) សម្រាប់ការវាយតម្លៃ នឹងត្រូវបានយកមកប្រើប្រាស់ ដើម្បីវាយតម្លៃលើលទ្ធផលសិក្សាសិស្ស ដោយប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម (ការកែសម្រួលប្រព័ន្ធដាក់ពិន្ទុរបស់ RUA ក៏អាចជាជម្រើសមួយផងដែរ)៖

**តារាងទី ១៥. ប្រព័ន្ធដាក់ពិន្ទុសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម**

| លំដាប់ពិន្ទុ | និទ្ទេស | ពិន្ទុ | ការពិពណ៌នា |
|---|---|---|---|
| 80 – 100 | A | 4.00 | ជាប់ដោយពិន្ទុលេចធ្លោ |
| 70 – 79 | B | 3.00 | ជាប់ដោយគុណសម្បត្តិខ្ពស់ |
| 60 – 69 | C | 2.00 | ជាប់ទាំងស្រុង |
| 50 – 59 | D | 1.00 | ជាប់ |
| 40 – 49 | D | 1.00 | ជាប់ដោយពិបាក |
| 0 – 39 | F | 0.00 | ធ្លាក់ |

ដើម្បីអាចបញ្ចប់ការសិក្សា សិស្សត្រូវបានរំពឹងថា ត្រូវបានទទួលពិន្ទុមធ្យមភាគយ៉ាងតិច ២.00 និង និងពិន្ទុអប្បបរមាយ៉ាងតិច ១ ឬបានជាប់និទ្ទេស D និងលើសពីនេះ សម្រាប់គ្រប់ម៉ូឌុលទាំងអស់។

ក្នុងករណីមិនបានជាប់នៅក្នុងម៉ូឌុលទាំងអស់តាមការតម្រូវទេនោះ **លិខិតបញ្ជាក់ការបញ្ចប់ការសិក្សា** នៅក្នុងម៉ូឌុលដែលបានជាប់ អាចនឹងត្រូវបានចេញជូនជំនួសឱ្យសញ្ញាបត្រឌីប្ល៉ូម៉ា ឬវិញ្ញាបនបត្រផ្លូវការ។

## ផ្នែកការហាត់ការ និងអនុវត្តន៍ជាក់ស្តែង

ផ្នែកការហាត់ការនិងការអនុវត្តនៅមូលដ្ឋានជាក់ស្តែង នឹងក្លាយជាផ្នែកដ៏សំខាន់កាត់ផ្តាច់ចេញមិនបានពីរាល់កម្មវិធីបណ្តុះបណ្តាលទាំងអស់។ ដូច្នេះ សិស្សទាំងឡាយណា ដែលពុំអាចបញ្ចប់កម្មសិក្សា និង/ឬវគ្គអនុវត្តផ្ទាល់នៅមូលដ្ឋានបានទាំងស្រុងទេ នឹងពុំអាចមានគុណវុឌ្ឍិ ដើម្បីទទួលបានឌីប្លូម៉ា នោះទេ បើទោះបីជា GPA របស់ពួកគាត់បាន ២.០០ ឬលើសពីនេះក្តី។ ដើម្បីអាចមានគុណវុឌ្ឍិទទួលបានសញ្ញាបត្រ សិស្សចាំបាច់ត្រូវអនុវត្តសកម្មភាពនោះឡើងវិញ ហើយត្រូវទទួលបានពិន្ទុជាប់។

## ការវាយតម្លៃពីភាគីពាក់ព័ន្ធ

សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ពេលកំពុងបំពេញការហាត់ការ ក៏ត្រូវទទួលការវាយតម្លៃពីអ្នកមើលខុសត្រូវ ឬគ្រូកម្មសិក្សាដែលជាអ្នកចង្អុលបង្ហាញផ្លូវដល់សិក្ខាកាមក្នុងអំឡុងពេលហាត់ការផងដែរ។ ទម្រង់ការដាក់ពិន្ទុសមស្រប នឹងត្រូវបានផ្តល់ដោយវិទ្យាស្ថានបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃ។

## ម៉ូឌុលបណ្តុះបណ្តាល

ផ្នែកនេះ ផ្តល់ជូននូវបញ្ជីរាយឈ្មោះម៉ូឌុលការបណ្តុះបណ្តាលដែលចែកទៅជាបួនកម្រិត ដូចបង្ហាញជូនក្នុងតារាងទី ១៦។ ម៉ូឌុលទី១ គឺជាការបណ្តុះបណ្តាលកសិកម្មកម្រិតមូលដ្ឋាន ម៉ូឌុលទី២ គឺជាសេចក្តីផ្តើមអំពីការផ្សព្វផ្សាយកសិកម្ម ហើយម៉ូឌុលទី៣ ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសផ្អែកលើការគ្រប់គ្រងសម្រាប់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម។ ជាចុងក្រោយ នៅក្នុងម៉ូឌុលទី៤ គឺមានម៉ូឌុលបច្ចេកទេសជាច្រើន។

ម៉ូឌុលបណ្តុះបណ្តាលត្រូវបានរៀបចំទៅតាមលំដាប់លំដោយឋានានុក្រម ហើយដើរតួនាទីជាកម្មវិធីបណ្តុះបណ្តាលសព្វជ្រុងជ្រោយសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ឧទាហរណ៍ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ត្រូវរៀនវគ្គសិក្សាមូលដ្ឋានស្តីពីការអប់រំផ្នែកផ្សព្វផ្សាយកសិកម្ម ហើយក៏ត្រូវបញ្ចប់ម៉ូឌុលបច្ចេកទេសផ្អែកលើសេចក្តីត្រូវការកសិកម្មក្នុងមូលដ្ឋានផងដែរ។ គួរកត់សម្គាល់ថា មានតែកម្មវិធីបណ្តុះបណ្តាលថ្មីៗ សម្រាប់ VEWs CEWs និង AEAs ប៉ុណ្ណោះ ដែលត្រូវអនុវត្តតាមកម្មវិធីសិក្សានេះ ហើយម៉ូឌុលទី១ ម៉ូឌុលទី២ និងម៉ូឌុលទី៣ គឺជាការបន្ថែមទៅលើកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសដែលវិទ្យាស្ថានអប់រំនាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា ធ្លាប់បានផ្តល់ជូនជាវគ្គបណ្តុះបណ្តាលការសិក្សាស្រាវជ្រាវជាប្រចាំរបស់ខ្លួនរួចមកហើយ។ មហាវិទ្យាល័យ និងស្ថាប័នបណ្តុះបណ្តាល/មជ្ឈមណ្ឌលបណ្តុះបណ្តាលជាច្រើនដែលត្រូវបានទទួលស្គាល់គុណភាពដោយ NATSC អាចផ្តល់ការបណ្តុះបណ្តាលបីកម្រិតដំបូង (ពោលគឺ ការបណ្តុះបណ្តាលរបស់ VEWs, CEWs, និង AEAs)។ ការបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម ត្រូវធ្វើឡើងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រាប់រយៈពេលបី ទៅបួនឆ្នាំខាងមុខ រហូតដល់វិទ្យាស្ថានដទៃទៀត អាចអភិវឌ្ឍសមត្ថភាពបណ្តុះបណ្តាលរបស់ខ្លួន។

**តារាងទី ១៦. ម៉ូឌុលបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម**

| ក្រុមសិក្ខាកាម | ចំនួន និងឈ្មោះម៉ូឌុល |
|---|---|
| ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) (២-៤ សប្តាហ៍) | ម៉ូឌុល ១.១៖ ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា |
| | ម៉ូឌុល ១.២៖ វិធីសាស្ត្រ និងបច្ចេកទេសដែលមានការចូលរួម |
| | **ចំនួន ១ម៉ូឌុល** ក្នុងម៉ូឌុលខាងក្រោម(សូមជ្រើសរើសម៉ូឌុលដោយផ្អែកតាមសេចក្តីត្រូវការរបស់ភូមិ/ឃុំ)។ |
| | ម៉ូឌុល ១.៣៖ វិស័យផលិតកម្មដំណាំ |
| | ម៉ូឌុល ១.៤៖ ផលិតកម្មដំណាំសាកវប្បកម្ម |
| | ម៉ូឌុល ១.៥៖ វារីវប្បកម្ម |
| | ម៉ូឌុល ១.៦៖ ផលិតកម្មសត្វ |
| | ម៉ូឌុល ១.៧៖ ផលិតកម្មដំណាំកៅស៊ូ |
| | ម៉ូឌុល ១.៨៖ ព្រៃឈើ |
| | ម៉ូឌុល ១.៩៖ សុខភាពសត្វ |
| ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ(CEWs) (២-៤ខែ) | ម៉ូឌុល ១.១៖ ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា |
| | ម៉ូឌុល ១.២៖ វិធីសាស្ត្រ និងបច្ចេកទេសដោយមានការចូលរួម |
| | **ចំនួន ៤ ម៉ូឌុល ពីម៉ូឌុលខាងលើ (១.៣-១.៩)** |
| | **ផ្តល់ការហាត់ការ៖ ពីរសប្តាហ៍** |
| ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (AEAs) (៣-៦ខែ) | ម៉ូឌុល ១.១៖ ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា |
| | ម៉ូឌុល ១.២៖ វិធីសាស្ត្រ និងបច្ចេកទេសដែលមានការចូលរួម |
| | **ចំនួន ៨ ម៉ូឌុល ពីម៉ូឌុលខាងក្រោម** |
| | ម៉ូឌុល ២.១៖ សង្គមវិទ្យាជនបទ |
| | ម៉ូឌុល២.២៖ ការប្រាស្រ័យទាក់ទងផ្នែកកសិកម្ម |
| | ម៉ូឌុល ២.៣៖  ការកៀងគរផ្នែកសង្គម |
| | ម៉ូឌុល ២.៤៖ ការអភិវឌ្ឍសហគមន៍ |
| | ម៉ូឌុល ២.៥៖ សហគមន៍កសិករ និងអង្គការកសិករ |
| | ម៉ូឌុល ២.៦៖ ការងារជាក្រុម និង ការអភិវឌ្ឍជាក្រុម |
| | ម៉ូឌុល ២.៧៖ យេនឌ័រ និង ការអភិវឌ្ឍ |
| | ម៉ូម៉ូឌុល ២.៨៖ ធ្វើការជាមួយសហគមន៍ជនបទ |
| | ម៉ូឌុល ២.៩៖ ការធ្វើទីផ្សារកសិកម្ម និងសហករ |
| | ម៉ូឌុល ២.១០៖ ការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ និងថាមពលកកើតឡើងវិញ |
| | **ផ្តល់ការហាត់ការ៖ មួយខែ** |
| អ្នកឯកទេសផ្សព្វ | ម៉ូឌុល ១.១៖ ការផ្សព្វផ្សាយកសិកម្មក្នុងនៅកម្ពុជា |

| | |
|---|---|
| ផ្សព្វផ្សាយកសិកម្ម (AESs) (៦-៩ខែ) | ម៉ូឌុល ១.២៖ វិធីសាស្ត្រ និងបច្ចេកទេសដែលមានការចូលរួម |
| | **ចំនួន ១២ ម៉ូឌុល ពីម៉ូឌុលទី២ ខាងលើ និង ចំនួន៣ម៉ូឌុល ខាងក្រោម** |
| | ម៉ូឌុល ៣.១៖ ការអភិវឌ្ឍកម្មវិធីផ្សព្វផ្សាយកសិកម្ម |
| | ម៉ូឌុល ៣.២៖ ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី |
| | ម៉ូឌុល ៣.៣៖ ការគ្រប់គ្រងកសិធុរកិច្ច |
| | ម៉ូឌុល ៣.៤៖ ការធ្វើទីផ្សារ និងការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់ |
| | ម៉ូឌុល ៣.៥៖ ការគ្រប់គ្រងការិយាល័យ និងបុគ្គលិក |
| | ម៉ូឌុល ៣.៦៖ ការអភិវឌ្ឍភាពជាអ្នកដឹកនាំ |
| | ម៉ូឌុល ៣.៧៖ ការធ្វើការងារជាមួយភាគីពាក់ព័ន្ធ |
| | ម៉ូឌុល ៣.៨៖ ការអនុវត្តការស្រាវជ្រាវ និងការសរសេររបាយការណ៍ |
| | **ផ្តល់ការហាត់ការ៖ ពីរខែ** |

កម្មវិធីសិក្សាដែលត្រូវបានស្នើឡើង ព្រមជាមួយការពិពណ៌នាលម្អិតអំពីវគ្គសិក្សាសម្រាប់ការបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មទាំងបួនកម្រិត គឺមានផ្តល់ជូនក្នុងឧបសម្ព័ន្ធ ខ។ វគ្គសិក្សាដែលបានរាយឈ្មោះ គឺគ្រាន់តែជាការផ្តល់មតិជូនប៉ុណ្ណោះ។ វិទ្យាស្ថានបណ្តុះបណ្តាលកម្ពុជា អាចប្រើប្រាស់ការពិពណ៌នាវគ្គសិក្សាណាមួយ ដើម្បីសម្រិតសម្រាំង ឬកែសម្រួលម៉ូឌុល/វគ្គបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មដែលមានស្រាប់របស់ខ្លួន។ ម៉ូឌុលចំនួនពីរ ឬច្រើនអាចច្របាច់បញ្ចូលគ្នាទៅជាម៉ូឌុលតែមួយ ដើម្បីឱ្យសមស្របតាមស្ថានភាពក្នុងមូលដ្ឋាន ឬកាលវិភាគការបណ្តុះបណ្តាល។

## ផែនការការអភិវឌ្ឍសមត្ថភាពសម្រាប់នាយកដ្ឋាន/ភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការលូតលាស់ប្រកបដោយនិរន្តរភាពរបស់វិស័យកសិកម្ម គឺពឹងផ្អែកលើកត្តាផ្សេងៗជាច្រើន ដោយក្នុងនោះ ការអប់រំដើរតួនាទីដ៏សំខាន់ក្នុងការកែលម្អកត្តាផលិតភាពសរុប។ ការអប់រំផ្នែកកសិកម្មក្នុងប្រទេសកម្ពុជា ត្រូវបានទុកចោលគួរឱ្យអាណិតអាសូរ និងមិនបានទទួលការវិនិយោគគ្រប់គ្រាន់អស់ពេលជាយូរ។ ដើម្បីធានាការលូតលាស់របស់វិស័យកសិកម្ម និន្នាការនៅក្នុងការវិនិយោគដ៏តិចតួចក្នុងការអប់រំវិស័យកសិកម្ម ចាំបាច់ត្រូវតែផ្លាស់ប្តូរ។ អ្នកប្រកបវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្មនៅគ្រប់កម្រិតទាំងអស់ ត្រូវការការបណ្តុះបណ្តាលរំឭកឡើងវិញ ដោយផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងលើសេវាផ្សព្វផ្សាយកសិកម្មដែលជំរុញដោយតម្រូវការ មានលក្ខណៈបែបការចូលរួម និងមានលក្ខណៈពហុនិយម។ សាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យ និងអ្នកប្រកបវិជ្ជាជីវៈតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលនានា ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពលើវិស័យមុខវិជ្ជាបច្ចេកទេស។ អ្នកស្រាវជ្រាវកសិកម្ម អ្នកអប់រំផ្នែកកសិកម្ម អ្នកប្រកបវិជ្ជាជីវៈការបណ្តុះបណ្តាល និងអ្នកតំណាងវិស័យឯកជន ចាំបាច់ត្រូវប្រកាន់យកចក្ខុវិស័យរួមសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។ តារាងទី ១៧ ខាងក្រោមស្នើឡើងនូវផែនការអភិវឌ្ឍសមត្ថភាពសម្រាប់នាយកដ្ឋាន/ទីភ្នាក់ងារ ដែលកំពុងប្រតិបត្តិការនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**តារាងទី ១៧. ការបណ្តុះបណ្តាលពេលកំពុងបំពេញការងារសម្រាប់នាយកដ្ឋាន/ទីភ្នាក់ងារនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

| ប្រភេទការ<br>បណ្តុះបណ្តាល | ការផ្តោតការយកចិត្តទុកដាក់របស់<br>ការបណ្តុះបណ្តាល | នាយកដ្ឋាន/ទីភ្នាក់ងារទទួលផល<br>គោលដៅ |
|---|---|---|
| ការបណ្តុះបណ្តាលរយៈពេលខ្លី និងទស្សនកិច្ចក្រៅប្រទេស | • ការគ្រប់គ្រងការផ្សព្វផ្សាយកសិកម្ម៖ កំណត់រកសេចក្តីត្រូវការកំណត់អាទិភាព និងចាត់ចែងធនធាន<br>• របៀបគ្រប់គ្រងការតភ្ជាប់រវាងការស្រាវជ្រាវជាមួយការផ្សព្វផ្សាយកសិកម្ម និងកសិករ?<br>• របៀបគ្រប់គ្រងមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មដោយប្រើប្រាស់ព័ត៌មានវិទ្យា<br>• ការទទួលស្គាល់គុណភាពលើកម្មវិធីសិក្សា និងការបណ្តុះបណ្តាលរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• ការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាលក្នុងពេលកំពុងបំពេញការងារការផ្តល់រង្វាន់/ការទទួលស្គាល់។ | បុគ្គលិកមកពីនាយកដ្ឋាន និងទីភ្នាក់ងាររបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>អង្គភាពក្នុងវិស័យឯកជន |
| ការបណ្តុះបណ្តាលរយៈពេលខ្លីក្នុងប្រទេសកម្ពុជា | • ការធ្វើផែនការកម្មវិធីផ្សព្វផ្សាយកសិកម្ម<br>• ការអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈចូលរួម<br>• ការវាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិកម្ម<br>• ការប្រាស្រ័យទាក់ទងនៅក្នុងការផ្សព្វផ្សាយកសិកម្ម<br>• សមត្ថភាពស្នូលសម្រាប់ភ្នាក់ងាផ្សព្វផ្សាយកសិកម្ម។ | អ្នកឯកទេសផ្សព្វផ្សាយកសិកម្មនៅកម្រិតមន្ទីរកសិកម្មខេត្ត ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក និង បុគ្គលិក អង្គការមិនមែនរដ្ឋាភិបាល/វិស័យឯកជន។ |
| ការបណ្តុះបណ្តាលបច្ចេកទេស | វគ្គសិក្សាខ្លី/វគ្គបណ្តុះបណ្តាលបច្ចេកទេសនៅស្ថាប័នក្រៅប្រទេសក្នុងប្រធានបទដូចជា៖<br>• ច្រវាក់តម្លៃស្រូវ<br>• វិធានការចំរុះថែទាំដំណាំ<br>• ផលិតកម្មគ្រាប់ពូជ<br>• ជម្ងឺសត្វ<br>• ច្រវាក់តម្លៃបន្លែ<br>• ច្រវាក់តម្លៃវារីវប្បកម្ម | នាយកដ្ឋាន/ទីភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់៖ សិក្ខាកាមដែលបម្រើការងារជាគ្រូបណ្តុះបណ្តាលរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងកសិករនាំមុខ។ |

| | | |
|---|---|---|
| | • អង្គការកសិករ | |
| ការបណ្តុះបណ្តាលទទួលសញ្ញាបត្រ | ការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត/បណ្ឌិត ដើម្បីអភិវឌ្ឍក្រុមវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្មអាជីព | អ្នកប្រកបវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្មដែលមានគុណវុឌ្ឍិ |

## ការតភ្ជាប់ការស្រាវជ្រាវ ការអប់រំ និងការផ្សព្វផ្សាយពីកសិកម្ម សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មនៅកម្ពុជា (CARDI) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០០ ជាអង្គភាពពាក់កណ្តាលស្វយ័ត និង មានភារកិច្ចទទួលខុសត្រូវចម្បងក្នុងការស្រាវជ្រាវវិស័យកសិកម្ម។ អគ្គនាយកដ្ឋានកសិកម្ម (GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកគ្រប់គ្រងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ព្រមទាំងសម្របសម្រួលប្រតិបត្តិការ និងការគ្រប់គ្រងរបស់កសិដ្ឋានស្រាវជ្រាវកសិកម្ម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មថ្នាក់តំបន់ទាំងអស់។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) ប្រតិបត្តិការនៅក្រោម GDA នឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់បុគ្គលិកថ្នាក់ខេត្ត និងថ្នាក់ស្រុក។ នាយកដ្ឋានដទៃទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាផ្នែកស្រូវ ជលផល ព្រៃឈើ គ្រឿងយន្តកសិកម្ម និងកៅស៊ូ ធ្វើការស្រាវជ្រាវ និងផ្តល់សេវាផ្សព្វផ្សាយកសិកម្មជូនដល់កសិករ និងកសិធុរកិច្ច។ ការបណ្តុះបណ្តាលមុនពេលចូលបម្រើការងាររបស់អ្នកប្រកបវិជ្ជាជីវៈកសិកម្ម គឺជាការទទួលខុសត្រូវរបស់មហាវិទ្យាល័យកសិកម្ម និងសាកលវិទ្យាល័យកសិកម្ម ដូចជាសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) សាលាជាតិកសិកម្មព្រែកលៀប (PNCA) និង សាលាជាតិកសិកម្មកំពង់ចាម (KNSA)។ វិស័យឯកជន និងសហករ ក៏ចូលរួមក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍលើការលើកកម្ពស់ដំណាំកាហ្វេ ម្រេចស និងក្រវាញផងដែរ។ នាពេលបច្ចុប្បន្ននេះ ការចែករំលែកព័ត៌មាន ចំណេះដឹង និងជំនាញរវាងអ្នកផ្តល់សេវាផ្នែកស្រាវជ្រាវ ផ្សព្វផ្សាយកសិកម្ម អប់រំ និង វិស័យឯកជនទាំងនេះ នៅមានភាពទន់ខ្សោយ និងមានកម្រិតកំណត់ អាស្រ័យដោយមានការតភ្ជាប់ទំនាក់ទំនងអន់ខ្សោយ ក្នុងចំណោមអ្នកទាំងអស់នេះ។

រចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មបច្ចុប្បន្ន (ឬក្របខ័ណ្ឌការងារប្រតិបត្តិការ) នៅខ្វះការតភ្ជាប់ទំនាក់ទំនងឱ្យបានគ្រប់គ្រាន់ជាមួយប្រព័ន្ធស្រាវជ្រាវ (ពោលគឺ CARDI)។ ក្របខ័ណ្ឌការងារនាពេលបច្ចុប្បន្ន ពុំផ្តល់យន្តការវិមជ្ឈការដើម្បីធានាផ្តល់ភាពរឹងមាំចំពោះអតិថិជនផ្សព្វផ្សាយកសិកម្ម តាមរយៈការចែករំលែកព័ត៌មាន និងចំណេះដឹង និងការកៀងគរធនធាន និងការចាត់ចែងធនធាននោះឡើយ។ បន្ថែមលើនេះទៀត ក្របខ័ណ្ឌការងារនេះពុំលើកឡើងឱ្យបានគ្រប់គ្រាន់នូវយន្តការដើម្បីបញ្ជ្រាបបញ្ហាអន្តរវិស័យ ដូចជាការគ្រប់គ្រងធនធានធម្មជាតិ កសិកម្មធនជាមួយអាកាសធាតុ និងការដាក់បញ្ចូលយេនឌ័រនោះឡើយ។

តម្រូវការឱ្យមានសេវាផ្សព្វផ្សាយកសិកម្មកាន់តែច្រើនឡើង ស្របពេលដែលយន្តការផ្តល់សេវារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៅមានភាពមិនគ្រប់គ្រាន់ និងទន់ខ្សោយ បាននាំឱ្យកើតចេញជាអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មជាជម្រើសជំនួសដទៃទៀត ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ និង អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មវិស័យឯកជន។ ក្របខ័ណ្ឌការងារប្រតិបត្តិការផ្នែកស្ថាប័ននាពេលបច្ចុប្បន្ន ពុំផ្តល់ឱ្យមានយន្តការនិយ័តកម្ម ដើម្បីកំណត់ និងជំរុញការអនុវត្តបទដ្ឋានសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម លើកកម្ពស់លក្ខណៈវិជ្ជាជីវៈ បង្កើតគណនេយ្យភាព និងពិនិត្យតាមដានលទ្ធផលការងារឡើយ។

ស្ថាប័នអប់រំ និងបណ្តុះបណ្តាលកសិកម្មភាគច្រើន បានប្រែក្លាយជាចាស់ទ្រុឌទ្រោម អាស្រ័យដោយកង្វះខាតថវិកា។ កម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាល រួមទាំងកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលផ្នែកផ្សព្វផ្សាយកសិកម្ម គឺដើរមិនទាន់ការរីកចម្រើនផ្នែកបច្ចេកវិទ្យា ការផ្លាស់ប្តូរនៃបរិស្ថានការធ្វើកសិកម្ម និងតម្រូវការការផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈបត់បែនខ្ពស់។ គ្រូបង្រៀននៅសាកលវិទ្យាល័យ មហាវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាល បានទទួលការបណ្តុះបណ្តាលយ៉ាងអន់ខ្សោយនៅក្នុងប្រធានបទនេះ។ ជាលទ្ធផល ធ្វើឱ្យវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្មបានទទួលការបណ្តុះបណ្តាលយ៉ាងអន់ខ្សោយក្នុងផ្នែកសមត្ថភាពស្នូល និងវិស័យមុខវិជ្ជានេះ។

គោលវិធីផ្សព្វផ្សាយកសិកម្ម និងវិធីសាស្រ្តផ្សព្វផ្សាយកសិកម្មនាពេលបច្ចុប្បន្ន នៅពុំទាន់បានក្តោបយកបរិស្ថានសង្គមសេដ្ឋកិច្ចរបស់អតិថិជន សង្វាក់តម្លៃ តម្រូវការទីផ្សារ ពិពិធកម្មគ្រប់បរិស្ថាន ចំណេះដឹងរបស់អតិថិជន និងការបញ្ជ្រាបបញ្ហាអន្តរវិស័យដែលពាក់ព័ន្ធនានា ដូចជាភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការដាក់បញ្ចូលយេនឌ័រ និងការបណ្តុះបណ្តាលយុវជនឱ្យចាប់យកអាជីពវិជ្ជាជីវៈផ្នែកកសិកម្មឱ្យបានពេញលេញនៅឡើយ។

នៅពុំទាន់មានគំរូណាមួយ ដើម្បីកែលម្អកិច្ចសហការ និងការតភ្ជាប់បណ្តាញរវាងវិស័យស្រាវជ្រាវ ផ្សព្វផ្សាយកសិកម្ម ការអប់រំ និងវិស័យឯកជន ដើម្បីផ្តល់មូលដ្ឋានរួមមួយសម្រាប់ការផ្តល់សេវាអភិវឌ្ឍកសិកម្មរួមគ្នានៅឡើយ។ ជំនួសឱ្យការស្តាបនាការទុកចិត្តគ្នាទៅវិញទៅមក និងសម្រេចបានសេវាបំពេញបន្ថែម និងមានការសម្របសម្រួលគ្នាល្អ ភាគីពាក់ព័ន្ធនានា ដូចជា NGOs/CBOs និងអង្គភាពវិស័យឯកជន តែងប្រជែងដើម្បីដណ្តើមធនធានគ្នា។

ការតភ្ជាប់អន់ខ្សោយរវាងវិស័យស្រាវជ្រាវ ជាមួយការផ្សព្វផ្សាយកសិកម្ម និងការអប់រំ បានផ្តល់លទ្ធផលឱ្យមានលំហូរព័ត៌មានមិនមានប្រសិទ្ធភាព ក្នុងចំណោមអ្នកស្រាវជ្រាវ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងស្ថាប័នអប់រំ/បណ្តុះបណ្តាល។ CARDI គឺជាស្ថាប័នពាក់កណ្តាលស្វយ័ត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកម្នាក់ ដែលរាយការណ៍ជូនទៅក្រុមប្រឹក្សានាយក តែងតាំងដោយរដ្ឋាភិបាល។ ស្រដៀងគ្នានេះដែរ ការអប់រំវិស័យកសិកម្មត្រូវបានផ្តល់ដោយមហាវិទ្យាល័យ និងសាកលវិទ្យាល័យជាច្រើន ស្ថិតក្រោមការគ្រប់គ្រងរួមគ្នាដោយក្រសួងអប់រំ ជាមួយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលគ្រប់គ្រងលើកម្មវិធីផ្សព្វផ្សាយកសិកម្ម និងបុគ្គលិក។ ពុំមានយន្តការសម្រាប់ការប្រាស្រ័យទាក់ទងគ្នាជាប្រចាំ រវាងអ្នកស្រាវជ្រាវរបស់ CARDI បុគ្គលិកធ្វើការនៅមូលដ្ឋានរបស់ GDA និង RUA ឬបុគ្គលិកសិក្សាដទៃទៀតឡើយ។ ម្យ៉ាងទៀត មានអន្តរទំនាក់ទំនងគ្នាយ៉ាងតិចតួចរវាងការស្រាវជ្រាវ ការអប់រំ និងប្រតិបត្តិករផ្នែកវិស័យឯកជន។ លំហូរព័ត៌មានអន់ខ្សោយរវាងវិស័យស្រាវជ្រាវ ការផ្សព្វផ្សាយកសិកម្ម អង្គការអប់រំ និងវិស័យឯកជន ជារឿយៗត្រូវបានលើកឡើងថា ជាបុព្វហេតុឫសគល់មួយនៃការទទួលយកបច្ចេកវិទ្យាកសិកម្មជឿនលឿនក្នុងកម្រិតតិចតួចពីសំណាក់កសិករ។

ដូចបានបញ្ជាក់នៅក្នុងគោលនយោបាយផ្សព្វផ្សាយកសិកម្មថ្មីរួចហើយថា ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងមានគណៈកម្មាធិការជាតិទទួលបន្ទុកបច្ចេកទេសកសិកម្ម ហើយផែនការសកម្មភាពនេះស្នើឱ្យមានអនុគណៈកម្មាធិការ ពោលគឺអនុគណៈកម្មាធិការជាតិទទួលបន្ទុកបច្ចេកទេសកសិកម្ម (NATSC) ដើម្បីចង្អុលបង្ហាញផ្លូវការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម។ អនុគណៈ កម្មាធិការនេះនឹងជួយធានាឱ្យមានការភ្ជាប់ទំនាក់ទំនងយ៉ាងរលូនរវាងផ្នែកស្រាវជ្រាវកសិកម្ម ការផ្សព្វផ្សាយកសិកម្ម ការអប់រំ និងស្ថាប័នបណ្តុះបណ្តាល។ NATSC នឹងទទួលបន្ទុកដើម្បីធានា

ឱ្យមានលំហូរព័ត៌មានទៅវិញទៅមក រវាងកសិករ វិស័យឯកជន ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកស្រាវជ្រាវផ្នែកកសិកម្ម។

## ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម

ការផ្សព្វផ្សាយកសិកម្ម គឺជាដំណើរការអប់រំមួយ។ មុខងារចម្បងរបស់ដំណើរនេះ គឺដើម្បីសម្របសម្រួលការរៀនសូត្រ និងដើម្បីពង្រីកចំណេះដឹង និងបច្ចេកវិទ្យានៅក្នុងបរិយាកាសការអប់រំក្រៅប្រព័ន្ធ ដើម្បីកែលម្អផលិតភាពកសិកម្ម និងបង្កើនចំណូលរបស់កសិករ។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មទាំងអស់មានតួនាទីដូចគ្នា គឺ៖ អប់រំកសិករ និងអ្នកផលិត ដើម្បីឱ្យកសិករ/អ្នកផលិត អាចជួយខ្លួនឯង និងផ្សារភ្ជាប់កសិករ/អ្នកផលិត ជាមួយព័ត៌មានផ្អែកលើការស្រាវជ្រាវ ដើម្បីកែលម្អផលិតកម្មកសិកម្ម ផលិតភាព ការកែច្នៃ និងទីផ្សាររបស់ទំនិញកសិកម្ម និងសេវាកម្ម។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មទាំងអស់នេះ គឺជាតំណភ្ជាប់រវាងគោលនយោបាយផ្នែកកសិកម្ម ការស្រាវជ្រាវផ្នែកកសិកម្ម ការអប់រំ និងការបណ្តុះបណ្តាលផ្នែកកសិកម្ម អង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការកសិករ និងភាគីពាក់ព័ន្ធវិស័យឯកជន (រូបភាពទី ៨)។




**រូបភាពទី ៨. ភ្នាក់ងារផ្សព្វផ្សាយកសិកម្មដើរតួនាទីជាស្ពានភ្ជាប់រវាងសហគមន៍ជាមួយការស្រាវជ្រាវផ្នែកកសិកម្ម អង្គការបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្ម។**

(ប្រភពឯកសារ៖ Suvedi & Kaplowitz, 2016, p. 2)។

កម្មវិធីផ្សព្វផ្សាយកសិកម្មដែលមានជោគជ័យ គឺជាកម្មវិធីដែលផ្អែកលើសេចក្តីត្រូវការ ជំរុញដោយតម្រូវការ និងមាននិន្នាការបែបទីផ្សារ។ តួនាទីរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម គឺប្រៀបបីដូចជាអ្នកសម្របសម្រួលដំណើរការការរៀនសូត្រ។ ហេតុនេះ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មចាំបាច់ត្រូវការសម្ភារៈផ្សព្វផ្សាយកសិកម្មដែលមានលក្ខណៈបច្ចុប្បន្នភាព មានព័ត៌មានផ្អែកលើការស្រាវជ្រាវ ហើយអាចរកបានដោយងាយស្រួល និងងាយស្រួលយល់សម្រាប់កសិករ។ ទាំងអស់នេះសុទ្ធតែទាមទារឱ្យមានសម្ភារៈផ្សព្វផ្សាយកសិកម្មមានគុណភាពខ្ពស់។ រូបភាពទី ៩ បង្ហាញក្រាហ្វិកលំហូរការងារសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម។

ផែនការសកម្មភាពនេះធានាការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្មមានគុណភាពសម្រាប់ឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករ និង ដៃគូផ្សព្វផ្សាយកសិកម្មនៅថ្នាក់មូលដ្ឋានយកទៅប្រើប្រាស់។ លក្ខណៈវិនិច្ឆ័យដើម្បីធានាគុណភាពសម្ភារៈផ្សព្វផ្សាយកសិកម្ម មានដូចជា៖

- ព័ត៌មានដែលបង្ហាញជូន គឺផ្អែកលើការស្រាវជ្រាវផ្នែកកសិកម្មចុងក្រោយបំផុត
- ជំនួយស្មារតី គោលការណ៍ និងគំនិតទាំងឡាយ ត្រូវបានបង្ហាញនៅក្នុងលក្ខណៈច្បាស់លាស់ និងសង្ខេបខ្លី (ពោលគឺប្រើប្រាស់ពាក្យឱ្យបានតិចបំផុតតាមដែលអាចធ្វើបាន និងដាក់បញ្ចូលនូវរូបភាពបង្ហាញ និងជំនួយក្នុងការមើល ដូចជាដ្យាក្រាម រូបភាព និងរូបថត)
- បច្ចេកវិទ្យា/ការអនុវត្តថ្មីៗ ដែលត្រូវបានណែនាំឱ្យប្រើប្រាស់ គឺមានភាពស៊ីសង្វាក់ជាមួយវប្បធម៌ និងគុណតម្លៃក្នុងមូលដ្ឋាន
- ការបោះពុម្ពផ្សាយផ្នែកផ្សព្វផ្សាយកសិកម្ម ដូចជា របាយការណ៍សង្ខេបព្រឹត្តបត្រព័ត៌មាន ផ្ទាំងបដាព័ត៌មាន វីដេអូ គេហទំព័រ សារាចរ។ល។ ត្រូវបានពិនិត្យឡើងវិញ និងអនុម័តដោយ អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម មុនពេលការផ្សព្វផ្សាយឯកសារទាំងនោះ តាមរយៈមជ្ឈមណ្ឌលព័ត៌មានផ្សព្វផ្សាយកសិកម្ម គេហទំព័រផ្សព្វផ្សាយកសិកម្ម ឬប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងអភិវឌ្ឍកម្មវិធីអប់រំ និងព័ត៌មាន ដែលឆ្លើយតបចំពោះបញ្ហាអន្តរវិស័យនានា ដូចជាការដាក់បញ្ចូលយេនឌ័រទៅក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ភាពធន់ជាមួយការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍសហគ្រិនភាពរបស់យុវជន។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងអភិវឌ្ឍ "**ភូមិគំរូ**" នៅជិតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មខេត្តស្វាយរៀង និង មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូខាងលិចភ្នំពេញ ដោយក្នុងនោះអនុសាសន៍ផ្អែកលើការស្រាវជ្រាវចុងក្រោយបំផុត ត្រូវបានយកមកអនុវត្តបង្ហាញ និងចងក្រងជាឯកសារ។ ភូមិគំរូប្រហាក់ប្រហែលគ្នានេះ នឹងត្រូវបានបង្កើតឡើងនៅក្នុងតំបន់ជាប់ជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មថ្មី ដែលត្រូវបានស្នើឡើង។ អត្ថប្រយោជន៍នៃការមានភូមិគំរូ នឹងត្រូវបានចងក្រងក្នុងទម្រង់ជាវីដេអូ ដើម្បីយកទៅចែករំលែកជាមួយអ្នកទទួលព័ត៌មានថ្នាក់ជាតិ។ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងគ្រឹះស្ថានទាំងអស់នេះ ក៏នឹងត្រូវបានប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ទាក់ទងជាមួយការប្រើប្រាស់គេហទំព័រផ្សព្វផ្សាយកសិកម្ម បម្រើបម្រាស់ដទៃទៀតនៃ ICTs សម្រាប់ការទទួលយកបច្ចេកវិទ្យា និងការរៀនសូត្រពីគ្នាទៅវិញទៅមក រវាងកសិករ និងកសិករ។ បរិក្ខានៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មទាំងពីរនេះ នឹងត្រូវបានកែលម្អ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលចំនួនបីថ្មីទៀត ដោយមជ្ឈមណ្ឌលមួយ គឺនៅក្នុងតំបន់ឆ្នេរ មួយទៀតសម្រាប់តំបន់ទន្លេសាប និងមួយទៀតគឺសម្រាប់តំបន់ខ្ពង់រាប គឺត្រូវបានផ្តល់អនុសាសន៍ឱ្យបង្កើតឡើង។

ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម រួមទាំងព្រឹត្តិបត្រ ផ្ទាំងបដា ព្រឹត្តបត្រព័ត៌មាន វីដេអូ និងគេហទំព័រ ត្រូវគោរពតាមគោលការណែនាំដែលស្នើឡើងដោយ Khieu (២០១៧)។ ក្រុមការងារអ្នកឯកទេសផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង CARDI នឹងនាំមកក្នុងការកំណត់រកសម្ភារៈដែលអាចជួយដល់អគ្គនាយកដ្ឋានកសិកម្ម និងអ្នកវិទ្យាសាស្ត្រ CARDI។ បន្ទាប់ពីការពិនិត្យឡើងវិញបឋម ក្រុមការងារ DAE-CARDI នឹងស្នើឱ្យ NATSC ពិនិត្យឡើងវិញលើខ្លឹមសារ និងទម្រង់ ហើយផ្តល់អនុសាសន៍ឱ្យផលិតសម្ភារៈសម្រាប់ការផ្សព្វផ្សាយទូលំទូលាយថែមទៀត។

រូបភាពទី ៩.ក្រាហ្វិកលំហូរការងារសម្រាប់ការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម។ (កែសម្រួលចេញពី Knowledge Management and IT Advisors, n.d.)។




នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងគាំទ្រដល់ការបង្កើត មជ្ឈមណ្ឌលព័ត៌មានកសិកម្ម (AIH) នៅក្នុងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មជ្ឈមណ្ឌលព័ត៌មានកសិកម្ម នឹងក្លាយជាយន្តការមួយសម្រាប់សម្របសម្រួលការងាររវាងនាយកដ្ឋានបច្ចេកទេសផ្សេងៗ សាកលវិទ្យាល័យភូមិន្ទកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា អង្គភាពវិស័យឯកជនដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល។

មុខងាររបស់ AIH រួមមាន៖

- ប្រមូល និងរក្សាឯកសារបានមកពីនាយកដ្ឋាន និងទីភ្នាក់ងារពាក់ព័ន្ធរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំង CARDI, RUA, PNCA និង KNSA
- ចងក្រងព័ត៌មានស្តីពីសេចក្តីត្រូវការរបស់កសិករ តម្រូវការទីផ្សារ និងនិន្នាការតម្លៃ សម្រាប់ទំនិញកសិកម្មទៅតាមខេត្ត/ស្រុក
- រក្សាដេតាបេសស្តីពីអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រួមទាំងដៃគូអភិវឌ្ឍផងដែរ ចែកទៅតាមខេត្ត ស្រុក និងឃុំ

- ដើរតួនាទីជាកន្លែងបកស្រាយបញ្ជាក់ព័ត៌មានសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មក្នុងប្រទេសកម្ពុជា ពោលគឺជាអ្នកប្រមូល និងរក្សាទុកព័ត៌មាន និងសម្របសម្រួលក្នុងការរកមកវិញនូវឯកសារ ក្នុងទម្រង់លើក្រដាស និង/ឬក្នុងទម្រង់អេឡិចត្រូនិច។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) គឺជាទីតាំងសម្រាប់មជ្ឈមណ្ឌលព័ត៌មានកសិកម្ម ហើយ NATSC នឹងចង្អុលបង្ហាញអំពីប្រតិបត្តិការរបស់មជ្ឈមណ្ឌលនេះ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏ធ្វើជាទីតាំងសម្រាប់គេហទំព័រពីរភាសា ដែលអាចបើកមើលបានតាមអ៊ីនធើណេត ហៅថា គេហទំព័រផ្សព្វផ្សាយកសិកម្ម សម្រាប់ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន។ គេហទំព័រតាមបណ្ដាញអ៊ីនធើណេត គឺជាវេទិកាដែលអាចបើកមើលបានតាមប្រព័ន្ធអ៊ីនធើណេត ដោយក្នុងនោះ ព័ត៌មានគួរជាទីទុកចិត្ត និងទាន់ពេលវេលា ទទួលបានពីប្រភពព័ត៌មានផ្សេងៗក្នុងរូបរាង និងទម្រង់ជាច្រើន ដូចជាវីដេអូ ប្លក់ អត្ថបទចុះនៅក្នុងទិនានុប្បវត្តិ សៀវភៅ សៀវភៅណែនាំ របាយការណ៍សង្ខេប ព្រឹត្តបត្រព័ត៌មាន សារាចរ។ល។ ត្រូវបានរក្សាទុកជាឯកសារសំខាន់ រៀបជាកាតាឡុក និងចាត់ចែងក្នុងលក្ខណៈឯកភាពគ្នា ហើយដាក់ឱ្យមានជាស្រេចជូនសម្រាប់អ្នកប្រើប្រាស់ចុងក្រោយ (Reese et al., 2004)។ គេហទំព័រផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនឹងផ្ដល់ជាមធ្យោបាយច្នៃប្រឌិតបង្កើតថ្មី និងមានប្រសិទ្ធភាពក្នុងការចាប់យកទិដ្ឋភាពទាំងមូល គ្រប់គ្រង និងចែករំលែកព័ត៌មាន និងចំណេះដឹង ជាចម្បងតាមរយៈមធ្យោបាយអេឡិចត្រូនិច ដោយប្រើប្រាស់ព័ត៌មានវិទ្យា (ICT)។ គេហទំព័រនេះក៏ដើរតួនាទីជា "**កន្លែងប្រជុំ**" របស់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបង្កើត ពិភាក្សា និងមានលទ្ធភាពចូលទៅរកគំនិត និងចំណេះដឹងច្នៃប្រឌិតបង្កើតថ្មី ដែលចាំបាច់ដើម្បីស្ថាបនាភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពចម្រើនរុងរឿងផ្នែកសេដ្ឋកិច្ចរបស់កសិកម្មកម្ពុជា។

ក្រុមការងារអ្នកឯកទេសផ្សព្វផ្សាយកសិកម្មមួយក្រុមនៅ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងគ្រប់គ្រងលើគេហទំព័រផ្សព្វផ្សាយកសិកម្ម។ ក្រុមការងារនេះ រួមមានសមាសភាពអ្នកតំណាងមកពី GDA, DAE, CARDI, និង RUA។

## មុខងាររបស់គេហទំព័រផ្សព្វផ្សាយកសិកម្ម

- ដើរតួនាទីជាច្រកទ្វារសម្រាប់ព័ត៌មានបច្ចេកទេស ដែលគាំទ្រដល់សកម្មភាពការរៀនសូត្ររបស់កសិករ ក៏ដូចជាផ្សព្វផ្សាយព័ត៌មាន (បច្ចេកទេស ការគ្រប់គ្រង និងពាក់ព័ន្ធជាមួយគោលនយោបាយ) សម្រាប់ឱ្យអ្នកប្រើប្រាស់ចុងក្រោយផ្សេងៗជាច្រើនប្រើប្រាស់ រួមមានដូចជា អ្នកប្រកបវិជ្ជាជីវៈផ្នែកផ្សព្វផ្សាយកសិកម្ម ប្រតិបត្តិករវិស័យឯកជន និងកសិករ រួមទាំងក្រុមកសិកម្ម និងសហករកសិកម្ម
- ផ្ដល់ព័ត៌មានទាន់ពេលវេលាជូនដល់កសិករ និងកសិឧស្សាហកម្មនានា ដូចជាទាក់ទងជាមួយការព្យាករណ៍អាកាសធាតុ សាររំលឹកតាមរដូវ ការរំលឹក និងព័ត៌មានទីផ្សារ។ ព័ត៌មានយោងទៅតាមពេលវេលាទាំងអស់នេះ គឺជាសេចក្ដីត្រូវការរបស់កសិករ ដើម្បីឱ្យពួកគាត់អាចធ្វើការសម្រេចចិត្ត ហើយព័ត៌មានទាំងនេះតែងប្រែប្រួលយ៉ាងរហ័សពីពេលមួយទៅពេលមួយ
- ផ្ដល់ឱកាសរៀនសូត្រក្នុងរយៈពេលកំពុងការងារតាមប្រព័ន្ធអ៊ីនធើណេត សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្សព្វផ្សាយកសិកម្ម និងស្រាវជ្រាវ ក្នុងសហការជាមួយ RUA និងសាកលវិទ្យាល័យកសិកម្មដទៃទៀត។ សម្ភារៈបណ្ដុះបណ្ដាលតាមប្រព័ន្ធអ៊ីនធើណេត អាចបំពេញបន្ថែមដោយការបណ្ដុះបណ្ដាល/សិក្ខាសាលា ដែលត្រូវធ្វើឡើង

ជាទៀងទាត់ពេលវេលា ទល់មុខគ្នា។ ប្រធានបទនៃការសិក្សា អាចរួមមានដូចជា សមត្ថភាពស្នូលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំជាជំហានៗសម្រាប់ការអនុវត្តវិធីសាស្ត្រ និងការអនុវត្តបង្ហាញលទ្ធផល ដែលផ្តល់ជូនតាមរយៈធនធាននៅលើអ៊ីនធើណេត និងសិក្ខាសាលាតាមអ៊ីនធឺណិត។

គេហទំព័រផ្សព្វផ្សាយកសិកម្ម រួមមានឧបករណ៍ ICT ដែលជួយសម្រួលក្នុងការផ្សព្វផ្សាយ និងការគ្រប់គ្រងគុណភាពសម្ភារៈផ្សព្វផ្សាយកសិកម្ម សម្របសម្រួលដល់ការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ក្រោមជាតិ និងជួយពង្រឹងចំណងទាក់ទងរវាងភាគីពាក់ព័ន្ធនានានៅក្នុងរង្វង់ការផ្សព្វផ្សាយកសិកម្ម និងការស្រាវជ្រាវ (Knowledge Management and IT Advisors, n.d.)។

គេហទំព័រផ្សព្វផ្សាយកសិកម្ម នឹងត្រូវរក្សាឱ្យមានភាពសាមញ្ញ ងាយស្រួលបើករកមើល និងមានប្រសិទ្ធភាពចំណាយ។ អ្នកទទួលព័ត៌មានគោលដៅ រួមមានជាចម្បងដូចជា ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករនាំមុខ អ្នកផ្តល់សេវា។ គេហទំព័រផ្សព្វផ្សាយកសិកម្ម ក៏ជាកន្លែងសម្រាប់មជ្ឈមណ្ឌលទូរស័ព្ទហៅចូល ឬទូរស័ព្ទទាន់ហេតុការណ៍សម្រាប់កសិករផងដែរ។

ក្រុមការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដែលមានឯកទេសក្នុងការពិនិត្យតាមដាន និងការវាយតម្លៃ (M&E) និងបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង (ICT) នឹងបានទទួលភារកិច្ចក្នុងការកំណត់អត្តសញ្ញាណការជ្រើសរើស និងការអភិវឌ្ឍអនុសាសន៍ផ្សព្វផ្សាយកសិកម្មផ្អែកលើការស្រាវជ្រាវ និងការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម ដូចជា របាយការណ៍សង្ខេបព្រឹត្តបត្រព័ត៌មាន ប្រតិទិនកសិកម្ម និងធនធានផ្អែកលើព័ត៌មានវិទ្យាដទៃទៀតសម្រាប់ការផ្សព្វផ្សាយជូនដល់អ្នកប្រើប្រាស់ចុងក្រោយ (រួមមានកសិករ កសិធុរកិច្ច សហករណ៍ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ល។)តាមរយៈគេហទំព័រផ្សព្វផ្សាយកសិកម្ម។ NATSCនឹងផ្តល់ការចង្អុលបង្ហាញដល់ក្រុមការងារព័ត៌មានវិទ្យា។

ក្រុមការងារព័ត៌មានវិទ្យា ក៏នឹងអភិវឌ្ឍឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ ដែលនឹងត្រូវបានប្រើប្រាស់ជាចម្បង ដើម្បីពិនិត្យតាមដានលើសកម្មភាពផ្សព្វផ្សាយកសិកម្ម និងសមិទ្ធផល និងរាយការណ៍អំពីមុខងារ។ ក្រុមការងារព័ត៌មានវិទ្យា នឹងសម្របសម្រួលជាមួយ DAO និងមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការប្រមូលទិន្នន័យ និងការរៀបចំរបាយការណ៍។ ក្រុមការងារនេះក៏នឹងជួយសម្រួលដល់ DAO និង/ឬ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការវាយតម្លៃសេចក្តីត្រូវការសហគមន៍ ការវាយតម្លៃច្រវាក់តម្លៃ និង ការវាយតម្លៃលើកម្មវិធីផ្សព្វផ្សាយកសិកម្ម និងសកម្មភាពគម្រោង។

បន្ថែមលើការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម ដែលសមស្របសម្រាប់មជ្ឈមណ្ឌលផ្សព្វផ្សាយកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងអភិវឌ្ឍធនធានអប់រំដទៃទៀត ដូចជាប្រតិទិនកសិកម្មដែលមានព័ត៌មានតាមរដូវសម្រាប់កសិករផងដែរ។ ប្រតិទិននេះអាចរួមមានព័ត៌មានដើម្បីជំនួយដល់សេចក្តីសម្រេចចិត្ត ការគ្រប់គ្រងកសិដ្ឋានផ្អែកតាមរដូវ។ ប្រតិទិននេះក៏អាចមានព័ត៌មានជាសារបច្ចេកទេស ដូចជាអំពីរបៀបពិនិត្យតាមដានវាលស្រែរកមើលសត្វល្អិត និងជម្ងឺ វិធានការថែទាំដំណាំ ការគ្រប់គ្រងថ្នាលដំណាំ គោលការណ៍ណែនាំអំពីការដាំដុះ។ល។ បន្ថែមលើនេះទៀត គេហទំព័រលើប្រព័ន្ធអ៊ីនធើណេត អាចរួមមានគោលការណ៍

ណែនាំសម្រាប់ការបង្កើតភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន និងការផ្តល់កិច្ចសន្យាជួលសេវាទៅដល់អង្គការក្នុងមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និង វិស័យឯកជន។

ការប្រកាសសេវាសាធារណៈតាមទូរទស្សន៍ និងវិទ្យុ (PSAs) នឹងត្រូវបានបង្កើតឡើង និងប្រើប្រាស់តាមការសមស្រប។ PSAs ទាំងអស់នេះ នឹងត្រូវបានបង្កើតឡើងលើបញ្ហា/ប្រធានបទដែលនាយកដ្ឋានកណ្តាល និងទីភ្នាក់ងារកណ្តាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកជ្រើសរើស។

## ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ទទួលបន្ទុកផ្តល់ការគាំទ្រផ្នែកបច្ចេកទេស សម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងរបស់សេវាផ្សព្វផ្សាយកសិកម្ម ដែលជំរុញដោយតម្រូវការ មានលក្ខណៈបែបចូលរួម និងពហុនិយម។ បច្ចុប្បន្ននេះ ការប្រើប្រាស់ព័ត៌មានវិទ្យា និងការទទួលយកបម្រើបម្រាស់ព័ត៌មានវិទ្យា ក្នុងការផ្សព្វផ្សាយកសិកម្ម មានភាពយឺតយ៉ាវដោយសារតែសមត្ថភាពអន់ខ្សោយក្នុងការទទួលបាន និងយកព័ត៌មានវិទ្យាទៅប្រើប្រាស់ ដែលធ្វើឱ្យមានភាពកាន់តែធ្ងន់ធ្ងរឡើង ដោយសារហេដ្ឋារចនាសម្ព័ន្ធជនបទមានភាពអន់ខ្សោយ និងកម្រិតការចេះអាន សរសេរ របស់អតិថិជនមានកម្រិតទាប។

PAEC ទទួលស្គាល់ថា សមត្ថភាពរបស់អង្គការផ្សព្វផ្សាយកសិកម្មដើម្បីផ្តល់សេវាប្រកបដោយគុណភាព នៅមានភាពទន់ខ្សោយ ហើយតួនាទីផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋាន និង ទីភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមានភាពស្រពិចស្រពិល។ ដោយហេតុនេះ PAEC សូមផ្តល់អនុសាសន៍ឱ្យធ្វើវិមជ្ឈការប្រតិបត្តិការ និងការគ្រប់គ្រងសេវាផ្សព្វផ្សាយកសិកម្ម ទៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ នៅក្រោមគោលនយោបាយថ្មីនេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក ដើម្បីអភិវឌ្ឍផែនការបែបរួមបញ្ចូលមួយសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងទទួលខុសត្រូវធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើសេវាផ្សព្វផ្សាយកសិកម្មនៅក្នុងខេត្តផងដែរ។ ការិយាល័យកសិកម្មស្រុក នឹងធ្វើផែនការលើកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មក្នុងមូលដ្ឋាន តាមរយៈការធ្វើឱ្យមានការចូលរួមពីគណៈកម្មធិការភាគីពាក់ព័ន្ធ ដូចជាក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក និងគណៈ កម្មាធិការ កសិកម្មឃុំ (សូមមើលរូបភាពទី ១០)។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក នឹងរក្សាបញ្ជីបច្ចុប្បន្នភាពអ្នកផ្តល់សេវា ហើយនឹងអនុវត្តកម្មវិធី និង សកម្មភាពផ្សព្វផ្សាយកសិកម្ម តាមរយៈអ្នក ផ្តល់សេវាក្នុងមូលដ្ឋាន។

សេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្ម គឺផ្អែកទៅតាមសេចក្តីត្រូវការ ឬជំរុញដោយតម្រូវការ ពុំមែនជំរុញដោយភាគីផ្គត់ផ្គង់នោះឡើយ។ គណៈកម្មាធិការកសិកម្មឃុំ និងក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក ដើរតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃលើសេចក្តីត្រូវការថ្នាក់មូលដ្ឋាន កំណត់អាទិភាពសេចក្តីត្រូវការការផ្សព្វផ្សាយក្នុងមូលដ្ឋាន និងធ្វើឱ្យមានការចូលរួម និងការផ្តល់មូលនិធិ (ផ្តល់កិច្ចសន្យាជួលភាគីខាងក្រៅ) លើសេវានានា ទៅដល់អ្នកផ្តល់សេវាក្នុងមូលដ្ឋាន។

**រូបភាពទី ១០. រចនាសម្ព័ន្ធការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយកសិកម្ម**




លក្ខណៈវិនិច្ឆ័យដែលត្រូវបានផ្តល់អនុសាសន៍ដោយធនាគារពិភពលោក សម្រាប់ការវាយតម្លៃលើអ្នកផ្តល់សេវាដែលអគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានផ្ទៀងផ្ទាត់ក្នុងឆ្នាំ ២០១៧ (ពោលគឺ ទម្ងន់ ៤០% សម្រាប់ អត្តសញ្ញាណអង្គភាព ៣០% សម្រាប់សមត្ថភាព និងបទពិសោធន៍របស់អង្គការ ២០% សម្រាប់ប្រព័ន្ធគ្រប់គ្រង និង ១០% ដែលនៅសល់សម្រាប់កត្តាសម្រាប់ពិចារណាដទៃទៀត) នឹងត្រូវយកមកប្រើប្រាស់។

ប្រទេសកម្ពុជា នឹងអនុវត្តភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជនក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ ការិយាល័យកសិកម្មស្រុកដោយមានការចូលរួមយ៉ាងសកម្មពីក្រុមការងារ គាំទ្របច្ចេកទេសកសិកម្មស្រុក និងគណៈកម្មាធិការកសិកម្មឃុំ នឹងធ្វើផែនការលើកម្មវិធីផ្សេងៗជាច្រើន ដើម្បីបម្រើឱ្យកសិករក្នុងប្រភេទផ្សេងៗ និងដាក់ផែនការជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការអនុម័ត និងការផ្តល់ថវិការ។ សេវាផ្សព្វផ្សាយកសិកម្ម ដូចជាការបណ្តុះបណ្តាលកសិករនាំមុខ VEWs និង CEWs ធ្វើការអនុវត្តបង្ហាញនៅតាមកសិដ្ឋាន និងតាមផ្ទះ រៀបចំសាលារៀនស្រែកសិករ ចាត់ចែងផ្តល់ធាតុចូល (គ្រាប់ពូជ ថ្នាំសម្លាប់សត្វល្អិត និងជី) និងការតភ្ជាប់កសិករទៅកាន់ទីផ្សារ និងត្រូវផ្តល់កិច្ចសន្យាជួលទៅឱ្យអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ និងអង្គការកសិករដែលមានគុណវុឌ្ឍិគ្រប់គ្រាន់។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក នឹងសម្របសម្រួលដល់ការកសាងសមត្ថភាពអង្គការក្នុងមូលដ្ឋាន (ពោលគឺ អង្គការកសិករ អង្គការសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក ឬគណៈកម្មាធិការកសិកម្មឃុំ) និងធានាឱ្យមានការពិនិត្យតាមដាន និងវាយតម្លៃសមស្របលើកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្មក្នុងមូលដ្ឋាន។

សេវារបស់វិស័យឯកជន ឬឯកជនភាវូបនីយកម្មលើសេវាផ្សព្វផ្សាយកសិកម្ម ពុំមែនសុទ្ធតែមានន័យថា អតិថិជនត្រូវតែបង់ប្រាក់សម្រាប់សេវានោះឡើយ។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា និងអង្គការឯកជនដទៃទៀត ឬបុគ្គលនានាអាចផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយឥតគិតថ្លៃ។ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី

ជាច្រើនផ្តល់សេវាផ្សព្វផ្សាយកសិកម្មដោយឥតគិតថ្លៃតាមរយៈ NGOs និង/ឬអង្គការឯកជន។ បន្ថែមលើនេះទៀត សេវាផ្សព្វផ្សាយកសិកម្ម ដែលត្រូវបានជ្រើសរើស និងបន្តទទួលបានមូលនិធិតាមរយៈមូលនិធិសាធារណៈ ហើយនៅតែអាចផ្តល់សេវាដោយឥតគិតថ្លៃ។

ប្រទេសកម្ពុជា នឹងអភិវឌ្ឍឱ្យមានក្រុម CEWs និង VEWS ជាសហគ្រិនក្នុងមូលដ្ឋាន ប៉ុន្តែពុំមែនជាអ្នកបច្ចេកទេសសេវាស៊ីវិលនោះឡើយ។ CEWs និង VEWS អាចធ្វើការដោយឯករាជ្យក្នុងនាមជាសហគ្រិន ឬធ្វើការជូនដល់វិស័យឯកជន ឬ NGO ឬសម្រាប់គម្រោងដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍ។ គោលដៅ គឺដើម្បីស្ថាបនាសមត្ថភាពក្នុងមូលដ្ឋានរបស់វិស័យឯកជន និង NGO ដើម្បីលើកកម្ពស់ពហុភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្រិតមូលដ្ឋាន។ គំរូនេះ គឺជាគំរូដែលមានលក្ខណៈច្នៃប្រឌិតបង្កើតថ្មី មានប្រសិទ្ធភាពចំណាយ និងមាននិរន្តរភាព។

វិធីសាស្រ្តផ្សព្វផ្សាយកសិកម្ម នឹងសង្កត់ធ្ងន់លើការប្រើប្រាស់ការរៀនសូត្រពីកសិករទៅកសិករ តាមរយៈការអនុវត្តបង្ហាញនៅតាមផ្ទះ និងកសិដ្ឋាន សាលារៀនស្រែកសិករ និងកម្មវិធីបណ្តុះបណ្តាល។ អង្គភាពមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏នឹងអភិវឌ្ឍ និងប្រើប្រាស់ការច្នៃប្រឌិតបង្កើតថ្មី និង ICT ដែលមានភាពសមស្របនៅថ្នាក់មូលដ្ឋាន (ឧ. ទូរស័ព្ទវៃឆ្លាត គេហទំព័រ និងអ៊ីនធើណេត) និងប្រព័ន្ធផ្សព្វផ្សាយសម្រាប់ព័ត៌មាន និងការប្រាស្រ័យទាក់ទង។

ការតភ្ជាប់កសិករជាមួយទីផ្សារតាមមធ្យោបាយវិធីសាស្រ្តច្រវាក់តម្លៃ គឺជាអាទិភាពមួយនៃសេវាផ្សព្វផ្សាយកសិកម្ម។ ដើម្បីឱ្យកសិករឆ្លើយតបចំពោះសេចក្តីត្រូវការទីផ្សារ គេហទំព័រផ្សព្វផ្សាយកសិកម្មនឹងដាក់បង្ហោះព័ត៌មានអំពីមុខទំនិញម្ហូបអាហារក្នុងទីផ្សារធំៗក្នុងប្រទេសកម្ពុជា ជារៀងរាល់សប្តាហ៍/ថ្ងៃ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នឹងធ្វើពិពិធកម្មកម្លាំងភ្នាក់ងារផ្សព្វផ្សាយកសិកម្មរបស់ខ្លួន។ បច្ចុប្បន្ននេះ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភាគច្រើន គឺជាបុរស ហើយកម្មវិធីផ្សព្វផ្សាយកសិកម្ម និងសកម្មភាពរបស់ពួកគេច្រើនតែចូលទៅរកកសិករភាគច្រើនគឺជាបុរស។ ស្រ្តីចូលរួមយ៉ាងសកម្មក្នុងវិស័យកសិកម្ម ដូចជាក្នុងផលិតកម្មដំណាំ បន្លែ និងត្រី។ ស្រ្តីក៏ចូលរួមក្នុងសកម្មភាពចិញ្ចឹមបសុសត្វខ្នាតតូចផងដែរ។ ស្រ្តីទទួលខុសត្រូវជាចម្បងក្នុងការធ្វើម្ហូបអាហារ មើលថែទាំកូន និងការលក់ដូរផលិតផលកសិកម្ម។ ហេតុនេះ ស្រ្តីនឹងបានទទួលអត្ថប្រយោជន៍យ៉ាងធំធេញពីការចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្ម។ បន្ថែមលើនេះទៀត ជារឿយៗបុរស គឺជាអ្នកដែលត្រូវធ្វើចំណាកស្រុក ហេតុនេះ ការបណ្តុះបណ្តាលស្រ្តី អាចជួយបង្កើនលទ្ធភាពក្នុងការកែលម្អជំនាញដែលបន្តស្ថិតនៅក្នុងសហគមន៍ និងផ្តល់អត្ថប្រយោជន៍ឱ្យប្រជាជនកាន់តែច្រើន។ ហេតុនេះ ការផ្តល់ឱកាសឱ្យស្រ្តីអាចរកចំណូលបន្ថែមពីការងារកសិកម្មតាមរយៈការទទួលយកបច្ចេកវិទ្យាកែលម្អថ្មីៗ អាចជាអាទិភាពមួយសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ ការចូលរួមរបស់ស្រ្តីក្នុងការផ្សព្វផ្សាយកសិកម្ម ក៏នឹងអាចជួយឱ្យពួកគាត់មានសម្លេង ក្នុងការសម្រេចចិត្តរបស់សហគមន៍ផងដែរ។

នៅក្រោមផែនការសកម្មភាពយុទ្ធសាស្រ្តនេះ យើងនឹងទទួលស្គាល់ការចូលរួមចំណែករបស់ស្រ្តីទៅក្នុងកសិកម្ម និងជីវភាពរស់នៅ ហើយដែលនឹងគាំទ្រដល់ការជ្រើសរើសចូលបម្រើការងារ និងបណ្តុះបណ្តាល VEWs, CEWs, និង AEAs ជាស្រ្តី។ ក្រោមផែនការសកម្មភាពយុទ្ធសាស្រ្តនេះ កម្ពុជានឹងទទួលស្គាល់ការចូលរួមចំណែករបស់ស្រ្តីក្នុង

វិស័យកសិកម្មនិងជីវភាពរស់នៅ ហើយផែនការនេះនឹងគាំទ្រដល់ការជ្រើសរើសនិងបណ្តុះបណ្តាលស្ត្រីដូចជា VEWs, CEWs, AEAs និងAESs។ សេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្ម នឹងត្រូវប្រារព្ធឡើងនៅទីតាំង និងពេលវេលា ដែលផ្តល់ភាពងាយស្រួលចំពោះការចូលរួមរបស់ស្ត្រី។ ការផ្សព្វផ្សាយកសិកម្ម និងទទួលស្គាល់ស្ត្រីជាដៃគូស្មើភាពសម្រាប់ការអភិវឌ្ឍសហគមន៍ និងធ្វើឱ្យពួកគាត់មានការចូលរួមនៅក្នុងគ្រប់គណៈកម្មាធិការ ក្រុមប្រឹក្សា និងក្រុមការងារទាំងអស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តួចផ្តើមឱ្យមានប្រព័ន្ធវាយតម្លៃបុគ្គលិក ដើម្បីផ្តល់ការលើកទឹកចិត្ត ការទទួលស្គាល់ និងរង្វាន់ ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឆ្នើម។

## យុទ្ធសាស្ត្រដើម្បីពង្រឹងការផ្សព្វផ្សាយកសិកម្ម

PAEC លើកឡើងនូវយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំជាច្រើនសម្រាប់ការអនុវត្តគោលនយោបាយនេះ។ យុទ្ធសាស្ត្រខាងក្រោមមានសារៈសំខាន់ជាពិសេស ដើម្បីអនុវត្តផែនការសកម្មភាពនេះ៖

- លើកកម្ពស់សេវាដែលមានលក្ខណៈចូលរួម ផ្អែកលើសេចក្តីត្រូវការ ជំរុញដោយតម្រូវការ
- ដាក់ឱ្យមានជាស្ថាប័ននូវសេវាមានលក្ខណៈពហុនិយម តាមរយៈភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន
- ពង្រឹងចំណងតភ្ជាប់រវាងការស្រាវជ្រាវ ការអប់រំ ការផ្សព្វផ្សាយកសិកម្ម និងវិស័យឯកជន នៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យា កញ្ចប់ព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានសម្រាប់ឱ្យមានការទទួលយកទៅប្រើប្រាស់
- ធ្វើវិមជ្ឈការសេវាផ្សព្វផ្សាយកសិកម្មទៅថ្នាក់ក្រោមជាតិ (ខេត្ត និងស្រុក)
- ការលើកកម្ពស់ភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា
- ការអភិវឌ្ឍសមត្ថភាពបុគ្គលិកក្នុងការប្រាស្រ័យទាក់ទង និងប្រើប្រាស់ ICT ក្នុងការផ្សព្វផ្សាយកសិកម្ម និងបង្កើតមជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មសម្រាប់ការផ្សព្វផ្សាយបច្ចេកវិទ្យា
- បញ្ជ្រាបបញ្ហាអន្តរវិស័យនានា ដូចជាការដាក់បញ្ចូលយេនឌ័រ ការទទួលយកការអនុវត្តកសិកម្មធន់ទៅនឹងអាកាសធាតុ និងការអភិវឌ្ឍសហគ្រិនភាពរបស់យុវជន
- ពង្រឹងការអប់រំ និងបណ្តុះបណ្តាលកសិកម្ម (ការអប់រំមុនពេលចូលបម្រើការងារ និងការអប់រំក្នុងរយៈពេលកំពុងបម្រើការងារ ឬការបណ្តុះបណ្តាលដោយអនុវត្តផ្ទាល់ក្នុងពេលកំពុងបម្រើការងារ) តាមរយៈការកែលម្អកម្មវិធីសិក្សា និងការអភិវឌ្ឍធនធានមនុស្ស
- សម្រេចបាននូវនិរន្តរភាពនៃសេវាផ្សព្វផ្សាយកសិកម្ម តាមរយៈការផ្តល់ហិរញ្ញវត្ថុពីស្ថាប័នរដ្ឋ និងវិស័យឯកជន ការសហការគ្នាជាមួយដៃគូអភិវឌ្ឍ និងការលើកកម្ពស់ភាពជាម្ចាស់លើកម្មវិធីផ្សព្វផ្សាយកសិកម្មនៅថ្នាក់មូលដ្ឋាន

## ការផ្តល់ហិរញ្ញវត្ថុសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម

ការផ្សព្វផ្សាយកសិកម្ម គឺជាផ្នែកសំខាន់នៃការអភិវឌ្ឍកសិកម្ម។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់មូលនិធិដល់បុគ្គលិក និងសម្ភារៈសំខាន់ៗ ដូចជា ទីតាំង(ការិយាល័យ) សម្ភារៈផ្គត់ផ្គង់ និងសេវាធ្វើដំណើរសម្រាប់សេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(ថ្នាក់ខេត្ត និងថ្នាក់ស្រុក)។ នៅក្រោមផែនការវិមជ្ឈការរបស់រាជរ

ដ្ឋាភិបាលកម្ពុជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងអាចគ្រប់គ្រងកាន់តែច្រើនលើការធ្វើផែនការ និង ថវិកា។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងទទួលថវិកាកម្មវិធីដោយផ្ទាល់ពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ក្នុងរយៈពេលខ្លីកម្មវិធី ASPIRE នឹងវិនិយោគលើការកសាងសមត្ថភាពស្ថាប័នសម្រាប់ការផ្សព្វផ្សាយ កសិកម្ម។

សម្រាប់រយៈពេលវែង អង្គភាពរដ្ឋាភិបាលថ្នាក់មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ អង្គការ កសិករ អង្គភាពវិស័យឯកជន និងដៃគូអភិវឌ្ឍ នឹងផ្តល់មូលនិធិដល់ប្រតិបត្តិការសកម្មភាពផ្សព្វផ្សាយកសិកម្មនៅថ្នាក់ ឃុំ និងថ្នាក់ភូមិ។ នាយកដ្ឋានរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងសម្របសម្រួលការចរចាការផ្តល់មូលនិធិសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម តាមរយៈភាពជាដៃគូរវាង ស្ថាប័នរដ្ឋ និងវិស័យឯកជន។ ភាពជាដៃគូរវាងស្ថាប័នរដ្ឋជាមួយ INGO/NGO និងការចូលរួមបដិភាគ/អំណោយ របស់វិស័យឯកជន។

ដូចបានបញ្ជាក់ខាងដើមហើយថា តួនាទីរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការប្រែប្រួលពីតួនាទី ជាអ្នកអនុវត្តការផ្សព្វផ្សាយកសិកម្ម ទៅជាអ្នកសម្របសម្រួលភាពជាដៃគូ។ ដើម្បីអនុវត្តតួនាទីថ្មីនេះ មន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាពផ្សេងៗជាច្រើន រួមមានដូចជាវិស័យឯកជន NGOs និង គម្រោងផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចក្លាយជាសហវិនិយោគិននៅក្នុង អង្គភាពទាំងអស់នេះ ដើម្បីសម្រេចបានគោលបំណងការអភិវឌ្ឍកសិកម្មថ្នាក់ខេត្តរបស់ខ្លួន។

សមាជិកភាពរបស់រដ្ឋាភិបាលថ្នាក់ស្រុក និងថ្នាក់ឃុំ នឹងមានការចូលរួមយ៉ាងពេញលេញក្នុងការធ្វើផែនការ និងការអនុវត្តកម្មវិធីអភិវឌ្ឍកសិកម្មក្នុងមូលដ្ឋាន។ DATST និង CAC នឹងជួយក្នុងការស្វែងរកដៃគូសម្រាប់មកធ្វើជា សហវិនិយោគិន ក្នុងការងារផ្សព្វផ្សាយកសិកម្ម។ អង្គការមិនមែន រដ្ឋាភិបាល និងអង្គភាពក្នុងវិស័យឯកជន ក៏អាចធ្វើ សហវិនិយោគក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មថ្នាក់មូលដ្ឋាន ដោយប្រើប្រាស់ VEWs និង CEWs ថ្នាក់ មូលដ្ឋានផងដែរ។

## ការតាមដាន វាយតម្លៃ និងការរៀនសូត្រ

ការវាយតម្លៃគឺជាដំណើរការមួយនៃការប៉ាន់ប្រមាណជាប្រព័ន្ធទៅលើប្រតិបត្តិការ និង/ឬលទ្ធផលរំពឹងទុក និងផលប៉ះពាល់របស់កម្មវិធី ឬគម្រោងមួយតាមរយៈការប្រមូលភស្តុតាងដើម្បីកំណត់ថាតើគោលបំណងរបស់កម្មវិធី ឬគម្រោងនោះត្រូវបានឆ្លើយតប ឬយ៉ាងណា។ ការងារនេះទាមទារឲ្យមានគោលបំណងច្បាស់លាស់ និងអាចវាស់វែង បានត្រូវបានបង្កើតឡើងសម្រាប់កម្មវិធី ឬគម្រោងនីមួយៗ (ឬហៅថា ផែនការការងារ) នៅមុនពេលការអនុ វត្តកម្មវិធី ឬគម្រោងនោះ (Suvedi & Vander Stoep, 2014)។ តាមធម្មតាផែនការការងារមួយរួមមានខ្លឹមសារ សង្ខេបនៃភារកិច្ចប្រចាំឆ្នាំ ឬភារកិច្ចរយៈពេលច្រើនឆ្នាំ ព្រមជាមួយធនធានជាចេតនាដែលនឹងត្រូវប្រើប្រាស់ ព្រមទាំង ធាតុចេញ និងលទ្ធផលរំពឹងទុក។

ការតាមដានគឺទាក់ទងជាមួយការវាយតម្លៃ ប៉ុន្តែខុសគ្នាពីការវាយតម្លៃ។ ការតាមដានជួយធានាថា កម្មវិធីត្រូវ បានអនុវត្តអនុលោមតាមការតាក់តែងរបស់ខ្លួន។ ការតាមដានជួយឆ្លើយសំណួរដូចជា តើយើងកំពុងធ្វើរឿងដែលត្រឹម ត្រូវ ឬទេ និងតើយើងកំពុងធ្វើការងារទាំងនោះត្រឹមត្រូវឬទេ? អ្នកគ្រប់គ្រងការផ្សព្វផ្សាយកសិកម្មប្រើប្រាស់ការតាម

ដានដើម្បីពិនិត្យលើវឌ្ឍនភាព និងកែសម្រួលចំពោះបុគ្គលិក ការចាត់ធនធាន និង/ឬការទទួលស្គាល់បុគ្គលជាបន្តបន្ទាប់របស់ខ្លួន។ ការតាមដានរួមមានការប្រមូលព័ត៌មានជារយៈៗស្តីពីធាតុចូលរបស់គម្រោង និងសកម្មភាពដើម្បីធានាថា គម្រោងនោះត្រូវបានអនុវត្តតាមការគ្រោងទុក (Misra, 1997)។ ជាទូទៅអ្នកគ្រប់គ្រងការផ្សព្វផ្សាយកសិកម្មពិនិត្យតាមលើធនធាន (ឧ. មូលនិធិ បុគ្គលិក និងសម្ភារៈផ្គត់ផ្គង់) និងដំណើរការ (ឧ. កិច្ចប្រជុំដែលកើតមានជាក់ស្តែង ការអនុវត្តបង្ហាញ និងការបោះពុម្ពផ្សាយ) និងលទ្ធផលដើម្បីកំណត់ថាអ្វីខ្លះដែលដំណើរការបានល្អ និងអ្វីខ្លះដែលពុំមានវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផលជាដែលចង់បាន។ ជាការល្អការតាមដានត្រូវស្ថាបនាបញ្ចូលទៅក្នុងគម្រោងដើម្បីឲ្យសូចនាករនៃវឌ្ឍនភាពសំខាន់ៗនៅក្នុងកម្មវិធី ឬ គម្រោងទាំងមូលអាចត្រូវបានតាមដានកើត។ តារាងទី១៨ PAEC។ ទិន្នន័យទាំងអស់នេះអាចបម្រើតួនាទីជាមូលដ្ឋានដើម្បីវាយតម្លៃ លទ្ធផលរំពឹងទុករបស់អន្តរាគមន៍ (Khandker et al., 2010)។ ឧបសម្ព័ន្ធ គ-១ និង គ-២ បង្ហាញគំរូសូចនាករពិនិត្យតាមដាននិងអ្វីដែលត្រូវវាស់វែង។

**តារាងទី ១៨. ឧទាហរណ៍អំពីសូចនាករតាមដានសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម**

| | |
|---|---|
| កិច្ចប្រជុំ DATSC/CAC | ចំនួនកិច្ចប្រជុំ DATSC ឬCAC ដែលត្រូវបានធ្វើឡើង (ប្រចាំឆ្នាំ) ភាគរយសមាជិកដែលបានចូលរួមកិច្ចប្រជុំ។ |
| ការចូលរួមរបស់វិស័យឯកជន | ចំនួនដៃគូវិស័យឯកជនធ្វើការផ្នែកផ្សព្វផ្សាយកសិកម្ម និង%នៃថវិកាផ្សព្វផ្សាយកសិកម្មដែលផ្តល់មូលនិធិដោយវិស័យឯកជន ឬ NGOs។ |
| កម្រិតនៃការផ្តល់មូលនិធិផ្សព្វផ្សាយកសិកម្ម | កម្រិតនៃមូលនិធិសម្រាប់សកម្មភាពសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ |
| បន្ទុកការងាររបស់ VEWs/CEWs | ផ្ទៃដីមានការដាំដុះ (ហត) សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មម្នាក់ ចំនួនគ្រួសារកសិករនៅក្នុងភូមិគោលដៅ ឬឃុំគោលដៅ។ |
| ការចុះធ្វើការងាររបស់ VEWs/CEWs | ចំនួនការចុះទៅកាន់កសិដ្ឋាន/ផ្ទះធ្វើឡើងដោយ VEWs និងCEWs (ជារៀងរាល់ខែ។ |
| កិច្ចប្រជុំនៅមូលដ្ឋាន | ចំនួនកិច្ចប្រជុំក្រុមជាមួយកសិករធ្វើឡើងដោយ VEWs និងCEWs។ |
| សាលារៀនស្រែកសិករ | ចំនួនសាលារៀនស្រែកសិករដែលបានធ្វើឡើងដោយ VEWs/CEWsនិងសិក្ខាកាម FFS ចែកទៅតាមភេទ។ |
| ការអនុវត្តបង្ហាញ | ចំនួនការអនុវត្តបង្ហាញវិធីសាស្ត្រ និងការអនុវត្តបង្ហាញលទ្ធផលដែលធ្វើឡើង VEWs/CEWs (រៀងរាល់ត្រីមាស ឬ រៀងរាល់ឆ្នាំ)។ |
| ការមើលថែ និងតម្រង់ទិស | ចំនួនការចុះមើលថែនិងតម្រង់ទិសដែលធ្វើឡើងដោយ AEAs,DAO និងPDAFF។ |
| ការតភ្ជាប់រវាងការស្រាវជ្រាវនិងការផ្សព្វផ្សាយកសិកម្ម | ចំនួនកិច្ចប្រជុំតភ្ជាប់ការស្រាវជ្រាវជាមួយការផ្សព្វផ្សាយកសិកម្មដែលត្រូវបានរៀបចំឡើងក្នុងមួយខែ/ឆ្នាំ |
| ចំនួនកសិករដែលត្រូវបានចូលទៅដល់ | ចំនួនកសិករជាក់ស្តែងដែល VEWs និង CEWs បានចូលទៅដល់តាមរយៈការចុះទៅដល់តាមរយៈកសិដ្ឋានការបណ្តុះបណ្តាល FFS ប្រជុំអនុវត្តបង្ហាញ។ល។ ចែកទៅតាមភេទ |
| សន្ទស្សន៍ការជ្រៀតចូល | ចំនួនកសិករទទួលយកការអនុវត្តដែលត្រូវបានណែនាំធៀបនឹងចំនួនកសិករជាក់ស្តែងដែលបានចូលទៅដល់ (ភាគរយ) |

| | |
|---|---|
| ទិន្នផល | ទិន្នផលក្នុងមួយហិចតាសម្រាប់ដំណាំចម្បងដែលត្រូវបានគ្របដណ្តប់ដោយគម្រោងផ្សព្វផ្សាយកសិកម្ម |
| ការបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្ម | ចំនួនវគ្គបណ្តុះបណ្តាលក្នុងពេលបំពេញការងារដែលភ្នាក់ងារផ្សព្វផ្សាយកសិកម្មបានចូលរួម សន្និសីទ/សិក្ខាសាលាដែលបានចូលរួម (ប្រចាំឆ្នាំ) |

កម្មវិធី ASPIRE មានអង្គភាពតាមដាន និងវាយតម្លៃមួយ។ អង្គភាពនេះប្រមូលទិន្នន័យ ការតាមដានស្តីពីអថេរទូទៅជាច្រើន ព្រមទាំងចំនួនស្រ្តី និងបុរសជាអ្នកចូលរួម ប្រភេទសកម្មភាពផ្សព្វផ្សាយកសិកម្មដែលបានអនុវត្តសកម្មភាព និងល័ក្ខខ័ណ្ឌនៃដំណាំ និង បសុសត្វ ព័ត៌មានទីផ្សារ និងលទ្ធភាពចូលទៅកាន់ទីផ្សារ លក្ខណៈសម្បត្តិ និងទំហំនៃភាពដៃគូរវាងវិស័យ សាធារណៈ និងឯកជន ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងសេចក្តីត្រូវការការអប់រំជាបន្ត និងទើបកើតឡើងថ្មីៗរបស់អតិថិជនខ្លួន។ កម្មវិធី ឬសកម្មភាពផ្សព្វផ្សាយកសិកម្មធំៗនឹងត្រូវវាយតម្លៃដើម្បីពិនិត្យលើប្រសិទ្ធភាព និងកំណត់រកវិស័យដែលត្រូវការកែលម្អបន្ថែម។

ទិន្នន័យតាមដានត្រូវបានសង្ខេប និងបង្ហាញជូនជារបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឬប្រចាំឆ្នាំ។ របាយការណ៍ទាំងនេះត្រូវបានពិនិត្យឡើងវិញដោយទីភ្នាក់ងារផ្តល់មូលនិធិឬដៃគូអភិវឌ្ឍដើម្បីធ្វើការសម្រេចចិត្តក្នុងការផ្តល់មូលនិធិ។

ការវាយតម្លៃឆ្លើយតបចំពោះសំណួរ "**បើដូច្នេះតើយ៉ាងដូចម្តេច**" ពោលគឺតើមានអ្វីកើតឡើងជា លទ្ធផលនៃកម្មវិធី ឬគម្រោងនេះ? ការវាយតម្លៃផលប៉ះពាល់ផ្តល់ភស្តុតាងគួរជាទីជឿជាក់អំពីថាតើកម្មវិធីផ្សព្វផ្សាយកសិកម្មនោះគឺជាការវិនិយោគដ៏ល្អ ឬ យ៉ាងណា។ ការវាយតម្លៃប្រភេទនេះតាមធម្មតា ច្រើនប្រើការវិភាគបែបបរិមាណដោយប្រើប្រាស់ការពិនិត្យធៀបជាមួយស្ថានភាពជាក់ស្តែង ដើម្បីប៉ាន់ប្រមាណទំហំការផ្លាស់ប្តូរដែលកើតមានក្នុងផលប៉ះពាល់ដែលអាចអះអាងថា កើតចេញពីគម្រោង ឬអន្តរាគមន៍។ ដោយហេតុថា PAEC នឹងត្រូវអនុវត្តក្នុងគ្រប់ខេត្តទាំងអស់ ហេតុនេះពុំអាចធ្វើការពិនិត្យធៀបជាមួយស្ថានភាពជាក់ស្តែង ឬក្រុមស្ថិតក្រោមការគ្រប់គ្រង/ក្រុមប្រៀបធៀបសម្រាប់ការវាយតម្លៃផលប៉ះពាល់ទេ។ ទោះយ៉ាងណាក្តីប្រសិទ្ធភាព និងផលប៉ះពាល់នៃសេវាផ្សព្វផ្សាយកសិកម្មអាចកំណត់បានតាមរយៈការប្រៀបធៀបធាតុចេញរបស់កសិដ្ឋាន (ឧ. ទិន្នផល/ហាត ឬចំណូល/ហាត ឬក្នុងសត្វមួយក្បាល) រវាងសំណាកដែលមានលក្ខណៈតំណាងឲ្យអ្នកចូលរួមក្នុងការផ្សព្វផ្សាយកសិកម្ម និងអ្នកមិនបានចូលរួម។ សូមកត់សម្គាល់ថា ទិន្នន័យដើមឃ្លាមានភាពចាំបាច់ណាស់សម្រាប់ការវាយតម្លៃផលប៉ះពាល់។

សេវាផ្សព្វផ្សាយកសិកម្មអាចវាយតម្លៃបានដោយប្រើប្រាស់រង្វាស់លទ្ធផលការងារផ្សេងៗជាច្រើន។ គម្រោងទ្រង់ទ្រាយធំដូចជា កម្មវិធី ASPIRE ប្រចាំប្រទេសកម្ពុជាអាចមានផលប៉ះពាល់លើការអភិវឌ្ឍផ្នែកស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការតភ្ជាប់រវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្មសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា ចំនួន និងប្រភេទនៃការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម និងការផ្សព្វផ្សាយបច្ចេកវិទ្យាតាមរយៈការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ បញ្ជីសូចនាករសព្វជ្រុងជ្រោយគឺនៅហួសពីវិសាលភាពនៃសេចក្តីណែនាំសម្រាប់ការអនុវត្តនេះ ប៉ុន្តែនៅក្នុងតារាងទី១៩មានស្នើឡើងនូវបញ្ជីសូចនាករមួយសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មប្រកបដោយជោគជ័យ និងប្រសិទ្ធភាពនៃការអនុវត្តនោះ។ សូចនាករគំរូត្រូវបានស្នើឡើងដើម្បីការអនុវត្តសមាសភាពនីមួយៗនៃផែនការសកម្មភាពយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្ម។ ទិន្នន័យដើមគ្រាគឺជាធាតុដែលត្រូវបានណែនាំឲ្យមានសម្រាប់គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់ ហើយឧបសម្ព័ន្ធ ឃ បង្ហាញជូននូវការស្ទាបស្ទង់មតិដើមគ្រាគំរូ

មួយដែលកម្មវិធី ASPIRE អាចកែសម្រួលយកទៅប្រើបាន។ យើងខ្ញុំសូមផ្តល់អនុសាសន៍យ៉ាងខ្លាំងឲ្យកម្មវិធី ASPIRE បង្កើតការសិក្សាដើមគ្រាសម្រាប់ការវាយតម្លៃផលប៉ះពាល់។ ស្រដៀងគ្នានេះដែរ ឧបសម្ព័ន្ធ ង-១ ដល់ ង-៧ បង្ហាញអំពីឧបករណ៍ស្ទាបស្ទង់មតិគំរូសម្រាប់វាយតម្លៃលើកម្មវិធី និង សកម្មភាពផ្សព្វផ្សាយកសិកម្មជាក់លាក់។ ព័ត៌មានអំពីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មគឺអាចប្រមូលបានតាមរយៈការកែសម្រួលកម្រងសំណួរដែលមានផ្តល់ជូនក្នុងឧបសម្ព័ន្ធ ច-១ និង ច-២ ។

**តារាងទី ១៩. បញ្ជីសូចនាករវាយតម្លៃផលប៉ះពាល់ដែលត្រូវបានស្នើឡើង**

| **សូចនាករអភិវឌ្ឍស្ថាប័ន** | **ការវាស់វែង** |
|---|---|
| កិច្ចប្រជុំជាប្រចាំរបស់គណៈកម្មាធិការភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ និង ការចូលរួមរបស់សមាជិកគណៈកម្មាធិការនៅក្នុងការសម្រេចចិត្ត។ | ភាពទៀងទាត់និងការចូលរួមរបស់សមាជិកគណៈកម្មាធិការAEAC, NATSC(និងអនុគណៈកម្មាធិការ), PAEWG, DATST, CAC |
| ភាពតំណាងផ្នែកយេនឌ័រនៅក្នុងគណៈកម្មាធិការភាគីពាក់ព័ន្ធ | % សមាជិកជាស្ត្រី |
| ចំនួនអង្គការដៃគូដែលផ្តល់សេវាផ្សព្វផ្សាយកសិកម្ម (ចែកទៅតាមប្រភេទអ្នកផ្តល់សេវា ឧ.សហគ្រាសឯកជន NGO អង្គការអ្នកផលិត ទីភ្នាក់ងារសាធារណៈ) ចែកទៅតាមខេត្ត | ចំនួនដៃគូចែកទៅតាមខេត្ត |
| ថវិកាប្រតិបត្តិការផ្សព្វផ្សាយកសិកម្មចែកទៅតាមប្រភពមូលនិធិ (ឧ. MAFF/GDA ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍជនបទ រដ្ឋាភិបាលថ្នាក់ខេត្ត/ស្រុក/ឃុំ NGOs និងវិស័យឯកជន) | ការផ្តល់មូលនិធិសរុបចែកទៅតាមខេត្ត និងតាមស្រុក |
| ទឹកប្រាក់សហហិរញ្ញប្បទានរបស់កម្មវិធីផ្សព្វផ្សាយកសិកម្មនិងសកម្មភាពផ្សព្វផ្សាយកសិកម្មចែកទៅតាមប្រភេទអង្គការ(ឧ.សហគមន៍ សហគ្រាសឯកជន អង្គការអ្នកផលិត។ល។) | % នៃថវិកាផ្សព្វផ្សាយកសិកម្មសរុប |
| ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម៖CEWs, VEWS, AEAs និង AESs | ចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្មបែងចែកទៅតាមភេទ |
| តុល្យភាពយេនឌ័រនៃភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ | %ភ្នាក់ងារផ្សព្វផ្សាយកសិកម្មជាស្ត្រី (VEWs, CEWs, AEAs, AESs) |
| **សូចនាករអភិវឌ្ឍធនធានមនុស្ស** | **ការវាស់វែង** |
| វិទ្យាស្ថានបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មត្រូវបានពង្រឹង | ចំនួននិងប្រភេទ(សាធារណៈនិងឯកជន) |
| ចំនួនអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មវិស័យឯកជន(VEWs និង CEWs) បានទទួលការបណ្តុះបណ្តាល | ចំនួនអ្នកបានទទួលការបណ្តុះបណ្តាលចែកទៅតាមខេត្ត និងស្រុក |

| | |
|---|---|
| ការបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើសេវារបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ឧ.វគ្គបណ្តុះបណ្តាលតម្រង់ទិសពេលចាប់ផ្តើមធ្វើការ និងការបណ្តុះបណ្តាលក្នុងរយៈពេលកំពុងបម្រើសេវា ឬបណ្តុះបណ្តាលរំលឹកឡើងវិញ) | ចំនួនបុគ្គលិកធ្វើការបណ្តុះបណ្តាល ចំនួនថ្ងៃបណ្តុះបណ្តាលក្នុងមួយឆ្នាំចែកទៅតាមខេត្ត/ស្រុក |
| ចំនួនវគ្គបណ្តុះបណ្តាលគ្រូបង្គោល (ToT) ដែលបានបញ្ចប់ | ToT ចែកទៅតាមស្ថាប័ន/ភេទ |
| ចំនួនកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មបង្កើត/កែសម្រួលឡើងវិញ | ចំនួនវគ្គសិក្សា |
| ចំនួនកម្មវិធីសិក្សាបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលបានបង្កើតឡើង/កែសម្រួលឡើងវិញ | ចំនួនអ្នកបានទទួលការបណ្តុះបណ្តាលចែកទៅតាមភេទ |
| ចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលបានទទួលការបណ្តុះបណ្តាល (VEWs, CEWs, AEAs, និង AESs) | ចំនួនអ្នកបានទទួលការបណ្តុះបណ្តាលចែកទៅតាមភេទ |
| ចំនួនវគ្គបណ្តុះបណ្តាលថ្នាក់វិញ្ញាបនបត្រ(ថ្នាក់អនុបណ្ឌិតនិងថ្នាក់បណ្ឌិត) ដែលបានបញ្ចប់ដោយភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ឬបុគ្គលិកសិក្សារបស់សាកលវិទ្យាល័យ | ចំនួនចែកទៅតាមភេទ |
| ឯកសារណែនាំការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម សៀវភៅណែនាំមន្ទីរពិសោធន៍ ឬសៀវភៅណែនាំនៅទីវាល | ចំនួនសម្ភារៈបណ្តុះបណ្តាលដែលបានអភិវឌ្ឍៈឯកសារបោះពុម្ពជាក្រដាស និងព័ត៌មានវិទ្យា |
| **សូចនាករ ការតភ្ជាប់ការស្រាវជ្រាវជាមួយការផ្សព្វផ្សាយ និងវិស័យឯកជន** | **ការវាស់វែង** |
| ចំនួនគម្រោងការស្រាវជ្រាវ និងគម្រោងបែបអនុវត្តដែលផ្តល់ហិរញ្ញប្បទានដោយ GDA/DAE-CARDI | ចំនួនចែកទៅតាមខេត្ត |
| ចំនួនកិច្ចប្រជុំនិងសិក្ខាសាលាការតភ្ជាប់រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអប់រំ និងវិស័យឯកជនជាអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម | ចំនួនសិក្ខាសាលារួមគ្នានិងវគ្គមានចូលរួមចែកទៅតាមភេទ |
| ការគាំទ្រការបណ្តុះបណ្តាលសម្រាប់ CARDI និងអ្នកស្រាវជ្រាវវិស័យឯកជននៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យាបែបការចូលរួមនិងការផ្សព្វផ្សាយបច្ចេកវិទ្យា | ចំនួនសិក្ខាសាលា |
| ការផ្តល់ការគាំទ្រសមត្ថភាព ICTនៅស្ថាប័នស្រាវជ្រាវផ្សព្វផ្សាយកសិកម្ម អប់រំ (ឧ.តំណភ្ជាប់ជាមួយអ៊ីធើណេត លទ្ធភាពទទួលបានទិន្នន័យប្បវត្តិអេឡិចត្រូនិច។ល។) | ចំនួនអ្នកស្រាវជ្រាវដែលមានលទ្ធភាពអាចប្រើប្រាស់អ៊ីធើណេតភ្ជាប់ទៅកាន់ AIH និងគេហទំព័រផ្សព្វផ្សាយកសិកម្ម ទិន្នន័យប្បវត្តិអេឡិចត្រូនិច និង គេហទំព័រ |
| មន្ទីរពិសោធន៍របស់ CARDI និង RUA/PNCA/KNSA ត្រូវបានបំពាក់ | ចំនួនគុណភាព និងភាពញឹកញាប់នៃការ |

| | |
|---|---|
| បរិក្ខារ | ប្រើប្រាស់ |
| ពូជដំណាំថ្មីៗ ឬបច្ចេកវិទ្យាថ្មីៗ ត្រូវបានអភិវឌ្ឍ | ចំនួន និងប្រភេទ |
| បច្ចេកវិទ្យាថ្មីៗ និងអនុសាសន៍ដែលត្រូវបានអភិវឌ្ឍ | ចំនួន និងប្រភេទ |
| ចំនួនបុគ្គលិក GDA/DAE និង CARDI ដែលបានចូលរួមក្នុងសន្និសីទជាតិ/ក្រោមជាតិ បទបង្ហាញរួមគ្នារបស់ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយកសិកម្ម-ការអប់រំ | ចំនួន និងប្រភេទ |
| **សូចនាករការអភិវឌ្ឍសម្ភារៈផ្សព្វផ្សាយកសិកម្ម** | **ការវាស់វែង** |
| ចំនួនការបោះពុម្ពផ្សាយរួមគ្នារវាងផ្នែកស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម គេហទំព័រ និង ICTs ត្រូវបានរៀបចំឡើង | ចំនួន |
| ផលិតផលស្រាវជ្រាវដែលបានបញ្ចប់ ឧបករណ៍ស្រាវជ្រាវ/វិធីសាស្ត្រស្រាវជ្រាវដែលបានរៀបចំឡើង | ចំនួន |
| ការរៀបចំ និងការផ្សព្វផ្សាយសម្ភារៈផ្សព្វផ្សាយកសិកម្ម (ដូចជា ព្រឹត្តិបត្រ ខិតប័ណ្ណ ឬប្រព័ន្ធផ្សព្វផ្សាយ) | ចំនួនសម្ភារៈផ្សព្វផ្សាយកសិកម្មដែលបានអភិវឌ្ឍ៖ឯកសារការបោះពុម្ពលើក្រដាស និងព័ត៌មានវិទ្យា |
| សំណេរឬរបាយការណ៍ផ្អែកលើការស្រាវជ្រាវបែបអនុវត្តឬការការអនុវត្តបង្ហាញ និងបោះពុម្ពផ្សាយ | ចំនួន |
| ការរៀបចំសម្ភារៈបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្ម | ចំនួនសម្ភារៈបណ្តុះបណ្តាលដែលត្រូវបានរៀបចំ និងផ្សព្វផ្សាយ |
| មជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្ម | ចំនួនអ្នកប្រើប្រាស់ក្នុងមួយខែ/ឆ្នាំ |
| **សូចនាករសេវាផ្សព្វផ្សាយកសិកម្ម** | **ការវាស់វែង** |
| វគ្គបណ្តុះបណ្តាលសម្រាប់កសិករនាំមុខ សាលារៀនស្រែកសិករ និងអង្គការកសិករត្រូវបានធ្វើឡើង | ចំនួនអ្នកចូលរួមចែកទៅតាមភេទ |
| កសិករដែលបានទទួលការបណ្តុះបណ្តាលបានការទំនាក់ទំនងនិងចុះទៅដល់ទីតាំង (ចែកទៅតាមភេទ ស្រុក តំបន់) | ចំនួនចែកទៅតាមភេទ |
| ផ្ទៃដីអនុវត្តបង្ហាញត្រូវបានកំណត់ (នៅតាមស្ថានីយ៍ និងទៅតាមកសិដ្ឋាន) | ចំនួនចែកទៅតាមឃុំ ស្រុក ខេត្ត |
| កិច្ចប្រជុំក្រុមកសិករ ការតាំងបង្ហាញ និងពិពណ៌កសិករដែលត្រូវបានធ្វើឡើង | ចំនួនការចូលរួមទៅតាមឃុំ ស្រុក ខេត្ត |
| ព័ត៌មាន និងសម្ភារៈអប់រំត្រូវបានផលិតឡើង និងផ្សព្វផ្សាយ | ចំនួនខិតប័ណ្ណ សៀវភៅព័ត៌មាន ព្រឹត្តបត្រ |

| | |
|---|---|
| ការពេញចិត្តរបស់កសិករជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម | ការដាក់ពិន្ទុ |
| ឆន្ទៈរបស់កសិករក្នុងការចែករំលែកការចំណាយការផ្សព្វផ្សាយកសិកម្ម | % អ្នកមានឆន្ទៈចែករំលែកការចំណាយ |
| កសិករស្នើសុំសេវា (ថវិកា) ផ្សព្វផ្សាយកសិកម្ម | ចំនួនចែកទៅតាមភេទ |
| ការយល់ដឹងរបស់កសិករអំពីសកម្មភាពផ្សព្វផ្សាយកសិកម្ម (ចែកទៅតាមភេទ និងក្រុមយុវជន) | %ចំនួនប្រជាជនគោលដៅចែកទៅតាមភេទ |
| **សូចនាករអភិវឌ្ឍកសិកម្មទូទៅ** | **ការវាស់វែង** |
| ការទទួលយកការអនុវត្តកសិកម្មបែបទំនើបពីសំណាក់កសិករ | ភាគរយកសិករទទួលយកការអនុវត្តថ្មីៗ ចែកទៅតាមភេទ ចែកទៅតាមខេត្ត |
| ការចំណាយលើការផ្សព្វផ្សាយកសិកម្មក្នុងមួយឯកតាផលិតកម្ម | ការចំណាយក្នុងមួយឯកតាធ្វើឲ្យកើនឡើងផលិតកម្ម |
| ការចំណាយផ្នែកការផ្សព្វផ្សាកសិកម្មក្នុងមួយគ្រួសារកសិករ | ការចំណាយ/គ្រួសារ/ឆ្នាំ |
| អត្រាសាយភាយជម្ងឺកង្វះអាហារូបត្ថម្ភរបស់កុមារអាយុក្រោម៥ឆ្នាំ (តាមការវាស់វែងកម្ពស់ ទម្ងន់ និងរង្វង់ដៃ) | ចំនួន និង % ចែកទៅតាមខេត្ត ស្រុក |
| GDP កសិកម្ម | តម្លៃ % កំណើន/ឆ្នាំ |
| មុខរបរក្នុងវិស័យកសិកម្ម (ពេញម៉ោង ក្រៅម៉ោង) | ចំនួនកសិករធ្វើការពេញម៉ោងនិងក្រៅម៉ោងចែកទៅតាមខេត្ត ស្រុក ឃុំ |

ការវាយតម្លៃពីខាងក្រៅ ដោយប្រើប្រាស់វិធីសាស្ត្រការជ្រើសរើសសាកល្បងដោយចៃដន្យ (Randomized Control Trials-RCTs) ឬការបង្កើតការសិក្សាដើមគ្រា (Baseline) និងការប្រៀបធៀបជាមួយស្ថានភាពជាក់ស្តែងក៏អាចត្រូវបានធ្វើផែនការឡើងដើម្បីកំណត់អំពីផលប៉ះពាល់គម្រោងផងដែរ។ មេរៀនដែលទទួលបានអាចក្លាយជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តអំពីគម្រោងផ្សព្វផ្សាយកសិកម្មនាពេលអនាគត។

ការអនុវត្ត PAEC នឹងត្រូវបានវាយតម្លៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការបំពេញមុខងាររបស់ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងគណៈកម្មាធិការនៅថ្នាក់ជាតិដូចជា AEAC និង NATC និងការប្រើប្រាស់មជ្ឈមណ្ឌលព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មក៏នឹងត្រូវបានវាយតម្លៃផងដែរ។ ប្រសិទ្ធភាពនៃប្រតិបត្តិការបែបវិមជ្ឈការ និងបែបចូលរួមក៏នឹងត្រូវប៉ាន់ប្រមាណផងដែរ។ ការពិនិត្យតាមដានលើលទ្ធផលការងាររបស់កម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម និងថ្នាក់ស្រុក និងថ្នាក់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវបានតាមដានហើយរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំនឹងត្រូវបានចងក្រងនៅថ្នាក់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ មេរៀនដែលទទួលបាននឹងត្រូវបានចែករំលែក ក្នុងអំឡុងពេលសិក្ខាសាលាផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិប្រចាំឆ្នាំ។ អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកផ្សព្វផ្សាយកសិកម្មដែលមានស្នាដៃលេចធ្លោនឹងត្រូវបានជ្រើសរើសនិងទទួលស្គាល់ចំពោះលទ្ធផលការងារលេចធ្លោរបស់ខ្លួន។

# ឯកសារពិគ្រោះ


Agriculture and Forestry University, Nepal. (2015). Course Bulletin of B.Sc. Ag. Rampur, Chitwan, Nepal.

Chanrithy, P. (2017). Presenation on Extension Operation in AEAC Meeting (22nd November 2017), GDA/DAE, ASPIRE Program.

Cummins, J. (2017). ASPIRE Agricultural Extension Implementation Strategy (Draft document). Phnom Penh, Cambodia: ASPIRE.

Curriculum Development Divisiton. (2014). Curriculum for Technical School Leaving Certificate in Agriculture (Plant Science). Bhaktapur, Nepal: Council for Technical Education and Vocational Training.

Department of Agricultural Extension. (2017). Results of SWOT Analysis. Phnom Penh, Cambodia: National Agriculture Extension and Agriculture Extension Startegy Development Workshop, December 26.

Department of Planning and Statistics. (2017). Agricultural Master Plan 2030: Strategic Framework for Agricultural Sector Development toward 2030. Phnom Penh, Cambodia: MAFF.

Food and Agriculture Organization. (2014). Country Fact Sheet on Food and Agriculture Policy Trends. April 2014: FAO Food and Agriculture Policy Decision Analysis. Accessed on March 12, 2017: http://www.fao.org/docrep/field/009/i3761e/i3761e.pdf

GDA/DAE. (2017). Draft Roles and Responsibilities for Agriculture Extension in Cambodia (May 2017).

International Fund for Agricultural Develoment. (2017). ASPIRE Mid-term Review: The Way Forward. Asia and the Pacific Division, Programme Management Department.

Khandker, S. R., Koolwal, G. B., & Samad, H. A. (2010). Handbook on Impact Evaluation: Quantitative Methods and Practices. Washington, DC: World Bank Publications.

Khieu, H. (2017). Guidelines for Extension Materials Development (ASPIRE Report). Phnom Penh, Cambodia: MAFF/ASPIRE project.

Lilongwe University of Agriculture and Natural Resources. (2015). NRC Campus Curriculum and Syllabi for Diploma in Agriculture (3 Years). Lilongwe: Malawi.

MAFF/ASPIRE project. (2018). Guidelines for Implementation of Provincial Program Funding Options: Contracting Out. Phnom Penh, Cambodia: Ministry of Agriculture, Forestry, and Fisheries/ASPIRE project.

MAFF/ASPIRE Project. (2017). Guidelines for Implementation of Provincial Program Funding Options: Public Private Partnerships. Report # 2. Phnom Penh, Cambodia: Ministry of Agriculture, Forestry, and Fisheries/ASPIRE project.

MAFF. (2016). General Decision on Correct Members of AEACs and NATSCs of MAFF (20th July 2016).

Ministry of Agriculture, Forestry, and Fisheries. (2015). Agricultural Extension Policy in Cambodia 2015. Phnom Penh, Cambodia. Retrieved from http://extwprlegs1.fao.org/docs/pdf/cam152453.pdf

Misra, D. C. (1997). Monitoring Extension Programs and Resources (Chapter 17). In B. E. Swanson, R. P. Bentz, & A. J. Sofranko (Eds.), Improving Agricultural Extension: A Reference Manual. Rome, Italy: Food and Agriculture Organization of the United Nations. Retrieved from http://www.fao.org/docrep/W5830E/w5830e0j.htm

National Agricultural Sector Extension Policy. (2012). Nairobi, Kenya: Agricultural Sector Coordination Unit, Government of Kenya.

National Institute of Statistics. (2016). Cambodia Socioeconomic Survey 2015. Phnom Penh, Cambodia: National Institute of Statistics, Ministry of Planning. https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202015.pdf

Rajalahti, R., Woelcke, J., & Pehu, E. (2005). Monitoring and Evaluation for World Bank Agricultural Research and Extension Projects: A good Practice Note (Vol. 20). Washington, DC: Agriculture & Rural Development Department, World Bank. Retrieved from http://siteresources.worldbank.org/INTARD/Resources/ARD_DP20.pdf

Suvedi, M., & Kaplowitz, M. (2016). What Every Extension Workers Should Know: Core Competency Handbook. Urbana Champaign, IL: Modernizing Extension and Advisory Services Project. http://csus.msu.edu/meas

Suvedi, M., & Sarom, M. (2017). Assessment of Agricultural Extension Services in Cambodia: Needs and Constraints: Perceptions of Farmers on Agricultural Extension Services. In M. Suvedi, M. Kaplowitz, & R. Ghimire (Eds.), Case Study Reports (pp. 6-39). East Lansing, MI: Department of Community Sustainability and Department of Agriculture, Food and Resource Economics, Michigan State University.

Welsh, N. (2017). Agricultural Extension System in Cambodia: SWOT Analysis. (ASPIRE Report). Phnom Penh, Cambodia: MAFF/ASPIRE project.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ កៈ រចនាសម្ព័ន្ធស្ថាប័ននៃអង្គភាពផ្សេងៗរបស់សេវាផ្សព្វផ្សាយកសិកម្ម[2]

## ឧបសម្ព័ន្ធ ក-១ៈ រចនាសម្ព័ន្ធនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (ដែលត្រូវបានស្នើឡើង)




[2] រចនាសម្ព័ន្ធអង្គការនេះ ត្រូវបានកែសម្រួលចេញពីរបាយការណ៍ និងឯកសារការងារ កម្មវិធីASPIRE។

ឧបសម្ព័ន្ធ ក-២៖ រចនាសម្ព័ន្ធការិយាល័យកសិកម្មស្រុក (ដែលត្រូវបានស្នើឡើង)



## ឧបសម្ព័ន្ធ ក-៣៖ ការអភិវឌ្ឍបច្ចេកវិទ្យាសមស្របនៅថ្នាក់មូលដ្ឋានសម្រាប់កសិករ (ដែលត្រូវបានស្នើឡើង)



## ឧបសម្ព័ន្ធ ក-៤៖ ក្របខ្ណ្ឌរចនាសម្ព័ន្ធ និងលំហូរកិច្ចសហប្រតិបត្តិការរបស់ប្រព័ន្ធផ្សព្វផ្សាយកសិកម្ម



**ឧបសម្ព័ន្ធ ខ៖ ការពិពណ៌នាវគ្គសិក្សាសម្រាប់ការបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្ម (ដែលត្រូវបានស្នើឡើង)**

**កំណត់សម្គាល់សំខាន់៖** ទីប្រឹក្សារូបនេះ បានធ្វើការពិនិត្យឡើងវិញលើកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដែលត្រូវបានប្រើប្រាស់ក្នុងប្រទេសបង់ក្លាដែស កម្ពុជា ឥណ្ឌា ម៉ាឡាវី និងនេប៉ាល់។ វគ្គសិក្សាដែលត្រូវបានស្នើឡើង ក៏ត្រូវបានកែសម្រួលចេញពីកម្មវិធីបណ្តុះបណ្តាលផ្សព្វផ្សាយកសិកម្មផ្សេងៗជាច្រើនទៀតផងដែរ។ ដូច្នេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យអនុគណៈកម្មាធិការផ្សព្វផ្សាយកសិកម្ម (NATSC) ទទួលបន្ទុកការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (អាចជាក្រុមការងារមន្ត្រីបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្មកម្ពុជា ក្នុងនោះអាចរួមមានដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងបុគ្គលិកក្នុងនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍធនធានមនុស្ស RUA, PNCA, KNSA មន្ត្រីផ្សព្វផ្សាយកសិកម្មរបស់CARDI) ពិនិត្យឡើងវិញលើវិធីសាស្រ្តបណ្តុះបណ្តាលលើម៉ូឌុលបង្រៀនដែលត្រូវបានស្នើឡើង។

អនុគណៈកម្មាធិការផ្សព្វផ្សាយកសិកម្ម (NATSC) អាចកំណត់រកក្រុមបុគ្គលិកបណ្តុះបណ្តាល ដើម្បីពិនិត្យ និងកែសម្រួលមាតិការវគ្គសិក្សាសម្រាប់វគ្គសិក្សានីមួយៗ និងកំណត់ចំនួនមេរៀនសម្រាប់ថ្នាក់រៀនទ្រឹស្តី និងថ្នាក់អនុវត្តផ្ទាល់។ ក្រុមការងារក៏ចាំបាច់ត្រូវតែពិនិត្យថាតើវគ្គសិក្សាដែលត្រូវបានស្នើឡើង ត្រូវបានបន្សុំជាមួយវគ្គសិក្សាដែលមានស្រាប់នៅតាមវិទ្យាស្ថាននានារបស់ខ្លួន និងដាក់បញ្ចូលខ្លឹមសារតាមការចាំបាច់។ ក្រុមការងារអាចពិនិត្យឡើងវិញលើឯកសារពិគ្រោះតាមបណ្តាញអ៊ីធឺណិតសម្រាប់វគ្គសិក្សានីមួយៗ ដើម្បីកំណត់អំពីភាពសមស្របនៃខ្លឹមសារមេរៀនសម្រាប់បរិបទប្រទេសកម្ពុជា។

ចាំបាច់ត្រូវបង្កើតឱ្យមានសៀវភៅណែនាំសម្រាប់វគ្គបណ្តុះបណ្តាល ឬសៀវភៅមគ្គុទ្ទេសក៍សម្រាប់គ្រូបង្រៀនសម្រាប់វគ្គសិក្សានីមួយៗ។ ទីប្រឹក្សាយល់ឃើញថា កម្រិតនៃការអប់រំ និងជំនាញភាសាអង់គ្លេសរបស់ VEWs, CEWs, និង AEAs ជាទូទៅមានកម្រិតទាប ហេតុនេះ សម្ភារៈការបណ្តុះបណ្តាលសម្រាប់វគ្គសិក្សាទាំងអស់នេះ គួរបង្កើតឱ្យមានជាភាសាខ្មែរ។ កញ្ចប់មេរៀនការបណ្តុះបណ្តាល អាចរួមមានផែនការមេរៀន ដែលអាចយកទៅអនុវត្តបានរួចជាស្រេច បទបង្ហាញស្លាយ និងឧបករណ៍វាយតម្លៃ។ អ្នកជំនាញនៅថ្នាក់មូលដ្ឋាន ឬបុគ្គលិកបណ្តុះបណ្តាលអាចទាមទារការលើកទឹកចិត្ត ដើម្បីអាចអភិវឌ្ឍសៀវភៅណែនាំការបណ្តុះបណ្តាលទាំងអស់នេះបាន។

ជាចុងក្រោយ គួរបង្កើតឱ្យមានឯកសារពិគ្រោះ ឯកសារចែក និងកំណត់ត្រាថ្នាក់រៀន សម្រាប់វគ្គសិក្សានីមួយៗ ត្រូវព្រីនចេញ និងដាក់ឱ្យមានជូនសម្រាប់គ្រូបណ្តុះបណ្តាលទាំងអស់។ សម្ភារៈទាំងអស់នេះ ក៏គួរដាក់ឱ្យមាននៅលើគេហទំព័រផ្សព្វផ្សាយកសិកម្ម ហើយរក្សាទុកនៅវិទ្យាស្ថានបណ្តុះបណ្តាល (ឬបណ្ណាល័យរបស់សាកលវិទ្យាល័យ) ដើម្បីឱ្យសិក្ខាកាមអាចមានលទ្ធភាពទទួលបានធនធានទាំងនេះ។

**ម៉ូឌុលទី ១៖ មូលដ្ឋានគ្រឹះនៃការអប់រំកសិកម្ម**

**ម៉ូឌុល ១.១៖ ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**

**គោលបំណង៖** ផ្តល់ឱ្យសិស្សបានយល់ដឹង អំពីប្រវត្តិនៃការផ្សព្វផ្សាយកសិកម្ម និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវកសិកម្មនៅកម្ពុជា។

**លទ្ធផលចុងក្រោយនៃវគ្គបណ្តុះបណ្តាល៖** នៅពេលបញ្ចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាចពិពណ៌នាអំពីតួនាទីគោលគំនិត និងគោលការណ៍នៃការផ្សព្វផ្សាយកសិកម្មនៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍តាមរយៈការអានសំណេរក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារអនុវត្តជាក់ស្តែង និងទស្សនកិច្ចទៅទីវាល។

**ប្រធានបទ៖**

- ការផ្សព្វផ្សាយកសិកម្ម ការអប់រំស្តីពីការផ្សព្វផ្សាយកសិកម្ម៖ ធាតុជាមូលដ្ឋាន និងលក្ខណសម្បត្តិនៃការអប់រំអំពីការផ្សព្វផ្សាយកសិកម្ម
- វិសាលភាព និងមុខងារនៃការផ្សព្វផ្សាយកសិកម្មនៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ
- ទស្សនវិជ្ជា និងគោលការណ៍របស់ការអប់រំស្តីពីការផ្សព្វផ្សាយកសិកម្ម
- ព្រឹត្តិការណ៍ប្រវត្តិនៃការផ្សព្វផ្សាយកសិកម្មក្នុងពិភពលោក និងក្នុងប្រទេសកម្ពុជា
- ប្រព័ន្ធតភ្ជាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម៖ តើហេតុអ្វីបានជាប្រព័ន្ធការផ្សព្វផ្សាយកសិកម្មមានភាពចាំបាច់?
- គោលគំនិតនៃការបណ្តុះបណ្តាល៖ ភាពខុសគ្នារវាងការអប់រំ និងការបណ្តុះបណ្តាល និងការរៀនសូត្រ
- ការជ្រើសរើស និងការប្រើប្រាស់វិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម និងវិធីសាស្ត្របង្រៀន
- គោលគំនិតស្តីពីនវានុវត្តន៍ ប្រភេទ និងលក្ខណសម្បត្តិនៃនវានុវត្តន៍ ការទទួលយក និងការផ្សព្វផ្សាយ
- ការផ្សព្វផ្សាយដែលជំរុញដោយតម្រូវការ មានលក្ខណៈពហុនិយម មានលក្ខណៈបែបការចូលរួម៖ ការផ្សព្វផ្សាយកសិកម្មរបស់ស្ថាប័នរដ្ឋ និងវិស័យឯកជន
- ការផ្តល់មូលនិធិសម្រាប់ការផ្សព្វផ្សាយកសិកម្ម
- សមត្ថភាពរបស់អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកការផ្សព្វផ្សាយកសិកម្ម
- វិធីសាស្ត្រនៃការផ្សព្វផ្សាយកសិកម្ម និងការជ្រើសរើសវិធីសាស្ត្រការផ្សព្វផ្សាយកសិកម្ម។

**ការអនុវត្តជាក់ស្តែង៖**

- សូមរៀបចំបន្ទាត់ពេលវេលានូវប្រវត្តិនៃការអប់រំការផ្សព្វផ្សាយកសិកម្ម និងសេវាផ្សព្វផ្សាយកសិកម្មក្នុងប្រទេសកម្ពុជា
- ទៅទស្សនកិច្ចមជ្ឈមណ្ឌលសេវាផ្សព្វផ្សាយកសិកម្មក្នុងមូលដ្ឋាន ឬការិយាល័យកសិកម្មឃុំ ឬមន្ទីរកសិកម្មខេត្ត និងសិក្សាអំពីរចនាសម្ព័ន្ធសេវាដែលផ្តល់មូលនិធិដែលទទួលបាននិងបញ្ហានានាដែលកើតមានក្នុងសេវាផ្សព្វផ្សាយកសិកម្ម
- ចុះទៅទស្សនកិច្ចក្រុមកសិករ និង/ឬ កសិករជនបទ ក៏ដូចជា កសិករធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម និងសិក្សាស្វែងយល់ថាតើអ្នកប្រកបវិជ្ជាជីវៈអាជីព/អង្គការផ្នែកផ្សព្វផ្សាយកសិកម្ម បានបម្រើឱ្យពួកគេ ឬទេ និងបានបម្រើដោយយ៉ាងណាខ្លះ កំណត់រកបញ្ហា និងស្នើឡើងនូវដំណោះស្រាយ ដើម្បីកែលម្អសេវាផ្សព្វផ្សាយកសិកម្មជូនដល់អ្នកប្រើប្រាស់

- រៀបចំសម្ភារៈបណ្តុះបណ្តាលការផ្សព្វផ្សាយកសិកម្ម និងសម្ភារៈអប់រំ ដូចជា ព្រឹត្តិបត្រ វីដេអូ សារតាមវិទ្យុ ។ល។ លើបញ្ហាពាក់ព័ន្ធ និងយកសម្ភារៈនោះទៅអនុវត្តសាកល្បង ថាតើសម្ភារៈនោះបានផលឬទេ និងតើបានផលដោយរបៀបណា។

## អំណានបន្ថែម៖


Suvedi, M. & Kaplowitz, M. *(2016). What Every Extension Worker Should Know?* Urbana Champaign, IL: USAID-MEAS.

Swanson, B. E., Bentz, R. P., & Sofranko, A. J. (1996). *Improving Agricultural Extension: A Reference Manual*. New Delhi, India: Daya Publisher House Delhi.

Umali, D. L., & Schwartz, L. (1994). *Public and Private Agricultural Extension: Beyond Traditional Frontiers*. World Bank Discussion Papers; no. WDP 236. Washington, D.C.: The World Bank. http://documents.worldbank.org/curated/en/892021468762569269/Public-and-private-agricultural-extension-beyond-traditional-frontiers

Van den Ban, A. W., & Hawkins, H. S. (1996). *Agricultural Extension (2nd ed.)*. Cornwall: Blackwell Science.

**ម៉ូឌុល ១.២៖ វិធីសាស្ត្រ និងបច្ចេកទេសដែលមានការចូលរួម**[3]

**គោលបំណង៖** បំពាក់ចំណេះដឹង និងជំនាញដល់សិស្សអំពីវិធីសាស្ត្រ និងបច្ចេកទេសបែបការចូលរួម ពាក់ព័ន្ធជាមួយការផ្សព្វផ្សាយកសិកម្ម ការអប់រំ និងការបណ្តុះបណ្តាល។

**លទ្ធផលចុងក្រោយនៃវគ្គបណ្តុះបណ្តាល៖** បន្ទាប់ពីចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពន្យល់គោលគំនិត ស្តីពីការចូលរួម និងការបង្កើនសិទ្ធអំណាច ពន្យល់អំពីទំនាក់ទំនងរវាងការបង្កើនសិទ្ធអំណាច និងការអភិវឌ្ឍជនបទ វាយឈ្មោះ និងពិពណ៌នាវិធីសាស្ត្រ និងបច្ចេកទេសបែបការចូលរួម ដែលត្រូវបានប្រើប្រាស់ជាសាមញ្ញនៅក្នុងការផ្សព្វផ្សាយកសិកម្ម និងយកវិធីសាស្ត្របែបការចូលរួមដែលត្រូវបានប្រើប្រាស់ជាទូទៅ ទៅអនុវត្តនៅក្នុងវិជ្ជាជីវៈអាជីពរបស់ខ្លួន។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ ការប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចនៅទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម ការធ្វើបទបង្ហាញ លំហាត់ផ្ទាល់/លំហាត់ជាក្រុម ការសម្តែងតួ។

**ប្រធានបទ៖**

- គោលគំនិត ស្តីពីការចូលរួម និងការបង្កើនសិទ្ធអំណាច៖ ការចូលរួម និយមន័យនៃការចូលរួម ហេតុផលដែលធ្វើឱ្យកសិករ (ឬភាគីពាក់ព័ន្ធ) គួរចូលរួមនៅក្នុងកម្មវិធី/សកម្មភាពណាមួយ អ្នកទទួលផល និងតួនាទីរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មក្នុងការធ្វើផែនការដោយមានការចូលរួម វិធីសាស្ត្របែបការចូលរួមដែលត្រូវបានប្រើប្រាស់ជាសាមញ្ញ
- ការបង្កើនសិទ្ធអំណាចដល់សហគមន៍ គោលគំនិត និងវិធីសាស្ត្រសម្រាប់ការបង្កើនសិទ្ធអំណាចដល់សហគមន៍ សារៈសំខាន់នៃការបង្កើនសិទ្ធអំណាច ដំណើរការនៃការបង្កើនសិទ្ធអំណាចដល់សហគមន៍ និងកម្រិតនៃការបង្កើនសិទ្ធអំណាច
- វិធីសាស្ត្រ និងបច្ចេកទេសបែបការចូលរួម៖ ឧបករណ៍ការវិភាគស្ថានភាព ការធ្វើផែនទីធនធាន/សង្គម ការដើរកាត់ទទឹង/ការដើរបែបសង្កេត ក្រាហ្វិចលំហូរអាហារ ដ្យាក្រាមវ៉េន
- ការកំណត់បញ្ហា និងចាត់អាទិភាព៖ ការពិភាក្សាក្រុមគោលដៅ ការរៀងលំដាប់ចំណង់ចំណូលចិត្ត ការរៀងលំដាប់ជាគូៗ
- ការវិភាគបញ្ហា និងបង្កើតដំណោះស្រាយ៖ ដើមឈើបញ្ហា ដើមឈើគោលបំណង ម៉ាទ្រិចផែនការ/តារាងដំណោះស្រាយ វិធីសាស្ត្រធ្វើផែនការសកម្មភាព
- ផែនការសកម្មភាពសហគមន៍
- វិធីសាស្ត្រតាមដាន និងវាយតម្លៃ តារាងឫសគល់នៃការតាមដាន រង្វាស់ការផ្លាស់ប្តូរការអភិវឌ្ឍ ការពិភាក្សាតាមភូមិ ការចុះទស្សនកិច្ចនៅទីវាលរួមគ្នា។

**ការអនុវត្តជាក់ស្តែង៖** សិក្ខាកាមម្នាក់ៗ នឹងត្រូវចាត់តាំងឱ្យយកវិធីសាស្ត្រ ពីរទៅអនុវត្តនៅក្នុងស្ថានភាពទីវាលរបស់ខ្លួន។

---

[3] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលចេញពីកម្មវិធីបង្រៀនរបស់ Lilongwe University of Agriculture and Natural Resources NRC Campus និងកម្មវិធីបង្រៀនសម្រាប់ឌីប្លូម៉ាផ្នែកកសិកម្ម (ឆ្នាំទី ៣) ២០១៥ នៅប្រទេសម៉ាឡាវី។*

## **អំណានបន្ថែម៖**

Humboldt – universitat zu Berlin. (1994). *Facilitating the Introduction of a Participatory and Integrated Development Approach* (PIDA). Kenya: Kilifi.

Pretty, J. N., Guijt, T., & Scoones, I. (1995). *A Trainer's Guide for Participatory Learning and Action.* London: IIED Participatory Methodology Series.

Suvedi, M. & Kaplowitz, M. *(2016). What Every Extension Worker Should Know?* Urbana Champaign, IL: USAID-MEAS.

**ម៉ូឌុល ១.៣៖ ផលិតកម្មដំណាំនៅតាមវាល**[4]

**គោលបំណង៖** ធ្វើឱ្យសិស្សបានស្គាល់ការអនុវត្តផលិតកម្មទំនើបអំពីដំណាំធញ្ញជាតិសំខាន់ៗដែលដាំដុះក្នុងប្រទេសកម្ពុជា។

**លទ្ធផលចុងក្រោយនៃវគ្គបណ្តុះបណ្តាល៖** ក្រោយពីបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាចពិពណ៌នាអំពីការអនុវត្តសាកវប្បកម្មបែបទំនើបរបស់ផលិតកម្មដំណាំធញ្ញជាតិ និងឱកាស ការលំបាក និងស្ថានភាពការស្រាវជ្រាវនាពេលបច្ចុប្បន្នស្តីពីការស្រាវជ្រាវដំណាំធញ្ញជាតិ។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និងការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារអនុវត្តជាក់ស្តែង និង/ឬ ការងារមន្ទីរពិសោធន៍ និងការចុះទស្សនកិច្ចនៅទីវាល។

**ប្រធានបទ៖**

**ស្រូវ៖**

- សេចក្តីផ្តើម និងសារៈសំខាន់ ប្រភពការចែកចាយ តំបន់ ផលិតកម្ម និងផលិតភាពនៅក្នុងប្រទេសកម្ពុជា
- ការតម្រូវអំពីដី និងអាកាសធាតុ និងផលប៉ះពាល់របស់ដី និងអាកាសធាតុមកលើផលិតកម្ម
- រូបសាស្ត្រ (Morphology) ការលូតលាស់ និងការអភិវឌ្ឍ
- ពូជស្រូវសំខាន់ៗ និងពូជស្រូវកូនកាត់ក្នុងប្រទេសកម្ពុជា
- ប្រព័ន្ធដាំដុះស្រូវ ការរៀបចំដី និង ការបង្ហូរទឹកចូលស្រែ
- ការរៀបចំថ្នាលសំណាប៖ សើម ស្ងួត ថ្នាលសំណាប និងថ្នាលសំណាបកែសម្រួល និងអត្រាគ្រាប់ពូជ ប្រព្រឹត្តកម្មគ្រាប់ពូជ និងការទុកចន្លោះ
- អាហារូបត្ថម្ភខនិក និងការគ្រប់គ្រងជី៖ N, P, K, ស័ង្កសី ដែក និងជីជីវសាស្ត្រ ការគ្រប់គ្រងសារធាតុចិញ្ចឹមបែបរួមបញ្ចូល ជំហានដើម្បីបង្កើនប្រសិទ្ធផល ក្នុងការប្រើប្រាស់ជីចំពោះស្រូវ
- ការប្រើប្រាស់ទឹក និងការអនុវត្តការគ្រប់គ្រងទឹក៖ ការតម្រូវឱ្យមានទឹក ដំណាក់កាលសំខាន់ៗ ស្មៅចង្រៃ និងការគ្រប់គ្រងស្មៅចង្រៃ៖ ស្មៅចង្រៃដុះដែងជាមួយដំណាំ គោលការណ៍ និងវិធីសាស្ត្រក្នុងការគ្រប់គ្រងស្មៅចង្រៃ
- ការវិនិច្ឆ័យស្រូវទុំ ការប្រមូលផល ការបោកបែន ការសម្អាត ការសម្ងួត និងស្តុកទុកដាក់។

**ពោត៖**

- សេចក្តីផ្តើម និងសារៈសំខាន់ ប្រភព ការចែកចាយ តំបន់ ផលិតកម្ម និងផលិតភាពនៅក្នុងប្រទេសកម្ពុជា
- ការតម្រូវអំពីដី និងអាកាសធាតុ ការចាត់ចំណាត់ប្រភេទ ពូជសំខាន់ៗ និងពូជកូនកាត់
- រូបសាស្ត្រ (Morphology) ការលូតលាស់ និងការអភិវឌ្ឍ
- ការរៀបចំដី ប្រព្រឹត្តិកម្មគ្រាប់ពូជ អត្រាគ្រាប់ពូជ ពេលវេលាសាបព្រួស វិធីសាបព្រួស
- អាហារូបត្ថម្ភខនិក និងការគ្រប់គ្រងជី ការប្រើប្រាស់ទឹក ការអនុវត្តក្នុងការគ្រប់គ្រងទឹក
- ស្មៅចង្រៃ និងការគ្រប់គ្រងស្មៅចង្រៃ ការវិនិច្ឆ័យពោតទុំ ការប្រមូលផល ការបោកបែន ការសម្អាត ការសម្ងួត និងស្តុកទុកដាក់។

[4] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

**ស្រូវសាឡី (? ឬរុក្ខជាតិសាមញ្ញដទៃទៀត)៖**

- សេចក្តីផ្តើម និងសារៈសំខាន់ ប្រភព ការចែកចាយ តំបន់ ផលិតកម្ម និងផលិតភាពអេកូឡូស៊ីនៅក្នុងប្រទេសកម្ពុជា
- រូបសាស្ត្រ (Morphology) ការលូតលាស់ និងការអភិវឌ្ឍ
- ការតម្រូវអំពីដី និងអាកាសធាតុ ការចាត់ចំណាត់ប្រភេទ ពូជសំខាន់ៗ
- ការរៀបចំដី ប្រព្រឹត្តិកម្មគ្រាប់ពូជ អត្រាគ្រាប់ពូជ ពេលវេលាសាបព្រួស វិធីសាបព្រួស
- អាហារូបត្ថម្ភខនិក និងការគ្រប់គ្រងជី ការប្រើប្រាស់ទឹក និងការអនុវត្តក្នុងការគ្រប់គ្រងទឹក
- ស្មៅចង្រៃ និងការគ្រប់គ្រងស្មៅចង្រៃ ការវិនិច្ឆ័យដំណាំទុំ ការប្រមូលផល ការបោកបែន ការសម្អាត ការសម្ងួត និងស្តុកទុកដាក់
- ការគ្របដណ្តប់ ស្ថានភាព កត្តានានាដែលជះឥទ្ធិពលលើទិន្នផលក្នុងប្រព័ន្ធ បញ្ហាការគ្រប់គ្រង។

**ការអនុវត្តជាក់ស្តែង៖**

- ការរៀបចំទីវាលសម្រាប់ដំណាំធញ្ញជាតិ
- ការដាំដុះសំណាបស្រូវ
- ការសាបព្រួសដំណាំធញ្ញជាតិ
- ការសិក្សាអំពីដំណាក់កាលលូតលាស់របស់ស្រូវ ស្រូវសាឡី និងពោត
- ការអនុវត្តលើការគណនាលេខសម្រាប់ការតម្រូវផ្នែកជី និងថ្នាំពុលកសិកម្មរបស់ដំណាំធញ្ញជាតិ
- ការដាក់ជីលើដំណាំធញ្ញជាតិ
- ការវិនិច្ឆ័យលើដំណាំធញ្ញជាតិទុំ
- ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងលើរុក្ខជាតិមិនបានការសំខាន់ៗ សម្រាប់ស្រូវ ស្រូវសាឡី និងពោត
- ការប៉ាន់ប្រមាណទិន្នផល និងការប្រមូលផលដំណាំធញ្ញជាតិ
- ការសិក្សាអំពីរង្វាស់ជីវសាស្ត្រ (biometrics ) រុក្ខជាតិរបស់ដំណាំធញ្ញជាតិ
- ការចុះទស្សនកិច្ច និងសិក្សាលើការស្រាវជ្រាវនានាធ្វើឡើងនៅទីតាំងស្រាវជ្រាវ។

**ឯកសារពិគ្រោះ៖**

Dutta, S. K. (1981.) *Principles and Practices of Rice Production.* New York, NY: John Wiley and Sons.

Pal, M., Jayanta, D., & Rai, R. K. (1996). *Fundamentals of Cereal Crop Production*. New Delhi, India: Tata McGraw-Hill Publishing Co. Ltd.

Martin, J. H., Leonard, W. H., & Stamp, D. L. (1976). *Principles of Field Crop Production*. Third Edition. New York, NY: Macmillan Publishing Co. Inc.

Nanda, J. S., & Agrawal, P. K. (2008). *Botany of Field Crops.* India: Kalyani Publishers.

Reddy, S. R. (2009). *Agronomy of Field Crops*. India: Kalyani Publishers.

Singh, C. (2001). *Modern Techniques of Raising Field Crops*. New Delhi, India: Oxford and New Delhi: IBH Pub. Co. Pvt. Ltd.

**ម៉ូឌុល ១.៤៖ ផលិតកម្មដំណាំសាកវប្បកម្ម**[5]

**គោលបំណង៖** ធ្វើឱ្យសិស្សស្គាល់អំពីដំណាំសារកប្បកម្មសំខាន់ៗ ដែលដាំដុះក្នុងប្រទេសកម្ពុជា។

**លទ្ធផលចុងក្រោយនៃវគ្គបណ្តុះបណ្តាល៖** បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច ពន្យល់អំពីសារៈសំខាន់នៃសាកវប្បកម្មមកលើសេដ្ឋកិច្ចជាតិ ចាត់ចំណាត់ប្រភេទសាកវប្បកម្ម និងពិពណ៌នាអំពីការបង្កើតថ្នាលកូនរុក្ខជាតិ ជ្រើសរើស ដាំកូនរុក្ខជាតិ និងការអនុវត្តផ្នែកកសិកម្មដទៃទៀតពាក់ព័ន្ធជាមួយផលិតកម្មសាកវប្បកម្ម ស្គាល់អំពីសាកវប្បកម្មបែបសរីរាង្គ ក៏ដូចជាសាកវប្បកម្មតំបន់ទីក្រុង តំបន់ជុំវិញទីក្រុង និងការអភិរក្ស ព្រមទាំងផ្សព្វផ្សាយដំណាំសាកវប្បកម្មជនជាតិដើមភាគតិច។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និងការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារអនុវត្តជាក់ស្តែង និង/ឬការងារមន្ទីរពិសោធន៍ និងការចុះទស្សនកិច្ចនៅកសិដ្ឋានសាកវប្បកម្ម និងទីផ្សារ។

**ប្រធានបទ៖**

- អត្ថន័យនៃពាក្យសាកវប្បកម្ម ផ្នែករបស់សាកវប្បកម្ម និងទំនាក់ទំនងសាកវប្បកម្មជាមួយមុខវិជ្ជាដទៃទៀត
- សារៈសំខាន់ វិសាលភាព ស្ថានភាពបច្ចុប្បន្ន គោលនយោបាយជាតិ និងផែនការ ព្រមទាំងការលំបាកចំពោះការអភិវឌ្ឍសាកវប្បកម្មក្នុងប្រទេសកម្ពុជា
- ការចាត់ប្រភេទដំណាំសាកវប្បកម្ម
    - ចំណាប់ប្រភេទដំណាំសាកវប្បកម្មផ្អែកទៅតាមភូតគាមសាស្ត្រ
    - ចំណាប់ប្រភេទដំណាំសាកវប្បកម្មផ្អែកទៅតាមសាកវប្បកម្ម
    - ការចែកតំបន់គ្បេត្របរិស្ថាន និងឱកាសលក់ផលិតផល ដោយមើលចេញពីទស្សនៈវិស័យសាកវប្បកម្ម
    - ភាពគួរជាទីកត់សម្គាល់ផ្នែកសេដ្ឋកិច្ចនៃការកំណត់តំបន់គ្បេត្រ-បរិស្ថានរបស់ប្រទេសកម្ពុជា
- កត្តានានាដែលជះឥទ្ធិពលលើផលិតកម្មដំណាំសាកវប្បកម្ម ភាពតានតឹងផ្នែកបរិស្ថានផ្សេងៗ (សំណើមសីតុណ្ហភាព ពន្លឺ ទឹកជំនន់ និងជាតិប្រៃ) និងវិធានការដើម្បីជម្នះបញ្ហាទាំងនេះ
- សេចក្តីផ្តើមទូទៅស្តីពីប្រភេទសហគ្រាសសាកវប្បកម្ម៖ សួនដំណាំ ការបណ្តុះកូនឈើ សួនរុក្ខជាតិល្អ កសិកម្មបន្លែ និងការចាត់ចែងក្រោយពេលប្រមូលផល និងការរក្សាទុក
- ការបង្កើតសួនដំណាំ និងការគ្រប់គ្រង៖
    - ការជ្រើសរើសទីតាំង និងការរៀបចំប្លង់សួនដំណាំ
    - ការដាំដុះ: ការគ្រប់គ្រងដី និងគ្រប់គ្រងទឹក ការបំបែកខ្យល់ និងខ្សែក្រវាត់ទីជម្រក
    - ការដាក់ជីលាមកសត្វ និងជីគីមី ការគ្រប់គ្រងរុក្ខជាតិឥតប្រយោជន៍ ការថែរក្សា និងថែទាំ
- ការផ្សាំរុក្ខជាតិកម្រិតមូលដ្ឋាន
    - ណែនាំអំពីការផ្សាំរុក្ខជាតិ វិធីសាស្ត្រភេទ វិធីសាស្ត្រអភេទ
    - ការកាត់ និងការដាក់ជាស្រទាប់
    - ការចេញផ្កា និងការបំបៅខ្នែង
    - ការផ្សាំបំណែករុក្ខជាតិឯកទេស ការផ្សាំបែបមីក្រូ និងការផ្សាំដោយប្រើលំអងទឹក
- ការលូតលាស់ និងការអភិវឌ្ឍ

[5] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

- ○ គោលគំនិត ស្ដីពីការលូតលាស់
- ○ ការចេញពន្លក និងការលាស់ខ្ចី
- ○ ការចេញផ្កា ការចេញផ្លែ ការលូតលាស់របស់ផ្លែ និងការអភិវឌ្ឍ
- ○ ការទុំ ការមិនមានផ្លែផ្កា និងការជ្រុះផ្លែ
- ○ ការទុំ ការចេញមើម ការអភិវឌ្ឍរបស់មើម ការប្រែជាចាស់

- ការគ្រប់គ្រងការលូតលាស់របស់រុក្ខជាតិ
  - ○ ចំណាត់ប្រភេទធំៗនៃសារធាតុធ្វើឱ្យរុក្ខជាតិលូតលាស់ (អុកស៊ីន ជីប័រេលីន ស៊ីតូគីនីន អេទីឡែន និងអ៊ីនហ៊ីប៊ីតទ័រ) និងមុខងាររបស់សារធាតុទាំងនេះ
  - ○ ការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្មនៃ PGR ក្នុងសាកវប្បកម្ម
- ការបណ្ដុះបណ្ដាល និងការកាត់មែកៈ
  - ○ គោលការណ៍ជាមូលដ្ឋាន និងគោលបំណងនៃការបណ្ដុះបណ្ដាល និងការកាត់មែក
  - ○ ប្រព័ន្ធ/វិធីសាស្ត្រផ្សេងៗដែលត្រូវបានយកមកប្រើប្រាស់និងការអនុវត្តជាពិសេសរបស់ប្រព័ន្ធ/វិធីសាស្ត្រទាំងនោះ
- គោលការណ៍ជាមូលដ្ឋាន និងបច្ចេកវិទ្យារបស់សាកវប្បកម្មខុសរដូវ និងសាកវប្បកម្មទទួលបានការការពារ និងអនាគតរបស់វិស័យនេះក្នុងប្រទេសកម្ពុជា ប្រសិនបើមាន
- សារៈសំខាន់ និងសក្ដានុពលនាំផលិតកម្មដំណាំសាកវប្បកម្មបែបសរីរាង្គក្នុងប្រទេសកកម្ពុជា
- គោលការណ៍ជាមូលដ្ឋាននៃការដាំដំណាំមានដង់ស៊ីតេខ្ពស់ ការដាំដំណាំមានច្រើនជាន់ និងការដាំដំណាំជាមួយដំណាំសាកវប្បកម្ម
- សារៈសំខាន់ និងសក្ដានុពលនៃរុក្ខជាតិសាកវប្បកម្មជនជាតិដើមភាគតិច និងសារៈសំខាន់នៃ រុក្ខជាតិទាំងនេះនៅក្នុងសន្តិសុខអាហារូបត្ថម្ភ និងសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជា
- គោលការណ៍ស្ដីពីសាកវប្បកម្មក្នុងទីប្រជុំជន និងសាកវប្បកម្មជុំវិញទីប្រជុំជន ការដាំដុះទំពាំងបាយជូដែលដាំដុះក្នុងទឹក (អ៊ីដ្រូប៉ូនិក) និងក្នុងខ្យល់ (អ៊ែរ៉ូប៉ូនិក) និងការធ្វើកសិកម្មនៅបាតទន្លេ។

**ការអនុវត្តជាក់ស្ដែង៖**

- ធ្វើផែនទីប្រទេសកម្ពុជាដោយចែកទៅតាមតំបន់កសិអាកាសធាតុ និងពិពណ៌នាតំបន់នានាសម្រាប់ការដាំដុះដំណាំសាកវប្បកម្មសំខាន់ៗ
- ការកំណត់រកផ្លែឈើតាមរដូវ បន្លែ គ្រឿងទេស និងរុក្ខជាតិលម្អ
- ការកំណត់អត្តសញ្ញាណសម្ភារៈ និងឧបករណ៍សាកវប្បកម្ម ជីលាមកសត្វ និងជីគីមី អ័រម៉ូន និងមីក្រូសារធាតុចិញ្ចឹម
- ការរៀបប្លង់សួនផ្លែឈើសម្រាប់ប្រព័ន្ធផ្សេងៗនៃការដាំដុះរុក្ខជាតិហូបផ្លែ
- ការរៀបចំរណ្ដៅសម្រាប់ការដាំដុះកូនឈើហូបផ្លែ
- ការអនុវត្តការផ្សាំរុក្ខជាតិសាកវប្បកម្មតាមរដូវ៖ ការកាត់ ការដាក់ជាស្រទាប់ ការបំបៅមែក ការបណ្ដុះតាមផ្កា ការប្រើគ្រាប់ពូជដាំ
- ការអនុវត្តក្នុងការបង្ខឹករុក្ខជាតិសាកវប្បកម្មតាមរដូវ
- ហ្វឹកហាត់ការកាត់មែកតាមវិធីសាស្ត្រផ្សេងៗ

- ការរៀបចំ និងការយករូបមន្ត Bordeaux ទៅអនុវត្ត
- គម្រោងដែលត្រូវបានអភិវឌ្ឍលើសហគ្រាសសាកវប្បកម្ម
- ដំណើរទស្សនកិច្ចទៅកាន់កសិដ្ឋានសាកវប្បកម្មនៅថ្នាក់មូលដ្ឋាន។

**អំណានបន្ថែម៖**


ICAR. (2002). *Handbook of Horticulture*. New Delhi, India: Indian Council of Agric. Research.

Prasad, S. (1997). *Agros. Dictionary of Horticulture.* Bikaner, India: Agro-Botanics.

Prasad, S. (1997). *Principles of Horticulture.* Bikaner, India: Agro-Botanics.

**ម៉ូឌុល ១.៥៖ វារីវប្បកម្ម**[6]

**គោលបំណង៖** ធ្វើឱ្យសិស្សបានស្គាល់អំពីបច្ចេកវិទ្យា និងការអនុវត្តក្នុងផលិតកម្មត្រី។

**លទ្ធផលចុងក្រោយនៃវគ្គបណ្តុះបណ្តាល៖** បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពន្យល់អំពីលក្ខណសម្បត្តិនៃពូជត្រីដែលអាចចិញ្ចឹមបាន និងពូជត្រីដែលបានចិញ្ចឹម ព្រមទាំងអនុវត្តក្នុងការគ្រប់គ្រងពូជត្រីទាំងនោះ។

**វិធីសាស្រ្តនៃការសិក្សា៖** សិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និងការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារអនុវត្តជាក់ស្តែង និង/ឬ ការងារមន្ទីរពិសោធន៍ និងការចុះទស្សនកិច្ចនៅទីវាល។

**ប្រធានបទ៖**

- សេចក្តីផ្តើម៖ និយមន័យអំពីមច្ឆជាតិ ការនេសាទ និងវារីវប្បកម្ម លក្ខណសម្បត្តិទូទៅរបស់មច្ឆជាតិ លក្ខណសម្បត្តិគួរជាទីចង់បានរបស់មច្ឆជាតិសម្រាប់វប្បធម៌ សារៈសំខាន់របស់មច្ឆជាតិក្នុងប្រទេសកម្ពុជា
- ជីវសាស្រ្តនៃពូជត្រីដែលបានចិញ្ចឹម៖ លក្ខណសម្បត្តិផ្នែករូបសាស្រ្ត ទម្លាប់ក្នុងការឱ្យចំណី អត្រាលូតលាស់ និងអាកប្បកិរិយាបន្តពូជរបស់ត្រីកាបសាមញ្ញ ត្រីកាបចិន ត្រីកាបជនជាតិដើមភាគតិចសំខាន់ៗ ត្រីទីឡាបយ៉ា ត្រី Trout, ត្រីអណ្តែង ត្រី Sahar ត្រីឆ្ពិនប្រាក់ និងបង្កងទឹកសាប
- ការគ្រប់គ្រងគុណភាពទឹក៖ ប៉ារ៉ាម៉ែត្ររូបសាស្រ្ត៖ សីតុណ្ហភាព និងភាពកករ ប៉ារ៉ាម៉ែត្រគីមីសាស្រ្ត៖ DO និង pH ប៉ារ៉ាម៉ែត្រជីវសាស្រ្ត៖ ប្លង់តុង
- ការគ្រប់គ្រងស្រះ៖ ការជ្រើសរើសទីតាំងសម្រាប់សាងសង់ស្រះ ការដាក់កំបោរ ការដាក់ជី ចំណី និងការឱ្យចំណី រុក្ខជាតិដុះក្នុងទឹក និងការគ្រប់គ្រងសត្វស៊ីមច្ឆជាតិ
- ប្រព័ន្ធកសិដ្ឋានចិញ្ចឹមត្រី (FFS)៖ សេចក្តីផ្តើម ចំណាត់ប្រភេទ FFS ឈរលើមូលដ្ឋានដង់ស៊ីតេ ការព័ទ្ធជុំវិញពូជត្រី និងលក្ខណៈ
- ការបង្កាត់ពូជត្រី៖ គោលការណ៍មូលដ្ឋាននៃការបង្កាត់ពូជត្រី ការបង្កាត់ពូជត្រីកាបសាមញ្ញ ត្រីកាបចិន និងត្រីកាបជនជាតិដើមភាគតិចសំខាន់ៗ ការចិញ្ចឹមកូនត្រី និងការដឹកជញ្ជូនកូនត្រី
- ជម្ងឺ និងប៉ារ៉ាសិតដែលច្រើនកើតមានចំពោះត្រី៖ សេចក្តីផ្តើម សរីរៈបង្កហេតុ រោគសញ្ញា និងវិធានការគ្រប់គ្រងលើជំងឺផ្សិត (Saprolegniasis) ដំបៅកន្ទុយ/ដំបៅព្រុយ ជម្ងឺពកពណ៌ស ជម្ងឺដង្កូវបរាសិត (Dactylogyrosis), ជម្ងឺបង្កដោយចៃ (Argulosis) និង កង្វះអុកស៊ីសែន (Asphyxiation)។

**ការអនុវត្តជាក់ស្តែង៖**

- ទស្សនកិច្ចទៅកសិដ្ឋានចិញ្ចឹមត្រី
- រូបសាស្រ្តនៃត្រីដែលបានចិញ្ចឹមក្នុងប្រទេសកម្ពុជា
- សរីរវិទ្យារបស់ត្រី (សរីរាង្គខាងក្នុង៖ ប្រព័ន្ធរំលាយអាហារ ស្រកី អវយវៈភេទ)
- ប្រភេទស្រះ និងរង្វាស់ស្រះទូទៅ ការដាក់កំបោរ និងជីក្នុងស្រះ
- រង្វាស់គុណភាពទឹក (សីតុណ្ហភាព ភាពថ្លា DO និង pH)
- រូបមន្តចំណី និងការឱ្យចំណី ការសិក្សាអំពីប្រព័ន្ធកសិដ្ឋានមច្ឆជាតិផ្សេងៗ ការបង្កាត់ពូជត្រី

[6] *កំណត់សម្គាល់៖ កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

- ការសិក្សាអំពីឧបករណ៍នេសាទ និងការដាក់ស្បៃស្រះ ការពិនិត្យស្បៃក និងស្រគី
- ការកំណត់អត្តសញ្ញាណថ្នាំ និងសារធាតុគីមីដែលត្រូវបានប្រើប្រាស់ជាសាមញ្ញនៅក្នុងការគ្រប់គ្រងសុខភាពត្រី។

**អំណានបន្ថែម៖**


ICAR. (2006). *Handbook of Fisheries and Aquaculture*. New Delhi: India: Indian Council of Agricultural Research (ICAR).

Jhingran, V. G., & Pullin, R. S. V. (1985.) *A Hatchery Manual for the Common, Chinese and Indian Major Carps*. Manila, Philippines: Asian Development Bank.

NACA. (1989). *Integrated Fish Farming in China Technical Manual 7. A World Food Day*. Bangkok, Thailand: Publication of the Network of Aquaculture Centre in Asia and the Pacific.

Woynarovich, E., & Horvath, L. (1984). *The Artificial Propagation of Warm Water Finfishes, A Manual for Extension.*

**ម៉ូឌុល ១.៦៖ ផលិតកម្មសត្វ**[7]

**គោលបំណង**៖ ផ្តល់ឱ្យសិស្សនូវទិដ្ឋភាពទូទៅស្តីពីប្រព័ន្ធផលិតកម្មសត្វ។

**លទ្ធផលចុងក្រោយនៃវគ្គបណ្តុះបណ្តាល**៖ នៅពេលបញ្ចប់ម៉ូឌុលសិក្សានេះ សិស្សនឹងមានសមត្ថភាពអាចៈ ពិពណ៌នាការចិញ្ចឹមសត្វកសិកម្ម និងសត្វស្លាបនៅតាមផ្ទះ និងចេះការអនុវត្តការចិញ្ចឹមសត្វទូទៅសម្រាប់សត្វចិញ្ចឹមក្នុងកសិដ្ឋាន និងសត្វស្លាប។

**វិធីសាស្ត្រនៃការសិក្សា**៖ ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារអនុវត្តជាក់ស្តែង និង/ឬ ការងារមន្ទីរពិសោធន៍ និងការចុះទស្សនកិច្ចនៅទីវាល។

**ប្រធានបទ**៖

- សេចក្តីផ្តើម សព្ទដែលច្រើនប្រើប្រាស់នៅក្នុងការចិញ្ចឹមសត្វ និងបក្សី
- សារៈសំខាន់ វិសាលភាព និងការលំបាករបស់សត្វ និងបក្សីក្នុងប្រទេសកម្ពុជា
- ចំណាត់ថ្នាក់សត្តវិទ្យានៃសត្វចិញ្ចឹមក្នុងកសិដ្ឋាន និងសត្វស្លាប
- ពូជសត្វចិញ្ចឹមក្នុងកសិដ្ឋាន និងសត្វស្លាបដែលមានជាសាមញ្ញបំផុត
- ពូជគោ ក្របី ចៀម ពពែ ជ្រូក និងសត្វស្លាប
- ភាពខុសគ្នារវាងសត្វ សត្វទំពាអៀង និងសត្វមិនទំពាអៀង
- ប្រព័ន្ធកន្លែងរស់នៅសាមញ្ញរបស់សត្វចិញ្ចឹមក្នុងកសិដ្ឋាន និងសត្វស្លាប
- ការកំណត់អត្តសញ្ញាណ អាយុ ទម្ងន់ ការគ្រៀវ ការកាត់ស្នែងសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ការបង្ខាំង និងការចាត់ចែងលើសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- សញ្ញាបង្ហាញអំពីសុខភាពល្អ និង កត្តានានាដែលជះឥទ្ធិពលលើសុខភាពសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ការអនុវត្តក្នុងការគ្រប់គ្រងស្ត្រេសរបស់សត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ការថែទាំ និងការគ្រប់គ្រងលើសត្វចិញ្ចឹមក្នុងកសិដ្ឋានប្រភេទផ្សេងៗ៖ កូនគោទើបកើត សត្វពោះធំ និងកំពុងបំបៅដោះកូន គោគ្រាវយកសាច់ ការបង្កាត់ពូជក្របី និងសត្វឈើ
- សត្វនៅតាមតំបន់ភ្នំខ្ពស់ៗ លក្ខណសម្បត្តិ ការគ្រប់គ្រង និងការឱ្យចំណី
- សារៈសំខាន់នៃអនាម័យក្នុងកសិដ្ឋាន និងការចាត់ចែងកាកសំណល់
- ការអនុវត្តបែបអភិរក្សរបស់ចំណីសត្វពនេចរ ការប្រើប្រាស់ NPN នៅក្នុងចំណីរបស់សត្វទំពាអៀង
- ការរកទីផ្សារ និងការដឹកជញ្ជូនសត្វចិញ្ចឹមក្នុងកសិដ្ឋាន និង សត្វស្លាប
- សារៈសំខាន់ និង ប្រភេទកំណត់ត្រាកសិដ្ឋាន។

**ការអនុវត្តជាក់ស្តែង**៖

- ការកំណត់អត្តសញ្ញាណបំណែក/ចំណុចរាងកាយខាងក្រៅរបស់ សត្វចិញ្ចឹមក្នុងកសិដ្ឋាន និង សត្វស្លាប
- ការកំណត់អត្តសញ្ញាណ/ការដាក់លេខសម្គាល់សត្វចិញ្ចឹមក្នុងកសិដ្ឋាន និង សត្វស្លាប
- ការកំណត់អត្តសញ្ញាណពូជសត្វចិញ្ចឹមក្នុងកសិដ្ឋាន និង សត្វស្លាប
- ការគ្រៀវសត្វចិញ្ចឹមក្នុងកសិដ្ឋាន

[7] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ត្រឹភូវិបត្រនៃប៉ាល់ ឆ្នាំ ២០១៥។*

- ការកាត់ស្នែងសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ការប៉ាន់ប្រមាណអំពីទម្ងន់ខ្លួនតាមរយៈការវាស់ខ្លួនសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ការកំណត់អាយុ និងការវាស់ទម្ងន់ខ្លួនសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ការគៀបសត្វធំកុំឱ្យរើ និង ការចាត់ចែងសត្វចិញ្ចឹមក្នុងកសិដ្ឋាន
- ភាពខុសគ្នារវាងសត្វចិញ្ចឹមយកពង និងសត្វចិញ្ចឹមយកសាច់(layers and loafers)
- ការសិក្សាអំពីប្រភេទផ្សេងៗនៃកំណត់ត្រាកសិដ្ឋាន
- ការសម្អាត និងការសម្លាប់មេរោគកសិដ្ឋានចិញ្ចឹមសត្វ
- ការវិនិច្ឆ័យលើបសុសត្វ និង សត្វស្លាប។

**អំណានបន្ថែម៖**


Banerjee, G. C. (2006). *A Text Book of Animal Husbandry*. New Delhi, India: Oxford and IBH Publishing Co-Pvt. Ltd.

Thomas, C. K., Sastry, N. S. R., & Singh, R. A. (1990). *Livestock Production and Management*. India: Kalyani Publishers.

**ម៉ូឌុល ១.៧៖ ផលិតកម្មដំណាំចម្ការ**

**គោលបំណង៖** ធ្វើឱ្យសិស្សមានសមត្ថភាពក្នុងផលិតកម្មកៅស៊ូធម្មជាតិ និងបច្ចេកវិទ្យា និងការអនុវត្តក្នុងការកែច្នៃ។

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីសារៈសំខាន់ ប្រវត្តិ ការចូលរួមចំណែករបស់កៅស៊ូក្នុងសេដ្ឋកិច្ចកម្ពុជា រៀនសូត្រអំពីរបៀបដើម្បីបង្កើតថ្នាលកូនកៅស៊ូ ពន្យល់អំពីដំណើរការរក្សា និង បង្ករជ័រកៅស៊ូ និងដំណើរការក្នុងការចៀរយកជ័រ និងកែច្នៃកៅស៊ូ។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក និងការសិក្សាបែបពិសោធន៍តាមរយៈស្វ័យសិក្សា បទឧទ្ទេស ការអនុវត្តជាក់ស្តែង គម្រោង ការចុះទស្សនកិច្ចទៅកសិដ្ឋានកៅស៊ូ វីដេអូ ការងារជាក្រុម សិក្ខាសាលា។ល។

**ប្រធានបទ៖**

- សារៈសំខាន់ ការចូលរួមចំណែក ប្រវត្តិ សេណារីយ៉ូបច្ចុប្បន្ន និងសក្តានុពលនៃចម្ការកៅស៊ូ
- ចម្ការកៅស៊ូក្នុងប្រទេសកម្ពុជា៖ តម្រូវការទីផ្សារ ផលិតកម្ម និន្នាការ តម្លៃ។ល។
- ជីវសាស្ត្ររបស់ដើមកៅស៊ូ
- ក្រុមហ៊ុនចម្ការកៅស៊ូជាកម្មសិទ្ធិរបស់រដ្ឋ និងស្ថានភាពរបស់ក្រុមហ៊ុនទាំងនោះ
- ការបណ្តុះថ្នាលកូនកៅស៊ូ៖ ការអនុវត្តល្អ
- គោលនយោបាយរដ្ឋាភិបាលចំពោះការអភិវឌ្ឍកៅស៊ូ
- ការអនុវត្តផ្នែកក្សេត្រសាស្ត្រសម្រាប់ចម្ការកៅស៊ូ
- ចម្ការកៅស៊ូខ្នាតតូច និងចម្ការកៅស៊ូជាលក្ខណៈពាណិជ្ជកម្ម
- ការចំណាយ អត្ថប្រយោជន៍
- ការរក្សា និងការបង្ករជ័រកៅស៊ូ
- ការប្រមូលផល ការរក្សា និងការធ្វើទីផ្សារដំណាំកៅស៊ូ
- ការចៀរកៅស៊ូ៖ សម្ភារៈ និងឧបករណ៍ដែលត្រូវប្រើប្រាស់ វិធានការសុវត្ថិភាព និងការការពារ វិធីសាស្ត្រក្នុងការចៀរជ័រកៅស៊ូ ចម្ការកៅស៊ូ ចៀរសម្បកយកជ័រ ការទាក់ជ័រ ការប្រើប្រាស់សម្ភារៈការពារភ្លៀងបច្ចេកទេសចៀរជ័រ ការប្រមូលជ័រកៅស៊ូ ការប្រើប្រាស់សារធាតុការពារកក
- ការកែច្នៃកៅស៊ូ និងការផលិតដុំកៅស៊ូឆៅ៖ ឧបករណ៍ និងសារធាតុគីមីដែលត្រូវបានប្រើប្រាស់សម្រាប់ដំណើរការ សារធាតុគីមីដែលត្រូវបានប្រើប្រាស់ និងបច្ចេកទេសបង្ករជ័រកៅស៊ូ ម៉ាស៊ីនមូរ និងរបៀបប្រតិបត្តិការម៉ាស៊ីនទាំងនេះ ការអនុវត្តជាក់ស្តែងក្នុងការបន្ទះជ័រកៅស៊ូ ការឆ្អើរបន្ទះជ័រកៅស៊ូ៖ ទ្រឹស្តី។

**ការអនុវត្តជាក់ស្តែង**

- ការកំណត់អត្តសញ្ញាណសម្ភារៈ ឧបករណ៍ និងសារធាតុគីមីដែលត្រូវបានប្រើប្រាស់នៅក្នុងផលិតកម្មដំណាំចម្ការ
- ប្លង់ទូទៅ និងការធ្វើផែនការចម្ការដើមឈើ
- ការជីក និងការចាក់បំពេញរណ្តៅ
- ការកាត់ផ្តាច់រុក្ខជាតិដែលមានជាស្រទាប់ និងការស្ទូងនៅក្នុងថ្នាលបណ្តុះកូនឈើ
- ការរៀបចំកូនរុក្ខជាតិសម្រាប់លក់ និងសម្រាប់ស្ទូង
- ការអនុវត្តនៅក្នុងការពត់ដើមឈើ និងការកាត់មែក

- ការដាក់ជី និងការអនុវត្តក្នុងការស្រោចស្រពដំណាំ
- ការគណនា ការរៀបចំដំណោះស្រាយស្តុក ការគ្រប់គ្រងការលូតលាស់របស់រុក្ខជាតិ និងការ អនុវត្ត
- បច្ចេកទេសធ្វើសំណាកសម្រាប់ដី និងបំណែករុក្ខជាតិសម្រាប់ការវិភាគសារធាតុចិញ្ចឹម
- កិច្ចការផ្ទះ៖ រៀបចំគម្រោង ដើម្បីបង្កើតសហគ្រាសចម្ការដំណាំ (រួមទាំងថ្លៃក្នុងការបង្កើត និងចំណូលបានទទួលមកវិញ សម្រាប់អំឡុងរយៈពេលជាក់លាក់)
- សិក្សាសមាសធាតុរូបរបស់ជ័រកៅស៊ូពីទីវាល ការបង្វាប់ជ័យកៅស៊ូ
- ការរៀបចំកៅស៊ូបន្ទះ
- ការចុះទស្សនកិច្ចទៅកាន់ឧស្សាហកម្មកៅស៊ូ ដើម្បីយល់អំពីទិដ្ឋភាពការអនុវត្តជាក់ស្តែងក្នុងពាណិជ្ជកម្មនេះ
- កំណត់រកបញ្ហាប្រឈមដែលសហគ្រិនជួបប្រទះ
- អន្តរទំនាក់ទំនងជាមួយមន្ត្រីនិយ័តកម្មកៅស៊ូរបស់រដ្ឋាភិបាល។

**អំណានបន្ថែម៖**


Kohjiya, S., & Ikeda, Y. (Eds.) (2014). *Chemistry, Manufacture and Applications of Natural Rubber*. Woodhead Publishing.

Kumar, N., Abdul, K., Rangaswami, P., & Irulappan, I. (2000). *Introduction to Spices, Plantation Crops, Medicinal and Aromatic Plants*. New Delhi, India: Oxford & IBH Pub. Co. Pvt. Ltd.

Roberts, A. D. (Ed.). (1988). *Natural Rubber Science and Technology*. London, UK: Oxford University Press.

**ម៉ូឌុល ១.៨៖ ព្រៃឈើ**

**គោលបំណង៖** ធ្វើឱ្យសិស្សមានចំណេះដឹង និងជំនាញអំពីការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើប្រកបដោយនិរន្តរភាពសម្រាប់គាំទ្រជីវភាពរស់នៅ និងការអភិរក្សបរិស្ថាន។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីសរីរវិទ្យារបស់ដើមឈើ និងកំណត់អំពីពូជឈើផ្សេងៗ ពន្យល់អំពីការលូតលាស់ និងរចនាសម្ព័ន្ធរបស់ដើមឈើ ពន្យល់អំពីតំបន់ព្រៃប្រភេទ និងអេកូឡូស៊ីរបស់ព្រៃ ស្គាល់អំពីប្រព័ន្ធគ្រប់គ្រងព្រៃឈើ និងសុខភាពព្រៃឈើ ពន្យល់អំពីការដាំដុះព្រៃការប្រមូលផលនិងការរកទីផ្សារផលិតផលព្រៃឈើនិងទទួលបានចំណេះដឹងជាមូលដ្ឋានល្អប្រសើរស្តីពីគោលនយោបាយ និងកម្មវិធីនានាស្តីពីការគ្រប់គ្រងព្រៃឈើក្នុងប្រទេសកម្ពុជា។

**វិធីសាស្ត្រសិក្សា៖** សិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក និងការសិក្សាបែបពិសោធន៍តាមរយៈស្វ័យសិក្សា បទឧទ្ទេស គម្រោង  បទឧទ្ទេស គម្រោង ទស្សនកិច្ចព្រៃឈើ វីដេអូ ការងារជាក្រុម ការងារមន្ទីរពិសោធន៍ សិក្ខាសាលា។ល។

**ប្រធានបទ៖**

- សេចក្តីផ្តើម និង ស័ព្ទបច្ចេកទេស
- សរីរវិទ្យារបស់ដើមឈើ និង ការកំណត់អំពីដើមឈើ
- ការលូតលាស់ដើមឈើ រចនាសម្ព័ន្ធព្រៃឈើ
- តំបន់ព្រៃឈើ
- អេកូឡូស៊ីព្រៃឈើ
- ការគ្រប់គ្រងព្រៃឈើ និងប្រវត្តិ
- សុខភាពព្រៃឈើ
- ការដាំដុះព្រៃឈើ
- ទីភ្នាក់ងារ និងច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាល
- ផលិតផលព្រៃឈើ៖ ការរកទីផ្សារ និងការប្រមូលផល។

**ការអនុវត្តជាក់ស្តែង៖**

- អនុវត្តបង្ហាញអំពីរចនាសម្ព័ន្ធដើមឈើ និងសរីរវិទ្យារបស់ដើមឈើ
- ការកំណត់អត្តសញ្ញាណពូជព្រៃឈើ
- វង្វាស់ដើមឈើ
- រោគសញ្ញា និងរោគវិនិច្ឆ័យជម្ងឺដើមឈើ
- ទស្សនកិច្ចទៅកាន់ទីផ្សារឈើអា/ឈើហ៊ុប និងសិក្សាអំពីឱកាស និងបញ្ហាប្រឈមនានាដែលឧស្សាហកម្មឈើជួបប្រទះ។

**អំណានបន្ថែម៖**

Burton, L. D. (2012). *Introduction to Forestry Science*. Virginia Department of Forestry: Delmar Publishers. ISBN: 0-8273-8010-0

**ម៉ូឌុល ១.៩៖ សុខភាពសត្វ**[8]

**គោលបំណង**៖ ផ្តល់ឱ្យសិស្សនូវទិដ្ឋភាពទូទៅស្តីពីសុខភាពសត្វ សត្វស្លាប និងជម្ងឺ។

**លទ្ធផលចុងក្រោយ**៖ បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីប្រព័ន្ធរាងកាយរបស់សត្វ និងបក្សី យល់អំពីប៉ារ៉ាម៉ែត្ររាងកាយរបស់បសុសត្វ និងបក្សី និងពិពណ៌នាអំពីបុព្វហេតុរោគ រោគសញ្ញា ការគ្រប់គ្រង និងវិធានការបង្ការជម្ងឺបង្កដោយបាក់តេរី ផ្សិត វីរុស និងប៉ារ៉ាសិត ដែលរីកសាយភាយក្នុងចំណោមសត្វ និងបក្សីកម្ពុជា។

**វិធីសាស្ត្រនៃការសិក្សា**៖ សិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក និងការសិក្សាបែបពិសោធន៍តាមរយៈស្វ័យសិក្សា បទឧទ្ទេស ការអនុវត្តជាក់ស្តែង គម្រោង ការដោះស្រាយករណីគ្លីនិក ទស្សនកិច្ចកសិដ្ឋានសត្វ វីដេអូ ការងារជាក្រុម សិក្ខាសាលា។ល។

**ប្រធានបទ**៖

- សព្ទបច្ចេកទេសទាក់ទងទៅនឹងសុខភាព និងជម្ងឺ សញ្ញានៃសុខភាព និងជម្ងឺ
- ការប្រមូលប្រវត្តិជម្ងឺ៖ ការពិនិត្យរាងកាយ
- ចំណាត់ប្រភេទជម្ងឺ ទម្រង់នៃការចម្លងជម្ងឺ
- ជម្ងឺសំខាន់ៗបង្កឡើងដោយបាក់តេរី៖ ការបង្ករោគក្នុងឈាមដោយមានការហូរឈាម ជម្ងឺអង់ត្រាក់ រលាកដោះ (mastitis)
- ជម្ងឺសំខាន់ៗបង្កឡើងដោយវីរុស៖ អ៊ុតក្តាម ផ្តាយសាយជ្រូក ឆ្កែឆ្កួត
- ជម្ងឺសំខាន់ៗបង្កឡើងដោយបរាសិតប្រភេទប្រូតូសូអែ (protozoal) ៖ ជម្ងឺទឹកនោមក្រហមក្រម៉ៅ(Babesiosis), ជម្ងឺពោះវៀនបង្កដោយប៉ារ៉ាសិត (Coccidiosis)
- ជម្ងឺសំខាន់ៗបង្កឡើងដោយប៉ារ៉ាសិត៖ ប៉ារ៉ាសិតនៅក្នុងថ្លើម (Liver fluke) ព្រូន (Ascariasis) តេនញ៉ា
- ជម្ងឺសំខាន់ៗនៅក្នុងផលិតកម្ម៖ គ្រុនទឹកដោះ (Milk fever)
- ជម្ងឺសំខាន់ៗសម្រាប់បក្សី៖ ជម្ងឺរាគពណ៌ស (Pullorum) ដង្កោកាច់ ជម្ងឺហ្គាំបូរ៉ូ (Infectious Bursal Disease) ជម្ងឺខ្វាក់មាន់ (Marek´s Disease)
- បញ្ហាសំខាន់ៗផ្នែកបន្តពូជរបស់សត្វ៖ រយៈពេលគ្មានសកម្មភាពផ្លូវភេទ (anestrous) ការធ្លាក់ចុះលទ្ធភាពបង្កកំណើត (repeat breeding)
- ការមានផ្ទៃពោះសត្វចិញ្ចឹមក្នុងកសិដ្ឋាន និងការពិបាកសម្រាល
- ជម្ងឺសត្វសំខាន់ៗ វិធានការណ៍ការពារ និងគ្រប់គ្រង។

**ការអនុវត្តជាក់ស្តែង**៖

- វិធីសាស្ត្រក្នុងការយកសីតុណ្ហភាព ជីពចរ និងចង្វាក់ដង្ហើម
- ការប្រមូលប្រវត្តិជម្ងឺ
- ការធ្វើតេស្តទឹកនោមជាប្រចាំ
- ការចាក់វ៉ាក់សាំងសម្រាប់ពូជសត្វ (គោ ក្របី ចៀម ពពែ ពពួកសេះ និងបក្សី)
- ការធ្វើរោគវិនិច្ឆ័យជម្ងឺបង្កឡើងដោយប៉ារ៉ាសិតផ្សេងៗ

---

[8] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងវត្ថុប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

- ការធ្វើតេស្តឈាមដើម្បីធ្វើការប៉ាន់ប្រមាណរ TLC, DLC និង Hb
- ការធ្វើតេស្តប្រយោលលើទឹកដោះដើម្បីពិនិត្យរកអាប់សែក្រពេញទឹកដោះ។

### អំណានបន្ថែម៖


Chakravarti, A. (2011). *Text Book of Clinical Veterinary Medicine*. India: Kalyani Publishers.

Chakravarti, A. (2011). *Text Book of Preventive Veterinary Medicine*. India: Kalyani Publishers.

Merck Veterinary Manual. (2010). USA: Merc and Co.

**ម៉ូឌុលទី ២៖ ម៉ូឌុលកម្រិតខ្ពស់ស្តីពីការផ្សព្វផ្សាយកសិកម្ម**

**ម៉ូឌុល ២.១៖ សង្គមវិទ្យាជនបទ**[9]

**គោលបំណង**៖ ធ្វើឱ្យសិស្សយល់អំពីទិដ្ឋភាពផ្នែកសង្គមវិទ្យារបស់ប្រជាជនជនបទ និងដើម្បីឱ្យពួកគេស្គាល់អំពីលក្ខណសម្បត្តិសំខាន់ៗនៃសង្គមជនបទ ហើយអនុវត្តចំណុចទាំងអស់នេះ នៅលើការអភិវឌ្ឍកសិកម្ម។

**លទ្ធផលចុងក្រោយ**៖ បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ កំណត់និយមន័យ ថាតើអ្វីជាសង្គមជនបទ គុណតម្លៃផ្នែកសង្គម និងឥរិយាបថរបស់សហគមន៍ជនបទ តួនាទីរបស់ក្រុមសង្គមនានាទៅលើការអភិវឌ្ឍកសិកម្ម កំណត់អត្តសញ្ញាណ និងពិពណ៌នាស្ថាប័នសង្គមជនបទ និងទទួលបានទិដ្ឋភាពទូទៅស្តីអំពីការចូលរួមជាសង្គម។

**វិធីសាស្ត្រសិក្សា**៖ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និងការសិក្សាបែបពិសោធន៍តាម រយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ចូលរួមការងារអនុវត្តជាក់ស្តែង និងទស្សនកិច្ចទីវាលបទឧទ្ទេស លំហាត់ជាក្រុម ចូលរួមការពិភាក្សាក្នុងថ្នាក់រៀន ករណីសិក្សា/គម្រោង។

**ប្រធានបទ**៖

- សង្គមវិទ្យាជនបទ៖ អត្ថន័យ លក្ខណសម្បត្តិ វិសាលភាព សារៈសំខាន់ក្នុងបរិបទប្រទេសកម្ពុជា និងទំនាក់ទំនងជាមួយការផ្សព្វផ្សាយកសិកម្ម និងវិទ្យាសាស្ត្រសង្គមដទៃទៀត
- គុណតម្លៃផ្នែកសង្គម និងឥរិយាបថ៖ អត្ថន័យ និយមន័យ ប្រភេទ និងតួនាទីរបស់គុណតម្លៃផ្នែកសង្គមនិងឥរិយាបថនៅក្នុងការផ្សព្វផ្សាយកសិកម្ម សង្គមជនបទកម្ពុជា លក្ខណសម្បត្តិ គោលគំនិតផ្នែកវប្បធម៌៖ វប្បធម៌ ទំនៀបទម្លាប់ វិធីជីវិតប្រជាជន តំណម ពិធី និងប្រពៃណី៖ អត្ថន័យ និយមន័យ និងតួនាទីរបស់ធាតុទាំងនេះនៅក្នុងការផ្សព្វផ្សាយកសិកម្ម
- ភាពបន្តជាប់គ្នានៃជនបទ និងទីក្រុង៖ គោលគំនិត ភាពខុសគ្នា និងទំនាក់ទំនងរវាងសង្គមជនបទ និងសង្គមទីក្រុង
- ក្រុមសង្គម៖ អត្ថន័យ និងនិយមន័យ ការចាត់ប្រភេទក្រុមផ្សេងៗ
- តួនាទីរបស់ក្រុមសង្គមនៅក្នុងការផ្សព្វផ្សាយកសិកម្ម
- ដំណើរការផ្នែកសង្គម (ដំណើរការនៃអន្តរកម្មផ្នែកសង្គម)៖ គោលគំនិតជាមូលដ្ឋានគ្រឹះ ការទទួលយក ការកែសម្រួល ការលាយឡំ ការប្រដូច កិច្ចសហប្រតិបត្តិការ មតិឯកច្ឆន្ទ ការប្រកួតប្រជែង ទំនាស់ ភាពគ្នា
- ជម្លោះ៖ ដំណាក់កាល ការបន្តភាពតានតឹងនៃជម្លោះ ការគ្រប់គ្រងជម្លោះ
- ចលនាសង្គម៖ អត្ថន័យ និងបុព្វហេតុ ទ្រឹស្តី និងប្រភេទចលនាសង្គម
- ការចាត់ថ្នាក់សង្គម៖ អត្ថន័យ មូលដ្ឋានគ្រឹះ (ថ្នាក់ វណ្ណៈ អាយុ យេនឌ័រ) ទស្សនៈយល់ឃើញចំពោះការចាត់ថ្នាក់៖ទ្រឹស្តីនៃការបំពេញមុខងារ ទ្រឹស្តី Marx និង Max weber
- ស្ថាប័នសង្គមជនបទ៖ គោលគំនិត និងមុខងារ៖ ស្ថាប័នសង្គម៖ ផ្ទះសម្បែង គ្រួសារ និងប្រភេទ ប្រព័ន្ធអាពាហ៍ពិពាហ៍ ស្ថាប័នសេដ្ឋកិច្ច៖ កសិកម្ម នេសាទ បរបាញ់ និងលក់ពលកម្ម និងស្ថាប័នអប់រំ ស្ថាប័ននយោបាយ រដ្ឋាភិបាល ស្ថាប័នសាសនា៖ ប្រភេទសាសនា ការថែទាំ និងអ្នកដើរតាមសាសនា
- បញ្ហាសង្គម និងដំណោះស្រាយ

[9] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

- ការរួបរួមជាសង្គម៖ អត្ថន័យ ដំណាក់កាល និងភ្នាក់ងារនៃការរួបរួមជាសង្គម
- ទិដ្ឋភាពទូទៅនៃទ្រឹស្តីអំពីការរួបរួមជាសង្គម/អត្តដោយ Cooley, Mead និង Freud
- ការផ្លាស់ប្តូរសង្គម៖ អត្ថន័យ កត្តាការផ្លាស់ប្តូរផ្នែកសង្គម
- បច្ចេកវិទ្យាកសិកម្ម និងការផ្លាស់ប្តូរផ្នែកសង្គមជនបទ។

**ការអនុវត្តជាក់ស្តែង៖**

- ការសិក្សាអំពីស្ថាប័ន និងអង្គការសង្គមជនបទ ដូចជា សាលារៀន សហករ ឬ អាជ្ញាធររដ្ឋាភិបាលក្រុង/មូលដ្ឋាននៅតាមជនបទ ការធ្វើការងាររបស់ស្ថាប័នជនបទក្នុងកម្រិតមូលដ្ឋាន(លំហាត់ក្រុម)
- ទស្សនកិច្ចទៅកាន់សហគមន៍ជនបទដើម្បីកំណត់រកក្រុមសង្គមផ្សេងៗ ដែលកសិករជាប់ពាក់ព័ន្ធជាមួយ
- ទស្សនកិច្ចទៅកាន់ភូមិណាមួយ ដើម្បីធ្វើបញ្ជីរាយឈ្មោះតំណម វិធីជីវិតប្រជាជន ពិធី និងគុណតម្លៃផ្នែកសង្គមនៅក្នុងភូមិ
- រៀបចំកាលវិភាគការសម្ភាសន៍ដើម្បីសិក្សា អំពីលក្ខណសម្បត្តិផ្នែកសង្គមរបស់សង្គមជនបទ ដូចជាអំពីទម្រង់នៃការតាំងលំនៅ វប្បធម៌ ការចាត់ថ្នាក់សង្គម គុណតម្លៃសង្គម ការគ្រប់គ្រងសង្គម ទំនៀបទម្លាប់ ដំណើរការអន្តរកម្មសង្គម ការផ្លាស់ប្តូរសង្គម និងបញ្ហាសង្គម (លំហាត់ក្រុម)
- ការកំណត់រកប្រព័ន្ធតម្លៃសំខាន់ៗនៅក្នុងបរិយាកាសជនបទជាមធ្យោបាយនៃការគ្រប់គ្រងសង្គម
- ទស្សនកិច្ចទៅកាន់ភូមិណាមួយដើម្បីរៀបចំការតាំងពិព័រណ៌បង្ហាញសម្រាប់កសិករ (លំហាត់ក្រុម)។

**អំណានបន្ថែម៖**

Bhushan, V., & Sachdeva, D. R. (1994). *An Introduction to Sociology*. Allahabad, India: Kitab Mahal.

Chitambar, J. B. (1973). *Introductory Rural Sociology*. India: Wiley Eastern Limited.

**ម៉ូឌុល២.២៖ ការប្រាស្រ័យទាក់ទងផ្នែកកសិកម្ម**[10]

**គោលបំណង៖** ធ្វើឱ្យសិស្សបានស្គាល់អំពីគោលគំនិតនៃ ដំណើរការ ឧបករណ៍ និងបច្ចេកទេសនៃការប្រាស្រ័យទាក់ទង និងធ្វើឱ្យមានសមត្ថភាពអាចយកការសិក្សារបស់ខ្លួនទៅអនុវត្តក្នុងអាជីពនាពេលអនាគតរបស់ខ្លួន។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ សិស្សនឹងបានអភិវឌ្ឍចំណេះដឹង និងជំនាញស្ដីពីការប្រាស្រ័យទាក់ទង គោលគំនិត ដំណើរការ គំរូ ទ្រឹស្ដី ទម្រង់ ប្រព័ន្ធ និងផលប្រយោជន៍របស់ការប្រាស្រ័យទាក់ទងនៅក្នុងការអភិវឌ្ឍកសិកម្ម រួមទាំងការធ្វើផែនការផងដែរ។ សិស្សនឹងអភិវឌ្ឍសមត្ថភាពក្នុងការប្រើប្រាស់វិធីសាស្ត្រ និងឧបករណ៍ការប្រាស្រ័យទាក់ទង (ឧ. ព័ត៌មានវិទ្យា) តាមសេចក្ដីត្រូវការ និងបរិបទរបស់អតិថិជន។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និងការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្ដាប់បទឧទ្ទេស ចូលរួមក្នុងការងារអនុវត្តជាក់ស្ដែង និងទស្សនៈកិច្ចទីវាល បទឧទ្ទេស លំហាត់ក្រុម ចូលរួមការពិភាក្សាក្នុងថ្នាក់រៀន ករណីសិក្សា/គម្រោង។

**ប្រធានបទ៖**

- គោលគំនិត ស្ដីពីការប្រាស្រ័យទាក់ទង (អត្ថន័យ និយមន័យ វិសាលភាព សារៈសំខាន់មុខងារ)
- គោលការណ៍នៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព
- ការប្រាស្រ័យទាក់ទងនៅក្នុងកសិកម្ម និងការអភិវឌ្ឍ
- ការប្រាស្រ័យទាក់ទងក្នុងនាមជាដំណើរការ៖ ធាតុផ្សំទាំងប្រាំបួននៃការប្រាស្រ័យទាក់ទង
- ការផ្សព្វផ្សាយកសិកម្ម និងការប្រាស្រ័យទាក់ទង
- គំរូនៃការប្រាស្រ័យទាក់ទង៖ អត្ថន័យ និងគោលគំនិត
- ទ្រឹស្ដីអំពីការប្រាស្រ័យទាក់ទង៖ អត្ថន័យ និងទស្សនាទាន និង សារៈសំខាន់
- ទម្រង់នានានៃការប្រាស្រ័យទាក់ទង៖ផ្ទាល់មាត់ ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ ការប្រាស្រ័យ ទាក់ទងមិនមែនជាពាក្យសម្ដី
- ឧបសគ្គរាំងការប្រាស្រ័យទាក់ទង៖ ប្រភេទនៃឧបសគ្គ និងយុទ្ធសាស្ត្រ ដើម្បីជម្នះឧបសគ្គទាំងនោះ
- ប្រព័ន្ធនៃការប្រាស្រ័យទាក់ទង៖ ប្រព័ន្ធជាបុគ្គល ប្រព័ន្ធជាក្រុមក្នុងការប្រាស្រ័យទាក់ទង ប្រព័ន្ធការប្រាស្រ័យទាក់ទងទ្រង់ទ្រាយធំ
- យោបល់ត្រឡប់ក្នុងការប្រាស្រ័យទាក់ទង
- បណ្ដាញការប្រាស្រ័យទាក់ទង
- ជំនាញសម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព
- ការប្រាស្រ័យទាក់ទងផ្នែកស្ថាប័ន
- ការធ្វើផែនការការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍកសិកម្ម
- យុទ្ធវិធីការប្រាស្រ័យទាក់ទងរបស់ទីភ្នាក់ងារអភិវឌ្ឍ សហករ និងទីភ្នាក់ងារឯកជន
- ប្រព័ន្ធព័ត៌មានចំណេះដឹងកសិកម្ម
- ទស្សនាទានស្ដីពីព័ត៌មានវិទ្យា (ICT)

---

[10] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

- ឧបករណ៍ព័ត៌មានវិទ្យាៈប្រព័ន្ធផ្សព្វផ្សាយលើក្រដាស ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច ទូរស័ព្ទដៃពហុប្រព័ន្ធផ្សព្វផ្សាយ និងវីដេអូ
- ការប្រើប្រាស់ និង សារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រព័ន្ធផ្សព្វផ្សាយទ្រង់ទ្រាយធំ និងបច្ចេកវិទ្យាអ៊ីនធឺណិត
- ការយកព័ត៌មានវិទ្យា ទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម
- ការស្រាវជ្រាវផ្នែកការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។

**ការអនុវត្តជាក់ស្តែង៖**

- ការរៀបចំសម្ភារៈបោះពុម្ពលើក្រដាស (ផ្ទាំងបដា កូនសៀវភៅ ព្រឹត្តបត្រព័ត៌មាន)
- ការរៀបចំក្រាហ្វិច (ក្រាហ្វិចដើមឈើបញ្ហា ក្រាហ្វិចជាសន្លឹកបើក ក្រាហ្វិចលំហូរ ក្រាហ្វិចស្លាប័ន)
- ការសរសេររបាយការណ៍ចុះមូលដ្ឋាន និងការធ្វើបទបង្ហាញ
- ការរៀបចំ និងការសម្តែងល្ខោន (ប្រព័ន្ធផ្សព្វផ្សាយរបស់ជនជាតិដើមភាគតិច)
- ការរៀបចំ និងការធ្វើបទបង្ហាញរឿងជារូបថត)
- ការរៀបចំព្រឹត្តិបត្រព័ត៌មាន
- ការអភិវឌ្ឍសំណើរការប្រាស្រ័យទាក់ទង
- សិក្ខាសាលាសំណើរ (ការប្រាស្រ័យទាក់ទង)
- ការតាក់តែងយុទ្ធនាការកសិកម្ម
- ការធ្វើយុទ្ធនាការកសិកម្ម
- ការសរសេរ និងការធ្វើបទបង្ហាញចម្រៀងក្នុងមូលដ្ឋាន កម្មវិធីទូរទស្សន៍
- ការធ្វើបទបង្ហាញស្តីពីការអភិវឌ្ឍជំនាញ
- ការរៀបចំ និងការធ្វើបទបង្ហាញការអភិវឌ្ឍជំនាញតាមរយៈកម្មវិធី Microsoft power point
- ការអភិវឌ្ឍវីដេអូ។

**អំណានបន្ថែម៖**


Robbins, S. P., Judge, T. A., & Sanghi, S. (2009). *Organizational Behavior*. New Delhi, India: Prentice Hall.

Sandhu, A. S. (2014). *Textbook on Agricultural Communication: Process and Method*. New Delhi, India: Oxford and IBH Publishing Company Pvt. Ltd.

Dahama, O. P. & Bhatnagar, O. P. (2009). *Education and Communication for Development*. New Delhi, India: Oxford and IBH Publishing Company Pvt. Ltd.

Dubey, V. K., & Bishnoi, I. (2009). *Extension Education and Communication*. New Delhi, India: New Age International Publishers.

**ម៉ូឌុល ២.៣៖ ការកៀងគរផ្នែកសង្គម**

**គោលបំណង៖** ធ្វើឱ្យសិស្សយល់ និងអាចយកទស្សនទានស្តីពីការកៀងគរផ្នែកសង្គមទៅអនុវត្ត និងហ្វឹកហាត់លើការអភិវឌ្ឍសហគមន៍។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ដឹងអំពីសារៈសំខាន់នៃក្រុម និងសហគមន៍ដែលមានការចងក្រងផ្នែកសង្គម និងមានសាមគ្គីភាព ដើម្បីជ្រើសរើស និងអនុវត្តដំណើរការគោលវិធី និងបច្ចេកទេសសមស្របបំផុតនៅក្នុងការអភិវឌ្ឍកម្មវិធីអភិវឌ្ឍជនបទ និងកម្មវិធីអភិវឌ្ឍសហគមន៍តាមរយៈការទទួលស្គាល់សារៈសំខាន់នៃក្រុមដែលមានការចងក្រងផ្នែកសង្គម និង ការកៀងគរពួកគេនៅក្នុងសកម្មភាពអភិវឌ្ឍន៍ និង ដើម្បីប្រើប្រាស់ គោលគំនិតយេនឌ័រ និងវិធីសាស្រ្តសិក្សាតាមបែបការចូលរួម ពាក់ព័ន្ធជាមួយការអភិវឌ្ឍក្នុងលក្ខណៈវៃឆ្លាត និងពាក់ព័ន្ធបំផុត។

**វិធីសាស្រ្តសិក្សា៖**ការសិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ដោយប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចទីវាល សិក្ខាសាលា ការងារគម្រោង និង កំណត់ហេតុឆ្លុះបញ្ចាំង។

**ប្រធានបទ៖**

- ការកៀងគរផ្នែកសង្គម៖ និយមន័យ គោលគំនិត និងអត្ថន័យ ការកៀងគរផ្នែកសង្គមបែបផ្លាស់ប្រែសង្គម និងបែបប្រតិបត្តិការ ការកៀងគរផ្នែកសង្គម និងដំណើរការនៃការផ្លាស់ប្រែសង្គម
- គោលគំនិត អត្ថន័យ និងគោលបំណងនៃការកៀងគរផ្នែកសង្គម
- ដំណាក់កាល/ជំហាន/កិច្ចសន្ទនាក្នុងការកៀងគរផ្នែកសង្គម
- គុណភាពនៃអ្នកកៀងគរផ្នែកសង្គម៖ ការស្ថាបនាម៉ាកយីហោការកៀងគរផ្នែកសង្គម
- ការកៀងគរផ្នែកសង្គម និងអភិបាលកិច្ចល្អ
- គោលគំនិតស្តីពីភេទ និងយេនឌ័រ៖ ផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រ តួនាទីយេនឌ័រ និងតម្រូវការយេនឌ័រ
- ការចាត់ថ្នាក់សង្គម និងយេនឌ័រ ការរើសអើងផ្នែកយេនឌ័រក្នុងប្រទេសកម្ពុជា
- ទស្សនទានស្តីពីសមធម៌ និងសមភាព៖ ការវិភាគយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រ
- ការធ្វើផែនការដែលមានការយកចិត្តទុកដាក់ផ្នែកយេនឌ័រ ការរៀបចំថវិកាយេនឌ័រ
- ការបញ្ជ្រាបយេនឌ័រ៖ ដំណើរការ និងនីតិវិធី វិស័យ និងកម្រិតនៃការផ្លាស់ប្តូរ
- គោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា និងសកម្មភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ
- គោលគំនិត ស្តីពីបរិយាប័ន្នសង្គម ការធ្វើផែនទីបរិយាប័ន្នសង្គម
- យុទ្ធសាស្រ្ត និងសកម្មភាពយេនឌ័រ និងបរិយាប័ន្នសង្គម
- ទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ ជាមួយការកៀងគរផ្នែកសង្គម
- ការធ្វើផែនការបែបការចូលរួមនៅក្នុងដំណើរការកៀងគរផ្នែកសង្គម
- សកម្មភាពសំខាន់ៗនៃការធ្វើផែនការកម្មវិធីការកៀងគរផ្នែកសង្គម
- ដំណើរការអនុវត្ត និងនីតិវិធីនៃការកៀងគរផ្នែកសង្គម
- បញ្ហាប្រឈម និងបញ្ហានានាក្នុងការអនុវត្តការកៀងគរផ្នែកសង្គម
- ការរៀនសូត្របែបការចូលរួម និងឧបករណ៍សកម្មភាពសម្រាប់ការកៀងគរផ្នែកសង្គម
- ឧបករណ៍ និងបច្ចេកទេស PRA និង RRA ដែលត្រូវបានប្រើប្រាស់ក្នុងដំណើរការកៀងគរផ្នែកសង្គម។

**ការអនុវត្តជាក់ស្តែង៖**

- ចុះទស្សនកិច្ចទៅកាន់ភូមិ និងសិក្សាអំពីដំណើរការកៀងគរផ្នែកសង្គម
- សិក្សាលើគោលការណ៍ណែនាំស្តីពីការកៀងគរធនធាន/ការកៀងគរផ្នែកសង្គម
- ហ្វឹកហាត់អនុវត្តឧបករណ៍ និងបច្ចេកទេស PRA/RRA ដែលត្រូវបានប្រើប្រាស់
- អនុវត្តការដើរកាត់ទទឹង ការស្នាក់នៅក្នុងសហគមន៍ និងរៀបចំរបាយការណ៍
- អនុវត្តការចាត់លំដាប់ថ្នាក់សុខុមាលភាព អនុវត្តការពិភាក្សាក្រុមគោលដៅ
- អនុវត្តការធ្វើផែនទីការផ្លាស់ទីសម្រាប់ភារកិច្ច/ព្រឹត្តិការណ៍ណាមួយដែលមនុស្សភាគច្រើនចាប់អារម្មណ៍តាមដាន
- ធ្វើការវិភាគយេនឌ័រ ដោយប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រណាមួយ។

**អំណានបន្ថែម៖**

Chambers, R. (2016). *Revolution in Development Enquiry* (Nepal edition). New York, NY: Earthscan.

Singh, K. (1999). *Rural Development* (2nd ed.). New Delhi, India: Sage Publications.

**ម៉ូឌុល ២.៤៖ ការអភិវឌ្ឍសហគមន៍**

**គោលបំណង៖** ធ្វើឱ្យសិស្សមានសមត្ថភាពអំពីទស្សនទាន និងការអនុវត្តការអភិវឌ្ឍសហគមន៍។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ម៉ូឌុលសិក្សានេះ សិស្សនឹងបានរៀនសូត្រអំពី គោលគំនិត និងគោលការណ៍នានានៃការអភិវឌ្ឍសហគមន៍។ ពួកគេនឹងបានសិក្សាដើម្បីជ្រើសរើស និងអនុវត្តដំណើរការគោលវិធី និងបច្ចេកទេសសមស្របបំផុតក្នុងការអភិវឌ្ឍកម្មវិធីអភិវឌ្ឍជនបទ និងកម្មវិធីអភិវឌ្ឍសហគមន៍ ឧបករណ៍រៀនសូត្របែបការចូលរួមពាក់ព័ន្ធជាមួយការអភិវឌ្ឍក្នុងលក្ខណៈពាក់ព័ន្ធបំផុត។

**វិធីសាស្ត្រនៃការសិក្សា៖**ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និងការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ចូលរួមការងារអនុវត្តជាក់ស្តែង និងទស្សនកិច្ចទីវាលបទឧទ្ទេស លំហាត់ក្រុម ចូលរួមការពិភាក្សាក្នុងថ្នាក់រៀន ករណីសិក្សា/គម្រោង។

**ប្រធានបទ៖**

- គោលគំនិតស្តីពីការអភិវឌ្ឍ ៖ លក្ខណសម្បត្តិនៃការអភិវឌ្ឍ សូចនាករ
- ភាពខុសគ្នារវាងកំណើនការផ្លាស់ប្តូរ និងការអភិវឌ្ឍ
- ទិដ្ឋភាពទូទៅស្តីពីទ្រឹស្តីអភិវឌ្ឍ
- ទិដ្ឋភាពទូទៅនៃគោលវិធី និន្នាការ និងការអនុវត្តផ្នែកការអភិវឌ្ឍក្នុងប្រទេសកម្ពុជា
- គោលគំនិត ស្តីពីទំនើបនីយកម្ម៖ ទិដ្ឋភាពទូទៅស្តីពីទ្រឹស្តីទំនើបនីយកម្ម
- គោលគំនិត គោលការណ៍ និងយុទ្ធសាស្ត្រអំពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- ការអភិវឌ្ឍសហគមន៍៖ ដំណើរការ វិធីសាស្ត្រ កម្មវិធី និងនីតិវិធី
- ការថមថយដោយធៀប ភាពក្រីក្រមនុស្ស និងសន្ទស្សន៍ភាពក្រីក្រមនុស្ស
- វិធីសាស្ត្រគណនាសន្ទស្សន៍ភាពក្រីក្រមនុស្សសន្ទស្សន៍អភិវឌ្ឍមនុស្ស
- គោលគំនិត និងនិយមន័យអំពីវិមជ្ឈការ និងគោលការណ៍នៃអំណាចស្ថិតនៅថ្នាក់ទាបបំផុត
- ទម្រង់នៃវិមជ្ឈការ ប្រវត្តិសង្ខេបនៃការអនុវត្តវិមជ្ឈការក្នុងប្រទេសកម្ពុជា
- ទិដ្ឋភាពទូទៅនៃកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន និងសហព័ន្ធនីយកម្មក្នុងប្រទេសកម្ពុជា
- លក្ខណសម្បត្តិសំខាន់ៗនៃការអនុវត្តវិមជ្ឈការនាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា
- គុណសម្បត្តិ គុណវិបត្តិ បញ្ហានានានៃការអនុវត្តវិមជ្ឈការក្នុងប្រទេសកម្ពុជា
- គោលគំនិត អំពីភេទ និងយេនឌ័រ គំនិតខុសឆ្គងអំពីយេនឌ័រ តួនាទីយេនឌ័រ និងតម្រូវការផ្នែកយេនឌ័រ
- ការចាត់ថ្នាក់សង្គម និងយេនឌ័រ ការរើសអើងផ្នែកយេនឌ័រក្នុងប្រទេសកម្ពុជា
- គោលគំនិត ស្តីពីសមធម៌ និងសមភាព។

**ការអនុវត្តជាក់ស្តែង៖**

សិស្សនឹងចុះទស្សនកិច្ចទៅកាន់សហគមន៍មូលដ្ឋាន រៀបចំប្រូហ្វាលរបស់ខ្លួន ធ្វើការវិភាគ SWOT និងរៀបចំផែនការអភិវឌ្ឍ ដែលពួកគេចែករំលែកជាមួយសហគមន៍។

**អំណានបន្ថែម៖**

Selected articles from Community Development Journal published by Tylor and Francis http://www.tandfonline.com/toc/rcod20/current

Ledwith, M. (2005). Community Development: A Critical Approach (2nd ed.). Bristol, UK: The Open Press.

**ម៉ូឌុល ២.៥៖ ការគ្រប់គ្រងសមាគមន៍ និងសហគមន៍**

**គោលបំណង៖** ដើម្បីផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋាន និងជំនាញស្តីពីការបង្កើត និងការគ្រប់គ្រងសមាគមន៍កសិករ និងសហគមន៍ក្នុងនាមជាសហគ្រាសអាជីវកម្ម និង/ឬវិទ្យាស្ថានសង្គម។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖

- ពន្យល់ថាតើសមាគមន៍ និងសហគមន៍ជាអ្វី និងអំពីសារៈសំខាន់របស់សមាគម និងសហករនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស
- ពិពណ៌នាអំពីជំហាននានាក្នុងការបង្កើតសមាគមន៍ និងសហគមន៍
- ពិពណ៌នាអំពីកត្តាសំខាន់ៗក្នុងការគ្រប់គ្រងសមាគមន៍ និងសហគមន៍
- ពន្យល់ថាតើសមាជិកអាចទទួលអត្ថប្រយោជន៍យ៉ាងណាខ្លះពីការធ្វើការងារតាមរយៈសមាគមន៍ និងសហគមន៍។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ដោតប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម និងការធ្វើបទបង្ហាញ។

**ប្រធានបទ៖**

- គោលគំនិត និងគោលការណ៍របស់អង្គការកសិករ
- ចំណេះដឹងអាជីវកម្មកម្រិតមូលដ្ឋាន៖ អាជីវកម្ម/កសិធុរកិច្ច ធនធាននៅក្នុងកសិធុរកិច្ច
- សហគ្រិនភាពនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យម (SMEs)
- អភិវឌ្ឍគំនិតធុរកិច្ចដែលទទួលជ័យជម្នះ៖ ការបង្កើតគំនិត ការវាយតម្លៃគំនិត ការវិភាគចំណូលដុល និងចំណេញ ការវិភាគការលក់លម្អិត ការវិភាគច្រវាក់តម្លៃ ការជ្រើសរើសគំនិត ការអភិវឌ្ឍគំនិត
- សហគមន៍៖ អត្ថន័យរបស់សហគមន៍ ប្រភេទសហគមន៍ គោលការណ៍របស់សហគមន៍ គោលការណ៍អាជីវកម្មរបស់សហគមន៍ ទស្សនវិជ្ជារបស់សហករ ការគ្រប់គ្រងសហគមន៍ និង រចនាសម្ព័ន្ធ ការបង្កើត និងការចុះបញ្ជីសហគមន៍ មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសហគមន៍
- សមាគមន៍កសិករខ្នាតតូច (SFAs)៖ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងការទទួលខុសត្រូវ តួនាទីរបស់សមាជិកជាបុគ្គល តួនាទីរបស់ខ្លឹប តួនាទីរបស់ក្រុមព្រឹក្សាភិបាល អ្នកគ្រប់គ្រង និងគណៈកម្មាធិការគ្រប់គ្រងរដ្ឋាភិបាល
- ការរក្សាបញ្ជីកំណត់ត្រារបស់សមាគមន៍/សហគមន៍៖ សេចក្តីផ្តើមអំពីគណនេយ្យ អ្នកប្រើប្រាស់ព័ត៌មានគណនេយ្យ សមីការគណនេយ្យ វដ្តគណនេយ្យ ឯកសារច្បាប់ដើម បញ្ជីកំណត់ត្រាច្បាប់ដើម សៀវភៅបញ្ជីកត់ត្រាធំ (ledger) សមតុល្យសាកល្បង របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ចំណេញ និងខាត របាយការណ៍សមតុល្យសាច់ប្រាក់ គោលគំនិតគណនេយ្យ ប្រព័ន្ធគណនេយ្យចុះបញ្ជីទ្វេដង
- ការដាក់បញ្ចូលយេនឌ័រនៅក្នុងការគ្រប់គ្រងសមាគមន៍និងសហគមន៍៖សព្ទបច្ចេកទេសយេនឌ័រ យេនឌ័រជាការបង្កើតឡើងដោយសង្គម ការវិភាគយេនឌ័រនៅក្នុង SFGA និងសហគមន៍ អនុសាសន៍ដើម្បីធ្វើឱ្យមានការចូលរួមកាន់តែច្រើនពីស្ត្រី។

**ការអនុវត្តជាក់ស្តែង៖**

- លំហាត់ការសម្តែងតួស្តីពីរចនាសម្ព័ន្ធគ្រប់គ្រង
- ការអភិវឌ្ឍផែនការអាជីវកម្ម និងគណនេយ្យសម្រាប់សមាគមន៍
- ទស្សនកិច្ចទៅកាន់សហគមន៍ និង/ឬសមាគមន៍ដែលនៅក្បែរនោះ។

**អំណានបន្ថែម៖**

Wood, F., & Sangster, A. (2005). *Business Accounting 1 (10th ed.)*. London: Prentice Hall.

**ម៉ូឌុល ២.៦៖ ការងារជាក្រុម និង ការអភិវឌ្ឍជាក្រុម**

**គោលបំណង៖** ដើម្បីបំពាក់ចំណេះដឹង និងជំនាញឱ្យសិស្សសម្រាប់ការងារជាក្រុម និងទំនាក់ទំនងជាក្រុម ព្រមទាំងអនុវត្តចំណេះដឹង និងជំនាញទាំងអស់នេះនៅលើការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ។

**លទ្ធផលចុងក្រោយ៖** ក្រោយពីបញ្ចប់ការសិក្សាម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាថាតើក្រុម និងក្រុមការងារបំពេញមុខងារយ៉ាងដូចម្ដេចខ្លះ? តើវដ្ដរបស់ក្រុមមានលក្ខណៈបែបណា តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើអាកប្បកិរិយារបស់សមាជិក ធ្វើយ៉ាងណាដើម្បីអាចបង្កើតក្រុមប្រកបដោយប្រសិទ្ធភាព ដើម្បីសម្របសម្រួលដល់អន្តរាគមន៍ការអភិវឌ្ឍដោយប្រើប្រាស់គោលវិធីក្រុម និងតើចំណុច និងបញ្ហាអ្វីខ្លះដែលក្រុម និងក្រុមការងារជួបប្រទះ និងធ្វើយ៉ាងណាដើម្បីជម្នះបញ្ហា និងចំណុចទាំងនោះ។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ដោយប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម ការធ្វើបទ លំហាត់ក្រុម/លំហាត់អនុវត្តជាក់ស្ដែង ការសម្ដែងតួ។

**ប្រធានបទ៖**

- ទ្រឹស្ដីការអភិវឌ្ឍក្រុម៖ ទ្រឹស្ដីការផ្លោះប្ដូរផ្នែកសង្គម និងអត្តសញ្ញាណសង្គម
- លក្ខណសម្បត្តិនៃក្រុមប្រកបដោយប្រសិទ្ធភាព តើអ្វីខ្លះដែលនាំទៅរកបរាជ័យសម្រាប់ក្រុម? ធ្វើយ៉ាងណាដើម្បីជំរុញការងារជាក្រុមនៅក្នុងអង្គភាពមួយ?
- ប្រភេទនៃក្រុម៖ ក្រុមបញ្ហា ភារកិច្ចក្រុម តួនាទីរបស់ក្រុម ក្រុមដែលមានចំណាប់អារម្មណ៍ ក្រុមស្នូល
- លក្ខណសម្បត្តិនៃក្រុម៖ តួនាទី បទដ្ឋាន(norm) រចនាសម្ព័ន្ធ/ទំហំ ភាពជាអ្នកដឹកនាំ សមាជិក សមត្ថកិច្ច ការយកចិត្តទុកដាក់ចំពោះវប្បធម៌ សីលធម៌
- ដំណាក់កាលនៃការអភិវឌ្ឍក្រុម៖ ការបង្កើត ការបំផុស ការកំណត់និយាមបទដ្ឋាន ការអនុវត្ត ការផ្អាក
- ការបង្កើតផែនការក្រុម និងការអនុវត្តផែនការ
- ការប្រាស្រ័យទាក់ទងនៅក្នុងក្រុម៖ ការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងខ្លួនឯង
- យុទ្ធសាស្ត្រដើម្បីបង្កើនទំនាក់ទំនងក្រុម៖
    - ការគ្រប់គ្រងជម្លោះ
    - ការសម្រេចចិត្ត
    - អភិបាលកិច្ច
    - តម្លាភាព
    - ការចែករំលែកការទទួលខុសត្រូវ អត្ថប្រយោជន៍ និងបន្ទុក
    - ការបង្កើតកម្មសិទ្ធិរបស់ក្រុមកម្មវិធី/សកម្មភាពសម្រាប់សមាជិក
    - ការចែករំលែកព័ត៌មានគំនិត ធនធាន និងជំនាញ។

**ការអនុវត្តជាក់ស្ដែង៖**

- សិស្សសម្ដែងតួអំពីទំនាក់ទំនងក្រុមនៅក្នុងប្រធានបទ ឬភារកិច្ចជាក់លាក់ណាមួយ
- ទស្សនកិច្ចទៅកាន់ក្រុមកសិករ និង/ឬក្រុមសហគមន៍ណាមួយ សិក្សាអំពីទំនាក់ទំនងរបស់ពួកគេ និងវិភាគលើអ្វីដែលបានសង្កេតឃើញ និងថាតើក្រុមទាំងនេះ អាចធ្វើការបានកាន់តែប្រសើរជាងនេះទៀតលើអ្វីខ្លះ និងដោយរបៀបណា?។

## អំណានបន្ថែម៖

Bunch, R. (1995). *Two Ears of Corn*. Oklahoma City, OK: World Neighbors.

Fitzgerald, D. R. (2012). *If I had a Water Buffalo. Microfinance as a Means to Sustainability*. Traverse City, MI: CGS Publishing.

Forsyth, D. R. (2006). *Group Dynamics* (International Student Edition). Belmont, CA: Thomson Wadsworth Publishing.

Parker, G. M. (2009). *Teamwork. 20 Steps to Success*. Amherst, MA: HRD Press.

**ម៉ូឌុល ២.៧៖ យេនឌ័រ និង ការអភិវឌ្ឍ**

**គោលបំណង៖** ដើម្បីពង្រឹងចំណេះដឹង និងជំនាញរបស់សិស្សស្តីអំពីការដាក់បញ្ចូលយេនឌ័រនៅក្នុងការអភិវឌ្ឍកសិកម្ម។

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់ម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពន្យល់អំពីទំនាក់ទំនងយេនឌ័រ និងការអភិវឌ្ឍ និងផលិតភាពកសិកម្ម ពិភាក្សាលើផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ចរបស់បញ្ហាយេនឌ័រលើកសិដ្ឋានគ្រួសារនិងវិស័យកសិកម្ម ការយកជំនាញ និងបច្ចេកទេសសមស្របទៅអនុវត្តក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងផែនការកសិកម្ម និងប្រតិបត្តិការកសិកម្ម និងបកស្រាយគោលនយោបាយការដាក់បញ្ចូលយេនឌ័រ។

**វិធីសាស្រ្តនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ដោតប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម និងការធ្វើបទបង្ហាញ លំហាត់ក្រុម/លំហាត់អនុវត្តជាក់ស្តែង ការសម្តែងតួ ការចាក់វីដេអូបង្ហាញ។

**ប្រធានបទ៖**

- សេចក្តីផ្តើមអំពីយេនឌ័រ៖ និយមន័យសព្ទបច្ចេកទេសយេនឌ័រ ទិដ្ឋភាពទូទៅអំពីយេនឌ័រ និងកសិកម្ម តួនាទីយេនឌ័រធៀបជាមួយតួនាទីភេទ តម្រូវការជាក់ស្តែងផ្នែកយេនឌ័រ និងតម្រូវការយុទ្ធសាស្រ្តផ្នែកយេនឌ័រ
- ការវិវត្តគោលគំនិត អំពីយេនឌ័រ៖ ស្ត្រីនៅក្នុងវិធីសាស្រ្តនៃការអភិវឌ្ឍ យេនឌ័រនិងវិធីសាស្រ្តការអភិវឌ្ឍ
- យេនឌ័រ គឺជាការបង្កើតឡើងដោយសង្គម៖ ដំណើរការនៃការបង្កើតឡើងដោយសង្គម និងគំនិតខុសឆ្គងផ្នែកយេនឌ័រ លទ្ធផលចុងក្រោយនៃការបង្កើតឡើងដោយសង្គម និងការបង្កើតទស្សនៈខុសឆ្គងផ្នែកយេនឌ័រ ស្ថាប័ន និងប្រព័ន្ធដែលជួយពង្រឹងផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រ
- ឧបករណ៍វិភាគយេនឌ័រ៖ សេចក្តីផ្តើមអំពីឧបករណ៍វិភាគយេនឌ័រ សារៈសំខាន់នៃការវិភាគយេនឌ័រ
- ការបញ្ជ្រាបយេនឌ័រ៖ និយមន័យ គោលការណ៍ មូលហេតុសម្រាប់ការបញ្ជ្រាបយេនឌ័រ ការលំបាកក្នុងការបញ្ជ្រាបយេនឌ័រ ការបញ្ជ្រាបយេនឌ័រនៅក្នុងវដ្តគម្រោង។

**ការអនុវត្តជាក់ស្តែង៖**

- ការអភិវឌ្ឍ និងការកៀងគរការឆ្លើយតបពីសហគមន៍ផ្អែកលើយេនឌ័រ
- ឧបករណ៍អនុវត្តដើម្បីទាក់ទាញដល់អ្នកស្តាប់ជាមនុស្សពេញវ័យ
- វិធីសាស្រ្តអនុវត្តជាក់ស្តែង និងឧបករណ៍ដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រនៅថ្នាក់សហគមន៍ (ក្របខ័ណ្ឌការងារវិភាគរបស់ Harvard)។

**អំណានបន្ថែម៖**

Gillespie, S., & Kadiyala, S. (2005). *HIV/AIDS and Food and Nutrition Security: From Evidence to Action.* Washington DC: International Food Policy Research Institute.

Moser, C. (1993). *Gender Planning and Development. Theory, Practice and Training.* London: Routledge.

Slayter. T. B., Polestico, R., Esser, A. L., Taylor, O., & Mutua, E. (1995). *A Manual for Socio-Economic and Gender Analysis: Responding to the Development Challenge*. Worcester, MA: Clark University, Program for International Development [and] Rome: FAO.

Slocum, L. (1995). *Power Process and Participation: Tools for Change*. London: Intermediate Technology Publications Ltd.

## ម៉ូឌុល ២.៨៖ ធ្វើការជាមួយសហគមន៍ជនបទ[11]

**គោលបំណង៖** ធ្វើឱ្យអ្នកសិក្សាបានដឹងនិងបានទទួលជំនាញ ដើម្បីធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយសហគមន៍ និងតាមការរំពឹងទុករបស់សហគមន៍

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់ម៉ូឌុលសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពន្យល់អំពីសារៈសំខាន់នៃសហគមន៍ជនបទនៅក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា ពិភាក្សាអំពីសេវាផ្សព្វផ្សាយកសិកម្ម និងបញ្ហាប្រឈមរបស់សេវានេះ ពាក់ព័ន្ធជាមួយការផ្តល់សេវាជូនដល់សហគមន៍ជនបទក្នុងប្រទេសកម្ពុជា និង ពិពណ៌នាការប្រើប្រាស់បែបការអនុវត្តជាក់ស្តែងនៃវិធីសាស្ត្រការផ្តល់សារផ្សព្វផ្សាយកសិកម្មសំខាន់ៗ ដើម្បីបម្រើសហគមន៍ជនបទក្នុងប្រទេសកម្ពុជាប្រកបដោយប្រសិទ្ធភាព។

**វិធីសាស្ត្រសិក្សា៖** សិក្សាដោយខ្លួនឯង ការសិក្សាពីគ្នាទៅវិញទៅមក ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ដោយការប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចនៅទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម ការធ្វើបទបង្ហាញ លំហាត់ផ្ទាល់/លំហាត់ជាក្រុម ការសម្តែងតួ។

**ប្រធានបទ៖**

- សេចក្តីផ្តើម៖ និយមន័យសហគមន៍ជនបទ តួនាទីរបស់សង្គមជនបទក្នុងការអភិវឌ្ឍ
- ស្ថាប័នវប្បធម៌ដែលមានទូទៅនៅក្នុងសង្គមកម្ពុជា និងគុណតម្លៃរបស់ស្ថាប័នទាំងនេះក្នុងសង្គម
- និយាមវប្បធម៌ គុណតម្លៃ និងជំនឿ និងការជះឥទ្ធិពលមកលើការផ្លាស់ប្តូរសង្គម៖ ប្រភពនៃការផ្លាស់ប្តូរ ទ្រឹស្តីនៃការផ្លាស់ប្តូរសង្គម កត្តាជំរុញឱ្យមានការផ្លាស់ប្តូរសង្គម
- ចំណងទាក់ទងរវាងសង្គមវិទ្យាជនបទជាមួយការអភិវឌ្ឍកសិកម្ម
- កត្តាជំរុញទឹកចិត្តមនុស្សដើម្បីផ្លាស់ប្តូរ៖ ទ្រឹស្តីឋានានុក្រមនៃសេចក្តីត្រូវការរបស់លោក Maslow ទ្រឹស្តីរបស់លោក Herzberg ស្តីពីកត្តាទាំងពីនៃការជំរុញទឹកចិត្ត ការជះឥទ្ធិពលលើការផ្លាស់ប្តូរក្នុងចំណោមសហគមន៍កសិកម្ម
- គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា៖ ផលិតកម្មអាហារ កំណើនសេដ្ឋកិច្ច សុខុមាលភាពរបស់គ្រួសារកសិកម្ម និងប្រជាជនបទ កសិកម្មប្រកបដោយនិរន្តរភាព
- វិធីសាស្ត្រការផ្សព្វផ្សាយកសិកម្ម៖ វិធីសាស្ត្រជាបុគ្គល ជាក្រុម ប្រព័ន្ធផ្សព្វផ្សាយទ្រង់ទ្រាយធំ
- ដំណើរការនៃការទទួលយកបច្ចេកវិទ្យា នវានុវត្តន៍ ការផ្សព្វផ្សាយ និងការទទួលយក ប្រភេទនៃអ្នកទទួលយក
- កត្តានានាដែលជះឥទ្ធិពលដល់ការផ្សព្វផ្សាយនវានុវត្តន៍។

**ការអនុវត្តជាក់ស្តែង៖**

ការងារគម្រោងជាមួយសហគមន៍។

**អំណានបន្ថែម៖**


Reijntjes, C., Haverkort, B., & Waters-Bayer, A. (1992). *Farming for the Future. An Introduction to Low-External-Input and Sustainable Agriculture* (pp. 119-162). Macmillan Education Ltd, London.

Rogers, E. (1995). *Diffusion of Innovations (4th ed.). New York: NY:* Free Press.

Swanson, B. E., Bentz, R. P., & Sofranko, A. J. (1997). *Improving Agricultural Extension: A Reference Manual*. Rome: FAO.

Van den Ban, A. W., & Hawkins, H. S. (1996). *Agricultural Extension* (2nd ed.). Cornwall: Blackwell Science.


[11] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលចេញពីកម្មវិធីបង្រៀនរបស់ Lilongwe University of Agriculture and Natural Resources NRC Campus និងកម្មវិធីបង្រៀនសម្រាប់ឌីប្លូម៉ាផ្នែកកសិកម្ម (ឆ្នាំទី ៣) ២០១៥ នៅប្រទេសម៉ាឡាវី។*

**ម៉ូឌុល ២.៩៖ ការធ្វើទីផ្សារកសិកម្ម និងសហគមន៍**[12]

**គោលបំណង៖** ធ្វើឱ្យសិស្សបានស្គាល់ និងមានសមត្ថភាពអាចអនុវត្តគោលការណ៍ និងគោលវិធីការធ្វើទីផ្សារកសិកម្ម និងសហគមន៍នៅក្នុងការអភិវឌ្ឍកសិកម្ម។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ការសិក្សាម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីអត្ថន័យគោលគំនិតនិងសារៈសំខាន់នៃការធ្វើទីផ្សារកសិកម្ម និងសហគមន៍ ពិពណ៌នាអំពីយុទ្ធសាស្ត្រ ដើម្បីកំណត់អត្តសញ្ញាណ និងរក្សានិរន្តរភាពតម្រូវការផលិតផលកសិកម្មអភិវឌ្ឍបច្ចេកទេសវិភាគនៅក្នុងការស្រាវជ្រាវទីផ្សារកសិកម្ម និងពន្យល់អំពីបញ្ហាក្នុងការធ្វើទីផ្សារកសិកម្ម និងជម្នះបញ្ហាទាំងអស់នោះ។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ និង ការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ចូលរួមការងារអនុវត្តជាក់ស្តែង និងទស្សនកិច្ចនៅទីវាល។

**ប្រធានបទ៖**

- ការធ្វើទីផ្សារកសិកម្ម៖ គោលគំនិត អំពីទីផ្សារ និងការធ្វើទីផ្សារ លក្ខណៈសម្បត្តិនៃផលិតផលកសិកម្ម ចំណាត់ប្រភេទទីផ្សារ សារៈសំខាន់នៃតម្លៃផលិតផល និង ការធ្វើទីផ្សារកសិកម្មសម្រាប់វឌ្ឍនភាពផ្នែកសង្គមសេដ្ឋកិច្ច
- ទ្រឹស្តីអំពីអាកប្បកិរិយារបស់អតិថិជន៖ គោលគំនិត ស្តីពីផលប្រយោជន៍ និងវិធីសាស្ត្រក្នុងការវាស់វែង មុខងារតម្រូវការ និងកត្តានានាដែលជះឥទ្ធិពលលើអាកប្បកិរិយារបស់អ្នកប្រើប្រាស់ លំនឹងទីផ្សារ អ្នកប្រើប្រាស់ និងផលិតផលលើស
- ភាពបត់បែន៖ ភាពបត់បែនផ្សេងៗនៃតម្រូវការ ការផ្គត់ផ្គង់ និងទំនាក់ទំនងរបស់ពួកគេ
- ទ្រឹស្តីរបស់ក្រុមហ៊ុន៖ ទ្រឹស្តី និងលក្ខណសម្បត្តិរបស់ក្រុមហ៊ុន មុខងារផ្គត់ផ្គង់ និងការប្រែប្រួលរបស់វា វដ្តជីវិត និងការអភិវឌ្ឍផលិតផល យុទ្ធសាស្ត្រធ្វើទីផ្សារ ទីផ្សារ និងការផ្សព្វផ្សាយផលិតផល
- រចនាសម្ព័ន្ធទីផ្សារ និងលំនឹង (equilibrium) ៖ ផលិតផលលើសដែលអាចរកទីផ្សារបាន រចនាសម្ព័ន្ធទីផ្សារ ការកំណត់តម្លៃ និងភាពរើសអើងតម្លៃ
- មុខងារទីផ្សារ និងបណ្តាញទីផ្សារ៖ មុខងារទីផ្សារ៖ មុខងាររូបវ័ន្ត មុខងារក្នុងការដោះដូរ និងមុខងារក្នុងការសម្របសម្រួល៖ បណ្តាញការធ្វើទីផ្សារ ការចំណាយក្នុងការធ្វើទីផ្សារ ផលចំណេញនៃការធ្វើទីផ្សារ និងការផ្សព្វផ្សាយតម្លៃ
- ការប្រែប្រួលតម្លៃ៖ ចលនាតម្លៃដែលប្រែប្រួលទៅតាមពេលវេលា៖ ការប្រែប្រួលតម្លៃទៅតាមរដូវកាល និងវដ្តការប្រែប្រួលតម្លៃទៅតាមទីតាំង របាយទីតាំងនៃទំនិញ និងគំរូលំនឹងតាមតំបន់
- ការស្រាវជ្រាវទីផ្សារ៖ ការស្រាវជ្រាវក្នុងការធ្វើទីផ្សារកសិកម្ម ប្រសិទ្ធភាពការធ្វើទីផ្សារ និងការវាស់វែងប្រសិទ្ធភាព
- ការគ្រប់គ្រងគុណភាពទាំងស្រុង (TQM) និងសេវាអតិថិជន
- បញ្ហានៃការធ្វើទីផ្សារកសិកម្ម៖ លក្ខខណ្ឌផលិតកម្ម ការដឹកជញ្ជូន និងការប្រាស្រ័យទាក់ទង ការចាត់ថែង ការវេចខ្ចប់ និងការកែច្នៃ ការស្តុកទុក និងឃ្លាំង

[12] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រនេប៉ាល់ ឆ្នាំ ២០១៥។*

- អន្តរាគមន៍របស់រដ្ឋាភិបាល និងស្ថាប័នសាធារណៈ៖ តួនាទីរបស់រដ្ឋាភិបាលក្នុងការកំណត់តម្លៃទំនិញ និងការធ្វើទីផ្សារកសិកម្ម ស្ថាប័នសាធារណៈពាក់ព័ន្ធជាមួយផលិតកម្ម ការធ្វើទីផ្សារ និងការផ្សព្វផ្សាយ
- សហគមន៍៖ គោលគំនោត និយមន័យ ប្រវត្តិ តួនាទី ការរៀបចំ រចនាសម្ព័ន្ធ លក្ខន្តិកៈ ការធ្វើកសិកម្មបែបសហគមន៍ ការធ្វើទីផ្សារបែបសហគមន៍។

**ការអនុវត្តជាក់ស្តែង៖**

- ធ្វើសវនកម្មក្នុងការស្វែងរកទីផ្សារលើសហគ្រាសកសិកម្ម
- ទស្សនកិច្ចទៅកាន់ទីផ្សារកសិកម្ម និងរៀបចំបញ្ជីទំនិញ និងសេវាដែលមានផ្តល់ជូននៅទីផ្សារ និងកំណត់រកចំណងទាក់ទងថយក្រោយ និងឆ្ពោះទៅមុខ (ច្រវាក់តម្លៃ) របស់ទំនិញទាំងនោះ
- សិក្សាស្ថានភាពតម្រូវការ និងការផ្គត់ផ្គង់ និងលទ្ធភាពអាចទទួលបានផលចំណេញរបស់ទំនិញកសិកម្មសំខាន់ៗក្នុងប្រទេសកម្ពុជា។

**អំណានបន្ថែម៖**


Barker, J. (1989). Agricultural Marketing (2nd ed). London: Oxford University Press.

Crawford I. M. (1997). Agricultural and Food Marketing Management. Marketing and Agribusiness Text 2. Rome: FAO.

Kohls, L. R., & Uhl, J. N. (2002). The Marketing of Agricultural Products (9th ed.). New Jersey, NJ: Prentice Hall Inc.

Koutsoyiannis, A. K. (1994). Microeconomics. Prentice Hall, India.

Rae, A. N. (1994). Agricultural Management Economics: Activity and Decision Making. New York, NY: CAB.

Rhodes, V. J. (1983). The Agricultural Marketing Systems. Singapore: John, Wiley and Sons, Inc.

## ម៉ូឌុលទី ៣៖ ការគ្រប់គ្រង ផ្តោតលើវគ្គបណ្តុះបណ្តាលសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម

### ម៉ូឌុល៣.១៖ ការអភិវឌ្ឍកម្មវិធីផ្សព្វផ្សាយកសិកម្ម

**គោលបំណង៖** ធ្វើឱ្យសិស្សមានសមត្ថភាពអំពីទ្រឹស្តី វិធីសាស្ត្រ និងបច្ចេកទេសការធ្វើផែនការកម្មវិធី រួមទាំងការវាយតម្លៃសេចក្តីត្រូវការ និងការយកចំណេះដឹងទាំងអស់នេះទៅអនុវត្តក្នុងអាជីពការងារនាពេលអនាគតរបស់ខ្លួន។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ការសិក្សាម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីគោលគំនិត និងទ្រឹស្តីនានានៃការអភិវឌ្ឍកម្មវិធី ពិពណ៌នាវដ្តការធ្វើផែនការកម្មវិធី (រួមទាំងគំរូតក្កភាព) និងមានការយល់ដឹងច្បាស់អំពីគន្លឹះនានានៃវិធីសាស្ត្រធ្វើផែនការកម្មវិធី រួមទាំងវិធីសាស្ត្រ/បច្ចេកទេសនៃការធ្វើផែនការកម្មវិធីតាមបែបការចូលរួម។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ ការសិក្សាផ្តោតលើបញ្ហាមូលដ្ឋាន ការសិក្សាតាមរយៈការចូលរួមក្នុងបទឧទ្ទេស ការងារទីវាល ការពិភាក្សា សិក្ខាសាលា ការងារក្រុម បទបង្ហាញដោយសិស្ស ករណីសិក្សា យោបល់ត្រឡប់ ការផ្ទៀងផ្ទាត់ជាមួយដៃគូទៅវិញទៅមក ការអាន និង កំណត់ហេតុឆ្លុះបញ្ចាំងនឹងត្រូវបានប្រើប្រាស់។

**ប្រធានបទ៖**

- ការធ្វើផែនការកម្មវិធីនៅក្នុងការអភិវឌ្ឍកសិកម្ម
- ប្រភេទកម្មវិធីអប់រំ៖ កម្មវិធីអភិវឌ្ឍ ស្ថាប័ន ព័ត៌មាន
- វដ្តការធ្វើផែនការកម្មវិធី
- គំរូតក្កភាពកម្មវិធី
- វិធីសាស្ត្រនៃការអនុវត្តល្អសម្រាប់ការធ្វើផែនការកម្មវិធីតាមបែបការចូលរួម
    - ការអនុវត្តការវាយតម្លៃសេចក្តីត្រូវការ
    - ការចាត់អាទិភាពសេចក្តីត្រូវការ និងបញ្ហា
    - ការកំណត់រកភាគីពាក់ព័ន្ធ និងធ្វើឱ្យពួកគេចូលរួមក្នុងកម្មវិធីកសិកម្ម
    - ការទទួលបានធនធាន និងការចាត់ចែងធនធាន
    - ការអនុវត្តបច្ចេកទេសកំណត់បញ្ហា រកដំណោះស្រាយ និងសម្រេចចិត្ត
    - ការធ្វើលំហាត់បំផុសគំនិត
    - ការធ្វើកិច្ចពិភាក្សាក្រុមគោលដៅ
    - ការកំណត់រកឱកាសទីផ្សារ
    - ការវិភាគ និងការធ្វើផែនការសម្រាប់ការរួមបញ្ចូលយេនឌ័រ
    - ការរៀបចំផែនការការងារ
    - ការរៀបចំគម្រោងស្នើសុំថវិកាសម្រាប់ការផ្តល់មូលនិធិពីខាងក្រៅ។

**ការអនុវត្តជាក់ស្តែង៖**

- សិស្ស នឹងចុះទស្សនកិច្ចទៅកាន់សហគមន៍មូលដ្ឋាន វាយតម្លៃសេចក្តីត្រូវការសហគមន៍ អភិវឌ្ឍប្រូហ្វាល (profile)សហគមន៍ វាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយ ឧបសគ្គ និងឱកាស កំណត់រកធនធាន និងភាគីពាក់

ព័ន្ធនានា ចាត់អាទិភាពសេចក្តីត្រូវការ ប្រមែប្រមូលធាតុចូលរបស់ភាគីពាក់ព័ន្ធ និងអភិវឌ្ឍផែនការការងារដើម្បីអនុវត្តកម្មវិធីដែលពួកគេយល់ឃើញថា នឹងអាចឆ្លើយតបចំពោះសេចក្តីត្រូវការដែលបានកំណត់ឃើញ

- សរសេរកំណត់ហេតុឆ្លុះបញ្ចាំង ដោយគូសបញ្ជាក់អំពីការរៀនសូត្រដែលពួកគេបានទទួលពីការងារគម្រោង និងចែករំលែកការរៀនសូត្រទាំងនោះជាមួយមិត្តភក្តិរបស់ខ្លួនក្នុងអំឡុងកិច្ចពិភាក្សាក្នុងថ្នាក់រៀន។

## អំណានបន្ថែម៖


Baker, H. (1984). The Program Planning Process (pp 50-64), In Blackburn (Ed.), *Extension Handbook*. Ontario, Canada: University of Guelph.

Diehl, D. C., & Galindo-Gonzalez, S. (2014). *Planning or Refining an Extension Program*. Gainesville, FL: University of Florida.

Oakley, P., & Garforth, C. (1997). *Guide to Extension Training* (originally printed in 1985, reprinted in 1997). Rome, Italy: Food and Agriculture Organization of the United Nations. www.fao.org/docrep/t0060e/t0060e07.htm

Rietbergen-McCracken, J., & Narayan, D. (1997). *Participatory Tools and Techniques: A Resource Kit for Participation and Social Assessment*. Washington, D.C.: The World Bank. www.fao.org/ag/againfo/programmes/en/lead/toolbox/Refer/STkHold.htm

Rivera, W. M., Blum, M., & Sulaiman, R. (2009). ម៉ូឌុល4: Funding, Cost Recovery and Outsourcing. Rome, Italy: FAO. www.fao.org/nr/res/Course1/index.html.

Suvedi, M., & Kaplowitz, M. (2016). What Every Extension Workers Should Know? East Lansing, MI: UASID-MEAS. http://www.canr.msu.edu/csus/uploads/457/48841/MEAS-2016ExtensionHandbook.pdf

Swanson, B. E., & Rajalahti, R. (2010). Procedures for assessing, transforming, and evaluating extension systems: Agriculture and rural ការអភិវឌ្ឍ discussion paper 45. Washington, D.C., USA: The World Bank.

University of Wisconsin. (2014). *Logic Model*. Madison, WI: Program Development and Evaluation, University of Wisconsin. www.uwex.edu/ces/pdande/evaluation/evallogicmodel.html

## ម៉ូឌុល ៣.២៖ ការអនុវត្តកម្មវិធីផ្សព្វផ្សាយកសិកម្ម

**គោលបំណង៖** ធ្វើឱ្យសិស្សបានស្គាល់អំពីវិធីសាស្ត្រ និងបច្ចេកទេសផ្សេងៗ ដែលចាំបាច់សម្រាប់ការអនុវត្តកម្មវិធីកសិកម្មប្រកបដោយប្រសិទ្ធភាព។

**លទ្ធផលចុងក្រោយ៖** នៅចុងបញ្ចប់នៃវគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ កំណត់ និងវិភាគភាគីពាក់ព័ន្ធ យល់អំពីរបៀបដើម្បីធ្វើឱ្យមានការចូលរួមជាអតិបរមាពីអ្នកពាក់ព័ន្ធ ព្រមទាំងជ្រើសរើស និងប្រើប្រាស់វិធីសាស្ត្រការអនុវត្តល្អ (ឧ. ការធ្វើបទបង្ហាញ ការរៀបចំយុទ្ធនាការផ្សព្វផ្សាយកសិកម្ម ការសរសេរព័ត៌មាន និង របាយការណ៍ទីវាល ការរៀបចំសាលារៀនស្រែកសិករ។ល។) ដើម្បីអប់រំ ជម្រុញទឹកចិត្ត និងគៀងគរភាគីពាក់ព័ន្ធនៅលើការអភិវឌ្ឍកសិកម្ម។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ និងការឆ្លុះបញ្ចាំងតាមរយៈការចូលរួមក្នុងបទឧទ្ទេស ឧបករណ៍ជំនួយការស្តាប់ និងការមើល ការងារទីវាល ការពិភាក្សា សិក្ខាសាលា ការងារក្រុម បទបង្ហាញ ករណីសិក្សា យោបល់ត្រឡប់ ការផ្ទៀងផ្ទាត់ជាមួយដៃគូទៅវិញទៅមក ការអាន និង កំណត់ហេតុឆ្លុះបញ្ចាំងនឹងត្រូវបានប្រើប្រាស់។

**ប្រធានបទ៖**

- សេចក្តីផ្តើម៖ កំណត់និយមន័យភាគីពាក់ព័ន្ធ កំណត់រកនិងចាត់ប្រភេទភាគីពាក់ព័ន្ធ
- ធ្វើការវិភាគភាគីពាក់ព័ន្ធ ដោយប្រើដំណើរការបីជំហាន៖ ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធ ការចាត់អាទិភាពភាគីពាក់ព័ន្ធ (ពិចារណាលើអំណាច ការជះឥទ្ធិពល និងផលប្រយោជន៍របស់ពួកគេ) និងអភិវឌ្ឍការយល់ដឹងឱ្យបានល្អអំពីភាគីពាក់ព័ន្ធសំខាន់ជាងគេបំផុត (ឈ្នះ និងធ្វើការជាមួយពួកគេ)
- តើធ្វើយ៉ាងណាដើម្បីឱ្យភាគីពាក់ព័ន្ធសហគមន៍ចូលរួមជាអតិបរមា? http://webmedia.unmc.edu/Community/CityMatch/DataTraining/CommunityDimensionsofPractice/player.html
- ប្រើប្រាស់វិធីសាស្ត្រការអនុវត្តល្អក្នុងការផ្សព្វផ្សាយកសិកម្ម ដើម្បីអាចធ្វើការជាមួយភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព៖
    - ធ្វើទស្សនកិច្ចទៅកាន់កសិដ្ឋាន និងផ្ទះ
    - ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដឹកនាំសហគមន៍
    - រៀបចំយុទ្ធនាការផ្សព្វផ្សាយកសិកម្ម
    - សរសេរអត្ថបទកាសែត ឬប្រព័ន្ធផ្សព្វផ្សាយទ្រង់ទ្រាយធំ
    - ប្រើប្រាស់ព័ត៌មានវិទ្យា (ICTs)/ លទ្ធភាពទទួលបាន និងការប្រើប្រាស់ធនធាននៅតាមអ៊ីនធឺណិតឱ្យមានប្រយោជន៍
    - សរសេររបាយការណ៍ចុះមូលដ្ឋាន
    - ធ្វើការអនុវត្តបង្ហាញវិធីសាស្ត្រ និងលទ្ធផល
    - រៀបចំសាលារៀនស្រែកសិករ
    - រៀបចំទិវាវាលស្រែ
    - បង្កើតភូមិគំរូ
    - រៀបចំកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាព

- គ្រប់គ្រងជម្លោះ
- គ្រប់គ្រងពេលវេលា
- គ្រប់គ្រងក្រុម និងការធ្វើការងារជាក្រុម
- យល់ដឹងអំពីទំនាក់ទំនងនៅក្នុងក្រុម និង/ឬសម្របសម្រួលក្រុម
- ធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព។

**ការអនុវត្តជាក់ស្តែង៖**

សិស្សនឹងចុះទស្សនកិច្ចទៅកាន់អាជីវកម្មក្នុងមូលដ្ឋាន អង្គការមិនរកប្រាក់កម្រៃ ឬ អង្គការរដ្ឋាភិបាល ឬ ស្ថាប័នក្នុងវិស័យឯកជន និងរៀបចំប្រវត្តិរូបភាគីពាក់ព័ន្ធ ព្រមទាំងធ្វើការវិភាគភាគីពាក់ព័ន្ធ រួមទាំងបញ្ហានានាក្នុងការធ្វើការងាររួមជាមួយភាគីពាក់ព័ន្ធ និងស្នើឡើងនូវវិធានការដើម្បីឆ្លើយតបបញ្ហាទាំងនោះ។

**អំណានបន្ថែម៖**


Aker, J. C. (2011). Dial "A" for Agriculture: A Review of Information and Communication Technologies for Agricultural Extension in Developing Countries. *Agricultural Economics*, *42*(6), 631-647.

Barrick, K. (ed.). (2012). *Methods and Techniques for Effective Teaching in Extension and Advisory Services: A MEAS Training Module*. Urbana, IL: University of Illinois. www.meas-extension.org/meas-offers/training/methods-and-techniques-for-effective-teaching-in-extension-and-advisory-services

Bunch, R. (1995). *Two Ears of Corn*. Oklahoma City, OK: World Neighbors.

Calvert, P. (Ed.), *The Communicator's Handbook: Tools, Techniques and Technology*. Gainesville, FL: Maupin House.

Community Tool Box. (2017). http://ctb.ku.edu/en/table-of-contents

Lansdale, B. M. (2000). *Cultivating Inspired Leaders: Making Participatory Management Work*. West Hartford, CT: Kumarian Press.

Parker, G. M. (2009). *Teamwork: 20 Steps to Success*. Amherst, MS: HRD Press.

Suvedi, M., & Kaplowitz, M. (2016). What Every Extension Workers Should Know? East Lansing, MI: UASID-MEAS.http://www.canr.msu.edu/csus/uploads/457/48841/MEAS2016Extension Handbook.pdf

University of Oregon. (2015). *Time Management*. Eugene, OR: Holden Leadership Center, University of Oregon. http://leadership.uoregon.edu/resources/exercises_tips/skills/effective_time_management

## ម៉ូឌុល ៣.៣៖ ការតាមដាន និងវាយតម្លៃកម្មវិធី

**គោលបំណង**៖ ធ្វើឱ្យសិស្សមានសមត្ថភាព យល់ដឹងអំពីសារៈសំខាន់ ទ្រឹស្តី ការអនុវត្ត និងវិធីសាស្រ្តក្នុងការតាមដាន និងវាយតម្លៃកម្មវិធី (PME) និង អនុវត្តចំណេះដឹងទាំងអស់នេះ នៅក្នុងអាជីពនាពេលអនាគតរបស់ខ្លួន។

**លទ្ធផលចុងក្រោយ**៖ នៅចុងបញ្ចប់នៃវគ្គនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាថាតើ PME ជាអ្វី តើត្រូវធ្វើ PME ដោយរបៀបណា ហេតុអ្វីបានជាត្រូវធ្វើ PME និងពេលណាដែលត្រូវធ្វើ PME និងពន្យល់ ព្រមទាំងអនុវត្តវិធីសាស្រ្ត PME សម្រាប់ការអនុវត្តល្អជាទូទៅ ដូចជាការរៀបចំវិធីសាស្រ្តអង្កេតសម្រាប់វាយតម្លៃ ការប្រមូលទិន្នន័យ ការជ្រើសរើស និងការប្រើប្រាស់វិធីសាស្រ្តការប្រមូលទិន្នន័យសមស្រប ដូចជាការអង្កេតអ្នកចូលរួម អនុវត្ត RRA/PRA ធ្វើកិច្ចពិភាក្សាក្រុមគោលដៅ (FGD) ប្រមូល វិភាគ វាយតម្លៃទិន្នន័យ និងសរសេររបាយការណ៍វាយតម្លៃ។

**វិធីសាស្រ្តសិក្សា**៖ ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ ការរៀនសូត្របែបឆ្លុះបញ្ចាំងតាមរយៈការចូលរួមក្នុងបទឧទ្ទេស ការងារទីវាល ការពិភាក្សា សិក្ខាសាលា ការងារក្រុម បទបង្ហាញដោយសិស្ស ករណីសិក្សា យោបល់ត្រឡប់ ការផ្ទៀងផ្ទាត់ជាមួយដៃគូទៅវិញទៅមក ការអាន និង កំណត់ហេតុឆ្លុះ បញ្ចាំងនឹងត្រូវបានប្រើប្រាស់។

**ប្រធានបទ**៖

- ការវាយតម្លៃផ្តោតលើគោលបំណងជាមូលដ្ឋាននៃការវាយតម្លៃ ការប្រើប្រាស់និងភាពខុសប្លែកគ្នានៃគោលគំនិត
- ការវាយតម្លៃក្រៅផ្លូវការ និងការវាយតម្លៃជាផ្លូវការ
- ភាពខុសគ្នារវាងការវាយតម្លៃ និងការស្រាវជ្រាវ
- គោលបំណងនៃការវាយតម្លៃ
- តួនាទី និងសកម្មភាពរបស់អ្នកវាយតម្លៃអាជីព
- ប្រភេទនៃការវាយតម្លៃ៖ ការវាយតម្លៃដើម្បីសិក្សារៀនសូត្រ និងការវាយតម្លៃដើម្បីសង្ខេបឡើងវិញ ការវាយតម្លៃដំណើរការ និងលទ្ធផលរំពឹងទុក ការវាយតម្លៃផ្ទៃក្នុង និងការវាយតម្លៃពីខាងក្រៅ
- សារៈសំខាន់នៃការវាយតម្លៃ និងដែនកំណត់របស់ការវាយតម្លៃ
- បញ្ហាផ្នែកនយោបាយ អន្តរបុគ្គល និងផ្នែកសីលធម៌នៅក្នុងការវាយតម្លៃ
- វិធីសាស្រ្តជាជម្រើសជំនួសសម្រាប់ការវាយតម្លៃកម្មវិធី
- ជំនាញ និងវិធីសាស្រ្តតម្រង់ទិសអតិថិជន
- វិធីសាស្រ្តវាយតម្លៃ តម្រង់ទិសទៅរកគោលបំណងកម្មវិធី
- វិធីសាស្រ្តវាយតម្លៃ តម្រង់ទិសទៅរកសេចក្តីសម្រេចចិត្ត
- វិធីសាស្រ្តវាយតម្លៃ តម្រង់ទិសទៅរកការណែនាំអ្នកចូលរួម
- ការកំណត់អំពីពេលវេលាសមស្រប ដើម្បីធ្វើការវាយតម្លៃ៖ ការប៉ាន់ប្រមាណលើលទ្ធភាពអាចធ្វើការវាយតម្លៃបាន
- ការកំណត់រក និងការជ្រើសរើសសំណួរ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ
- ផែនការថាតើធ្វើការវាយតម្លៃយ៉ាងដូចម្តេច
- ការបង្កើតផែនការវាយតម្លៃ
- ការរៀបចំការវាយតម្លៃ

- វិធីសមស្របដើម្បីរាយការណ៍អំពីគំហើញពីការវាយតម្លៃ
- សេចក្តីណែនាំបែបអនុវត្តជាក់ស្តែងដើម្បីធ្វើ និងការប្រើប្រាស់ការវាយតម្លៃ
- ការរៀបចំការវាយតម្លៃ៖ វិធីសាស្ត្រ ការរៀបចំបែបពិពណ៌នា ករណីសិក្សា ការរៀបចំបែបឆ្លងវិស័យ ការរៀបចំកម្រងពេលវេលា ការរៀបចំបែបហេតុនិងផល ការរៀបចំបែបពិសោធន៍ ការរៀបចំបែបពាក់កណ្តាលពិសោធន៍ ការរៀបចំវិធីសាស្ត្របែប
- ការជ្រើសរើសសំណាក៖ ទំហំសំណាក ការជ្រើសរើសសំណាកដោយចៃដន្យ ការប្រើប្រាស់សំណាកដោយមានគោលបំណង
- ការវិភាគការប្រាក់ចំណេញ
- ប្រភព និងវិធីសាស្ត្រសាមញ្ញសម្រាប់ប្រមូលព័ត៌មាន
- ឯកសារ និងកំណត់ត្រាដែលមានស្រាប់
- ការកំណត់រកប្រភព និងវិធីសាស្ត្រសម្រាប់ការប្រមូលទិន្នន័យដើម៖ ការអង្កេត ការស្ទាបស្ទង់មតិ ការសម្ភាសន៍ ការពិភាក្សាក្រុមគោលដៅ
- ការវិភាគទិន្នន័យ និងការបកស្រាយគំហើញ
- ការរាយការណ៍លទ្ធផលការវាយតម្លៃ
- ការផ្តល់សារអវិជ្ជមាន
- សមាសធាតុសំខាន់ៗនៃរបាយការណ៍ជាលាយលក្ខណ៍អក្សរ។

**ការអនុវត្តជាក់ស្តែង៖**

សិស្ស នឹងធ្វើករណីសិក្សាការវាយតម្លៃដែលគ្របដណ្តប់លើវដ្តនៃការវាយតម្លៃទាំងមូលចាប់ពីការសិក្សាលទ្ធភាពអាចវាយតម្លៃបានរហូតដល់ការបង្កើតគោលគំនិតនិងការរៀបចំការវាយតម្លៃរហូតដល់ការរាយការណ៍អំពីគំហើញ ពីការវាយតម្លៃស្តីពីបញ្ហាពាក់ព័ន្ធជាមួយកសិកម្ម។

**អំណានបន្ថែម៖**


Bennett, C. F. (1979). *Analyzing Impacts of Extension Programs*. Washington, D.C.: U.S. Department of Agriculture.

Frechtling, J., Frierson, H., Hood, H., Hughes, G., & Katzenmeyer, C. (2002). *The User Friendly Handbook for Project Evaluation*. Washington, D.C.: National Science Foundation.

Khandker, S., Koolwal, G. B., & Samad, H. A. (2010). *Handbook on Impact Evaluation: Quantitative Methods and Practices*. Washington, D.C.: World Bank.

Kruger, R. A., & Casey, M. N. (2009). *Focus Groups: A Practical Guide for Applied Research* (5th ed.). Thousand Oaks, CA: Sage Publications.

Suvedi, M. (2011). *Evaluation of Agricultural Extension and Advisory Services: A MEAS Training Manual*.USAID/MEAS/MSU.www.meas-extension.org/measoffers/training/evaluatingextensionprograms

Suvedi, M., & Kaplowitz, M. (2016). *What Every Extension Workers Should Know?* East Lansing, MI: UASID-MEAS.

http://www.canr.msu.edu/csus/uploads/457/48841/MEAS-2016ExtensionHandbook.pdf

## ម៉ូឌុល ៣.៤៖ការគ្រប់គ្រងភាពជាអ្នកដឹកនាំ

**គោលបំណង៖** ជួយស្ថាបនាទំនាក់ទំនង និងបណ្តាញជាមួយភាគីពាក់ព័ន្ធនានា និងបណ្តុះកិច្ចសន្ទនា និងយោបល់ត្រឡប់ពីពួកគេ និងជួយអង្គភាព និងសហគមន៍ឱ្យកាន់តែមានភាពធន់ថែមទៀត។ ការងារនេះក៏ជួយលើកកម្ពស់សមត្ថភាពដោះស្រាយបញ្ហាសម្រាប់អ្នកដែលពាក់ព័ន្ធទាំងអស់ផងដែរ។

**លទ្ធផលចុងក្រោយ៖** បន្ទាប់ពីបញ្ចប់ការសិក្សាម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖

- កំណត់និយមន័យគោលគំនិត ទ្រឹស្តី និងប្រភេទនៃអ្នកដឹកនាំ
- ការបង្កើតជំនាញការសម្រេចចិត្តបែបការចូលរួម
- ការបង្កើតជំនាញសម្របសម្រួលប្រកបដោយប្រសិទ្ធភាព(ជំនាញដែលចាំបាច់ដើម្បីដំណើរការកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាព)
- យល់អំពីរបៀបដឹកនាំនៅក្នុងស្ថានភាពពិបាក/មានការប្រែប្រួល និងក្នុងចំណោមបុគ្គលិក ឬអតិថិជន ដែលមានលក្ខណៈគ្នា
- អនុវត្តជំនាញការគ្រប់គ្រងជម្លោះ ការចរចា និងកិច្ចសហការនៅក្នុងស្ថានភាពធ្វើការងារ។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ដោយប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចនៅទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម ការធ្វើបទបង្ហាញ លំហាត់ផ្ទាល់/លំហាត់ជាក្រុម ការសម្តែងតួ។

**ប្រធានបទ៖**

- និយមន័យ គោលគំនិត ទ្រឹស្តី ប្រភេទ និងបែបបទនៃភាពជាអ្នកដឹកនាំ
- ការយល់ដឹងអំពីការប្រើប្រាស់ខ្លឹមសារ ដំណើរការ និងជំនាញទំនាក់ទំនង
- ទ្រឹស្តីគ្រប់គ្រងការផ្លាស់ប្តូរ និងការដឹកនាំក្នុងពេលជួបការលំបាក
- ទ្រឹស្តី និងជំនាញការគ្រប់គ្រងជម្លោះ
- គណនេយ្យភាព៖ ធ្វើយ៉ាងណាដើម្បីឱ្យខ្លួនឯង និងអ្នកដទៃមានគណនេយ្យភាព
- ការគ្រប់គ្រងកិច្ចប្រជុំ
- ការយល់ដឹងអំពីក្រុម/ និងសមាជិករបស់ក្រុម
- ការប្រើប្រាស់អំណាច និងការត្រួតត្រានៅក្នុងភាពជាអ្នកដឹកនាំ
- ជំនាញក្នុងការសម្របសម្រួល
- ស្វ័យត្រួតពិនិត្យ ឬស្វ័យឆ្លុះបញ្ចាំងលើការងារភាពជាអ្នកដឹកនាំ
- ធ្វើការជាមួយអតិថិជន និងក្រុមដែលមានលក្ខណៈគ្នា
- របៀបប្រាស្រ័យទាក់ទងជាមួយសមាជិកក្រុម និងអតិថិជនប្រកបដោយប្រសិទ្ធភាព

**ការអនុវត្តជាក់ស្តែង៖**

- ទស្សនកិច្ចទៅកាន់ភូមិ ឬឃុំមូលដ្ឋាន មានអន្តរទំនាក់ទំនងជាមួយមេភូមិ ឬមេឃុំ និងអង្គបោះឆ្នោតរបស់ពួកគាត់ ព្រមទាំងកត់ត្រាជំនាញភាពជាអ្នកដឹកនាំរបស់ពួកគាត់ ចែករំលែកបទពិសោធន៍នៅក្នុងថ្នាក់រៀន
- ករណីសិក្សា៖ អភិវឌ្ឍការងារចុះមូលដ្ឋានជាក្រុម ចាត់តាំងជនណាម្នាក់ឱ្យធ្វើជាអ្នកដឹកនាំក្រុម សង្កេតរបៀបដែលគាត់ដឹកនាំក្រុម និង ឆ្លុះបញ្ចាំងលើចំណុចរៀនសូត្រដែលអ្នកទទួលបានពីលំហាត់នេះ។

**អំណានបន្ថែម៖**


Maxwell, J. C. (2005). *Developing the Leader within You*. Nashville, TN: Thomas Nelson, Inc.

Scheffert, D. R. (2007). Community leadership: What does it take to see results? *Journal of Leadership Education*, 6 (1), 175.

## ម៉ូឌុល ៣.៥៖ វិធីសាស្ត្រស្រាវជ្រាវ[13]

**គោលបំណង៖** ធ្វើឱ្យសិស្សមានចំណេះដឹង និងជំនាញអំពីការតាក់តែង និងការស្រាវជ្រាវជាលក្ខណៈប្រព័ន្ធ និងអនុវត្តចំណេះដឹង និងជំនាញទាំងអស់នេះសម្រាប់ការអភិវឌ្ឍកសិកម្ម។

**លទ្ធផលរំពឹងទុកនៃការរៀនសូត្រ៖** ក្រោយបញ្ចប់ការសិក្សាម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីសារៈសំខាន់នៃការស្រាវជ្រាវ និងចំណងទាក់ទងរវាងការស្រាវជ្រាវជាមួយការផ្សព្វផ្សាយកសិកម្មមកលើការអភិវឌ្ឍកសិកម្ម ការតាក់តែង និងការអនុវត្តការស្រាវជ្រាវ ការវិភាគទិន្នន័យ និងការបកស្រាយ ព្រមទាំងការបង្ហាញអំពីគំហើញពីការស្រាវជ្រាវដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសមស្រប។

**គោលវិធីនៃការរៀនសូត្រ៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ ការសិក្សាបែបពិសោធន៍ ដោយប្រើប្រាស់បទឧទ្ទេស ករណីសិក្សា ទស្សនកិច្ចនៅទីវាល សិក្ខាសាលា ការងារគម្រោង ការពិភាក្សាក្រុម ការធ្វើបទបង្ហាញ លំហាត់ផ្ទាល់/លំហាត់ជាក្រុម។

**ប្រធានបទ៖**

- តើការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្មមានចំណងទាក់ទងគ្នាដូចម្តេច និងមូលហេតុអ្វី
- សេចក្តីផ្តើម៖ អត្ថន័យនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវលើការអភិវឌ្ឍជាតិ ប្រភេទនៃការស្រាវជ្រាវ សីលធម៌ក្នុងការស្រាវជ្រាវ ជំហានក្នុងការអនុវត្តគម្រោងស្រាវជ្រាវសាមញ្ញ
- ការតាក់តែងការស្រាវជ្រាវ៖ ការជ្រើសរើសប្រធានបទ ការសរសេរសំណួរស្រាវជ្រាវ ការបញ្ជាក់សម្មតិកម្ម និង/ឬគោលបំណង ការរាយបញ្ជីប្រែប្រួល ដោយក្នុងនោះ រួមមានទាំងបញ្ជីប្រែប្រួល/បញ្ជីឯករាជ្យ
- ការស្រាវជ្រាវ និងការពិនិត្យឯកសារដែលមានស្រាប់៖ ហេតុអ្វី ដោយរបៀបណា ប្រភព ការពិនិត្យឡើងវិញលើសំណេរ ការដាក់ឯកសារពិគ្រោះ ការលួចស្នាដៃរបស់អ្នកដទៃ
- ប្រភេទនៃការស្រាវជ្រាវ៖ ការស្រាវជ្រាវបែបបរិមាណវិស័យ និងបែបគុណវិស័យ ការស្រាវជ្រាវបែបពិសោធន៍ និងការស្រាវជ្រាវបែបមិនមែនពិសោធន៍
- ការប្រមូលសំណាក៖ ការប្រមូលសំណាកដោយចោះៗ (សាមញ្ញ មានការចាត់ថ្នាក់) ការជ្រើសរើសសំណាកជាចង្កោម ការជ្រើសរើសសំណាកដោយមានគោលបំណង ការជ្រើសរើសសំណាកទៅតាមភាពងាយស្រួល
- វិធីសាស្ត្រប្រមូលទិន្នន័យ៖ ការស្ទាបស្ទង់មតិ សំបុត្រ ទូរសព្ទ ក្រុមគោលដៅ ការសម្ភាសន៍ការសង្កេត។ល។
- ការវិភាគទិន្នន័យ៖ បែបពិពណ៌នា ស្ថិតិបែបសន្និដ្ឋាន ការភ្ជាប់ទំនាក់ទំនង ការទាញភាពពាក់ព័ន្ធ
- ការធ្វើបទបង្ហាញទិន្នន័យ៖ ក្រាហ្វិច ដ្យាក្រាមរបារ ដ្យាក្រាមវ៉ែន តារាង ក្រាហ្វិចថាស។ល។
- ការសរសេរសំណើស្រាវជ្រាវ របាយការណ៍ស្រាវជ្រាវ និងសំណេរចុះក្នុងព្រឹត្តិប័ត្រ។

[13] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលចេញពីកម្មវិធីបង្រៀនរបស់ Lilongwe University of Agriculture and Natural Resources NRC Campus និងកម្មវិធីបង្រៀនសម្រាប់ឌីប្លូម៉ាផ្នែកកសិកម្ម (ឆ្នាំទី ៣) ២០១៥ នៅប្រទេសម៉ាឡាវី។*

**ការអនុវត្តជាក់ស្តែង៖**

- ការសរសេរសំណើស្រាវជ្រាវ
- ការវិភាគទិន្នន័យដោយប្រើប្រាស់ស្ថិតិបរិមាណវិស័យសាមញ្ញ
- ការរៀបចំសម្ភារៈ/វិធីសាស្ត្រប្រមូលទិន្នន័យ
- ការប្រមូល ការវិភាគទិន្នន័យពីមូលដ្ឋាន
- ការសរសេររាបយការណ៍ស្រាវជ្រាវ។

**អំណានបន្ថែម៖**


Edriss, A. K. (2003). *A Passport to Research Methods: Research Skills Building Approach*. Las Vegas, NV: International Publishers and Press.

European Commission. (2004). *AID Delivering Methods: Project Cycle Management Guidelines*. Brussels: EuropeAid.

Fraenkel. J. R., & Wallen, N. E. (2003). *How to Design and Evaluate Research in Education*. New York, NY: McGraw-Hill Higher Education.

International Service Centre for National Agricultural Research. (2003). *Monitoring, Evaluation and Impact Assessment of R&D Investments in Agriculture*. Learning ម៉ូឌុលCD. The Hague.

Laws. S., Harper. C., & Marcus. R. (2003). *Research for Development: A Practical Guide*. London: SAGE Publications.

## ម៉ូឌុល ៣.៦៖ ការគ្រប់គ្រងកសិធុរកិច្ចកសិកម្ម[14]

**គោលបំណង៖** ធ្វើឱ្យសិស្សបានដឹងអំពីចំណេះដឹងបែបទ្រឹស្តី ក៏ដូចជាបែបអនុវត្តស្តីពីទិដ្ឋភាពនានានៃការគ្រប់គ្រងកសិធុរកិច្ចកសិកម្ម និងធ្វើឱ្យពួកគេមានសមត្ថភាពអាចអនុវត្តចំណេះដឹងទាំងអស់នេះនៅក្នុងអាជីពអនាគតរបស់ខ្លួន។

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពបានទទួលសមត្ថភាពផ្នែកទ្រឹស្តី ក៏ដូចជាផ្នែកអនុវត្តផ្ទាល់ស្តីពីទិដ្ឋភាពនានានៃការគ្រប់គ្រងកសិធុរកិច្ចកសិកម្ម និងពន្យល់អំពីគោលការណ៍នៃការគ្រប់គ្រងកសិដ្ឋាន និង សេដ្ឋកិច្ចនៃផលិតកម្ម និង ធ្វើការវិភាគធនធានរបស់កសិដ្ឋាន។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ និងការសិក្សាបែបឆ្លុះបញ្ចាំងតាមរយៈការចូលរួមក្នុងបទឧទ្ទេសសោតទស្សន៍ ការងារទីវាល ការងារគម្រោង ការពិភាក្សា សិក្ខាសាលា ការងារក្រុម បទបង្ហាញ ករណីសិក្សា ការផ្ទៀងផ្ទាត់ជាមួយដៃគូទៅវិញទៅមក ការអាន និង កំណត់ហេតុឆ្លុះបញ្ចាំងនឹងត្រូវបានប្រើប្រាស់។

**ប្រធានបទ៖**

- គោលគំនិត និងនិយមន័យ និងវិសាលភាពនៃការគ្រប់គ្រងកសិធុរកិច្ចកសិកម្ម ក្នុងប្រទេសកម្ពុជា
- គោលគំនិតជាមូលដ្ឋាន និងនិយមន័យរបស់ក្រុមហ៊ុន រោងចក្រ ឧស្សាហកម្ម និងអន្តរទំនាក់ទំនងរបស់ពាក្យទាំងនេះ ពាក់ព័ន្ធជាមួយផលិតកម្មកសិកម្ម
- បរិស្ថានកសិធុរកិច្ចកសិកម្ម និងប្រព័ន្ធគ្រប់គ្រងក្នុងប្រទេសកម្ពុជា
- ការរៀបចំ និងមុខងារការគ្រប់គ្រងធុរកិច្ចកសិកម្ម និងការសម្រេចចិត្តផ្នែកការគ្រប់គ្រង
- ការគ្រប់គ្រងធនធានមនុស្សក្នុងអង្គភាព
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការវិភាគ និងការផ្គត់ផ្គង់ហិរញ្ញវត្ថុកសិធុរកិច្ចកសិកម្ម
- ការវាយតម្លៃការវិនិយោគតាមរយៈការប្រើប្រាស់វិធានការការបញ្ចុះតម្លៃ និងការវាយតម្លៃ
- ភាពជាអ្នកដឹកនាំ និងការជំរុញទឹកចិត្ត គោលការណ៍សេដ្ឋកិច្ចពាក់ព័ន្ធជាមួយការទទួលបានដើមទុន
- កម្មវិធីគ្រប់គ្រងកសិធុរកិច្ចកសិកម្ម និងការវាយតម្លៃ
- ការវិភាគប្រវាក់តម្លៃ៖ គោលគំនិត ការធ្វើផែនទី និងវិធីសាស្ត្រ
- ការធ្វើផែនការផលិតកម្មនៅក្នុងកសិធុរកិច្ចកសិកម្ម៖ ការធ្វើផែនការផលិតកម្ម ការគ្រប់គ្រងហានិភ័យ
- លទ្ធផលដែលកើតមាន និងឱកាសពាណិជ្ជកម្មអន្តរជាតិនៅក្នុងវិស័យកសិកម្មរបស់ប្រទេសកម្ពុជា
- គោលនយោបាយកសិកម្ម និងផលប៉ះពាល់មកលើសហគ្រាសកសិធុរកិច្ចកសិកម្ម ក្នុងប្រទេសកម្ពុជា។

**ការគ្រប់គ្រងកសិដ្ឋាន៖**

- គោលគំនិត លក្ខណសម្បត្តិ ប្រធានបទ និងវិសាលភាពនៃការគ្រប់គ្រងកសិដ្ឋាន
- សារៈសំខាន់នៃការគ្រប់គ្រងកសិដ្ឋាន និងបញ្ហានានាពាក់ព័ន្ធជាមួយការគ្រប់គ្រងកសិដ្ឋានក្នុងប្រទេសកម្ពុជា
- ការគ្រប់គ្រងធនធានកសិដ្ឋាន ដូចជាដី ពលកម្ម គ្រឿងចក្រ និងឧបករណ៍ និងសំណង់ស៊ីវិល
- ទំនាក់ទំនងផលិតកម្ម ដូចជាទំនាក់ទំនងកត្តាផលិតកម្ម

[14] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥។*

- ទំនាក់ទំនងកត្តាផលិតកម្ម និងបន្សំការចំណាយតិចតួចបំផុត
- ទំនាក់ទំនងរវាងផលិតផល និងផលិតផល និងគោលការណ៍ស្តីពីការប្រៀបធៀបគុណសម្បត្តិ
- គោលការណ៍ស្តីពីការសម្រេចចិត្តការគ្រប់គ្រងកសិដ្ឋាន សមាមាត្រការប្រែប្រួល កត្តាជំនួស គោលការណ៍តម្លៃចំណូលស្មើចំណេញ គោលការណ៍ការខាតបង់ឱកាស គោលការណ៍ការប្រៀបធៀបពេលវេលា និងការប្រៀបធៀបគុណសម្បត្តិ
- លក្ខណសម្បត្តិ និងបច្ចេកទេសក្នុងការធ្វើផែនការកសិដ្ឋាន
- ការធ្វើថវិកាកសិដ្ឋាន៖ ការធ្វើថវិកាដោយផ្នែកសម្រាប់សហគ្រាស និងថវិកាទាំងស្រុង
- ធ្វើបញ្ជីកសិដ្ឋាន ការបង់រំលោះ និងបច្ចេកទេសកំណត់តម្លៃ ទ្រព្យរបស់កសិដ្ឋាន
- ការរក្សាបញ្ជីកំណត់ត្រាកសិដ្ឋាន៖ របាយការណ៍សមតុល្យ របាយការណ៍ចំណូល និងរបាយការណ៍លំហូរសាច់ប្រាក់
- វិធានការប្រសិទ្ធផលកសិដ្ឋាន
- ហានិភ័យ និងភាពមិនប្រាកដប្រជា៖ គោលគំនិត ប្រភេទ ការការពារ និងវិធានការ
- ការធ្វើកម្មវិធីជាបន្ទាត់ត្រង់៖ គោលគំនិត និងវិធីសាស្ត្រ។

**ការអនុវត្តជាក់ស្តែង៖**

- ពិនិត្យឡើងវិញលើរចនាសម្ព័ន្ធអង្គការ និងរចនាសម្ព័ន្ធការគ្រប់គ្រងក្នុងកសិឧស្សាហកម្មផ្សេងៗក្នុងប្រទេសកម្ពុជា
- វាយតម្លៃលើការផ្គត់ផ្គង់ធៀបនឹងការចំណាយទំនិញកសិកម្មក្នុងកសិឧស្សាហកម្មផ្សេងៗ
- ការវិភាគចំណងទាក់ទងថយក្រោយ និងទៅមុខរបស់ផលិតផលកសិកម្មសំខាន់ៗ
- ការរៀបចំ និងការវិភាគលើរបាយការណ៍សមតុល្យ៖ ករណីសិក្សា
- ការរៀបចំ និងការវិភាគលើរបាយការណ៍ចំណេញ និងខាត៖ ករណីសិក្សា
- ការវិភាគលំហូរសាច់ប្រាក់របស់កសិឧស្សាហកម្ម
- ការវិភាគសមមាត្រ និងបច្ចេកទេសព្យាករណ៍
- ការវាយតម្លៃការវិនិយោគតាមរយៈវិធានការលំហូរសាច់ប្រាក់បញ្ចុះតម្លៃនៃតម្លៃរបស់គម្រោង
- ទស្សនកិច្ចទៅកាន់អង្គភាពកសិធុរកិច្ចកសិកម្ម៖ វិភាគបញ្ហា លទ្ធផលការងារ និងសក្តានុពល៖ ករណីសិក្សា
- ការធ្វើផែនការច្រវាក់តម្លៃនៃអនុវិស័យកសិកម្មសំខាន់ៗ
- ការវិភាគ SWOT ទៅលើអនុវិស័យកសិកម្មសំខាន់ៗ
- ការរៀបចំផែនការអាជីវកម្មសម្រាប់ក្រុមហ៊ុនកសិកម្ម
- ការកំណត់ការប្រើប្រាស់ធាតុចូលប្រសើរបំផុតនិងការបង្កើនចំណេញឱ្យបានជាអតិបរមាដោយប្រើប្រាស់ធាតុចូលមួយ
- បន្សំការចំណាយតិចបំផុតនៃធាតុចុល
- ការបង្កើនចំណូលជាអតិបរមាតាមរយៈបន្សំសហគ្រាសប្រសើរបំផុត
- ការរក្សាកំណត់ត្រាកសិដ្ឋាន
- ការរៀបចំបញ្ជីកសិដ្ឋាន

- ការរៀបចំផែនការកសិដ្ឋានថ្មី
- ការរៀបចំរបាយការណ៍សមតុល្យកសិដ្ឋាន
- ការរៀបចំរបាយការណ៍ចំណូលរបស់កសិដ្ឋាន
- ការបង្កើត លំហូរថវិកាសាច់ប្រាក់របស់កសិដ្ឋាន
- ការវាស់វែងប្រសិទ្ធផលរូបវន្តរបស់កសិដ្ឋាន
- ការវាស់វែងប្រសិទ្ធផលហិរញ្ញវត្ថុរបស់កសិដ្ឋាន
- ការគណនាការបង់រំលោះលើទ្រព្យរបស់កសិដ្ឋាន
- បច្ចេកទេសកំណត់តម្លៃទ្រព្យរបស់កសិដ្ឋាន
- លំហាត់ស្តីពីតម្លៃកើនឡើងតាមពេលវេលារបស់ប្រាក់
- លំហាត់ស្តីពីកម្មវិធីតាមបន្ទាត់ត្រង់។

## អំណានបន្ថែម៖


Downey, W. D., & Erickson, S. P. (1987). *Agribusiness Management*. McGraw Hill Inc.

Fae, A. N. (1981). *Crop Management Economics.* London, UK: Granada Publishing.

Johl, S. S., & Rhodes, V. J. (1983). *The Agricultural Marketing Systems*. Singapore: John, Wiley & Sons, Inc.

Gittinger, J. P. (1982). *Economic Analysis of Agricultural Projects* (2nd ed.) London, UK: The John Hopkins University Press.

Kapoor, T. R. (1973). *Fundamentals of Farm Business Management*. New Delhi, India: Kalyani Publishers.

Kay, R. D., & Edwards, W. M. (1994). *Farm Management.* New Delhi, India: McGraw Hill, Inc.

Manson, J. (1996). *Farm Management*. Pennsylvania State University, US: Kangaroo Press.

Panda, S. C. (2007). Farm Management and Agricultural Marketing. New Delhi, India: Kalyani Publishers.

Shankhyan, P. L. (1983). *Introduction to Farm Management*. New Delhi: India: Tata, McGraw-Hill, Co. Ltd.

## ម៉ូឌុល ៣.៧៖ ទីផ្សារ និងការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់

**គោលបំណង៖** ដើម្បីឱ្យសិស្សស្គាល់អំពីការគ្រប់គ្រង និង/ឬការពង្រឹងច្រវាក់ការផ្គត់ផ្គង់ (តម្លៃ) នៃទំនិញកសិកម្ម និងជាលទ្ធផលធ្វើឱ្យអាចកែលម្អផលិតកម្មកសិកម្ម និងផលិតភាពកសិកម្ម និងបានទទួលអត្ថប្រយោជន៍ពីកសិកម្ម។

**លទ្ធផលរំពឹងចុងក្រោយ៖** ក្រោយពីបញ្ចប់ការសិក្សាម៉ូឌុលនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីទស្សនាទាន ដំណើរការ អ្នកដើរតួនាទីសំខាន់ៗ និងកត្តានានាដែលជះឥទ្ធិពល និងវិធានការដើម្បីកែលម្អការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់ទំនិញកសិកម្មសំខាន់ៗ។

**វិធីសាស្រ្តសិក្សា៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ និងការសិក្សាបែបឆ្លុះបញ្ចាំងតាមរយៈការចូលរួមក្នុងបទឧទ្ទេស សម្ភារៈជំនួយការស្តាប់និងការមើល ការងារទីវាល ការពិភាក្សា សិក្ខាសាលា ការងារក្រុម បទបង្ហាញ ករណីសិក្សា ការផ្ទៀងផ្ទាត់ជាមួយដៃគូទៅវិញទៅមក ការអាន និង កំណត់ហេតុឆ្លុះបញ្ចាំងនឹងត្រូវបានប្រើប្រាស់។

**ប្រធានបទ៖**

- សេចក្តីផ្តើមអំពីសារៈសំខាន់ និងគោលគំនិត ស្តីពីការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់ (SCM)
- ការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់ ៖ ដំណើរការសំខាន់ៗ
- សមាសធាតុនៃ SCM
- ការគ្រប់គ្រងសេវាអតិថិជន
- ការគ្រប់គ្រងទំនាក់ទំនងអ្នកផ្គត់ផ្គង់
- ការបង្កើតផលិតផល និងការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម
- ការធ្វើផែនទីច្រវាក់ការផ្គត់ផ្គង់ទំនិញកសិកម្មសំខាន់ៗ ដូចជា អង្ករ ត្រី ទឹកដោះគោ ជ្រូក កៅស៊ូ  កាហ្វេ
- ការបង្កើត និងការអនុវត្តភាពជាដៃគូក្នុងច្រវាក់ការផ្គត់ផ្គង់
- ការវាស់វែងលទ្ធផលការងារនៃច្រវាក់ផ្គត់ផ្គង់
- កត្តាដែលជួយជ្រោមជ្រែង និងរារាំងដល់ការផ្គត់ផ្គង់ការគ្រប់គ្រងច្រវាក់ការផ្គត់ផ្គង់
- ការវាយតម្លៃ និងការស្រាវជ្រាវនាពេលបច្ចុប្បន្នទៅលើ SCM។

**ការអនុវត្តជាក់ស្តែង៖**

ករណីសិក្សាអំពីច្រវាក់ការផ្គត់ផ្គង់ទំនិញកសិកម្មសំខាន់ៗ។

### អំណានបន្ថែម៖


Chopra, S., & Meindl, P. (2010). *Supply Chain Management* (4th ed.). Prentice Hall.

Eskola, E. (2005). *Agricultural Marketing and Supply Chain Management in Tanzania: A Case Study* (Working Paper Series No. 16). http://www.tanzaniagateway.org/docs/agriculturalmarketingandsupplychainmanagementintanzania.pdf

NIAEM. (n.d.). Training Program on Supply Chain Management in Agriculture: Reading Material http://www.manage.gov.in/studymaterial/scm-E.pdf

**ម៉ូឌុល ៣.៨៖ ការគ្រប់គ្រងការិយាល័យ និងបុគ្គលិក**

**គោលបំណង៖** ធ្វើឱ្យសិស្សមានសមត្ថភាពក្នុង ការបម្រើការងារជាបុគ្គលិកទទួលបន្ទុកតាមរយៈការដំណើរការការិយាល័យរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព កៀងគរធនធានមនុស្សបានយ៉ាងត្រឹមត្រូវ និងបង្កើនទិន្នផលរបស់បុគ្គល និងរបស់អង្គភាពបានជាអតិបរមា។

**លទ្ធផលចុងក្រោយ ៖** ក្រោយពីបញ្ចប់ការសិក្សាវគ្គនេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីគោលគំនិតស្ដីពីធនធានមនុស្ស និងអនុវត្តដើម្បីអាចយកគោលគំនិតទាំងនេះ ទៅអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងអង្គភាពមួយ និងយកទ្រឹស្ដីការគ្រប់គ្រងការិយាល័យ និងបុគ្គលិកទៅអនុវត្តក្នុងការអនុវត្តផ្ទាល់ខ្លួនរបស់ពួកគេ។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាបែបសកម្ម (សិក្សាដោយខ្លួនឯង) ការសិក្សាបែបសហការ និង ការសិក្សាបែបឆ្លុះបញ្ចាំងតាមរយៈការចូលរួមក្នុងបទឧទ្ទេស ឧបករណ៍ជំនួយការស្ដាប់និងការមើលឃើញ ការងារទីវាល ការពិភាក្សា សិក្ខាសាលា ការងារក្រុម បទបង្ហាញ ករណីសិក្សា ការផ្ទៀងផ្ទាត់ជាមួយដៃគូទៅវិញទៅមក ការអាន និង កំណត់ហេតុឆ្លុះបញ្ចាំងនឹងត្រូវបានប្រើប្រាស់។

**ប្រធានបទ៖**

- តួនាទីថ្នាក់គ្រប់គ្រងនៅក្នុងកន្លែងធ្វើការ
- កម្រិត និងមុខងាររបស់ថ្នាក់គ្រប់គ្រង
- ការយកបច្ចេកទេសល្អៗទៅអនុវត្តក្នុងការជ្រើសរើស និងការអប់រំតម្រង់ទិសបុគ្គលិកការិយាល័យ
- បុព្វហេតុធំៗនៃបញ្ហាបុគ្គលិកក្នុងការិយាល័យដែលជះឥទ្ធិពលដល់សុខុមាលភាពរបស់បុគ្គលិកនិងវិធីដើម្បីអាចដោះស្រាយបញ្ហានេះបាន
- បច្ចេកទេសមើលការខុសត្រូវ និងជំរុញទឹកចិត្តល្អៗ
- សីលធម៌ការងារល្អ និងសុជីវធម៌អាជីវកម្ម
- ជំនាញដោះស្រាយបញ្ហា ដើម្បីគ្រប់គ្រងបញ្ហាដែលកើតមានក្នុងការិយាល័យ
- ការកំណត់ និងការយល់អំពីទំនាក់ទំនងក្រុម ឥទ្ធិពលនៃការងារជាក្រុម និងបញ្ហាជម្លោះ
- ការគ្រប់គ្រងការបណ្ដុះបណ្ដាល និងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈដទៃទៀត ដូចជាការកំណត់រកតម្រូវការក្នុងការបណ្ដុះបណ្ដាល ការរៀបចំការបណ្ដុះបណ្ដាល (ការបណ្ដុះបណ្ដាលរំឭកឡើងវិញ និងការបណ្ដុះបណ្ដាលដទៃទៀត)
- ការវិភាគ និងតួនាទីបុគ្គលិក៖ ការវិភាគតួនាទី និងការរៀបចំតួនាទី ការជំរុញទឹកចិត្តបុគ្គលិក និងការរក្សាបុគ្គលិកឱ្យគង់វង្ស
- ការប្រាស្រ័យទាក់ទងក្នុងចំណោមបុគ្គលិក និងការប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធនានា
- ការរៀបចំកិច្ចប្រជុំ
- ការវាយតម្លៃការអនុវត្តការងារ និងការពិនិត្យឡើងវិញ
- ការទទួលស្គាល់និយោជិត និងការផ្ដល់រង្វាន់
- ការបង្កើតបរិស្ថានការងារដែលមានសុវត្ថិភាព
- ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធនានា និងការប្រមូល និងកៀងគរធនធាន។

**ការអនុវត្តជាក់ស្តែង៖**

ទស្សនកិច្ចទៅកាន់អង្គភាពអាជីវកម្ម និង/ឬការិយាល័យមួយ ធ្វើសវនកម្ម ថាតើការិយាល័យ ឬអាជីវកម្មនោះដំណើរការយ៉ាងដូចម្តេច។

**អំណានបន្ថែម៖**

Odgers, P. (2005). *Administrative Office Management* (13th ed.). Maxwell.  ISBN: 978-0-538-72769-

## ម៉ូឌុលទី ៤៖ ម៉ូឌុលស្តីពី បច្ចេកទេសកសិកម្ម

### ម៉ូឌុល ៤.១៖ ផលិតកម្មដំណាំស្រូវ[15]

**គោលបំណង៖** ធ្វើឲ្យសិស្សបានទទួលចំណេះដឹងមូលដ្ឋាន និងជំនាញស្តីពីផលិតកម្មដំណាំស្រូវ។

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នាអំពីប្រព័ន្ធអេកូឡូស៊ីស្រូវពាក់ព័ន្ធជាមួយប្រទេសកម្ពុជា និងកន្លែងផ្សេងៗទៀត ពន្យល់អំពីការអនុវត្តក្បេត្រសាស្ត្រទំនើបសម្រាប់ផលិតកម្មដំណាំស្រូវ ពន្យល់អំពីឱកាស ការលំបាក និងស្ថានភាពការស្រាវជ្រាវនាពេលបច្ចុប្បន្នស្តីពីផលិតកម្មដំណាំស្រូវ ការប្រមូលផល ការបោកបែន ការរក្សាទុកគ្រាប់ស្រូវ និងចាប់ផ្តើមស្គាល់អំពីប្រព័ន្ធទីផ្សារស្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ក៏ដូចជាកម្រិតសាកល។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាបែបសហការ តាមរយៈការពិសោធន៍ អានសំណេរក្នុងសៀវភៅ/ឯកសារ ស្តាប់បទឧទ្ទេស ចូលរួមក្នុងការងារអនុវត្តន៍ផ្ទាល់និង/ឬការងារ មន្ទីពិសោធន៍ និងចុះទស្សនកិច្ចនៅទីវាល។

**ប្រធានបទ៖**

- សេចក្តីផ្តើម៖ សារសំខាន់ ប្រភពដើមកំណើត ការចែកចាយ តំបន់ ផលិតកម្ម និងផលិតភាពស្រូវក្នុងប្រទេសកម្ពុជា
- ប្រព័ន្ធអេកូឡូស៊ីស្រូវក្នុងប្រទេសកម្ពុជា៖ ដីទំនាបដាំដុះដោយទឹកភ្លៀង ដីតំបន់ខ្ពង់រាបដាំដុះដោយទឹកភ្លៀង តំបន់ដាំដុះទឹកជ្រៅ/ស្រូវបណ្តែញទឹក និងដីប្រើប្រព័ន្ធស្រោចស្រពក្នុងរដូវប្រាំង
- ការតម្រូវផ្នែកដី និងអាកាសធាតុ និងផលប៉ះពាល់មកលើផលិតកម្មស្រូវ
- រូបសាស្ត្រ ការលូតលាស់ និងការអភិវឌ្ឍរបស់ស្រូវពូជផ្សេងៗ
- ការបែងចែកចំណាត់ថ្នាក់នៃពូជស្រូវសំខាន់ៗ រួមទាំងពូជកូនកាត់ក្នុងប្រទេសកម្ពុជា
- ការរៀបចំដី និងបង្ហូរទឹកចូលស្រែសម្រាប់ផលិតកម្មស្រូវ
- ការរៀបចំថ្នាលសំណាប៖ សើម ស្ងួត ថ្នាលសំណាប និងថ្នាលសំណាបកែសម្រួល និងអត្រាគ្រាប់ពូជ ប្រព្រឹត្តកម្មគ្រាប់ពូជ និងការទុកចន្លោះ
- សារធាតុចិញ្ចឹមខនិជ និងការគ្រប់គ្រងជី អិនប៉េកា (N, P, K ) ស័ង្កសី ដែក និងជីជីវសាស្ត្រ ការគ្រប់គ្រងសារធាតុចិញ្ចឹម ជំហានដើម្បីបង្កើនប្រសិទ្ធភាពការប្រើប្រាស់ជីលើស្រូវ
- ការអនុវត្តការប្រើប្រាស់ និង ការគ្រប់គ្រងទឹក៖ ការតម្រូវរបស់ទឹក ដំណាក់កាលសំខាន់ៗ ការសម្អាតរុក្ខជាតិមិនចង់បាន និងការគ្រប់គ្រងស្មៅចង្រៃ៖ ការប្រជែងគ្នានៃដំណាំ និងស្មៅចង្រៃ គោលការណ៍ និងវិធីសាស្ត្រនៃការគ្រប់គ្រងស្មៅចង្រៃ
- ការវិនិច្ឆ័យការទុំរបស់ស្រូវ ការប្រមូលផល ការបោកបែន ការសម្អាត ការសម្ងួត និងការរក្សាទុកដាក់។
- ការរកទីផ្សារស្រូវ៖ នៅក្នុងមូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

**ការអនុវត្តជាក់ស្តែង៖**

- ការបង្កើតថ្នាលសំណាប
- ការសាបព្រួសស្រូវ

---

[15] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥។*

- ការសិក្សាអំពីដំណាក់កាលលូតលាស់របស់ស្រូវ
- ការហ្វឹកហាត់លំហាត់គណនាលេខសម្រាប់តម្រូវការជី និងថ្នាំពុលកសិកម្មសម្រាប់ដំណាំស្រូវ
- ការដាក់ជីសម្រាប់ស្រូវ
- ការវិនិច្ឆ័យភាពទុំរបស់ដំណាំស្រូវ
- ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងស្មៅចង្រៃសំខាន់ៗ
- ការប៉ាន់ប្រមាណទិន្នផល និងការប្រមូលផលស្រូវ
- ការសិក្សាអំពីវង្វាស់ជីវៈរបស់រុក្ខជាតិសម្រាប់ដំណាំធញ្ញជាតិ
- ទស្សនកិច្ច និងការសិក្សាលើការស្រាវជ្រាវផ្សេងៗធ្វើឡើងនៅទីតាំងស្រាវជ្រាវ។

## អំណានបន្ថែម៖


Dutta, S. K. (1981). *Principles and Practices of Rice Production*. New York, NY: John Wiley and Sons.

Fageria, N. K., Baligar, V. C., & Jones, C. A. (1990). *Growth and Mineral Nutrition of Field Crops*. New York, NY: Marcel Dekker, Inc.

Pal, M., Jayanta, D., & Rai, R. K. (1996). *Fundamentals of Cereal Crop Production*. New Delhi, India: Tata McGraw-Hill Publishing Co. Ltd.

Martin, J. H., Leonard, W. H., & Stamp, D. L. (1976). *Principles of Field Crop Production* (3rd ed.). New York, NY: Macmillan Publishing Co. Inc.

Singh, C. (2001). *Modern Techniques of Raising Field Crops*. Oxford and IBH Pub. Co. Pvt. Ltd. New Delhi, India: New Delhi.

## ម៉ូឌុល ៤.២ ៖ ផលិតកម្មគ្រាប់ពូជ[16]

**គោលបំណង៖** ធ្វើឲ្យសិស្សបានស្គាល់អំពីបច្ចេកវិទ្យាផលិតកម្មគ្រាប់ពូជ និងការអនុវត្តផលិតកម្មគ្រាប់ពូជសម្រាប់ផ្លែឈើ និងគ្រាប់ធញ្ញជាតិសំខាន់ៗ

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាព អាចពិពណ៌នាអំពីផ្លែឈើ គ្រាប់ធញ្ញជាតិ គ្រាប់ពូជ និងសម្ភារៈគ្រាប់ពូជ បានស្គាល់អំពីកត្តានានាដែលជះឥទ្ធិពលលើផលិតកម្មគ្រាប់ពូជ និងបច្ចេកវិទ្យា និងការអនុវត្តផ្នែកផលិតកម្ម ការប្រមូលផលពូជ ការសម្អាត ការស្តុកទុកដាក់ ការចេញវិញ្ញាបនបត្របញ្ជាក់ ព្រមទាំងការធ្វើទីផ្សារ រួមជាមួយក្របខ័ណ្ឌការងារផ្នែកនិយ័តកម្មនៅថ្នាក់ជាតិ និងអន្តរជាតិស្តីពីផលិតកម្មគ្រាប់ពូជ និងការចែកចាយគ្រាប់ពូជ។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីមិត្តភក្តិ និងការសិក្សាបែបពិសោធន៍តាមរយៈការសិក្សាដោយខ្លួនឯង បទឧទ្ទេស ការអនុវត្តជាក់ស្តែង គម្រោងទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលស្រាវជ្រាវ/កសិដ្ឋាន ការងារជាក្រុម សិក្ខាសាលា។ល។

**ប្រធានបទ៖**

- ផ្លែឈើ គ្រាប់ធញ្ញជាតិ គ្រាប់ពូជ និងសម្ភារៈគ្រាប់ពូជ
- ការកកើត និងការអភិវឌ្ឍរបស់គ្រាប់ពូជ កត្តានានាដែលជះឥទ្ធិលើការអភិវឌ្ឍគ្រាប់ពូជ
- ដំណាក់កាលផ្អាកការលូតលាស់របស់គ្រាប់ពូជ និងវិធីសាស្ត្រដើម្បីបំបែកដំណាក់កាលនេះ ដំណុះគ្រាប់ពូជ និងទម្រង់នៃដំណុះ
- កម្លាំងគ្រាប់ពូជ និងតួនាទីរបស់គ្រាប់ពូជក្នុងការបង្កើតដំណាំ
- គុណភាពគ្រាប់ពូជ និងកត្តានានាដែលជះឥទ្ធិពលលើគុណភាពគ្រាប់ពូជ
- ប្រភេទគ្រាប់ពូជ និងផលិតកម្មគ្រាប់ពូជ
- ភាពយឺនយូរនៃអាយុគ្រាប់ពូជ និងបុព្វហេតុនៃការខូចខាតគ្រាប់ពូជ
- ការប្រមូលផល និងការបោកបែន
- ការសម្អាតគ្រាប់ពូជ ការសម្ងួត និងការស្តុកទុកដាក់
- គោលការណ៍មូលដ្ឋាននៃផលិតកម្មគ្រាប់ពូជ
- ការចេញវិញ្ញាបនបត្របញ្ជាក់គ្រាប់ពូជ និងប្រព័ន្ធចែកចាយគ្រាប់ពូជក្នុងប្រទេសកម្ពុជា
- សមាគមធ្វើតេស្តគ្រាប់ពូជអន្តរជាតិ និងច្បាប់ជាតិស្តីពីគ្រាប់ពូជ។

**ការអនុវត្តជាក់ស្តែង៖**

- ការកំណត់អត្តសញ្ញាណគ្រាប់ពូជដំណាំទីវាលផ្សេងៗ
- ការវាស់វែងលក្ខណៈសម្បត្តិផ្នែកក្សេត្រសាស្ត្ររបស់គ្រាប់ពូជដំណាំ
- ការសិក្សាអំពីភាពខុសគ្នានៃលក្ខណសម្បត្តិផ្នែកក្សេត្រសាស្ត្ររបស់ពូជស្រូវផ្សេងៗ ពោត ស្រូវសាឡី ពពួកសណ្តែកគ្រាប់ គ្រាប់រុក្ខជាតិផ្តល់ប្រេង ដំឡូង និងដំណាំដទៃទៀត

---

[16] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥។*

- ការអនុវត្តធ្វើតេស្តភាពសុទ្ធនៃពូជ
- ការអនុវត្តការធ្វើតេស្តលទ្ធភាពអាចដុះមានជីវិតរបស់គ្រាប់ពូជ
- ការហ្វឹកហាត់អំពីការធ្វើតេស្តដំណុះគ្រាប់ពូជនៅក្នុងមន្ទីរពិសោធន៍ និងក្នុងទីវាល
- ការអនុវត្តការធ្វើតេស្តកម្លាំងគ្រាប់ពូជ
- ការរៀបចំវិធីសាស្ត្ររបស់គ្រាប់ពូជសម្រាប់ដាំដុះ
- ទស្សនកិច្ចទៅកាន់រោងចក្រកែច្នៃគ្រាប់ពូជ និងមន្ទីរពិសោធន៍ធ្វើតេស្តគ្រាប់ពូជ
- ទស្សនកិច្ចទៅកាន់កសិដ្ឋានពង្រីកគ្រាប់ពូជ និងមជ្ឈមណ្ឌលស្រាវជ្រាវ។

**អំណានបន្ថែម៖**

Agrawal, R. L. (2005). *Seed Technology*. New Delhi: Oxford and IBH Publishing Co. Pvt. Ltd.

Bhattachan, B. K. (2010). *Manual of Principles and Practices of Seed Technology*.

Bhattachan, B. K. (2011). *Research Manual of Seed Technology*. Mrs. Lekha (Chhetri) Bhattachan.

Copeland, L. O., & McDonald, M. B. (1985). *Principles of Seed Science and Technology*. Minnesota: Burgress publishing Company.

Justice, O. L., & Louis, N. B. (1978). *Principles and Practices of Seed Storage*. Agric. Hand Book No 506

## ម៉ូឌុល ៤.៣ ៖ វិធានការចម្រុះការពារដំណាំ[17]

**គោលបំណង៖** ធ្វើឲ្យសិស្សបានស្គាល់ទ្រឹស្តី និងការអនុវត្តស្តីពីវិធានការចម្រុះការពារដំណាំ (IPM)
**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច ពិពណ៌នាគោលការជាមូលដ្ឋាន និងការអនុវត្តស្តីពីវិធានការចម្រុះការពារដំណាំ រួមទាំងគោលវិធី និងវិធីសាស្រ្តផ្សេងៗនៃវិធានការចម្រុះការពារដំណាំ បទបញ្ញត្តិច្បាប់ស្តីពីវិធានការចម្រុះការពារដំណាំ អនុវត្តសាលារៀនស្រែកសិករពី វិធានការចម្រុះការពារដំណាំ។ល។
**វិធីសាស្រ្តសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីមិត្តភក្តិ និងការសិក្សាបែបពិសោធន៍តាមរយៈការសិក្សា ដោយខ្លួនឯង បទឧទ្ទេស ការអនុវត្តជាក់ស្តែង ការងារគម្រោង ទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលស្រាវជ្រាវ/កសិដ្ឋាន មន្ទីពិសោធន៍ និងការងារនៅទីវាល សិក្ខាសាលា ការចូលរួមក្នុងសាលារៀនស្រែកសិករ ។ល។
**ប្រធានបទ៖**

- សត្វល្អិតចង្រៃរបស់ដំណាំ និងការគ្រប់គ្រងសត្វល្អិតចង្រៃ ៖ សត្វល្អិតចង្រៃ គោលគំនិតស្តីពីសត្វល្អិតចង្រៃ ការចាត់ប្រភេទសត្វល្អិតផ្អែកទៅតាមមូលដ្ឋានផ្សេងៗ ផលប៉ះពាល់ជាទូទៅរបស់សត្វល្អិតចង្រៃ សត្វល្អិតចង្រៃផ្នែកកសិកម្មដែលច្រើនកើតមាន
- ការគ្រប់គ្រងសត្វល្អិតចង្រៃ ៖ គោលគំនិតស្តីពីការគ្រប់គ្រង បច្ចេកទេសទាក់ទងនឹងវិធានការចម្រុះការពារដំណាំ ការគ្រប់គ្រងសត្វល្អិតចង្រៃ វិធានការចម្រុះការពារដំណាំ ការគ្រប់គ្រងសត្វល្អិតចង្រៃដោយប្រើសរីរាង្គ
- ប្រវត្តិ ទិដ្ឋភាពផ្នែកប្រវត្តិសាស្រ្តនៃការការពារដំណាំ ទិដ្ឋភាពផ្នែកប្រវត្តិសាស្រ្តនៃវិធានការចម្រុះការពារដំណាំ ក្នុងពិភពលោក ប្រវត្តិការអភិវឌ្ឍវិធានការចម្រុះការពារដំណាំ ក្នុងប្រទេសកម្ពុជា
- គោលគំនិត ជាមូលដ្ឋាននៃយុទ្ធវិធី និងយុទ្ធសាស្រ្តវិធានការចម្រុះការពារដំណាំ
- យុទ្ធវិធីវិធានការចម្រុះការពារដំណាំ ៖ ការទាញប្រយោជន៍ពីកត្តាចង្រៃ ការទាញប្រយោជន៍ពីរុក្ខជាតិ ការទាញប្រយោជន៍ពីបរិស្ថាន
- គោលគំនិត ស្តីពីកម្រិតការសម្រេចចិត្ត និង ការកត់សម្គាល់សម្រាប់ការវាយតម្លៃនៅកម្រិតចាប់ផ្តើម
- វិធីសាស្រ្ត វាយតម្លៃកម្រិតការសម្រេចចិត្ត៖ ការពិនិត្យតាមដាន ការស្ទាបស្ទង់មតិ និងការឃ្លាំមើល
- គោលគំនិត ស្តីពីការវាយតម្លៃនៅកម្រិតចាប់ផ្តើម សម្រាប់វាយតម្លៃកម្រិតធ្វើសេចក្តីសម្រេចចិត្តនៃការគ្រប់គ្រងសត្វល្អិតចង្រៃ
- ភាពគួរជាទីកត់សម្គាល់នៃកម្រិតធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ
- វិធីសាស្រ្តបែបការដាំ ៖ គោលការណ៍ និងការអនុវត្តជាសាមញ្ញនៃវិធីសាស្រ្តបែបការដាំ និងភាពគួរជាទីកត់សម្គាល់ក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ
- វិធីសាស្រ្តមេកានិច៖ គោលការណ៍ និងការអនុវត្តការគ្រប់គ្រងសត្វល្អិតចង្រៃបែបមេកានិច និងភាពគួរជាទីកត់សម្គាល់ក្នុងការគ្រប់គ្រប់គ្រងសត្វល្អិតចង្រៃ
- វិធីសាស្រ្តរូបវិទ្យា៖ គោលការណ៍ និងការអនុវត្តវិធីសាស្រ្តរូបវិទ្យាក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ និងភាពគួរជាទីកត់សម្គាល់នៅក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ

[17] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥។*

- វិធីសាស្ត្របែបច្បាប់៖ គោលគំនិតជាមូលដ្ឋានស្តីពីគោលវិធីបែបច្បាប់តាមរយៈចត្តាឡីស័ក្តិរបស់ប្រទេសកម្ពុជា និងតួនាទីរបស់ចត្តាឡីស័ក្តិក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ កាលវិភាគហានិភ័យសត្វល្អិតចង្រៃ និងភាពគួរជាទីកត់សម្គាល់នៅក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ គោលនយោបាយជាតិ និងអន្តរជាតិស្តីពីវិធានការចម្រុះការពារដំណាំ
- វិធីសាស្ត្របែបជីវសាស្ត្រក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ៖ គោលគំនិតប្រភេទនៃសរីរៈជីវសាស្ត្រ និងប្រវត្តិសង្ខេបលើផ្នែកជីវសាស្ត្រក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ ប្រភេទថ្នាំពុលជីវសាស្ត្រ និងតួនាទីរបស់ប្រភេទថ្នាំពុលកសិកម្មជីវសាស្ត្រនៅក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ
- ភាពស៊ាំរបស់រុក្ខជាតិជាអ្នកទទួល (HPR)៖ គោលគំនិតជាមូលដ្ឋាន ប្រវត្តិ និងភាពគួរជាទីកត់សម្គាល់ក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ យន្តការ និងបច្ចេកទេសវាស់វែង HPR បច្ចេកទេសវិស្វកម្ម សេនេទិច និងភាពគួរជាទុកត់សម្គាល់នៅក្នុងវិធានការចម្រុះការពារដំណាំ
- ការគ្រងគ្រងសត្វល្អិតចង្រៃបែបគីមីសាស្ត្រ៖ ប្រភេទ ចំណាត់ប្រភេទ ការបង្កើតកម្រិតគ្រោះថ្នាក់ និងអនុសញ្ញាអន្តរជាតិទាក់ទងជាមួយថ្នាំពុលកសិកម្ម ការបាញ់ថ្នាំពុលកសិកម្ម បច្ចេកទេសក្នុងការបាញ់ការប៉ះពាល់ជាមួយថ្នាំពុលកសិកម្ម កម្រិតសំណល់ និងរង្វាស់កម្រិតសំណល់របស់ថ្នាំពុលកសិកម្ម ការបំពុលបង្កឡើងដោយថ្នាំពុលកសិកម្មវិស័យនៃការប្រើប្រាស់បំពាន និងវិធានការប្រុងប្រយ័ត្ន
- វិធីសាស្ត្រគ្រប់គ្រងបែបបង្កើតថ្មី និងករាប្រើប្រាស់របស់វិធីទាំងនេះក្នុងវិធានការចម្រុះការពារដំណាំ
- វិធីសាស្ត្រ វិធានការចម្រុះការពារដំណាំសាមញ្ញដែលមានក្នុងប្រទេសកម្ពុជា និងលទ្ធភាពក្នុងការដាក់បញ្ចូលទៅក្នុងការគ្រប់គ្រងសត្វល្អិតចង្រៃ
- គោលគំនិត ស្តីពីគំរូការផ្សព្វផ្សាយវិធានការចម្រុះការពារដំណាំ តាមរយៈសាលារៀនស្រែកសិករ
- យុទ្ធសាស្ត្រគ្រប់គ្រងទីផ្សារដែលអាចមានសម្រាប់ផលិតផល មានវិធានការចម្រុះការពារដំណាំ។

**ការអនុវត្តជាក់ស្តែង៖**

- ធ្វើឲ្យយល់ច្បាស់អំពីឧបករណ៍វិធានការចម្រុះការពារដំណាំដែលមានក្នុងមន្ទីរពិសោធន៍បាណកសាស្ត្រ
- ការកំណត់អត្តសញ្ញាណសត្វចង្រៃដែលបឺតជញ្ជក់ជីជាតិពីគេ និងប៉ារាសិតដែលច្រើនមាននៅក្នុងមន្ទីរពិសោធន៍បាណកសាស្ត្រ
- ការពិនិត្យតាមដានជាប្រចាំទៅលើកត្តាចង្រៃសាមញ្ញតាមរយៈអន្ទាក់ហ្វេរ៉ូម៉ូន ការពិនិត្យតាមដានសត្វរុយ តាមរយៈអន្ទាក់ទាក់ចាប់
- ការត្រៀមរៀបចំថ្នាំសម្លាប់សត្វល្អិតជីវសាស្ត្ររុក្ខសាស្ត្រ និងបច្ចេកទេសបាញ់ថ្នាំទាំងនោះ
- រូបមន្តថ្នាំពុលគីមីកសិកម្ម និងបច្ចេកទេសបាញ់នៅក្នុងទីវាល
- ការកំណត់អត្តសញ្ញាណ និងការប្រមូលសម្ភារៈរុក្ខសាស្ត្របណ្តេញសត្វល្អិតដែលមានក្នុងមូលដ្ឋាន
- ការប្រមូល និងការកំណត់អត្តសញ្ញាណកត្តាចង្រៃ ជម្ងឺ រុក្ខជាតិមិនចង់បាន និងសត្រូវពីធម្មជាតិ(NEs) របស់ដំណាំផ្សេងៗ
- ការស្ទាបស្ទង់មតិអំពីថ្នាំពុលគីមីក្នុងទីផ្សារ និងការចាត់ប្រភេទថ្នាំពុលទាំងនោះ៖ **ករណីសិក្សា**
- ការវាយតម្លៃលើលក្ខណៈសម្បត្តិ ភាពស៊ាំផ្នែករូបសាស្ត្រនៃដំណាំមួយចំនួនចំពោះសត្វល្អិតចង្រៃ

- បច្ចេកទេសវិភាគប៉ាន់ប្រមាណប្រសិទ្ធភាព (Bioassay) នៃថ្នាំពុលកសិកម្ម និងថ្នាំពុលកសិកម្មជីវសាស្ត្រប្រឆាំងសត្វល្អិតចង្រៃសាមញ្ញៗ
- ការណែនាំអំពីថ្នាំពុលជីវសាស្ត្រដែលមានក្នុងទីផ្សារ និង តាមការស្គាល់បច្ចេកទេសផលិតកម្មនៃ Heli-NPV
- ការចិញ្ចឹម Corcyra សម្រាប់ផលិតកម្ម Trichogramma និង បច្ចេកទេសលែងទៅក្នុងវាលពោត
- សួនសត្វល្អិត និងការសិក្សា cup និងសារៈសំខាន់របស់វា
- ការញែក EPF ចេញពីដី និងការសិក្សាមន្ទីរពិសោធន៍លើថ្នាំពុលកសិកម្មដោយផ្តោតការ យកចិត្តទុកដាក់លើ Metarhizium ។

## អំណានបន្ថែម៖


Dhaliwal, G. S., & Arora, R. (2001). *Integrated Pest Management- Concepts and Approaches*. New Delhi, India: Kalyani Publishers.

FAO. (2000). *Cabbage Integrated Pest Management: An Ecological Guide*. *FAO Inter-Country Program for The Development and Application of Integrated Pest Management in Vegetable Growing in South and Southeast Asia 125p.*

Norris. R. F., & C-Chen, E. P., & Kogan, M. (2002). *Concepts in Integrated Pest Management.* New Delhi, India: Prentice-Hall of India Pvt. Ltd.

## ម៉ូឌុល ៤.៤៖ ផលិតកម្មការចិញ្ចឹមជ្រូក[18]

**គោលបំណង៖** ធ្វើឱ្យសិស្សរៀនអំពីរបៀបចិញ្ចឹមជ្រូក។

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់ម៉ូឌុលសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពន្យល់អំពីសារៈសំខាន់ ពូជ ការឱ្យចំណី ជម្ងឺជ្រូកសំខាន់ៗ ការអនុវត្តក្នុងការគ្រប់គ្រងជ្រូក។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីមិត្តភក្តិ និងការសិក្សាបែបពិសោធន៍តាមរយៈការសិក្សាដោយខ្លួនឯង បទឧទ្ទេស ការអនុវត្តជាក់ស្តែង គម្រោង ទស្សនកិច្ចទៅកាន់កសិដ្ឋានចិញ្ចឹមជ្រូក ការងារជាក្រុម សិក្ខាសាលា ។ល។

**ប្រធានបទ៖**

- ផលិតកម្មជ្រូក៖ ប្រវត្តិ សារៈសំខាន់ ការតម្រូវជាមូលដ្ឋានដើម្បីចាប់ផ្តើមកសិដ្ឋានជ្រូក
- ពូជជ្រូក៖ ពូជដែលបានកែលម្អ ពូជក្នុងស្រុក
- ការផ្តល់ចំណីជ្រូក/អាហារូបត្ថម្ភជ្រូក ការតម្រូវផ្នែកអាហារូបត្ថម្ភសម្រាប់ជ្រូកក្នុងក្រុមអាយុផ្សេងៗគ្នា (ឧ. កូនជ្រូក ជ្រូកសាច់ មេជ្រូក ជ្រូកបា)
- ការចាត់ចែងជ្រូក ការរៀបចំកន្លែងជ្រូក និងអនាម័យកូនជ្រូក
- ពូជសត្វជ្រូក៖ ការជ្រើសរើសមេជ្រូក ជ្រូកបា កូនជ្រូក
- ការគ្រប់គ្រងកូនជ្រូក មេជ្រូក និងជ្រូកបា
- ការគ្រៀវកូនជ្រូក
- ជម្ងឺបង្កដោយបាក់តេរី វីរុស ប៉ារាសិត និងអាហារូបត្ថម្ភសំខាន់ៗ ព្រមទាំងវិធីបង្ការ និងគ្រប់គ្រងជម្ងឺទាំងនោះ
- សុខភាព៖ ប៉ារ៉ាម៉ែត្រផ្នែករាងកាយរបស់ជ្រូក ការចាក់ថ្នាំបង្ការជ្រូក/កូនជ្រូក
- ជីវសន្តិសុខនៅក្នុងផលិតកម្មជ្រូក
- ការធ្វើទីផ្សារជ្រូក និងផលិតផលជ្រូក
- ការរៀបចំផែនការអាជីវកម្មសម្រាប់កសិដ្ឋានជ្រូក/ផលិតកម្មជ្រូក។

**ការអនុវត្តជាក់ស្តែង៖**

- ការកំណត់អត្តសញ្ញាណពូជជ្រូកផ្សេងៗ
- ការចាត់ចែងជ្រូក និងកូនជ្រូក
- ការកត់ត្រាជីពចរ សីតុណ្ហភាព ចង្វាក់ដង្ហើមរបស់ជ្រូក
- ការត្រួតពិនិត្យផ្នែករាងកាយរបស់ជ្រូក៖ ការពិនិត្យជ្រូកដើម្បីរកសភាពមានសុខភាពល្អ
- ការទស្សនកិច្ចទៅកាន់កសិដ្ឋានជ្រូក និងសង្កេតការអនុវត្តក្នុងការគ្រប់គ្រងជ្រូក
- ការរៀបចំកន្លែង និងការឱ្យចំណីជ្រូក
- ការកំណត់អត្តសញ្ញាណ (ការដាក់ស្លាកសញ្ញាសម្គាល់ និងសញ្ញាសម្គាល់នៅត្រចៀក) របស់ជ្រូក
- ការគ្រៀវជ្រូក ការដាក់កន្លុះ និងការចាក់ថ្នាំបង្ការសត្វជ្រូក

[18] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥។*

- ការរៀបចំផែនការអាជីវកម្មសម្រាប់កសិដ្ឋានជ្រូក។

**អំណានបន្ថែម៖**

Banerjee, G. C. (1991). *A Text Book of Animal Husbandry.* New Delhi, India: Oxford and IBH Publishing.

Swine Publications. (2017). https://animalscience.tamu.edu/livestock-species/swine/publications/

## ម៉ូឌុល ៤.៥៖ ផលិតកម្មទឹកដោះ និងសាច់គោ[19]

**គោលបំណង៖** បំពាក់ចំណេះដឹង និងជំនាញឱ្យសិស្សអំពីផលិតកម្មទឹកដោះ និងសាច់គោ និងកែលម្អផលិតកម្មបសុសត្វ និងផលិតភាពក្នុងប្រទេសកម្ពុជា

**លទ្ធផលចុងក្រោយ៖** ពេលបញ្ចប់ម៉ូឌុលសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពន្យល់អំពីគោលការណ៍ផលិតកម្មទឹកដោះ និងសាច់គោ និងការអនុវត្តក្នុងការគ្រប់គ្រង កំណត់ និងពន្យល់អំពីជម្ងឺ និងប៉ារាសិតដែលច្រើនកើតមានលើសត្វគោយកទឹកដោះ ការឆ្លងជម្ងឺ និងការគ្រប់គ្រងជម្ងឺនិងប៉ារាសិតទាំងនោះ ពន្យល់ប្រព័ន្ធផលិតកម្មសាច់គោ និងការគ្រប់គ្រងផលិតកម្មសាច់គោ និងរបៀបដែលប្រព័ន្ធទាំងនេះជះឥទ្ធិពលមកលើគុណភាពសាច់គោ និងផលិតកម្ម និងពិភាក្សាអំពីគោលការណ៍សំខាន់ៗ និងការអនុវត្តក្នុងការគ្រប់គ្រងការចិញ្ចឹមគោយកសាច់។

**វិធីសាស្ត្រសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីមិត្តភក្តិ និងការសិក្សាបែបពិសោធន៍តាមរយៈការអានអត្ថបទក្នុងសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ចូលរួមការងារអនុវត្តជាក់ស្តែង និង/ឬការងារមន្ទីរពិសោធន៍ និងទស្សនកិច្ចទៅកាន់ទីវាល កសិដ្ឋានសត្វគោសម្រាប់យកទឹកដោះគោ និងយកសាច់

**ប្រធានបទ៖**

- ផលិតកម្មទឹកដោះ៖ សេចក្តីផ្តើម គោលនយោបាយផលិតទឹកដោះក្នុងប្រទេសកម្ពុជា រចនាសម្ព័ន្ធនៃឧស្សាហកម្មទឹកដោះក្នុងប្រទេសកម្ពុជា តួនាទីរបស់សត្វគោក្នុងការធ្វើកសិកម្ម និងសេដ្ឋកិច្ចជាតិ
- ពូជសត្វគោយកទឹកដោះ និងប្រភពរបស់សត្វគោទាំងនោះ ប្រព័ន្ធផលិតកម្មទឹកដោះគោក្នុងប្រទេសកម្ពុជា ប្រព័ន្ធផលិតទឹកដោះគោជាលក្ខណៈពាណិជ្ជកម្មខ្នាតតូច ប្រព័ន្ធផលិតទឹកដោះគោជាលក្ខណៈពាណិជ្ជកម្មខ្នាតធំ ប្រព័ន្ធផលិតទឹកដោះគោបែបយថាផល ប្រព័ន្ធផលិតទឹកដោះគោជាលក្ខណៈហ្វូង
- ពូជគោយកទឹកដោះ និង ការគ្រប់គ្រងពូជ៖ ពូជសត្វគោយកទឹកដោះ និងប្រភពរបស់សត្វគោវិធីសាសាស្រ្តបង្កាត់ (ធម្មជាតិ សិប្បនិម្មិត) ការបន្តពូជរបស់សត្វគោ (វដ្តការបន្តពូជរបស់មេគោ) កម្មវិធីកែលម្អសត្វគោយកទឹកដោះក្នុងប្រទេសកម្ពុជា ការជ្រើសរើសបង្កាត់ពូជ ការលំបាក និងបញ្ហាក្នុងផលិតកម្មទឹកដោះគោក្នុងប្រទេសកម្ពុជា និងទស្សនវិស័យឆ្ពោះទៅមុខ
- ទឹកដោះគោ និងការច្របាច់យកទឹកដោះគោ៖ សរីរវិទ្យានៃការផ្តល់ទឹកដោះ សមាសធាតុផ្សំរបស់ទឹកដោះគោ វិធីសាស្រ្តច្របាច់យកទឹកដោះ/បច្ចេកទេសយកទឹកដោះ ផលិតកម្មទឹកដោះគោស្អាត ការប្រមូលយកទឹកដោះជាប្រចាំ
- ការចិញ្ចឹមកូនគោ៖ ការគ្រប់គ្រងមេគោដែលមានកូនតូច និងគោក្រមុំ ការរៀបចំសម្រាប់ការកើតកូនវិធីសាស្រ្តចិញ្ចឹមកូនគោ ការថែទាំកូនគោពេលកើត ការឱ្យចំណីកូនគោ (ទឹកដោះដំបូង និង ដំណាក់កាលមុនផ្តាច់ដោះ) ការផ្តាច់ដោះ និងការគ្រប់គ្រងក្រោយពេលផ្តាច់ដោះកូនគោ ជម្ងឺកូនគោ និងការគ្រប់គ្រងជម្ងឺសម្រាប់កូនគោ ការរៀបចំជម្រករបស់កូនគោ និងទម្លាប់ក្នុងការគ្រប់គ្រងលើកូនគោ (ការកាត់ស្នែង ការគ្រៀវ ការកំណត់អត្តសញ្ញាណ ការថ្លឹងទម្ងន់)
- ការចិញ្ចឹមគោក្រមុំ៖ ការឱ្យចំណី ការបង្កាត់ពូជ

---

[19] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលចេញពីកម្មវិធីបង្រៀនរបស់ Lilongwe University of Agriculture and Natural Resources NRC Campus និងកម្មវិធីបង្រៀនសម្រាប់ឌីប្លូម៉ាផ្នែកកសិកម្ម (ឆ្នាំទី ៣) ២០១៥ នៅប្រទេសម៉ាឡាវី។*

- ការគ្រប់គ្រងមេគោស្ងួត និងការគ្រប់គ្រងការបំបៅដោះកូន៖ ការឱ្យចំណី ការរៀបចំទីជម្រក/រចនាសម្ព័ន្ធទឹកដោះគោ ការគ្រប់គ្រងសុខភាពក្រុមហ្វូងគោផ្តល់ទឹកដោះ
- ផលិតកម្មសាច់គោ៖ សារៈសំខាន់ គោលនយោបាយរដ្ឋាភិបាលស្តីពីផលិតកម្មគោយកសាច់
- ពូជសត្វគោយកសាច់ ប្រព័ន្ធផលិតកម្មសាច់គោ៖ គោហ្វូង ឬការចិញ្ចឹមគោបែបពង្រីក ខ្លាំងក្លា ខ្នាតតូច យថាផល
- ការបង្កាត់ពូជ និងការជ្រើសរើស៖ លក្ខណសម្បត្តិនៃគោយកសាច់ ការចាត់ប្រភេទពូជសត្វគោយកសាច់(*Bos Indicus & Bos Taurus*) និងលក្ខណសម្បត្តិរបស់គោទាំងនេះ
- ការគ្រប់គ្រងសត្វគោយកសាច់៖ ការបង្កាត់ ការជ្រើសរើសស្តុកការបង្កាត់ សមាមាត្រការបង្កាត់ (ការដាក់ឈ្មោល) និងរដូវការបង្កាត់ (ការដាក់ឈ្មោល) វិធីសាស្ត្របង្កាត់ ការកំណត់រកវិនិច្ឆ័យការមានផ្ទៃពោះ
- រចនាសម្ព័ន្ធកសិដ្ឋានសាច់គោ៖ ទីព័ទ្ធរបង ទ្រុងមាំសម្រាប់ការពិនិត្យសត្វ កន្លែងដេក/ទ្រុង ការឱ្យចំណី និងការដាក់ទឹកក្នុងស្នូក
- ការគ្រប់គ្រងការឱ្យចំណីសត្វគោយកសាច់៖ សរីរវិទ្យាផ្នែកអាហារូបត្ថម្ភរបស់សត្វទំពាអៀង ចំណីមានអាហាររូបត្ថម្ភច្រើន និងចំបើងសម្រាប់ទំពារ អាហារូបត្ថម្ភរបស់សត្វទំពាអៀង ការឱ្យចំណីក្នុងទ្រុង ទីតាំងឱ្យចំណី ការគ្រប់គ្រងការឱ្យចំណីបន្ថែមលើសត្វគោយកសាច់ (សារធាតុរ៉ែខនិជ និងការប្រើប្រាស់កាកសំណល់ដំណាំ) ការគ្រប់គ្រងការផ្តល់ចំណីជាថ្នាក់ៗ សម្រាប់សត្វគោយកសាច់ (គោទើបផ្តាច់ដោះ គោក្រមុំ គោឈ្មោលឡើងក និងមេគោពូជ) បុរេលក្ខខណ្ឌនៃសត្វគោយកសាច់ ទឹក និងអាហារូបត្ថម្ភសារធាតុខនិជ
- ប្រព័ន្ធឱ្យស្មៅ៖ ការឱ្យស៊ីស្មៅជាបន្តបន្ទាប់ និងការឱ្យស៊ីស្មៅវិលជុំ សមត្ថភាពក្នុងការអូសទាញ ដង់ស៊ីតេការស្តុកទុក ការកំណត់អត្រាការស្តុកទុក
- ជម្ងឺ និងប៉ារាសិតសំខាន់ៗរបស់សត្វគោយកសាច់ និង ការគ្រប់គ្រងលើជម្ងឺ និង ប៉ារាសិតទាំងនោះ
- ប្រព័ន្ធការធ្វើទីផ្សារសត្វគោយកសាច់ និងការកំណត់តម្លៃ៖ វិធីសាស្ត្រដឹកជញ្ជូនសត្វគោយកសាច់ ការដាក់ពិន្ទុ និងកម្រិតគុណភាពសត្វគោយកសាច់ ការកំណត់តម្លៃ ការកំណត់អត្តសញ្ញាណ និងប្រព័ន្ធកំណត់ត្រា។

**ការអនុវត្តជាក់ស្តែង៖**

- ច្របាច់ទឹកដោះពីមេគោ
- ការដាក់ពិន្ទុស្ថានភាពសត្វគោយកសាច់
- ការឱ្យចំណីសត្វគោយកសាច់
- ការកែច្នៃផលិតផលទឹកដោះ
- ការប្រមូលសំណាកទឹកដោះគោ និងការធ្វើតេស្ត
- ការពិនិត្យរកជម្ងឺរលាកកន្សោមដោះ និងការព្យាបាល
- ការចិញ្ចឹមកូនគោ
- ការបង្ហាំងសត្វគោសម្រាប់យកទឹកដោះ
- លំហាត់ពីជគណិតសម្រាប់ផលិតផលទឹកដោះ
- ការធ្វើផែនការសហគ្រាសអាជីវកម្មទឹកដោះ
- ការកំណត់រោគវិនិច្ឆ័យការមានផ្ទៃពោះ

- ការជ្រើសរើសគោមេ និងគោឈ្មោលពូជ
- ទស្សនកិច្ចទៅកាន់កសិដ្ឋានផលិតទឹកដោះ និងរោងចក្រកែច្នៃទឹកដោះ
- ការគ្រៀវគោឈ្មោល
- ការកាត់ស្នែងកូនគោ និងការកាត់ស្នែងគោធំ
- ការបង្ខាំងសត្វគោយកសាច់
- ការកំណត់អត្តសញ្ញាណបសុសត្វ
- ទស្សនកិច្ចទៅកាន់ក្រុមហ៊ុនរក្សាស្តុកត្រជាក់ និងសត្តឃាតដ្ឋាន
- ការវាយតម្លៃដាក់ពិន្ទុស្ថានភាពនៃគោឈ្មោលគ្រាវសម្រាប់យកសាច់
- ទស្សនកិច្ច និងការសិក្សាលើទីផ្សារសត្វរស់។

## អំណានបន្ថែម៖


Agrodok Series No. 14. (1996). *Dairy Cattle Husbandry*. Wageningen: CTA Publication.

Chesworth, J. (1992). *Ruminant Nutrition*. Oxford: Macmillan Education Ltd.

Gillespie, J. R. (2004). *Modern Livestock and Poultry production (7th ed.).* New York, NY: Thomson & Delmar Learning.

Hunter, A. (1996). *Animal Health. Volume 1 General Principles*. London: Macmillan Education Ltd.

Pagot, J. (1992). *Animal Production in the Tropics and Subtropics*. London: Macmillan Education Ltd.

Tainton, N. M. (Ed.) (2000). *Pasture Management in South Africa.* Pietermaritzburg, South Africa: University of Natal Press.

Thickett, B., Mitchell, D., & Hallows, B. (1988). *Calf Rearing* (2nd ed.). Ipswich: Farming Press.

Wiener, G. (1994). *Animal Breeding*. London: Macmillan Education Ltd.

## ម៉ូឌុល ៤.៦៖ ផលិតកម្មបក្សី[20]

**គោលបំណង៖** ធ្វើឱ្យសិស្សយល់ច្បាស់អំពីបច្ចេកវិទ្យា និង ការអនុវត្តក្នុងផលិតកម្មបក្សីបែបទំនើប។

**លទ្ធផលចុងក្រោយ៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នា និងហ្វឹកហាត់ការអនុវត្ត ផលិតកម្មបក្សី៖ ទ្រុង ចំណី ការបង្កាត់ពូជ ការគ្រប់គ្រងជម្ងឺ ទីផ្សារ។

**វិធីសាស្ត្រនៃការសិក្សា៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីមិត្តភក្តិ និងការសិក្សាបែបពិសោធន៍ តាមរយៈការអានអត្ថបទពីសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារបែបអនុវត្តជាក់ស្តែង និង/ឬមន្ទីរពិសោធន៍ និងទស្សនកិច្ចទៅកាន់ទីវាល/កសិដ្ឋានចិញ្ចឹមបក្សី។

**ប្រធានបទ៖**

- សេចក្តីផ្តើម វិសាលភាព និងស្ថិតិនៃបក្សីក្នុងពិភពលោក និងក្នុងប្រទេសកម្ពុជា
- ការអនុវត្តផ្នែកការគ្រប់គ្រង ដែលត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់បក្សី
- ពូជបសុបក្សី៖ មាន់យកពង មាន់យកសាច់ និង មាន់យកសាច់ផង ពងផង
- សម្ភារៈ និងការរចនាទ្រុងបក្សី
- ការឱ្យទឹក និងផ្តល់ចំណីសម្រាប់ពូជ និងប្រភេទមាន់ផ្សេងៗគ្នា
- ការគ្រប់គ្រង មាន់យកពង មាន់យកសាច់
- ការបង្កពង ការជ្រើសរើសពង សម្រាប់គោលបំណងនៃការបរិភោគ និងការភ្ញាស់
- កត្តានានាដែលចាំបាច់ ដើម្បីទទួលបានការភ្ញាស់ល្អបំផុត
- វិធីសាស្ត្រក្រាបពង (បែបធម្មជាតិ និងសិប្បនិម្មិត)
- ការចាក់វ៉ាក់សាំងបសុបក្សី៖ វិធី និងពេលវេលាដែលត្រូវចាក់
- ការអនុវត្តផ្នែកការគ្រប់គ្រងជាទូទៅសម្រាប់មាន់យកសាច់ និងមាន់យកពង
- ជំងឺសំខាន់ៗដែលកើតមានចំពោះបសុបក្សី និងវិធីសាស្ត្រដើម្បីបង្ការ និងគ្រប់គ្រងជម្ងឺទាំងនោះ
- ជីវសន្តិសុខនៅក្នុងកសិដ្ឋានពាណិជ្ជកម្ម
- ការវិនិច្ឆ័យលើបក្សី៖ ពូជយកសាច់ ពូជយកពង
- ការធ្វើទីផ្សារបក្សី និងផលិតផលបក្សី។

**ការអនុវត្តផ្ទាល់៖**

- សារៈសំខាន់ ប្រវត្តិនៃផលិតកម្មបសុបក្សីក្នុងពិភពលោក និងក្នុងប្រទេសកម្ពុជា
- ការកំណត់រកពូជមាន់យកសាច់ និងមាន់យកពង
- ការរៀបទ្រុង និងការផ្តល់ចំណីបក្សី រួមទាំងការភ្ញាស់កូនមាន់
- ការកំណត់អត្តសញ្ញាណជម្ងឺ ការចាក់វ៉ាក់សាំង និងការគ្រប់គ្រងលើជម្ងឺបក្សី
- ការកាត់ចំពុះមេមាន់

---

[20] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥ និង កម្មវិធីបង្រៀនរបស់ Lilongwe University of Agriculture and Natural Resources NRC Campus និងកម្មវិធីបង្រៀនសម្រាប់ ឌីប្លូម៉ាផ្នែកកសិកម្ម (ឆ្នាំទី ៣) ២០១៥ នៅប្រទេសម៉ាឡាវី។*

- ការឆ្លុះដោយពន្លឺទៀន ការបែកកម្រិត និងការជ្រើសរើសពងមាន់
- ការឱ្យចំណី និងការឱ្យទឹកបក្សី។

## អំណានបន្ថែម៖


Arora, S. P., & Kaur, H. (2005). *Principles of Animal Nutrition and Nutrients Dynamics*. New Delhi, India: ICAR.

Banerjee, G. C. (1991). *A Text Book of Animal Husbandry (7th ed.)*. New Delhi, India: Oxford and IBH Publishing, New Delhi. (7th edition)

Banerjee, G. C. (1998). *Feeds and Principles of Animal Nutrition.* New Delhi, India: IBH Publishing.

Banerjee, G. C. (1995). *Poultry*. New Delhi: IBH Publishing.

Cheeke, P. R. (2005). *Applied Animal Nutrition: Feeds and Feeding (3rd ed).* Upper Saddle River: Prentice Hall.

Gillespie, J. R., (2004). *Modern Livestock and Poultry production*. 7th Edition, New York: Thomson & Delmar.

Smith, A.J. (2001). *Poultry*. *The Tropical Agriculturist (Revised edition)*, Wageningen: CTA & McMillan Publication.

## ម៉ូឌុល ៤.៧៖ កសិ-រុក្ខកម្ម[21]

**គោលបំណង៖** ធ្វើឱ្យសិស្សយល់ច្បាស់អំពីគោលការណ៍ និងការអនុវត្តនៅក្នុងប្រព័ន្ធកសិ-រុក្ខកម្ម (AFS)
**លទ្ធផលរំពឹងទុកពីការសិក្សា៖** នៅពេលបញ្ចប់វគ្គសិក្សានេះ សិស្សនឹងមានសមត្ថភាពអាច៖ ពិពណ៌នា និងអនុវត្តគោលការណ៍ និងការអនុវត្តនៅក្នុងប្រព័ន្ធកសិ-រុក្ខកម្ម រួមទាំងអន្តរកម្មរវាងដើមឈើ និងដំណាំ ការរចនាគម្រោង AFS និងពន្យល់អំពីការគ្រប់គ្រងដីនៅក្នុងប្រព័ន្ធកសិ-រុក្ខកម្ម ដាំ និងការគ្រប់គ្រងប្រតិបត្តិការការដាំ និងបម្រុងព្រៃឈើ។
**គោលវិធីនៃការរៀនសូត្រ៖** ការសិក្សាដោយខ្លួនឯង ការសិក្សាពីមិត្តភក្តិ និងការសិក្សាបែបពិសោធន៍ តាមរយៈការអានអត្ថបទពីសៀវភៅ/ឯកសារ ការចូលរួមស្តាប់បទឧទ្ទេស ការចូលរួមក្នុងការងារអនុវត្តជាក់ស្តែង និងការចុះទស្សនកិច្ចទៅទីវាល។
**ប្រធានបទ៖**

- គោលគំនិតស្តីពីកសិ-រុក្ខកម្ម ៖ និយមន័យ សារៈសំខាន់ និងវិសាលភាព
- ការជ្រើសរើសដើមឈើ និងការកែលម្អ៖ តួនាទីរបស់ដើមឈើនៅក្នុងការបំពេញតម្រូវការជាមូលដ្ឋានរបស់មនុស្ស លក្ខណៈសម្បត្តិនៃដើមឈើសម្រាប់ការអភិវឌ្ឍកសិ-រុក្ខកម្ម និងការកែលម្អដើមឈើ
- ប្រព័ន្ធកសិ-រុក្ខកម្ម ៖ ចំណាត់ប្រភេទ និងទិដ្ឋភាពទូទៅនៃ AFS ទិដ្ឋភាពទូទៅនៃ AFS ក្នុងប្រទេសកម្ពុជា និងការចាត់តំបន់ក្សេត្រ-បរិស្ថានប្រហាក់ប្រហែលនៅក្នុងពិភពលោក
- អន្តរកម្មរវាងដើមឈើ និងដំណាំ៖ កត្តា និងប្រភេទនៃលក្ខណៈសម្បត្តិរបស់អន្តរទំនាក់ទំនងរវាងដើមឈើជាមួយដំណាំ ការកំណត់បរិមាណផលិតផលកសិ-រុក្ខកម្ម
- ការគ្រប់គ្រងដីនៅក្រោម AFS៖ វិធីសាស្ត្រនៃការអភិរក្សដី-ទឹក ការគ្រប់គ្រងដី-ជី
- ការរចនា AFS៖ ក្របខ័ណ្ឌការងារផ្នែកទស្សនទានសម្រាប់ការរចនា AFS កត្តានានាដែលជះឥទ្ធិពលលើ AFS
- ការអភិវឌ្ឍគម្រោង៖ ការកំណត់រោគវិនិច្ឆ័យរបស់ ICFAF និងការតាក់តែង វិធីសាស្ត្រកំណត់រោគវិនិច្ឆ័យ និងឧបករណ៍ដែលត្រូវបានប្រើប្រាស់ក្នុង AFS
- ការគ្រប់គ្រងដើមឈើនៅក្នុង AFS៖ ការគ្រប់គ្រងដើមឈើនៅក្នុងវិស័យកសិកម្ម
- ការគ្រប់គ្រងផ្នែកកសិកម្ម និងការដាំ និងបម្រុងព្រៃឈើ ទាក់ទងជាមួយដំណាំ។

**ការអនុវត្តជាក់ស្តែង៖**

- ការជ្រើសរើសដើមឈើ និងការកំណត់អត្តសញ្ញាណ AFS នៅតាមតំបន់ផ្សេងៗ
- ការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធកសិកម្មបន្ទាត់កោង
- ការរៀបចំក្របខ័ណ្ឌ "ក" និងការកំណត់បន្ទាត់កោង
- ទ្រង់ទ្រាយនៃប្រព័ន្ធការអភិរក្សដី-ទឹក
- ការបង្កើតថ្នាលកូនឈើសម្រាប់ AFS
- ការប្រមូល និងការកំណត់អត្តសញ្ញាណគ្រាប់ពូជរបស់ដើមឈើក្នុងកសិ-រុក្ខកម្ម
- ការរៀបចំថ្នាលកូនឈើសម្រាប់ដើមឈើក្នុងកសិ-រុក្ខកម្ម

---
[21] *កម្មវិធីបង្រៀននេះ ត្រូវបានកែសម្រួលពីសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ ព្រឹត្តិបត្រវគ្គ B. Sc. Ag. នេប៉ាល់ ឆ្នាំ ២០១៥។*

- ការសាបគ្រាប់ពូជសម្រាប់ដើមឈើក្នុងកសិ-រុក្ខកម្ម
- គ្លីនិកដើមឈើសម្រាប់ AFS
- ការបណ្តុះបណ្តាល និងការកាត់មែកសម្រាប់ដើមឈើក្នុងកសិ-រុក្ខកម្ម
- កម្ពស់ និងការវាស់វែងកំពូលចុងឈើ សម្រាប់ដើមឈើចម្ការព្រៃដាំដែលត្រូវបានជ្រើសរើស
- ការអភិវឌ្ឍ AFS ផ្សេងៗ (SALT និងសួនតាមផ្ទះ)
- ទស្សនកិច្ចទៅកាន់គម្រោងកសិ-រុក្ខកម្ម ដែលបានទទួលជោគជ័យនៅថ្នាក់មូលដ្ឋាន។

**អំណានបន្ថែម៖**


Dwivedi, A. P. (1992). *Agroforestry: Principles and Practices*. India: IBH Publishing Co. Pvt. Ltd.

Chaundawat, B. S., & Gautam, S. K. (1996). *Text of Agroforestry*. India: IBH Publishing Co. Pvt. Ltd.

Singh, S. P. (1998). *Handbook of Agroforestry*. India: Agrotech Publishing Academy.

Prakash, R. (1991). *Propagation Practices of Important Indian Trees*. India: International Book Distributions.


**ប្រធានបទបន្ថែមសម្រាប់ម៉ូឌុលបណ្តុះបណ្តាល គឺមានរាយឈ្មោះដូចខាងក្រោម (វគ្គសិក្សាទាំងអស់នេះ ត្រូវការការពិពណ៌នាអំពីវគ្គសិក្សាបន្ថែមទៀត)៖**

ម៉ូឌុល ៤.៨៖ ការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ និងថាមពលកកើតឡើងវិញ
ម៉ូឌុល ៤.៩៖ ដំណាំជាលក្ខណៈពាណិជ្ជកម្ម៖ ផលិតកម្មម្រេចស កាហ្វេ ខ្ញី ក្រវាញ
ម៉ូឌុល ៤.១០៖ ប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹក
ម៉ូឌុល ៤.១១៖ ផលិតកម្មសត្វចៀម និងពពែ
ម៉ូឌុល ៤.១២៖ កសិកម្មបែបអភិរក្ស
ម៉ូឌុល ៤.១៣៖ ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍
ម៉ូឌុល ៤.១៤៖ គ្រឿងយន្តកសិកម្ម
ម៉ូឌុល ៤.១៥៖ បច្ចេកវិទ្យាក្រោយការប្រមូលផល។

## ឧបសម្ព័ន្ធ គ-១៖ ការពិនិត្យតាមដានសេវាផ្សព្វផ្សាយកសិកម្ម (គំរូសូចនាករ)

**សម្គាល់៖** ទម្រង់ប្រមូលទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណិត (អេឡិចត្រូនិច) គួរត្រូវបានបង្កើតឡើងដើម្បីបង្កើតទិន្នន័យស្ដីពីសូចនាករទាំងនេះ។ ចំណុចដៅ (T) ត្រូវបានកំណត់សម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ហើយសមិទ្ធផល (A) ត្រូវបានរាយការណ៍តាមរយៈទូរសព្ទឆ្លាតវៃ អាយផែត ឬកុំព្យូទ័រលើតុ។

**ទិន្នន័យរាយការណ៍ដោយ៖** __ DAE __ PDAFF __ DAO __ CAC __ វិទ្យាស្ថានបណ្ដុះបណ្ដាលផ្សេងទៀត

| | សេវាផ្សព្វផ្សាយកសិកម្ម | ឯកតាវាស់វែង | ២០១៨-២០១៩ | | ២០១៩-២០២០ | | | ២០២០-២០២១ | | ២០២១-២០២២ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | T | A | T | A | | T | A | T | A |
| ១. | **ការរៀបចំផ្នែកស្ថាប័ន និងក្របខ័ណ្ឌការងារផ្នែកច្បាប់** | | | | | | | | | | |
| ១.១ | ការបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ | | | | | | | | | | |
| ១.១.១ | ការបង្កើតគណៈកម្មធិការកសិកម្មឃុំ(CAC) | ១=បាទ/ចាស<br>២=ទេ | | | | | | | | | |
| | តើ CAC បានប្រជុំប៉ុន្មានដងក្នុងឆ្នាំនេះ? | ចំនួនកិច្ចប្រជុំដែលបានធ្វើឡើង | | | | | | | | | |
| | តើសមាជិកប៉ុន្មាននាក់បានចូលរួមក្នុងកិច្ចប្រជុំ? | ភាគរយវត្តមានក្នុងកិច្ចប្រជុំ | | | | | | | | | |
| | ការតំណាងផ្នែកយេនឌ័រក្នុង CAC | ភាគរយសមាជិកជាស្ត្រី | | | | | | | | | |
| ១.១.២ | ការបង្កើតក្រុមការងារគាំទ្របច្ចេកទេសកសិកម្មស្រុក(DATST) | ១=បាទ/ចាស<br>២=ទេ | | | | | | | | | |
| | តើDATSTបានប្រជុំប៉ុន្មានដងក្នុងឆ្នាំនេះ? | ចំនួនកិច្ចប្រជុំដែលបានធ្វើឡើង | | | | | | | | | |
| | តើសមាជិកប៉ុន្មានបានចូលរួមក្នុងកិច្ចប្រជុំ? | ភាគរយវត្តមានក្នុងកិច្ចប្រជុំ | | | | | | | | | |
| | ភាពតំណាងផ្នែកយេនឌ័រនៅក្នុង DATST | ភាគរយសមាជិកជាស្ត្រី | | | | | | | | | |
| ១.១.៣ | ការបង្កើតក្រុមការងារផ្សព្វផ្សាយកសិកម្មខេត្ត (PAEWG) | ១=បាទ/ចាស<br>២=ទេ | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | តើPAEWGបានប្រជុំប៉ុន្មានដងក្នុងឆ្នាំនេះ? | ចំនួនកិច្ចប្រជុំដែលបានធ្វើឡើង | | | | | | | | | |
| | តើសមាជិកប៉ុន្មានបានចូលរួមក្នុងកិច្ចប្រជុំ? | ភាគរយវត្តមានក្នុងកិច្ចប្រជុំ | | | | | | | | | |
